

ឯកសារគម្ពីព្រះត្រៃបិដកស្កាននេះ
ត្រូវបានថតចេញពីច្បាប់គម្ពីរព្រះត្រៃបិដកជប៉ុន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ១ ដល់ ភាគ៥០
គឺជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងបុត្រធីតា,
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត-សាវង្ស ។ និងទុកក្នុង
គេហទំព័រ៥000ឆ្នាំ សម្រាប់ជាធម្មទាន ។

កែសម្រួលតាមកុំព្យូទ័រ តម្រូវឧបករណ៍អានអេឡិត្រូនិច
ដោយខ្ញុំព្រះករុណា ខ្ញុំបាទ ស្រុង-ចាន់ណា ៕

www.5000-years.org

# ព្រះ

# ត្រៃបិដកបាលី

# និង

# សេចក្ដីប្រែជាភាសាខ្មែរ

# សុត្តន្តបិដក

## អង្គុត្តរនិកាយ សត្តកនិបាត

## ទុតិយភាគ

## ៤៧

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៤៩៨

# សុត្តន្តបិដកេ

# អង្គុត្តរនិកាយស្ស សត្តកនិបាតោ

# អដ្ឋមោ ភាគោ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## បឋមបណ្ណាសកោ

## ធនវគ្គោ

(១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ សព្រហ្មចារីនំ អប្បិយោ ច ហោតិ អមនាបោ ច អគរុ ច អភាវនីយោ ច ។ កតមេហិ សត្តហិ ។ ឥធ ភិក្ខវេ ភិក្ខុ លាភកាមោ ច ហោតិ សក្ការកាមោ ច

# សុត្តន្តបិដក

# អង្គុត្តរនិកាយ សត្តកនិបាត

## អដ្ឋមភាគ

---

*សូមនមស្ការចំពោះព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។*

## បឋមបណ្ណាសក

### ធនវគ្គ

(១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ឆ្លើយតបព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ។ ព្រះមានព្រះភាគទ្រង់ត្រាស់ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង រមែងមិនជាទីស្រឡាញ់ផង មិនជាទីពេញចិត្តផង មិនជាទីគោរពផង មិនជាទីសរសើរផង របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៧ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រាថ្នាលាភ ១ ប្រាថ្នាសក្ការៈ ១

អនវញ្ញត្តិកាមោ ច អហិរិកោ ច អនោត្តប្បី ច មហិច្ឆោ ច មិច្ឆាទិដ្ឋិ ច ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ ធម្មេហិ សមន្នាគតោ ភិក្ខុ សព្រហ្មចារីនំ អប្បិយោ ច ហោតិ អមនាបោ ច អគរុ ច អភាវនីយោ ច ។ សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ច ។ កតមេហិ សត្តហិ ។ ឥធ ភិក្ខវេ ភិក្ខុ ន លាភកាមោ ច ហោតិ ន សក្ការកាមោ ច ន អនវញ្ញត្តិកាមោ ច ហិរិមា ច ឱត្តប្បី ច អប្បិច្ឆោ ច សម្មាទិដ្ឋិ ច ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ ធម្មេហិ សមន្នាគតោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ចាតិ ។

(២) សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ សព្រហ្មចារីនំ អប្បិយោ ច ហោតិ អមនាបោ ច អគរុ ច អភាវនីយោ ច ។ កតមេហិ សត្តហិ ។ ឥធ ភិក្ខវេ ភិក្ខុ លាភកាមោ ច ហោតិ

មិនចង់ឲ្យគេមើលងាយខ្លួន ១ មិនខ្វាសព្វាប ១ មិនខ្វាចព្វាប ១ ប្រាថ្នាសក្ការ ១ ឃើញខុស ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាងនេះ រមែងមិនជាទីស្រឡាញ់ផង មិនជាទីពេញចិត្តផង មិនជាទីគោរពផង មិនជាទីសរសើរផង របស់សព្រហ្មចារីទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង រមែងជាទីស្រឡាញ់ផង ជាទីពេញចិត្តផង ជាទីគោរពផង ជាទីសរសើរផង របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៧ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនប្រាថ្នាលាភ ១ មិនប្រាថ្នាសក្ការៈ ១ មិនប្រាថ្នាមិនចង់ឲ្យគេមើលងាយខ្លួន ១ ខ្វាសព្វាប ១ ខ្វាចព្វាប ១ ប្រាថ្នាតិច ១ ឃើញត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាងនេះ រមែងជាទីស្រឡាញ់ផង ជាទីពេញចិត្តផង ជាទីគោរពផង ជាទីសរសើរផង របស់សព្រហ្មចារីទាំងឡាយ ។

[៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង រមែងមិនជាទីស្រឡាញ់ផង មិនជាទីពេញចិត្តផង មិនជាទីគោរពផង មិនជាទីសរសើរផង របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៧ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រាថ្នាលាភ ១

សក្ការកាមោ ច អនវញ្ញត្តិកាមោ ច អហិរិកោ ច អនោត្តប្បី ច ឥស្សុកី ច មច្ឆរី ច ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ ធម្មេហិ សមន្នាគតោ ភិក្ខុ សព្រហ្មចារីនំ អប្បិយោ ច ហោតិ អមនាបោ ច អគរុ ច អភាវនីយោ ច ។ សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ច ។ កតមេហិ សត្តហិ ។ ឥធ ភិក្ខវេ ភិក្ខុ ន លាភកាមោ ច ហោតិ ន សក្ការកាមោ ច ន អនវញ្ញត្តិកាមោ ច ហិរិមា ច ឱត្តប្បី ច អនិស្សុកី ច អមច្ឆរី ច ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ ធម្មេហិ សមន្នាគតោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ចាតិ ។

(៣) សត្តិមានិ ភិក្ខវេ ពលានិ ។ កតមានិ សត្ត ។ សទ្ធាពលំ វីរិយពលំ ហិរិពលំ ឱត្តប្បពលំ សតិពលំ សមាធិពលំ បញ្ញាពលំ ។

ប្រាថ្នាសក្ការៈ ១ មិនចង់ឲ្យគេមើលងាយខ្លួន ១ មិនខ្មាសបាប ១ មិនខ្លាចបាប ១ មានសេចក្តីប្រណែន ១ មានសេចក្តីកំណាញ់ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាងនេះឯង រមែងមិនជាទីស្រឡាញ់ផង មិនជាទីពេញចិត្តផង មិនជាទីគោរពផង មិនជាទីសរសើរផង របស់សព្រហ្មចារីទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង រមែងជាទីស្រឡាញ់ផង ជាទីពេញចិត្តផង ជាទីគោរពផង ជាទីសរសើរផង របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៧ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនប្រាថ្នាលាភ ១ មិនប្រាថ្នាសក្ការៈ ១ មិនប្រាថ្នាមិនចង់ឲ្យគេមើលងាយខ្លួន ១ ខ្មាសបាប ១ ខ្លាចបាប ១ មិនមានសេចក្តីប្រណែន ១ មិនមានសេចក្តីកំណាញ់ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាងនេះឯង រមែងជាទីស្រឡាញ់ផង ជាទីពេញចិត្តផង ជាទីគោរពផង ជាទីសរសើរផង របស់សព្រហ្មចារីទាំងឡាយ ។

(៣) ម្នាលភិក្ខុទាំងឡាយ កំឡាំងនេះមាន ៧ យ៉ាង ។ កំឡាំង ៧ យ៉ាង តើអ្វីខ្លះ ។ កំឡាំងគឺសទ្ធា ១ កំឡាំងគឺសេចក្តីព្យាយាម ១ កំឡាំងគឺហិរិ ១ កំឡាំងគឺឱត្តប្បៈ ១ កំឡាំងគឺសតិ ១ កំឡាំងគឺសមាធិ ១ កំឡាំងគឺបញ្ញា ១ ។

ឥមានិ ខោ ភិក្ខវេ សត្ត ពលានីតិ ។

សទ្ធាពលំ វីរិយពលំ(១) ហិរី ឱត្តប្បិយំ ពលំ
សតិពលំ សមាធិពលំ(២) បញ្ញា វេ សត្តមំ ពលំ
ឯតេហិ ពលវា ភិក្ខុ សុខំ ជីវតិ បណ្ឌិតោ
យោនិសោ វិចិនេ ធម្មំ បញ្ញាយត្ថំ វិបស្សតិ
បជ្ជោតស្សេវ និព្វានំ វិមោក្ខោ ហោតិ ចេតសោតិ ។

(៤) សត្តិមានិ ភិក្ខវេ ពលានិ ។ កតមានិ សត្ត ។ សទ្ធាពលំ វីរិយពលំ ហិរីពលំ ឱត្តប្បពលំ សតិពលំ សមាធិពលំ បញ្ញាពលំ ។ កតមញ្ច ភិក្ខវេ សទ្ធាពលំ ។ ឥធ ភិក្ខវេ អរិយសាវកោ សទ្ធោ ហោតិ សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ឥទំ វុច្ចតិ ភិក្ខវេ សទ្ធាពលំ ។ កតមញ្ច ភិក្ខវេ វីរិយពលំ ។

---

១ ឱ. ម. វីរិយញ្ច ។ ២ ឱ. សមាធិញ្ច ។ ម. សមាធិ ច ។

ម្នាលភិក្ខុទាំងឡាយ នេះឯងកំឡាំង ៧ យ៉ាង ។

កំឡាំងគឺសទ្ធា កំឡាំងគឺវីរិយៈ កំឡាំងគឺហិរិ កំឡាំងគឺឱត្តប្បៈ កំឡាំងគឺសតិ កំឡាំងគឺសមាធិ កំឡាំងគឺបញ្ញា ជាគំរប់ ៧ ភិក្ខុជាបណ្ឌិត មានកំឡាំងដោយកំឡាំងទាំងនេះ រមែងរស់នៅស្រួល ពិចារណាធម៌ដោយឧបាយ តែងឃើញច្បាស់នូវអត្ថ(១) ដោយបញ្ញាបាន ការរួចស្រឡះ (ចាកអារម្មណ៍) នៃចិត្តរបស់ភិក្ខុនោះ ដូចជាការរលត់នៃប្រទីប ។

(៤) ម្នាលភិក្ខុទាំងឡាយ ពលៈនេះមាន ៧ យ៉ាង ។ ៧ យ៉ាង តើអ្វីខ្លះ ។ គឺសទ្ធាពលៈ ១ វីរិយពលៈ ១ ហិរិពលៈ ១ ឱត្តប្បពលៈ ១ សតិពលៈ ១ សមាធិពលៈ ១ បញ្ញាពលៈ ១ ។ ម្នាលភិក្ខុទាំងឡាយ សទ្ធាពលៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសទ្ធា រមែងជឿចំពោះពោធិញ្ញាណរបស់ព្រះតថាគតថា ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ។បេ។ ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវសច្ចធម៌ ទ្រង់កំចាត់បង់នូវត្រៃភព ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សទ្ធាពលៈ ។ ម្នាលភិក្ខុទាំងឡាយ វីរិយពលៈ តើដូចម្តេច ។

១- រមែងឃើញច្បាស់នូវសច្ចធម៌ ដោយមគ្គប្បញ្ញា មួយអន្លើដោយវិបស្សនា ។ អដ្ឋកថា ។

ឥធ ភិក្ខវេ អរិយសាវកោ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។ ឥទំ វុច្ចតិ ភិក្ខវេ វីរិយពលំ ។ កតមញ្ច ភិក្ខវេ ហិរិពលំ ។ ឥធ ភិក្ខវេ អរិយសាវកោ ហិរិមា ហោតិ ហិរិយតិ កាយទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេន ហិរិយតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ។ ឥទំ វុច្ចតិ ភិក្ខវេ ហិរិពលំ ។ កតមញ្ច ភិក្ខវេ ឱត្តប្បពលំ ។ ឥធ ភិក្ខវេ អរិយសាវកោ ឱត្តប្បី ហោតិ ឱត្តប្បតិ កាយទុច្ចរិតេន វចីទុច្ចរិតេន មនោ-ទុច្ចរិតេន ឱត្តប្បតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ។ ឥទំ វុច្ចតិ ភិក្ខវេ ឱត្តប្បពលំ ។ កតមញ្ច ភិក្ខវេ សតិពលំ ។ ឥធ ភិក្ខវេ អរិយសាវកោ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតម្បិ ចិរភាសិតម្បិ សរិតា អនុស្សរិតា ។

ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ ប្រារព្ធសេចក្តីព្យាយាម ដើម្បីលះនូវអកុសលធម៌ទាំងឡាយ ដើម្បីបំពេញនូវកុសលធម៌ទាំងឡាយ ជាអ្នកមានកំឡាំងព្យាយាម ប្រឹងប្រែងមុតមាំ មិនដាក់ធុរៈក្នុងកុសលធម៌ទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វីរិយពលៈ ។ ម្នាលភិក្ខុទាំងឡាយ ហិរិពលៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ ជាអ្នកមានសេចក្តីអៀនខ្មាស រមែងអៀនខ្មាស កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត រមែងអៀនខ្មាសនូវការចូលប្រសព្វនូវអកុសលធម៌ដ៏លាមក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ហិរិពលៈ ។ ម្នាលភិក្ខុទាំងឡាយ ឱត្តប្បពលៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ ជាអ្នកមានសេចក្តីតក់ស្លុត រមែងតក់ស្លុតបំពោះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត រមែងតក់ស្លុតនូវការចូលប្រសព្វនូវអកុសលធម៌ដ៏លាមក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឱត្តប្បពលៈ ។ ម្នាលភិក្ខុទាំងឡាយ សតិពលៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយ-សាវ័កក្នុងសាសនានេះ ជាអ្នកមានសតិ ប្រកបដោយសតិ និងភាពជាអ្នកមានបញ្ញាភាស់ក្លាដ៏ឧត្តម ជាអ្នកនឹករលឹកចាំបាន នូវអំពើដែលខ្លួនធ្វើយូរហើយផង នូវសំដីដែលខ្លួននិយាយយូរហើយផង ។

ឥទំ វុច្ចតិ ភិក្ខវេ សតិពលំ ។ កតមញ្ច ភិក្ខវេ សមាធិពលំ ។ ឥធ ភិក្ខវេ អរិយសាវកោ វិវិច្ចេវ កាមេហិ ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឥទំ វុច្ចតិ ភិក្ខវេ សមាធិពលំ ។ កតមញ្ច ភិក្ខវេ បញ្ញាពលំ ។ ឥធ ភិក្ខវេ អរិយសាវកោ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មា ទុក្ខក្ខយគាមិនិយា ។ ឥទំ វុច្ចតិ ភិក្ខវេ បញ្ញាពលំ ។ ឥមានិ ខោ ភិក្ខវេ សត្ត ពលានីតិ ។

សទ្ធាពលំ វីរិយពលំ ហិរី ឱត្តប្បិយំ ពលំ
សតិពលំ សមាធិពលំ បញ្ញា វេ សត្តមំ ពលំ ។
ឯតេហិ ពលវា ភិក្ខុ សុខំ ជីវតិ បណ្ឌិតោ
យោនិសោ វិចិនេ ធម្មំ បញ្ញាយត្ថំ វិបស្សតិ
បជ្ជោតស្សេវ និព្វានំ វិមោក្ខោ ហោតិ ចេតសោតិ ។

(៨) សត្តិមានិ ភិក្ខវេ ធនានិ ។ កតមានិ សត្ត ។

ម្នាលភិក្ខុទាំងឡាយ នេះហៅថា សតិពលៈ ។ ម្នាលភិក្ខុទាំងឡាយ សមាធិពលៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលដល់នូវចតុត្ថជ្ឈាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សមាធិពលៈ ។ ម្នាលភិក្ខុទាំងឡាយ បញ្ញាពលៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានប្រាជ្ញា រមែងប្រកបដោយបញ្ញាជាគ្រឿងដឹងច្បាស់នូវការកើតឡើង និងសូន្យទៅ (នៃខន្ធ៥) ជាបញ្ញាប្រសើរមោះមុត ជាគ្រឿងដល់នូវការអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បញ្ញាពលៈ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ពលៈ ៧ យ៉ាង ។

សទ្ធាពលៈ វីរិយពលៈ ហិរិពលៈ ឱត្តប្បពលៈ សតិពលៈ
សមាធិពលៈ បញ្ញាពលៈ ជាគំរប់ ៧ ។ ភិក្ខុជាបណ្ឌិត
មានកម្លាំងដោយពលៈទាំងនេះ រមែងរស់នៅស្រួល ពិចារណា
ធម៌ដោយឧបាយ ឃើញច្បាស់នូវអត្ថដោយបញ្ញា ការរួចស្រឡះ
(ចាកអារម្មណ៍) នៃចិត្ត (របស់ភិក្ខុនោះ) ដូចជាការរលត់នៃប្រទីប ។

(៤) ម្នាលភិក្ខុទាំងឡាយ ទ្រព្យនេះមាន៧យ៉ាង ។ ៧យ៉ាង តើអ្វីខ្លះ ។

សទ្ធាធនំ សីលធនំ ហិរីធនំ ឱត្តប្បធនំ សុតធនំ ចាគធនំ បញ្ញាធនំ ។ ឥមានិ ខោ ភិក្ខវេ សត្ត ធនានីតិ

សទ្ធាធនំ សីលធនំ ហិរី ឱត្តប្បិយំ ធនំ
សុតធនញ្ច ចាគោ ច បញ្ញា វេ សត្តមំ ធនំ ។
យស្ស ឯតេ ធនា អត្ថិ ឥត្ថិយា បុរិសស្ស វា
អទលិទ្ទោតិ តំ អាហុ អមោឃំ តស្ស ជីវិតំ ។
តស្មា សទ្ធញ្ច សីលញ្ច បសាទំ ធម្មទស្សនំ
អនុយុញ្ជេថ មេធាវី សរំ ពុទ្ធានសាសនន្តិ ។

(៦) សត្តិមានិ ភិក្ខវេ ធនានិ ។ កតមានិ សត្ត ។ សទ្ធាធនំ សីលធនំ ហិរីធនំ ឱត្តប្បធនំ សុតធនំ ចាគធនំ បញ្ញាធនំ ។ កតមញ្ច ភិក្ខវេ សទ្ធាធនំ ។ ឥធ ភិក្ខវេ អរិយសាវកោ សទ្ធោ ហោតិ សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ។ បេ ។

ទ្រព្យគឺសទ្ធា ១ ទ្រព្យគឺសីល ១ ទ្រព្យគឺហិរិ ១ ទ្រព្យគឺឱត្តប្បៈ ១ ទ្រព្យគឺសុតៈ ១ ទ្រព្យគឺចាគៈ ១ ទ្រព្យគឺបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះទ្រព្យ ៧ យ៉ាង ។

ទ្រព្យគឺសទ្ធា ទ្រព្យគឺសីល ទ្រព្យគឺហិរិ ទ្រព្យគឺឱត្តប្បៈ
ទ្រព្យគឺសុតៈ ទ្រព្យគឺចាគៈ ទ្រព្យគឺបញ្ញា ជាគំរប់ ៧ ។
បុគ្គលណា ទោះស្រ្តីក្តី បុរសក្តី មានទ្រព្យទាំងនេះ អ្នក
ប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះថាជាអ្នកមិនទលក្រឡើយ
ការរស់នៅរបស់បុគ្គលនោះ មិនសោះសូន្យឡើយ ។
ហេតុនោះ អ្នកប្រាជ្ញ កាលរលឹកនូវពាក្យប្រៀនប្រដៅ
របស់ព្រះពុទ្ធទាំងឡាយ គប្បីប្រកបរឿយៗ នូវសទ្ធាសីល
សេចក្តីជ្រះថ្លានិងការឃើញនូវធម៌ ។

(៦) ម្នាលភិក្ខុទាំងឡាយ ទ្រព្យនេះមាន ៧ យ៉ាង ។ ៧ យ៉ាង តើអ្វីខ្លះ ។ ទ្រព្យគឺសទ្ធា ១ ទ្រព្យគឺសីល ១ ទ្រព្យគឺហិរិ ១ ទ្រព្យគឺឱត្តប្បៈ ១ ទ្រព្យគឺសុតៈ ១ ទ្រព្យគឺចាគៈ ១ ទ្រព្យគឺបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ទ្រព្យគឺសទ្ធា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសទ្ធា រមែងជឿចំពោះពោធិញ្ញាណរបស់ព្រះតថាគតថា ព្រះមានព្រះភាគព្រះអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ។ បេ

ពុទ្ធោ ភគវាតិ ។ ឥទំ វុច្ចតិ ភិក្ខវេ សទ្ធាធនំ ។ កតមញ្ច ភិក្ខវេ សីលធនំ ។ ឥធ ភិក្ខវេ អរិយសាវកោ បាណាតិបាតា បដិវិរតោ ហោតិ ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ ។ ឥទំ វុច្ចតិ ភិក្ខវេ សីលធនំ ។ កតមញ្ច ភិក្ខវេ ហិរិធនំ ។ ឥធ ភិក្ខវេ អរិយសាវកោ ហិរិមា ហោតិ ហិរិយតិ កាយទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេន ហិរិយតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ។ ឥទំ វុច្ចតិ ភិក្ខវេ ហិរិធនំ ។ កតមញ្ច ភិក្ខវេ ឱត្តប្បធនំ ។ ឥធ ភិក្ខវេ អរិយសាវកោ ឱត្តប្បី ហោតិ ឱត្តប្បតិ កាយទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេន ឱត្តប្បតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ។ ឥទំ វុច្ចតិ ភិក្ខវេ ឱត្តប្បធនំ ។ កតមញ្ច ភិក្ខវេ សុតធនំ ។ ឥធ ភិក្ខវេ អរិយសាវកោ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា

ព្រះអង្គត្រាស់ដឹងនូវសព្វធម៌ ទ្រង់កាប់បង់នូវត្រៃភព ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យគឺសទ្ធា ។ ម្នាលភិក្ខុទាំងឡាយ ទ្រព្យគឺសីល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកវៀរចាកបាណាតិបាត ។បេ។ ជាអ្នកវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យគឺសីល ។ ម្នាលភិក្ខុទាំងឡាយ ទ្រព្យគឺហិរិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសេចក្តីអៀនខ្មាស រមែងអៀនខ្មាសចំពោះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត រមែងខ្មាសនូវការចូលប្រសព្វនូវអកុសលធម៌ដ៏លាមក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យគឺហិរិ ។ ម្នាលភិក្ខុទាំងឡាយ ទ្រព្យគឺឱត្តប្បៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសេចក្តីតក់ស្លុត រមែងតក់ស្លុតចំពោះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត រមែងតក់ស្លុតចំពោះការចូលប្រសព្វនូវអកុសលធម៌ដ៏លាមក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យគឺឱត្តប្បៈ ។ ម្នាលភិក្ខុទាំងឡាយ ទ្រព្យគឺសុតៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាពហុស្សុត ទ្រទ្រង់នូវចំណេះ សន្សំទុកនូវចំណេះ ធម៌ទាំងឡាយណា

អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសាន-
កល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ
ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា
ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា
ទិដ្ឋិយា សុប្បដិវិទ្ធា ។ ឥទំ វុច្ចតិ ភិក្ខវេ សុតធនំ ។
កតមញ្ច ភិក្ខវេ ចាគធនំ ។ ឥធ ភិក្ខវេ
អរិយសាវកោ វិគតមលមច្ឆេរេន ចេតសា អគារំ
អជ្ឈាវសតិ មុត្តចាគោ បយតបាណិ វោស្សគ្គរតោ
យាចយោគោ ទានសំវិភាគរតោ ។ ឥទំ វុច្ចតិ ភិក្ខវេ
ចាគធនំ ។ កតមញ្ច ភិក្ខវេ បញ្ញាធនំ ។ ឥធ ភិក្ខវេ
អរិយសាវកោ បញ្ញវា ហោតិ ។ បេ ។ សម្មាទុក្ខ-
ក្ខយគាមិនិយា ។ ឥទំ វុច្ចតិ ភិក្ខវេ បញ្ញាធនំ ។
ឥមានិ ខោ ភិក្ខវេ សត្ត ធនានិ ។

សទ្ធាធនំ សីលធនំ ហិរិ ឱត្តប្បិយំ ធនំ
សុតធនញ្ច ចាគោ ច បញ្ញា វេ សត្តមំ ធនំ
យស្ស ឯតេ ធនា អត្ថិ ឥត្ថិយា បុរិសស្ស វា

## បឋមបណ្ណាសក ធនវគ្គ

ពីរោះបទដើម ពីរោះបទកណ្ដាលនឹងពីរោះបទចុង រមែងប្រកាសព្រហ្មចរិយធម៌ ប្រកបដោយអត្ថនឹងព្យញ្ជនៈដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ធម៌ទាំងឡាយនោះ ដែលអរិយសាវក មានសភាពដូច្នោះ បានស្ដាប់មកច្រើន បានទ្រទ្រង់ទុក បានចាំស្ទាត់តែមាត់ បានចូលចិត្តច្បាស់លាស់ បានយល់ច្បាស់ដោយទិដ្ឋិគឺបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យគឺសុតៈ ។ ម្នាលភិក្ខុទាំងឡាយ ទ្រព្យគឺចាគៈ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ មានចិត្តប្រាសចាកមន្ទិលគឺសេចក្ដីកំណាញ់ បានបរិច្ចាគរួចហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះ ជាអ្នកគួរដល់សូម ត្រេកអរក្នុងការចែករំលែកទាន រមែងនៅគ្រប់គ្រងផ្ទះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យគឺចាគៈ ។ ម្នាលភិក្ខុទាំងឡាយ ទ្រព្យគឺបញ្ញា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានបញ្ញា ។បេ។ ជាគ្រឿងដល់នូវការអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យគឺបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ នេះឯងទ្រព្យ ៧ យ៉ាង ។

ទ្រព្យគឺសទ្ធា ទ្រព្យគឺសីល ទ្រព្យគឺហិរិ ទ្រព្យគឺឱត្តប្បៈ
ទ្រព្យគឺសុតៈ ទ្រព្យគឺចាគៈ ទ្រព្យគឺបញ្ញា ជាគំរប់ ៧
បុគ្គលណា ទោះស្ត្រីក្ដី បុរសក្ដី មានទ្រព្យទាំងនេះ

អនប្បកោតិ តំ អាហុ អហោសិ តស្ស ជីវិតំ ។
តស្មា សទ្ធញ្ច សីលញ្ច បសាទំ ធម្មទស្សនំ
អនុយុញ្ជេថ មេធាវី សរំ ពុទ្ធានសាសនន្តិ ។

(៧) អថខោ ឧគ្គោ រាជមហាមត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ឧគ្គោ រាជមហាមត្តោ ភគវន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវ អឌ្ឍោ ចាយំ ភន្តេ មិគារោ រោហ-ណេយ្យោ យាវ មហទ្ធនោ យាវ មហាភោគោតិ ។ កីវ អឌ្ឍោ បនុគ្គ មិគារោ រោហណេយ្យោ កីវ មហទ្ធនោ កីវ មហាភោគោតិ ។ សតំ ភន្តេ សហស្សានិ ហិរញ្ញស្ស[១] កោ បន វាទោ រូបិយស្សាតិ ។ អត្ថិ ខោ ឯតំ ឧគ្គ ធនំ នេតំ នត្ថីតិ វទាមិ តញ្ច ខោ ឯតំ ឧគ្គ ធនំ សាធារណំ

១ ឱ, សតសហស្សានំ ។

អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះថាជាអ្នកមិនទ័លក្រ ការរស់នៅរបស់បុគ្គលនោះ មិនសោះសូន្យឡើយ ។ ហេតុដូច្នោះ អ្នកប្រាជ្ញកាលរលឹកនូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គប្បីប្រកបរឿយៗ នូវសទ្ធាសីល សេចក្តីជ្រះថ្លានឹងការឃើញនូវធម៌ ។

(៧) គ្រានោះឯង ឧគ្គរាជមហាមាត្យ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះឧគ្គរាជមហាមាត្យអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចំរើន ចំឡែកណាស់ បពិត្រព្រះអង្គដ៏ចំរើន ព្រោះមិគារសេដ្ឋីជាចៅរបស់រោហណសេដ្ឋីនេះ ពេញជាមនុស្សស្តុកស្តម្ភផង ជាអ្នកមានទ្រព្យច្រើនផង មានភោគៈច្រើនផង ។ ម្នាលឧគ្គៈ មិគារសេដ្ឋីជាចៅរបស់រោហណសេដ្ឋី ស្តុកស្តម្ភ តើអាស្រ័យរបស់អ្វី មានទ្រព្យច្រើន តើអាស្រ័យរបស់អ្វី មានភោគៈច្រើន តើអាស្រ័យរបស់អ្វី ។ បពិត្រព្រះអង្គដ៏ចំរើន មាសរាប់បានជាសែនទៅហើយ ចាំបាច់ពោលទៅថ្វីដល់រូបិយវត្ថុ ។ ម្នាលឧគ្គៈ ទ្រព្យនុ៎ះមានមែនហើយ ម្នាលឧគ្គៈ តថាគតមិននិយាយថា ទ្រព្យនុ៎ះគ្មានទេ ប៉ុន្តែទ្រព្យនោះឯង ជាសាធារណៈ

អគ្គិនា ឧទកេន រាជូហិ ចោរេហិ អប្បិយេហិ ទាយាទេហិ ។ សត្ត ខោ ឥមានិ ឧគ្គ ធនានិ អសាធារណានិ អគ្គិនា ឧទកេន រាជូហិ ចោរេហិ អប្បិយេហិ ទាយាទេហិ ។ កតមានិ សត្ត ។ សទ្ធាធនំ សីលធនំ ហិរិធនំ ឱត្តប្បធនំ សុតធនំ ចាគធនំ បញ្ញាធនំ ។ ឥមានិ ខោ ឧគ្គ សត្ត ធនានិ អសាធារណានិ អគ្គិនា ឧទកេន រាជូហិ ចោរេហិ អប្បិយេហិ ទាយាទេហីតិ ។

សទ្ធាធនំ សីលធនំ ហិរី ឱត្តប្បិយំ ធនំ
សុតធនញ្ច ចាគោ ច បញ្ញា វេ សត្តមំ ធនំ ។
យស្ស ឯតា ធនា អត្ថិ ឥត្ថិយា បុរិសស្ស វា
ស វេ មហទ្ធនោ លោកេ អជេយ្យោ ទេវមានុសេ ។
តស្មា សទ្ធញ្ច សីលញ្ច បសាទំ ធម្មទស្សនំ
អនុយុញ្ជេថ មេធាវី សរំ ពុទ្ធានសាសនន្តិ ។

(៨) សត្តិមានិ ភិក្ខវេ សញ្ញោជនានិ ។ កតមានិ សត្ត ។ អនុនយសញ្ញោជនំ បដិឃសញ្ញោជនំ

ដល់ភ្លើង ទឹក ពួកស្តេច ពួកចោរនិងពួកញាតិ មិនជាទីស្រឡាញ់ ។ ម្នាលឧគ្គៈ ទ្រព្យនេះមាន ៧ យ៉ាង ជារបស់មិនសាធារណៈដល់ភ្លើង ទឹក ពួកស្តេច ពួកចោរនិងពួកញាតិ មិនជាទីស្រឡាញ់ ។ ៧ យ៉ាងតើអ្វីខ្លះ ។ សទ្ធាធនៈ ១ សីលធនៈ ១ ហិរិធនៈ ១ ឱត្តប្បធនៈ ១ សុតធនៈ ១ ចាគធនៈ ១ បញ្ញាធនៈ ១ ។ ម្នាលឧគ្គៈ ទ្រព្យ ៧ យ៉ាងនេះឯង មិនសាធារណៈដល់ភ្លើង ទឹក ពួកស្តេច ពួកចោរ និងពួកញាតិ មិនជាទីស្រឡាញ់បានឡើយ ។

សទ្ធាធនៈ សីលធនៈ ហិរិធនៈ ឱត្តប្បធនៈ សុតធនៈ
ចាគធនៈ បញ្ញាធនៈ ជាគំរប់ ៧ ។ បុគ្គលណាទោះស្រ្តីក្តី
បុរសក្តី មានទ្រព្យទាំងនេះ បុគ្គលនោះឯងឈ្មោះថា មាន
ទ្រព្យច្រើន ដែលអ្នកណាមួយមិនគប្បីផ្ចាញ់បាន ក្នុងទេវលោក
និងមនុស្សលោក ។ ហេតុដូច្នោះ អ្នកប្រាជ្ញកាលរលឹកនូវ
ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គប្បីប្រកបរឿយៗ
នូវសទ្ធាសីលសេចក្តីជ្រះថ្លានិងការឃើញនូវធម៌ ។

(៨) ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈនេះ មាន ៧ យ៉ាង ។ ៧ យ៉ាង តើអ្វីខ្លះ ។ គឺអនុនយសញ្ញោជនៈ[១] ១ បដិឃសញ្ញោជនៈ ១

---

១ កាមរាគសញ្ញោជនៈ ។ អដ្ឋកថា ។

ទិដ្ឋិសញ្ញោជនំ វិចិកិច្ឆាសញ្ញោជនំ មានសញ្ញោជនំ ភវរាគសញ្ញោជនំ អវិជ្ជាសញ្ញោជនំ ។ ឥមានិ ខោ ភិក្ខវេ សត្ត សញ្ញោជនានីតិ ។

(៩) សត្តន្នំ ភិក្ខវេ សញ្ញោជនានំ បហានាយ សមុច្ឆេទាយ ព្រហ្មចរិយំ វុស្សតិ ។ កតមេសំ សត្តន្នំ ។ អនុនយសញ្ញោជនស្ស បហានាយ សមុច្ឆេទាយ ព្រហ្មចរិយំ វុស្សតិ ។ បដិឃសញ្ញោជនស្ស ។ បេ ។ ទិដ្ឋិសញ្ញោជនស្ស វិចិកិច្ឆាសញ្ញោជនស្ស មានសញ្ញោជនស្ស ភវរាគសញ្ញោជនស្ស អវិជ្ជាសញ្ញោជនស្ស បហានាយ សមុច្ឆេទាយ ព្រហ្មចរិយំ វុស្សតិ ។ ឥមេសំ ខោ ភិក្ខវេ សត្តន្នំ សញ្ញោជនានំ បហានាយ សមុច្ឆេទាយ ព្រហ្មចរិយំ វុស្សតិ ។ យតោ ខោ ភិក្ខវេ ភិក្ខុនោ អនុនយសញ្ញោជនំ បហីនំ ហោតិ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវំកតំ អាយតឹ អនុប្បាទធម្មំ បដិឃសញ្ញោជនំ ។ បេ ។ ទិដ្ឋិសញ្ញោជនំ វិចិកិច្ឆាសញ្ញោជនំ មានសញ្ញោជនំ ភវរាគសញ្ញោជនំ

ទិដ្ឋិសញ្ញោជនៈ ១ វិចិកិច្ឆាសញ្ញោជនៈ ១ មានសញ្ញោជនៈ ១ ភវរាគសញ្ញោជនៈ ១ អវិជ្ជាសញ្ញោជនៈ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង សញ្ញោជនៈ ៧ យ៉ាង ។

[៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីលះ ដើម្បីផ្តាច់ផ្តិលនូវសញ្ញោជនៈ ៧ យ៉ាង ។ ៧ យ៉ាង តើដូចម្តេច ។ គឺភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីលះ ដើម្បីផ្តាច់ផ្តិលនូវអនុនយសញ្ញោជនៈ បដិឃសញ្ញោជនៈ ។ បេ ។ ភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីលះ ដើម្បីផ្តាច់ផ្តិលនូវទិដ្ឋិសញ្ញោជនៈ វិចិកិច្ឆាសញ្ញោជនៈ មានសញ្ញោជនៈ ភវរាគសញ្ញោជនៈ អវិជ្ជាសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីលះ ដើម្បីផ្តាច់ផ្តិលនូវសញ្ញោជនៈ ទាំង ៧ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលណាអនុនយសញ្ញោជនៈ ភិក្ខុបានលះស្រឡះហើយ ផ្តាច់ផ្តិលឫសគល់អស់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាដើមត្នោតកំបុតក ធ្វើឲ្យលែងមានបែបភាព មិនមានទីកើតតទៅទៀតជាធម្មតា បដិឃសញ្ញោជនៈ ។ បេ ។ ទិដ្ឋិសញ្ញោជនៈ វិចិកិច្ឆាសញ្ញោជនៈ មានសញ្ញោជនៈ ភវរាគសញ្ញោជនៈ

អវិជ្ជាសញ្ញោជនំ បហីនំ ហោតិ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវំកតំ អាយតិំ អនុប្បាទធម្មំ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អច្ឆេជ្ជិ តណ្ហំ វិវត្តយិ សញ្ញោជនំ សម្មា មានាភិសមយា អន្តមកាសិ ទុក្ខស្សាតិ ។

(១០) សត្តិមានិ ភិក្ខវេ សញ្ញោជនានិ ។ កតមានិ សត្ត ។ អនុនយសញ្ញោជនំ បដិឃសញ្ញោជនំ ទិដ្ឋិសញ្ញោជនំ វិចិកិច្ឆាសញ្ញោជនំ មានសញ្ញោជនំ ឥស្សាសញ្ញោជនំ មច្ឆរិយសញ្ញោជនំ ។ ឥមានិ ខោ ភិក្ខវេ សត្ត សញ្ញោជនានីតិ ។

ធនវគ្គោ បឋមោ ។

## តស្សុទ្ទានំ

ទ្វេ បិយញ្ច[១] ពលំ ធនំ[២] (សំខិត្តញ្ច វិត្ថតំ)[៣]
ឧត្តសញ្ញោជនញ្ច[៤] បហានមច្ឆរិយេន ចាតិ ។

---

១ ម. ទ្វេបិ ធម្មា ។ ២ ឱ· ទ្វេ ពលំ ធនំ ។ ៣ ម. សំខិត្តញ្ចេវ វិត្ថតន្តិ ន ទិស្សតិ ។ ៤ ម. ឧត្តសញ្ញោជនំ ចេវ ។

អវិជ្ជាសញ្ញោជនៈ ភិក្ខុបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ មិនមានទីកើត ដូចជាដើមត្នោតកំបុតក ធ្វើឲ្យលែងមានបែបភាពមិនមានទីកើតតទៅទៀតជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះទើបហៅថា បានកាត់តណ្ហា បានស្រាយនូវសញ្ញោជនធម៌ ហើយធ្វើនូវទីបំផុតនៃទុក្ខ ព្រោះត្រាស់ដឹងនូវមានះ ដោយប្រពៃ ។

[ ១០ ] ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈនេះ មាន ៧ យ៉ាង ។ ៧ យ៉ាងតើអ្វីខ្លះ ។ គឺអនុនយសញ្ញោជនៈ ១ បដិឃសញ្ញោជនៈ ១ ទិដ្ឋិសញ្ញោជនៈ ១ វិចិកិច្ឆាសញ្ញោជនៈ ១ មានសញ្ញោជនៈ ១ ឥស្សាសញ្ញោជនៈ ១ មច្ឆរិយសញ្ញោជនៈ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះសញ្ញោជនៈ ៧ យ៉ាង ។

ចប់ ធនវគ្គទី ១ ។

## ឧទ្ទាននៃធនវគ្គនោះគឺ

និយាយពីភិក្ខុ ជាទីស្រឡាញ់ និងមិនជាទីស្រឡាញ់ពីរលើក
កំឡាំង ១ ទ្រព្យ ១ (ទាំងសង្ខេប ទាំងពិស្តារ) ឧគ្គជមហា-
មាត្យ ១ ការលះបង់សញ្ញោជនៈ ១ មានមច្ឆរិយៈជាទីបំផុត ១ ។

# អនុសយវគ្គោ

(១១) សត្តិមេ ភិក្ខវេ អនុសយា ។ កតមេ សត្ត ។ កាមរាគានុសយោ បដិឃានុសយោ ទិដ្ឋានុសយោ វិចិកិច្ឆានុសយោ មានានុសយោ ភវរាគានុសយោ អវិជ្ជានុសយោ ។ ឥមេ ខោ ភិក្ខវេ សត្ត អនុសយាតិ ។

(១២) សត្តន្នំ ភិក្ខវេ អនុសយានំ បហានាយ សមុច្ឆេទាយ ព្រហ្មចរិយំ វុស្សតិ ។ កតមេសំ សត្តន្នំ ។ កាមរាគានុសយស្ស បហានាយ សមុច្ឆេទាយ ព្រហ្មចរិយំ វុស្សតិ បដិឃានុសយស្ស ។ បេ ។ ទិដ្ឋានុសយស្ស វិចិកិច្ឆានុសយស្ស មានានុសយស្ស ភវរាគានុសយស្ស អវិជ្ជានុសយស្ស បហានាយ សមុច្ឆេទាយ ព្រហ្មចរិយំ វុស្សតិ ។ ឥមេសំ ខោ ភិក្ខវេ សត្តន្នំ អនុសយានំ បហានាយ សមុច្ឆេទាយ ព្រហ្មចរិយំ វុស្សតិ ។ យតោ ខោ ភិក្ខវេ ភិក្ខុនោ កាមរាគានុសយោ បហីនោ ហោតិ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំកតោ អាយតឹ អនុប្បាទធម្មោ បដិឃានុសយោ ។ បេ ។ ទិដ្ឋានុសយោ វិចិកិច្ឆានុសយោ មានានុសយោ

# អនុសយវគ្គ

(១១) ម្នាលភិក្ខុទាំងឡាយ អនុសយៈនេះមាន ៧ យ៉ាង ៗ ៧ យ៉ាង តើអ្វីខ្លះ ៗ គឺកាមរាគានុសយៈ ១ បដិឃានុសយៈ ១ ទិដ្ឋានុសយៈ ១ វិចិកិច្ឆានុសយៈ ១ មានានុសយៈ ១ ភវរាគានុសយៈ ១ អវិជ្ជានុសយៈ ១ ម្នាលភិក្ខុទាំងឡាយ នេះអនុសយៈ ៧ យ៉ាង ៗ

(១២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីលះ ដើម្បីផ្តាច់ផ្តិលនូវអនុសយៈទាំង ៧ ៗ ៧ យ៉ាង តើដូចម្តេចខ្លះ ៗ គឺភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីលះ ដើម្បីផ្តាច់ផ្តិលនូវកាមរាគានុសយៈ បដិឃានុសយៈ ។បេ។ ភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីលះ ដើម្បីផ្តាច់ផ្តិលនូវទិដ្ឋានុសយៈ វិចិកិច្ឆានុសយៈ មានានុសយៈ ភវរាគានុសយៈ អវិជ្ជានុសយៈ ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីលះ ដើម្បីផ្តាច់ផ្តិលនូវអនុសយៈ ៧ យ៉ាងនេះឯង ៗ ម្នាលភិក្ខុទាំងឡាយ កាលណា កាមរាគានុសយៈ ភិក្ខុបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ ធ្វើមិនឲ្យមានទីកើតដូចជាត្នោតកំបុតក ធ្វើឲ្យលែងមានបែបភាព មិនមានទីកើតតទៅទៀតជាធម្មតា បដិឃានុសយៈ ។បេ។ ទិដ្ឋានុសយៈ វិចិកិច្ឆានុសយៈ មានានុសយៈ

ភវរាគានុសយោ អវិជ្ជានុសយោ បហីនោ ហោតិ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំកតោ អាយតឹ អនុប្បាទធម្មោ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អច្ឆេច្ឆិ តណ្ហំ វិវត្តយិ សញ្ញោជនំ សម្មា មានាភិសមយា អន្តមកាសិ ទុក្ខស្សាតិ ។

(១៣) សត្តហិ ភិក្ខវេ អង្គេហិ សមន្នាគតំ កុលំ អនុបគន្ត្វា វា នាលំ ឧបគន្តុំ ឧបគន្ត្វា វា នាលំ និសីទិតុំ(១) ។ កតមេហិ សត្តហិ ។ ន មនាបេន បច្ចុដ្ឋេន្តិ ន មនាបេន អភិវាទេន្តិ ន មនាបេន អាសនំ ទេន្តិ សន្តមស្ស បរិគុហន្តិ ពហុកម្បិ ថោកំ ទេន្តិ បណីតម្បិ លូខំ ទេន្តិ អសក្កច្ចំ ទេន្តិ នោ សក្កច្ចំ ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ អង្គេហិ សមន្នាគតំ កុលំ អនុបគន្ត្វា វា នាលំ ឧបគន្តុំ ឧបគន្ត្វា វា នាលំ និសីទិតុំ ។ សត្តហិ ភិក្ខវេ អង្គេហិ សមន្នាគតំ កុលំ អនុបគន្ត្វា វា អលំ ឧបគន្តុំ ឧបគន្ត្វា វា អលំ និសីទិតុំ ។

---

១ ឱ. ឧបនិសីទិតុំ ។

ភវរាគានុសយៈ អវិជ្ជានុសយៈ ភិក្ខុបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ ធ្វើមិនឲ្យមានទីកើតដូចជាត្នោតកំបុតក ធ្វើឲ្យលែងមានបែបភាព មិនមានទីកើតតទៅទៀតជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ ទើបហៅថា បានកាត់តណ្ហា បានស្រាយនូវសញ្ញោជនៈ បានធ្វើនូវទីបំផុតនៃទុក្ខ ព្រោះបានត្រាស់ដឹងនូវមានៈ ដោយប្រពៃ ។

(១៣) ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៧ យ៉ាង ភិក្ខុមិនទាន់ចូលទៅជិត មិនគួរចូលទៅជិតទេ ឬបានចូលទៅជិតហើយ មិនគួរអង្គុយឡើយ ។ ៧ យ៉ាងតើអ្វីខ្លះ ។ គឺពួកជន មិនក្រោកទទួលដោយសេចក្តីពេញចិត្ត ១ មិនថ្វាយបង្គំ ដោយសេចក្តីពេញចិត្ត ១ មិនប្រគេនអាសនៈ ដោយសេចក្តីពេញចិត្ត ១ លាក់ទុកនូវទេយ្យធម៌របស់គេ ១ កាលបើទេយ្យធម៌មានច្រើន ឲ្យតិច ១ កាលបើមានទេយ្យធម៌ដ៏ឧត្តម ឲ្យរបស់សៅហ្មង ១ ឲ្យដោយសេចក្តីមិនគោរព មិនឲ្យដោយសេចក្តីគោរព ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៧ យ៉ាងនេះឯង ភិក្ខុមិនទាន់ចូលទៅជិត មិនគួរចូលទៅជិតទេ ឬ បានចូលទៅជិតហើយ មិនគួរអង្គុយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៧ យ៉ាង ភិក្ខុមិនទាន់ចូលទៅជិត គួរចូលទៅជិតបាន ឬ បានចូលទៅជិតហើយ គួរអង្គុយបាន ។

កតមេហិ សត្តហិ ។ មនាបេន បច្ចុដ្ឋេន្តិ មនាបេន អភិវាទេន្តិ មនាបេន អាសនំ ទេន្តិ សន្តមស្ស ន បរិគុហន្តិ ពហុកម្ពិ ពហុកំ ទេន្តិ បណីតម្ពិ បណីតំ ទេន្តិ សក្កច្ចំ ទេន្តិ នោ អសក្កច្ចំ ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ អង្គេហិ សមន្នាគតំ កុលំ អនុបគន្ត្វា វា អលំ ឧបគន្តុំ ឧបគន្ត្វា វា អលំ និសីទិតុំ ។

(១៤) សត្តិមេ ភិក្ខវេ បុគ្គលា អាហុនេយ្យា បាហុនេយ្យា ទក្ខិណេយ្យា អញ្ជលិករណីយា អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេ សត្ត ។ ឧភតោភាគវិមុត្តោ បញ្ញាវិមុត្តោ កាយសក្ខី ទិដ្ឋិប្បត្តោ សទ្ធាវិមុត្តោ ធម្មានុសារី សទ្ធានុសារី ។ ឥមេ ខោ ភិក្ខវេ សត្ត បុគ្គលា អាហុនេយ្យា បាហុនេយ្យា ទក្ខិណេយ្យា អញ្ជលិករណីយា អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

៧ យ៉ាង តើអ្វីខ្លះ ។ គឺពួកជនក្រោកទទួល ដោយសេចក្តីពេញចិត្ត ១ ថ្វាយបង្គំ ដោយសេចក្តីពេញចិត្ត ១ ប្រគេនអាសនៈ ដោយសេចក្តីពេញចិត្ត ១ មិនលាក់ទុកនូវទេយ្យធម៌របស់គេ ១ កាលបើមានទេយ្យធម៌ច្រើន ប្រគេនច្រើន ១ កាលបើមានទេយ្យធម៌ដ៏ឧត្តម ប្រគេនទេយ្យធម៌ដ៏ឧត្តម ១ តែងប្រគេនដោយសេចក្តីគោរព មិនប្រគេនដោយសេចក្តីមិនគោរព ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៧ យ៉ាងនេះឯង ភិក្ខុមិនទាន់ចូលទៅជិត គួរចូលទៅជិតបាន ឬ ចូលទៅជិតហើយ គួរអង្គុយបាន ។

(១៤) ម្នាលភិក្ខុទាំងឡាយ បុគ្គល ៧ ពួកនេះ គួរទទួលចតុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលនូវអាគន្តុកទាន ដែលគេនាំមកដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់នូវអញ្ជលីកម្ម ដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ៧ ពួកតើអ្វីខ្លះ ។ គឺឧភតោភាគវិមុត្ត ១ បញ្ញាវិមុត្ត ១ កាយសក្ខិ ១ ទិដ្ឋិប្បត្តៈ ១ សទ្ធាវិមុត្ត ១ ធម្មានុសារី ១ សទ្ធានុសារី ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៧ ពួកនេះឯង គួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលនូវអាគន្តុកទាន ដែលគេនាំមកដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលីកម្ម ដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

(១៥) សត្តិមេ ភិក្ខវេ ឧទកូបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ សត្ត ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សកឹ និមុគ្គោ និមុគ្គោវ ហោតិ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ ឧម្មុជ្ជិត្វា និមុជ្ជតិ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ ឧម្មុជ្ជិត្វា ឋិតោ ហោតិ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ ឧម្មុជ្ជិត្វា វិបស្សតិ វិលោកេតិ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ ឧម្មុជ្ជិត្វា បតរតិ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ ឧម្មុជ្ជិត្វា បដិគាធប្បត្តោ ហោតិ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ ឧម្មុជ្ជិត្វា តិណ្ណោ ហោតិ បារគតោ ថលេ តិដ្ឋតិ ព្រាហ្មណោ ។ កថញ្ច ភិក្ខវេ បុគ្គលោ សកឹ និមុគ្គោ និមុគ្គោវ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សមន្នាគតោ ហោតិ ឯកន្តកាឡកេហិ អកុសលេហិ ធម្មេហិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ សកឹ និមុគ្គោ និមុគ្គោវ ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ ឧម្មុជ្ជិត្វា និមុជ្ជតិ ។

[១៥] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រៀបដូចអ្នកមុជទឹក ក្នុងលោកនេះ មាន ៧ ពួក ។ ៧ ពួកតើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមុជទៅហើយ ក៏មុជបាត់ទៅតែម្តង ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ងើបឡើងហើយមុជចុះទៅវិញ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ងើបឡើងហើយឈរ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ងើបឡើងហើយក្រឡេកមើលមើល ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ងើបឡើងហើយហែលឆ្លងទៅ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ងើបឡើងហើយ បានដល់នូវទីពឹងហើយឈរនៅ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះជាព្រាហ្មណ៍ ក្នុងលោកនេះ ងើបឡើងហើយឆ្លងទៅដល់ត្រើយ ហើយឈរនៅលើគោក ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកមុជហើយ ក៏មុជបាត់ទៅតែម្តង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកប្រកបដោយអកុសលធម៌ខ្មៅសុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមុជទៅហើយ ក៏មុជបាត់ទៅតែម្តងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលងើបឡើងហើយមុជទៅវិញ តើដូចម្តេច ។

ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ឧម្មុជ្ជតិ សាធុ សទ្ធា កុសលេសុ ធម្មេសុ សាធុ ហិរិ សាធុ ឱត្តប្បំ សាធុ វិរិយំ សាធុ បញ្ញា កុសលេសុ ធម្មេសូតិ ។ តស្ស សា សទ្ធា នេវ តិដ្ឋតិ នោ វឌ្ឍតិ ហាយតេវ ។ តស្ស សា ហិរិ តស្ស តំ ឱត្តប្បំ តស្ស តំ វិរិយំ តស្ស សា បញ្ញា នេវ តិដ្ឋតិ នោ វឌ្ឍតិ ហាយតេវ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ ឧម្មុជ្ជិត្វា និមុជ្ជតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ ឧម្មុជ្ជិត្វា ឋិតោ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ឧម្មុជ្ជតិ សាធុ សទ្ធា កុសលេសុ ធម្មេសុ សាធុ ហិរិ សាធុ ឱត្តប្បំ សាធុ វិរិយំ សាធុ បញ្ញា កុសលេសុ ធម្មេសូតិ ។ តស្ស សា សទ្ធា នេវ ហាយតិ នោ វឌ្ឍតិ ឋិតា ហោតិ ។ តស្ស សា ហិរិ តស្ស តំ ឱត្តប្បំ តស្ស តំ វិរិយំ តស្ស សា បញ្ញា នេវ ហាយតិ នោ វឌ្ឍតិ ឋិតា ហោតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ រមែងងើបផ្ងោលដោយសេចក្ដីយល់ថា សេចក្ដីជឿចំពោះកុសលធម៌ទាំងឡាយ ជាការល្អ សេចក្ដីខ្មាសបាប ជាការល្អ សេចក្ដីតក់ស្លុតចំពោះបាប ជាការល្អ សេចក្ដីព្យាយាម ជាការល្អ ការដឹងច្បាស់ក្នុងកុសលធម៌ទាំងឡាយ ជាការល្អ ។ សទ្ធារបស់បុគ្គលនោះមិនតាំងនៅ មិនចំរើនឡើង រមែងសាបសូន្យទៅវិញ ។ ហិរិរបស់បុគ្គលនោះ ឱត្តប្បៈរបស់បុគ្គលនោះ វិរិយៈរបស់បុគ្គលនោះ បញ្ញារបស់បុគ្គលនោះ រមែងមិនតាំងនៅ មិនចំរើនឡើង មានតែសាបសូន្យទៅវិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងើបផ្ងោលហើយមុជទៅវិញយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងើបផ្ងោលហើយឈរ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ងើបឡើងដោយសេចក្ដីយល់ថា សេចក្ដីជឿចំពោះកុសលធម៌ទាំងឡាយ ជាការល្អ សេចក្ដីខ្មាសបាប ជាការល្អ សេចក្ដីតក់ស្លុតចំពោះបាប ជាការល្អ សេចក្ដីព្យាយាម ជាការល្អ ការដឹងច្បាស់ក្នុងកុសលធម៌ទាំងឡាយ ជាការល្អ ។ សទ្ធារបស់បុគ្គលនោះ ក៏មិនសាបសូន្យទៅ មិនចំរើនឡើង រមែងតាំងនៅដដែល ។ ហិរិរបស់បុគ្គលនោះ ឱត្តប្បៈរបស់បុគ្គលនោះ វិរិយៈរបស់បុគ្គលនោះ បញ្ញារបស់បុគ្គលនោះ រមែងមិនសាបសូន្យទៅ មិនចំរើនឡើង រមែងតាំងនៅដដែល ។

យំ សោ ភិក្ខវេ បុគ្គលោ ឧម្មុជ្ជិត្វា ឋិតោ ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ ឧម្មុជ្ជិត្វា វិបស្សតិ វិលោកេតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ឧម្មុជ្ជតិ សាធុ សទ្ធា កុសលេសុ ធម្មេសុ សាធុ ហិរី សាធុ ឱត្តប្បំ សាធុ វីរិយំ សាធុ បញ្ញា កុសលេសុ ធម្មេសូតិ ។ សោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នោ ហោតិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោ ។ យំ សោ ភិក្ខវេ បុគ្គលោ ឧម្មុជ្ជិត្វា វិបស្សតិ វិលោកេតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ ឧម្មុជ្ជិត្វា បតរតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ឧម្មុជ្ជតិ សាធុ សទ្ធា កុសលេសុ ធម្មេសុ សាធុ ហិរី សាធុ ឱត្តប្បំ សាធុ វីរិយំ សាធុ បញ្ញា កុសលេសុ ធម្មេសូតិ ។ សោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមី ហោតិ

ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកងើបផ្ងោលហើយឈរនៅយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងើបផ្ងោលហើយក្រឡេករមិលមើល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ងើបឡើងដោយសេចក្តីយល់ថា សេចក្តីជឿចំពោះកុសលធម៌ទាំងឡាយ ជាការល្អ សេចក្តីខ្មាសបាប ជាការល្អ សេចក្តីតក់ស្លុតចំពោះបាប ជាការល្អ សេចក្តីព្យាយាម ជាការល្អ ការដឹងច្បាស់ក្នុងកុសលធម៌ទាំងឡាយ ជាការល្អ ។ បុគ្គលនោះ ជាសោតាបន្ន ព្រោះអស់សញ្ញោជនៈ ៣ យ៉ាង ជាអ្នកមានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិប្រព្រឹត្តទៅក្នុងខាងមុខ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងើបផ្ងោលហើយ ក្រឡេករមិលមើលយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងើបផ្ងោលហើយឆ្លងទៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ងើបឡើងដោយសេចក្តីយល់ថា សេចក្តីជឿចំពោះកុសលធម៌ទាំងឡាយ ជាការល្អ សេចក្តីខ្មាសបាប ជាការល្អ សេចក្តីតក់ស្លុតចំពោះបាប ជាការល្អ សេចក្តីព្យាយាម ជាការល្អ ការដឹងច្បាស់ក្នុងកុសលធម៌ទាំងឡាយ ជាការល្អ ។ បុគ្គលនោះ ជាសកទាគាមី ព្រោះអស់សញ្ញោជនៈទាំង ៣ យ៉ាង ព្រោះរាគៈ ទោសៈ មោហៈ ក៏ស្រាលស្តើង

សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករោតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ ឧម្មុជ្ជិត្វា បតរតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ ឧម្មុជ្ជិត្វា បតិគាធប្បត្តោ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ឧម្មុជ្ជតិ សាធុ សទ្ធា កុសលេសុ ធម្មេសុ សាធុ ហិរិ សាធុ ឱត្តប្បំ សាធុ វីរិយំ សាធុ បញ្ញា កុសលេសុ ធម្មេសូតិ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ ឧម្មុជ្ជិត្វា បតិគាធប្បត្តោ ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ ឧម្មុជ្ជិត្វា តិណ្ណោ ហោតិ បារគតោ ថលេ តិដ្ឋតិ ព្រាហ្មណោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ឧម្មុជ្ជតិ សាធុ សទ្ធា កុសលេសុ ធម្មេសុ សាធុ ហិរិ សាធុ ឱត្តប្បំ សាធុ វីរិយំ សាធុ បញ្ញា កុសលេសុ ធម្មេសូតិ ។

រមែងមកកាន់លោកនេះ អស់វារៈតែម្តង ហើយធ្វើនូវទីបំផុតនៃទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងើបផ្លោលហើយ ឆ្លងទៅយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងើបផ្លោលហើយដល់នូវទីពឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ងើបឡើងដោយសេចក្តីយល់ថា សេចក្តីជឿចំពោះកុសលធម៌ទាំងឡាយ ជាការល្អ សេចក្តីខ្មាសបាប ជាការល្អ សេចក្តីតក់ស្លុតចំពោះបាប ជាការល្អ សេចក្តីព្យា-យាម ជាការល្អ ការដឹងច្បាស់ក្នុងកុសលធម៌ទាំងឡាយ ជាការល្អ ។ បុគ្គលនោះ ជាឧបបាតិកៈ ព្រោះអស់សញ្ញោជនៈ ជាចំណែកខាងក្រោម ៥ យ៉ាង ហើយបរិនិព្វានក្នុងលោកនោះ មិនបានត្រឡប់មកចាកលោកនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងើបផ្លោលហើយដល់នូវទីពឹងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាព្រាហ្មណ៍ងើបផ្លោលហើយឆ្លងទៅដល់ត្រើយនាយ ហើយឈរនៅលើគោក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ងើបឡើងដោយសេចក្តីយល់ថា សេចក្តីជឿចំពោះកុសលធម៌ទាំងឡាយ ជាការល្អ សេចក្តីខ្មាសបាប ជាការល្អ សេចក្តីតក់ស្លុតចំពោះបាប ជាការល្អ សេចក្តីព្យាយាម ជាការល្អ ការដឹងច្បាស់ក្នុងពួកកុសលធម៌ ជាការល្អ ។

សោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ ឧម្មុជ្ជិត្វា តិណ្ណោ ហោតិ បារគតោ ថលេ តិដ្ឋតិ ព្រាហ្មណោ ។ ឥមេ ខោ ភិក្ខវេ សត្ត ឧទកូបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

(១៦) សត្តិមេ ភិក្ខវេ បុគ្គលា អាហុនេយ្យា បាហុនេយ្យា ទក្ខិណេយ្យា អញ្ជលិករណីយា អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេ សត្ត ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សព្វសង្ខារេសុ អនិច្ចា-នុបស្សី វិហរតិ អនិច្ចសញ្ញី អនិច្ចប្បដិសំវេទី សតតំ សមិតំ អព្វោកិណ្ណំ ចេតសា អធិមុច្ចមានោ បញ្ញាយ បរិយោគាហមានោ ។ សោ អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អយំ ភិក្ខវេ បឋមោ បុគ្គលោ

បុគ្គលនោះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម របស់ខ្លួន ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាព្រាហ្មណ៍ ឆើបឆ្លោះ ហើយឆ្លងទៅដល់ត្រើយខាងនាយ ហើយឈរនៅលើគោក យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះឯងបុគ្គល ៧ ពួក ប្រៀប ដូចអ្នកមុជទឹក រមែងមានប្រាកដក្នុងលោក ។

(១៦) ម្នាលភិក្ខុទាំងឡាយ បុគ្គល ៧ ពួកនេះ គួរទទួលបតុប្ប័យ ដែលគេនាំមកបូជា គួរទទួលនូវអាគន្តុកទាន ដែលគេនាំមក ដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលីកម្ម ដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ៧ ពួកតើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញថា មិនទៀង មានសេចក្ដីសំគាល់ថា មិនទៀង ដឹងច្បាស់ថា មិនទៀង ក្នុងសង្ខារទាំងពួង ហើយកំណត់ដោយចិត្ត ស្ទង់មើលដោយបញ្ញារឿយ ៗ មិនដាច់ មិនឲ្យប្រឡំគ្នា ។ បុគ្គលនោះ បានធ្វើឲ្យជាក់ច្បាស់សម្រេច ។ បេ ។ ព្រោះអស់អាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ នេះបុគ្គលទី ១

អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិ-ករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ សព្វសង្ខារេសុ អនិច្ចានុបស្សី វិហរតិ អនិច្ចសញ្ញី អនិច្ចប្បដិសំវេទី សតតំ សមិតំ អព្វោកិណ្ណំ ចេតសា អធិមុច្ចមានោ បញ្ញាយ បរិយោគាហមានោ ។ តស្ស អបុព្វំ អចរិមំ អាសវបរិយាទានញ្ច ហោតិ ជីវិតបរិយាទានញ្ច ។ អយំ ភិក្ខវេ ទុតិយោ បុគ្គលោ អាហុនេយ្យោ ។បេ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ សព្វសង្ខារេសុ អនិច្ចា-នុបស្សី វិហរតិ អនិច្ចសញ្ញី អនិច្ចប្បដិសំវេទី សតតំ សមិតំ អព្វោកិណ្ណំ ចេតសា អធិមុច្ចមានោ បញ្ញាយ បរិយោគាហមានោ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អន្តរាបរិនិព្វាយី ហោតិ

ដែលគួរទទួលបច្ច័យដែលគេនាំមកបូជា គួរទទួលនូវភត្តទាន ដែលគេនាំមកដើម្បីភ្ញៀវ គួរទទួលទក្ខិណាទាន គួរដល់អញ្ជលីកម្មដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញថា មិនទៀង មានសេចក្តីសំគាល់ថា មិនទៀង ដឹងច្បាស់ថា មិនទៀងក្នុងសង្ខារទាំងពួង ហើយកំណត់ដោយចិត្ត ស្ទង់មើលដោយបញ្ញារឿយៗ មិនដាច់ មិនឲ្យប្រឡំគ្នា ។ ការអស់ទៅនៃអាសវៈ នឹងការអស់ទៅនៃជីវិត របស់បុគ្គលនោះដំណាលគ្នាតែម្តង ។ ម្នាលភិក្ខុទាំងឡាយ នេះបុគ្គលទី ២ ដែលគួរទទួលនូវបច្ច័យដែលគេនាំមកបូជា ។ បេ ។ ជាបុញ្ញក្ខេត្ត ដ៏ប្រសើររបស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញថា មិនទៀង មានសេចក្តីសំគាល់ថា មិនទៀង ដឹងច្បាស់ថា មិនទៀងក្នុងសង្ខារទាំងពួង ហើយកំណត់ដោយចិត្ត ស្ទង់មើលដោយបញ្ញារឿយៗ មិនដាច់ មិនឲ្យប្រឡំគ្នា ។ បុគ្គលនោះឈ្មោះថា អន្តរាបរិនិព្វាយី (១) ព្រោះអស់សញ្ញោជនៈ ជាចំណែកខាងក្រោម ៥

---

១ – បុគ្គលណា បានកើតក្នុងសុទ្ធាវាសទាំង ៥ ណាមួយ បានដល់នូវអរហត្តក្នុងខណៈដែលខ្លួនកើត ឬ ក៏កន្លងបន្តិច ឬ ក៏បិតនៅពាក់កណ្តាលអាយុ ពាក្យថា អន្តរាបរិនិព្វាយីនេះ ជាឈ្មោះរបស់បុគ្គលនោះ ។

ៗ បេ ៗ ឧបហច្ចបរិនិព្វាយី ហោតិ អសង្ខារបរិនិព្វាយី
ហោតិ សសង្ខារបរិនិព្វាយី ហោតិ ឧទ្ធំសោតោ ហោតិ
អកនិដ្ឋគាមី ៗ អយំ ភិក្ខវេ សត្តមោ បុគ្គលោ
អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជ-
លិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ៗ
ឥមេ ខោ ភិក្ខវេ សត្ត បុគ្គលា អាហុនេយ្យា
បាហុនេយ្យា ទក្ខិណេយ្យា អញ្ជលិករណីយា
អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ៗ

(១៧) សត្តិមេ ភិក្ខវេ បុគ្គលា អាហុនេយ្យា
ៗ បេ ៗ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ៗ

។បេ។ ឈ្មោះថា ឧបហច្ចបរិនិព្វាយី(១) ឈ្មោះថា អសង្ខារបរិនិព្វាយី(២) ឈ្មោះថា សសង្ខារបរិនិព្វាយី(៣) ឈ្មោះថា ឧទ្ធំសោតអកនិដ្ឋគាមី(៤) ។ ម្នាលភិក្ខុទាំងឡាយ នេះបុគ្គលទី ៧ ដែលគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលនូវអាគន្តុកទាន ដែលគេនាំមកដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលីកម្ម ដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៧ ពួកនេះឯង ដែលគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលនូវអាគន្តុកទាន ដែលគេនាំមកដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលីកម្ម ដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

(១៧) ម្នាលភិក្ខុទាំងឡាយ បុគ្គល ៧ ពួកនេះ គួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

---

១ - បុគ្គលណា កន្លងនូវពាក់កណ្ដាលអាយុ ហើយដល់នូវអរហត្តក្នុងសុទ្ធាវាសនោះ បុគ្គលនោះឈ្មោះថា ឧបហច្ចបរិនិព្វាយី ។

២ - បណ្ដាបុគ្គលទាំងនោះ បុគ្គលណាបានញុំាងកិលេសឲ្យអស់ទៅដោយមិនមានសេចក្ដីព្យាយាម បុគ្គលនោះឈ្មោះថា អសង្ខារបរិនិព្វាយី ។ ៣ - បុគ្គលណាញុំាងកិលេសឲ្យអស់ទៅដោយសេចក្ដីព្យាយាម បុគ្គលនោះឈ្មោះថា សសង្ខារបរិនិព្វាយី ។ ៤ - បុគ្គលណាកើតក្នុងសុទ្ធាវាសទាំង ៤ ខាងក្រោមណាមួយ ហើយច្យុតចាកសុទ្ធាវាសនោះទៅកើតក្នុងអកនិដ្ឋភពតាមលំដាប់ហើយដល់នូវអរហត្ត បុគ្គលនោះឈ្មោះថា ឧទ្ធំសោតអកនិដ្ឋគាមី ។ អដ្ឋកថា ។

កតមេ សត្ត ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សព្វសង្ខារេសុ ទុក្ខានុបស្សី វិហរតិ ។ បេ ។ សព្វេសុ ធម្មេសុ អនត្តានុបស្សី វិហរតិ និព្វានេ សុខានុបស្សី វិហរតិ សុខសញ្ញី សុខប្បដិសំវេទី សតតំ សមិតំ អព្វោកិណ្ណំ ចេតសា អធិមុច្ចមានោ បញ្ញាយ បរិយោគាហមានោ ។ សោ អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អយំ ភិក្ខវេ បឋមោ បុគ្គលោ អាហុនេយ្យោ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ និព្វានេ សុខានុបស្សី វិហរតិ សុខសញ្ញី សុខប្បដិសំវេទី សតតំ សមិតំ អព្វោកិណ្ណំ ចេតសា អធិមុច្ចមានោ បញ្ញាយ បរិយោគាហមានោ ។ តស្ស អបុព្វំ អចរិមំ អាសវបរិយាទានញ្ច ហោតិ ជីវិតបរិយាទានញ្ច ។ អយំ ភិក្ខវេ ទុតិយោ បុគ្គលោ អាហុនេយ្យោ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ

៧ ពួកតើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញថា ទុក្ខក្នុងសង្ខារទាំងពួង ។បេ។ ពិចារណាឃើញថា អនត្តាក្នុងធម៌ទាំងពួង ពិចារណាឃើញថា សុខ មានសេចក្ដីសំគាល់ថា សុខ ដឹងច្បាស់ថា សុខក្នុងព្រះនិព្វាន ហើយកំណត់ដោយចិត្ត ស្ទង់មើលដោយបញ្ញា រឿយៗមិនដាច់ មិនឲ្យប្រែឡំគ្នា ។ បុគ្គលនោះបានធ្វើឲ្យជាក់ច្បាស់សម្រេច ។បេ។ ព្រោះអស់អាសវៈទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះបុគ្គលទី ១ ដែលគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញថាសុខ មានសេចក្ដីសំគាល់ថាសុខ ដឹងច្បាស់ថាសុខក្នុងព្រះនិព្វាន ហើយកំណត់ដោយចិត្ត ស្ទង់មើលដោយបញ្ញា រឿយៗ មិនដាច់ មិនឲ្យប្រែឡំគ្នា ។ ការអស់ទៅនៃអាសវៈ នឹងការអស់ទៅនៃជីវិត របស់បុគ្គលនោះដំណាលគ្នាតែម្ដង ។ ម្នាលភិក្ខុទាំងឡាយ នេះបុគ្គលទី ២ ដែលគួរទទួលនូវចតុ-ប្បច្ច័យ ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ

និព្វានេ សុខានុបស្សី វិហរតិ សុខសញ្ញី សុខប្បដិសំវេទី សតតំ សមិតំ អព្វោកិណ្ណំ ចេតសា អធិមុច្ចមានោ បញ្ញាយ បរិយោគាហមានោ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អន្តរាបរិនិព្វាយី ហោតិ ។ បេ ។ ឧបហច្ចបរិនិព្វាយី ហោតិ អសង្ខារបរិនិព្វាយី ហោតិ សសង្ខារបរិនិព្វាយី ហោតិ ឧទ្ធំសោតោ ហោតិ អកនិដ្ឋគាមី ។ អយំ ភិក្ខវេ សត្តមោ បុគ្គលោ អាហុនេយ្យោ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ ឥមេ ខោ ភិក្ខវេ សត្ត បុគ្គលា អាហុនេយ្យា ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

(១៨) សត្តិមានិ ភិក្ខវេ និទ្ទសវត្ថូនិ ។ កតមានិ សត្ត ។ ឥធ ភិក្ខវេ ភិក្ខុ សិក្ខាសមាទានេ តិព្វច្ឆន្ទោ ហោតិ អាយតឹ ច សិក្ខាសមាទានេ អវិគតប្បេមោ(១) ធម្មនិសន្តិយា តិព្វច្ឆន្ទោ ហោតិ

១ ឱ. ម. អវិគតបេមោ ។

ពិចារណាឃើញថាសុខ មានសេចក្តីសំគាល់ថាសុខ ដឹងច្បាស់ថាសុខ ក្នុងព្រះនិព្វាន ហើយកំណត់ដោយចិត្ត ស្ទង់មើលដោយបញ្ញា រឿយៗមិនដាច់ មិនឲ្យប្រឡំគ្នា ។ បុគ្គលនោះឈ្មោះថាអន្តរាបរិនិព្វាយី ព្រោះអស់សញ្ញោជនៈជាចំណែកខាងក្រោម៥ ។បេ។ ឈ្មោះថាឧបហច្ចបរិនិព្វាយី ឈ្មោះថាអសង្ខារបរិនិព្វាយី ឈ្មោះថាសសង្ខារបរិនិព្វាយី ឈ្មោះថាឧទ្ធំសោតអកនិដ្ឋគាមី ។ ម្នាលភិក្ខុទាំងឡាយ នេះបុគ្គលទី៧ដែលគួរទទួលចតុប្បច្ច័យ ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល៧ពួកនេះឯង គួរទទួលចតុប្បច្ច័យ ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

(១៨) ម្នាលភិក្ខុទាំងឡាយ និទ្ទស(១) វត្ថុទាំងឡាយ នេះមាន ៧យ៉ាង ។ ៧យ៉ាងតើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្លៀវក្លា ក្នុងការសមាទាននូវសិក្ខា តទៅក្នុងកាលខាងមុខ ក៏នៅតែមានសេចក្តីស្រឡាញ់ ក្នុងការសមាទាននូវសិក្ខា ១ ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្លៀវក្លា ក្នុងការពិចារណានូវធម៌

---

១ ហេតុនៃភិក្ខុមិនមានអាយុ ១០ ឆ្នាំ ។ តែពាក្យនេះលោកសំដៅយកព្រះខីណាស្រព ព្រោះលោក សូម្បីបរិនិព្វានពីអាយុ ១០ ឆ្នាំ (ជាដើម) ក៏លែងមានអាយុ ១០ ឆ្នាំតទៅខាងមុខ កុំថាតែ១០ឆ្នាំ សូម្បីតែថយចុះមក៩ឆ្នាំរហូតដល់១ថ្ងៃ ឬ១យាមក៏មិនមាន ព្រោះលោកមិនចាប់បដិសន្ធិតទៅទៀត ។ អដ្ឋកថា ។

អាយតិំ ច ធម្មនិសន្តិយា អវិគតប្យេមោ ឥច្ឆាវិនយេ តិព្វច្ឆន្ទោ ហោតិ អាយតិំ ច ឥច្ឆាវិនយេ អវិគតប្យេមោ បដិសល្លានេ តិព្វច្ឆន្ទោ ហោតិ អាយតិំ ច បដិសល្លានេ អវិគតប្យេមោ វីរិយារម្ភេ តិព្វច្ឆន្ទោ ហោតិ អាយតិំ ច វីរិយារម្ភេ អវិគតប្យេមោ សតិនេបក្កេ តិព្វច្ឆន្ទោ ហោតិ អាយតិំ ច សតិនេបក្កេ អវិគតប្យេមោ ទិដ្ឋិប្បដិវេធេ តិព្វច្ឆន្ទោ ហោតិ អាយតិំ ច ទិដ្ឋិប្បដិវេធេ អវិគតប្យេមោ ។ ឥមានិ ខោ ភិក្ខវេ សត្ត និទ្ទសវត្ថូនីតិ ។

អនុសយវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

ទ្វេ អនុសយា កុលំ(១) បុគ្គលំ ឧទកូបមំ
អនិច្ចា(២) ទុក្ខា អនត្តា ច និព្វានំ និទ្ទសវត្ថូនីតិ ។

---

១ ឱ. កុសលំ ។ ២ ប. បញ្ចមំ អនិច្ចា ។

តទៅក្នុងកាលខាងមុខ ក៏នៅតែមានសេចក្តីស្រឡាញ់ ក្នុងការពិចារណានូវធម៌ ១ ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្រៀវក្លា ក្នុងការកំចាត់បង់នូវឥច្ឆា គឺតណ្ហា តទៅក្នុងកាលខាងមុខ ក៏នៅតែមានសេចក្តីស្រឡាញ់ ក្នុងការកំចាត់បង់នូវឥច្ឆា គឺតណ្ហា ១ ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្រៀវក្លា ក្នុងការពួនសម្ងំ តទៅក្នុងកាលខាងមុខ ក៏នៅតែមានសេចក្តីស្រឡាញ់ក្នុងការពួនសម្ងំ ១ ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្រៀវក្លាក្នុងការប្រារព្ធព្យាយាម តទៅក្នុងកាលខាងមុខ ក៏នៅតែមានសេចក្តីស្រឡាញ់ ក្នុងការប្រារព្ធព្យាយាម ១ ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្រៀវក្លា ក្នុងការតាំងស្មារតី នឹងភាពជាអ្នកមានប្រាជ្ញាចាស់ក្លា តទៅក្នុងកាលខាងមុខ ក៏នៅតែមានសេចក្តីស្រឡាញ់ ក្នុងការតាំងស្មារតី នឹងភាពជាអ្នកមានប្រាជ្ញាចាស់ក្លា ១ ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្រៀវក្លា ក្នុងការចាក់ធ្លុះដោយទិដ្ឋិ តទៅក្នុងកាលខាងមុខ ក៏នៅតែមានសេចក្តីស្រឡាញ់ ក្នុងការចាក់ធ្លុះដោយទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងនិទ្ទេសវត្ថុ ៧ យ៉ាង ។

ចប់ អនុសយវគ្គទី ២ ។

## ឧទ្ទាននៃអនុសយវគ្គនោះគឺ

និយាយពីអនុស័យពីរលើក ត្រកូល ១ បុគ្គលគួរបូជា ១ បុគ្គលប្រៀបដូចអ្នកមុជទឹក ១ បុគ្គលអ្នកពិចារណាឃើញក្នុងសង្ខារថា មិនទៀង ១ ជាទុក្ខ ១ ជាអនត្តា ១ ព្រះនិព្វាន ១ និទ្ទេសវត្ថុ ១ ។

# វជ្ជិវគ្គោ

(១៩) ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ សារន្ទទេ ចេតិយេ ។ អថខោ សម្ពហុលា លិច្ឆវី យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នេ ខោ តេ លិច្ឆវី ភគវា ឯតទវោច សត្ត វោ លិច្ឆវី អបរិហានិយេ ធម្មេ ទេសេស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ លិច្ឆវី ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមេ ច លិច្ឆវី សត្ត អបរិហានិយា ធម្មា ។ យាវកីវញ្ច លិច្ឆវី វជ្ជី អភិណ្ហសន្និបាតា ភវិស្សន្តិ សន្និបាតពហុលា វុឌ្ឍិយេវ លិច្ឆវី វជ្ជីនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច លិច្ឆវី វជ្ជី សមគ្គា សន្និបតិស្សន្តិ សមគ្គា វុដ្ឋហិស្សន្តិ សមគ្គា វជ្ជីករណីយានិ ករិស្សន្តិ

# វជ្ជីវគ្គ

(១៩) សម័យមួយ ព្រះដ៏មានព្រះភាគគង់ក្នុងសារន្ទទចេតិយ ជិតក្រុងវេសាលី ។ គ្រានោះឯង ពួកស្តេចលិច្ឆវីជាច្រើន ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះពួកស្តេចលិច្ឆវីទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះថា បពិត្រស្តេចលិច្ឆវីទាំងឡាយ តថាគតនឹងសំដែងនូវអបរិហានិយធម៌ ៧ យ៉ាង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ប្រុងស្តាប់ភាសិតនោះ ចូរប្រុងធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសំដែងប្រាប់ ។ ពួកស្តេចលិច្ឆវីទាំងនោះ បានទទួលស្តាប់ព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា បពិត្រស្តេចលិច្ឆវីទាំងឡាយ ចុះអបរិហានិយធម៌ ៧ យ៉ាង តើអ្វីខ្លះ ។ បពិត្រស្តេចលិច្ឆវីទាំងឡាយ បើពួកស្តេចក្នុងដែនវជ្ជី នឹងមានការប្រជុំគ្នារឿយ ៗ មានការប្រជុំគ្នាដោយច្រើន អស់កាលត្រឹមណា បពិត្រស្តេចលិច្ឆវីទាំងឡាយ សេចក្តីចំរើនតែងមានប្រាកដដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ១ ។ បពិត្រស្តេចលិច្ឆវីទាំងឡាយ ពួកស្តេចក្នុងដែនវជ្ជី ព្រមព្រៀងគ្នាប្រជុំ ព្រមព្រៀងគ្នាលើកលែងប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ចក្នុងដែនវជ្ជី អស់កាលត្រឹមណា

វុឌ្ឍិយេវ ភិក្ខវេ វជ្ជីនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ វជ្ជី អប្បញ្ញត្តំ ន បញ្ញាបេស្សន្តិ បញ្ញត្តំ ន សមុច្ឆិន្ទិស្សន្តិ យថាបញ្ញត្តេ ពោរាណេ វជ្ជិធម្មេ សមាទាយ វត្តិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ វជ្ជីនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ វជ្ជី យេ តេ វជ្ជីនំ វជ្ជិមហល្លកា តេ សក្ករិស្សន្តិ គរុករិស្សន្តិ មានេស្សន្តិ បូជេស្សន្តិ តេសញ្ច សោតព្វំ មញ្ញិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ វជ្ជីនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ វជ្ជី យា តា កុលិត្ថិយោ កុលកុមារិយោ តា ន ឱក្កស្ស បសយ្ហ វាសេស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ វជ្ជីនំ បាដិកង្ខា នោ បរិហានិ ។

បពិត្រស្តេចលិច្ឆវីទាំងឡាយ សេចក្តីចំរើន តែងមានប្រាកដ ដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។ បពិត្រស្តេចលិច្ឆវីទាំងឡាយ ពួកស្តេចក្នុងដែនវជ្ជី មិនបញ្ញត្តច្បាប់ ( ដែលពួកស្តេចពីដើម ) មិនបានបញ្ញត្ត មិនដកច្បាប់ ដែលបានបញ្ញត្តរួចហើយ កាន់តាម ប្រព្រឹត្តតាមច្បាប់ ក្នុងដែនវជ្ជីអំពីបុរាណ ដែលបានបញ្ញត្តរួចហើយយ៉ាងណា អស់កាលត្រឹមណា បពិត្រស្តេចលិច្ឆវីទាំងឡាយ សេចក្តីចំរើន តែងមានប្រាកដ ដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ ) ១ ។ បពិត្រស្តេចលិច្ឆវីទាំងឡាយ ពួកស្តេចក្នុងដែនវជ្ជី ធ្វើសក្ការៈគោរព រាប់អាន បូជា ពួកស្តេចក្នុងដែនវជ្ជី ដែលមានព្រះជន្មច្រើនជាងស្តេចក្នុងដែនវជ្ជីទាំងឡាយ ទាំងសំគាល់ពាក្យដែលគួរស្តាប់ របស់ពួកស្តេចក្នុងដែនវជ្ជី ដែលមានព្រះជន្មច្រើនជាងនោះ អស់កាលត្រឹមណា បពិត្រស្តេចលិច្ឆវីទាំងឡាយ សេចក្តីចំរើន តែងមានប្រាកដ ដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ ) ១ ។ បពិត្រស្តេចលិច្ឆវីទាំងឡាយ ពួកស្តេចក្នុងដែនវជ្ជី មិនកំហែងបង្ខំនូវពួកស្ត្រី ក្នុងត្រកូល ពួកកុមារី ក្នុងត្រកូលឲ្យនៅរួម អស់កាលត្រឹមណា បពិត្រស្តេចលិច្ឆវីទាំងឡាយ សេចក្តីចំរើន តែងមានប្រាកដដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណា )១ ។

យាវកីវញ្ច លិច្ឆវី វជ្ជី យានិ តានិ វជ្ជីនំ វជ្ជិចេតិយានិ អព្ភន្តរានិ ចេវ ពាហិរានិ ច តានិ សក្ករិស្សន្តិ គរុករិស្សន្តិ មានេស្សន្តិ បូជេស្សន្តិ តេសញ្ច ទិន្នបុព្វំ កតបុព្វំ ធម្មិកំ ពលឹ នោ បរិហាបេស្សន្តិ វុឌ្ឍិយេវ លិច្ឆវី វជ្ជីនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច លិច្ឆវី វជ្ជីនំ អរហន្តេសុ ធម្មិការក្ខាវរណគុត្តិ សុសំវិហិតា ភវិស្សតិ កិន្តិ អនាគតា ច អរហន្តោ វិជិតំ អាគច្ឆេយ្យុំ អាគតា ច អរហន្តោ វិជិតេ ផាសុំ វិហរេយ្យុន្តិ វុឌ្ឍិយេវ លិច្ឆវី វជ្ជីនំ បាដិកង្ខា នោ បរិហានិ ។

យាវកីវញ្ច លិច្ឆវី ឥមេ សត្ត អបរិហានិយា ធម្មា វជ្ជីសុ ឋស្សន្តិ ឥមេសុ ច សត្តសុ អបរិហានិយេសុ ធម្មេសុ វជ្ជី សន្ទិស្សិស្សន្តិ វុឌ្ឍិយេវ លិច្ឆវី វជ្ជីនំ បាដិកង្ខា នោ បរិហានីតិ ។

បឋមបណ្ណាសក វជ្ជីវគ្គ

បពិត្រស្ដេចលិច្ឆវីទាំងឡាយ ពួកស្ដេចក្នុងដែនវជ្ជី តែងធ្វើសក្ការៈ គោរព រាប់អាន បូជា ចេតិយក្នុងដែនវជ្ជី របស់ពួកអ្នកដែនវជ្ជី ដែលជាខាងក្នុងនគរក្ដី ខាងក្រៅនគរក្ដី នឹងមិនធ្វើគ្រឿងបូជាប្រកបដោយធម៌ ដែលគេធ្លាប់ថ្វាយ ធ្លាប់ធ្វើដល់ចេតិយទាំងនោះ ឲ្យសាបសូន្យឡើយ អស់កាលត្រឹមណា បពិត្រស្ដេចលិច្ឆវីទាំងឡាយ សេចក្ដីចំរើន តែងមានប្រាកដដល់ពួកស្ដេចក្នុងដែនវជ្ជី សេចក្ដីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ១ ។ បពិត្រស្ដេចលិច្ឆវីទាំងឡាយ ពួកស្ដេចក្នុងដែនវជ្ជី បានចាត់ចែងត្រឹមត្រូវនូវការរក្សា ការពារនឹងការគ្រប់គ្រងប្រកបដោយធម៌ក្នុងពួកព្រះអរហន្តដោយបំណងថា ធ្វើម្ដេចហ្ន៎! ព្រះអរហន្តទាំងឡាយ ដែលមិនទាន់មក ក៏សូមឲ្យមកកាន់ដែនរបស់យើង ព្រះអរហន្តទាំងឡាយ ដែលមកស្រាប់ហើយ ក៏សូមឲ្យគង់នៅសប្បាយក្នុងដែនរបស់យើង អស់កាលត្រឹមណា បពិត្រស្ដេចលិច្ឆវីទាំងឡាយ សេចក្ដីចំរើន តែងមានប្រាកដដល់ពួកស្ដេចក្នុងដែនវជ្ជី សេចក្ដីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ១ ។ បពិត្រស្ដេចលិច្ឆវីទាំងឡាយ នេះអបរិហានិយធម៌ ៧ យ៉ាង រមែងតាំងនៅក្នុងពួកស្ដេចក្នុងដែនវជ្ជី ឬថា ពួកស្ដេចក្នុងដែនវជ្ជី ប្រតិបត្តិក្នុងអបរិហានិយធម៌ទាំង ៧ នេះ អស់កាលត្រឹមណា បពិត្រស្ដេចលិច្ឆវីទាំងឡាយ សេចក្ដីចំរើន តែងមានប្រាកដដល់ពួកស្ដេចក្នុងដែនវជ្ជី សេចក្ដីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ១ ។

(២០) ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ តេន ខោ បន សមយេន រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ វជ្ជី អភិយាតុកាមោ ហោតិ ។ សោ ឯវមាហ អហំ ហិមេ វជ្ជី ឯវំមហិទ្ធិកេ ឯវំមហានុភាវេ ឧច្ឆេជ្ជិស្សាមិ វជ្ជី វិនាសេស្សាមិ វជ្ជី អនយព្យសនំ អាបាទេស្សាមីតិ(១) ។ អថខោ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ វស្សការំ ព្រាហ្មណំ មគធមហាមត្តំ អាមន្តេសិ ឯហិ ត្វំ ព្រាហ្មណ យេន ភគវា តេនុបសង្កម ឧបសង្កមិត្វា មម វចនេន ភគវតោ បាទេ សិរសា វន្ទ(២) អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆ រាជា ភន្តេ មាគធោ អជាតសត្តុ វេទេហិបុត្តោ ភគវតោ បាទេ សិរសា វន្ទតិ

១ ឱ. ម. អាបាទេស្សាមិ វជ្ជីតិ ។ ២ ម. វន្ទាហិ ។

[ ២០ ] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់លើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះរាជាជាធំ ក្នុងដែនមគធៈព្រះនាមអជាតសត្តុវេទេហិបុត្រ មានបំណងនឹងយាត្រាទៅជាន់យកពួកស្តេចក្នុងដែនវជ្ជី ។ ព្រះអង្គទ្រង់មានព្រះរាជឱង្ការយ៉ាងនេះថា អញនឹងផ្តាច់ផ្តិលពួកអ្នកដែនវជ្ជីទាំងនេះ ដែលមានឫទ្ធិធំយ៉ាងនេះ មានអានុភាពធំយ៉ាងនេះ អញ (មានបំណងនឹងយាត្រាទៅជិះជាន់) ពួកស្តេចក្នុងដែនវជ្ជី នឹងបំផ្លាញពួកស្តេចក្នុងដែនវជ្ជី នឹងធ្វើពួកស្តេចក្នុងដែនវជ្ជី ឲ្យដល់នូវសេចក្តីវិនាស ។ គ្រានោះ ព្រះបាទអជាតសត្តុមាគធរាជ វេទេហិបុត្រ ត្រាស់ហៅវស្សការព្រាហ្មណ៍ ដែលជាមហាមាត្យក្នុងដែនមគធៈថា ម្នាលព្រាហ្មណ៍ ចូរអ្នកមកនេះ ចូរអ្នកទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ចូរថ្វាយបង្គំព្រះបាទាព្រះដ៏មានព្រះភាគដោយត្បូងតាមពាក្យរបស់ខ្ញុំ រួចទូលសួរអំពីសេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងរហ័សដោយកំឡាំងកាយ នឹងការនៅសប្បាយគ្រប់ឥរិយាបថដោយពាក្យថា បពិត្រព្រះអង្គដ៏ចំរើន ព្រះបាទអជាតសត្តុវេទេហិបុត្រមាគធរាជ ថ្វាយបង្គំព្រះបាទាព្រះដ៏មានព្រះភាគ ដោយព្រះសិរ្ស

អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតីតិ ឯវញ្ច វទេហិ រាជា ភន្តេ មាគធោ អជាតសត្តុ វេទេហិបុត្តោ វជ្ជី អភិយាតុកាមោ ។ សោ ឯវមាហ អហំ ហិមេ វជ្ជី ឯវំមហិទ្ធិកេ ឯវំមហានុភាវេ ឧច្ឆេជ្ជិស្សាមិ វជ្ជី វិនាសេស្សាមិ វជ្ជី អនយព្យសនំ អាបាទេស្សាមីតិ ។ យថា ភគវា ព្យាករោតិ តំ សាធុកំ ឧគ្គហេត្វា មម អារោចេយ្យាសិ ។ ន ហិ តថាគតា វិតថំ ភណន្តីតិ ។ ឯវំ ភោតិ ខោ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ រញ្ញោ មាគធស្ស អជាតសត្តុស្ស វេទេហិបុត្តស្ស បដិស្សុណិត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារា-ណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ

ហើយផ្តាំមកក្រាបបង្គំទូលសួរ អំពីសេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងរហ័ស ដោយកំឡាំងកាយ និងការនៅសប្បាយ មួយទៀត ចូរក្រាបទូលយ៉ាងនេះទៀតថា បពិត្រព្រះអង្គដ៏ចំរើន ព្រះបាទអជាតសត្តុវេទេហិបុត្រមាគធរាជ មានបំណងនឹងយាត្រាទៅជិះជាន់យកពួកអ្នកដែនវជ្ជី ។ ព្រះអង្គទ្រង់ត្រាស់យ៉ាងនេះថា អញនឹងផ្តាច់បង់នូវពួកស្តេចក្នុងដែនវជ្ជីទាំងនេះ ដែលមានឫទ្ធិធំយ៉ាងនេះ មានអានុភាពធំយ៉ាងនេះ ( អញមានបំណងនឹងយាត្រាទៅជិះជាន់ ) ពួកស្តេច ក្នុងដែនវជ្ជី នឹងបំផ្លាញពួកស្តេចក្នុងដែនវជ្ជី នឹងធ្វើពួកស្តេចក្នុងដែនវជ្ជី ឲ្យដល់នូវសេចក្តីវិនាស ។ ប៉ុន្តែបើព្រះដ៏មានព្រះភាគ ទ្រង់ព្យាករយ៉ាងណា ចូរអ្នកចាំពាក្យនោះឲ្យជាក់ច្បាស់ ហើយនាំមកប្រាប់ខ្ញុំវិញ ។ ព្រោះព្រះតថាគតទាំងឡាយ មិនដែលមានព្រះបន្ទូលខុសទេ ។ វស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ ក៏ទទួលព្រះរាជឱង្ការព្រះបាទអជាតសត្តុវេទេហិបុត្រមាគធរាជ ដោយពាក្យថា ព្រះករុណាថ្លៃវិសេស ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹករួចហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះវស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ អង្គុយក្នុងទីដ៏សមគួរហើយ

ភគវន្តំ ឯតទវោច រាជា ភោ គោតម មាគធោ អជាតសត្តុ វេទេហីបុត្តោ ភោតោ គោតមស្ស បាទេ សិរសា វន្ទតិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតិ(១) រាជា ភោ គោតម មាគធោ អជាតសត្តុ វេទេហីបុត្តោ វជ្ជី អភិយាតុកាមោ ។ សោ ឯវមាហ អហំ ហិមេ វជ្ជី ឯវំមហិទ្ធិកេ ឯវំមហានុភាវេ ឧច្ឆេជ្ជិស្សាមិ(២) វជ្ជី អនយព្យសនំ អាបាទេស្សាមីតិ ។

តេន ខោ បន សមយេន អាយស្មា អានន្ទោ ភគវតោ បិដ្ឋិតោ ឋិតោ ហោតិ ភគវន្តំ វីជមានោ ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ កិន្តិ តេ អានន្ទ សុតំ វជ្ជី អភិណ្ហសន្និបាតា សន្និបាតពហុលាតិ ។ សុតំ មេ តំ ភន្តេ វជ្ជី អភិណ្ហសន្និបាតា សន្និបាតពហុលាតី ។ យាវកីវញ្ច អានន្ទ វជ្ជី អភិណ្ហសន្និបាតា ភវិស្សន្តិ សន្និបាតពហុលា

---

១ ឱ. ឯត្ថន្តរេ ឯវញ្ច វទេតិ ។ ម. ឯវញ្ច វទេហីតិ ទិស្សតិ ។ ២ ឱ. ម. ឯត្ថន្តរេ វជ្ជី វិនាសិស្សាមីតិ ទិស្សតិ ។

បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ព្រះបាទអជាតសត្តុវេទេហិបុត្រ មាគធរាជ ក្រាបថ្វាយបង្គំព្រះបាទាព្រះគោតមដ៏ចំរើនដោយព្រះសិរ្សៈហើយឲ្យទូលសួរ អំពីសេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងរហ័ស ដោយព្រះកាយពល នឹងការនៅសប្បាយ បពិត្រព្រះគោតមដ៏ចំរើន ព្រះបាទអជាតសត្តុវេទេហិបុត្រ មាគធរាជ មានបំណងនឹងយាត្រាទៅជាន់យកពួកស្តេចក្នុងដែនវជ្ជី ។ ព្រះអង្គទ្រង់មានព្រះរាជឱង្ការយ៉ាងនេះថា អញនឹងផ្តាប់ផ្តិលពួកស្តេចដែនវជ្ជីទាំងនេះ ដែលមានឫទ្ធិធំយ៉ាងនេះ មានអានុភាពធំយ៉ាងនេះ នឹងធ្វើពួកស្តេចក្នុងដែនវជ្ជី ឲ្យដល់នូវសេចក្តីវិនាស ។

សម័យនោះឯង ព្រះអានន្ទដ៏មានអាយុ ឋិតនៅអំពីខាងក្រោយព្រះដ៏មានព្រះភាគ កំពុងបក់ថ្វាយព្រះដ៏មានព្រះភាគ ។ គ្រានោះព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកបានឮថា ពួកស្តេចក្នុងដែនវជ្ជី មានការប្រជុំគ្នារឿយ ៗ មានការប្រជុំគ្នាដោយច្រើន ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឮដំណឹងនោះថា ពួកស្តេចក្នុងដែនវជ្ជី មានការប្រជុំគ្នារឿយ ៗ មានការប្រជុំគ្នាដោយច្រើន ដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកស្តេចក្នុងដែនវជ្ជី នឹងមានការប្រជុំគ្នារឿយ ៗ មានការប្រជុំគ្នាដោយច្រើនអស់កាលត្រឹមណា

វុឌ្ឍិយេវ អានន្ទ វជ្ជីនំ បាដិកង្ខា នោ បរិហានិ ។ កិន្តិ តេ អានន្ទ សុតំ វជ្ជី សមគ្គា សន្និបតន្តិ សមគ្គា វុដ្ឋហន្តិ សមគ្គា វជ្ជី-ករណីយានិ ករោន្តីតិ ។ សុតំ មេតំ ភន្តេ វជ្ជី សមគ្គា សន្និបតន្តិ សមគ្គា វុដ្ឋហន្តិ សមគ្គា វជ្ជីករណីយានិ ករោន្តីតិ ។ យាវកីវញ្ច អានន្ទ វជ្ជី សមគ្គា សន្និបតិ-ស្សន្តិ សមគ្គា វុដ្ឋហិស្សន្តិ សមគ្គា វជ្ជីករណីយានិ ករិស្សន្តិ វុឌ្ឍិយេវ អានន្ទ វជ្ជីនំ បាដិកង្ខា នោ បរិ-ហានិ ។ កិន្តិ តេ អានន្ទ សុតំ វជ្ជី អបញ្ញត្តំ ន បញ្ញាបេន្តិ បញ្ញត្តំ ន សមុច្ឆិន្ទន្តិ យថាបញ្ញត្តេ បោរាណេ វជ្ជីធម្មេ សមាទាយ វត្តន្តីតិ ។ សុតំ មេតំ ភន្តេ វជ្ជី អបញ្ញត្តំ ន បញ្ញាបេន្តិ បញ្ញត្តំ ន សមុច្ឆិន្ទន្តិ

ម្នាលអានន្ទ សេចក្ដីចំរើន តែងមានប្រាកដ ដល់ពួកស្ដេចក្នុងដែនវជ្ជី សេចក្ដីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកស្ដេចក្នុងដែនវជ្ជី ព្រមព្រៀងគ្នាប្រជុំ ព្រមព្រៀងគ្នាលើកលែងប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ច ក្នុងដែនវជ្ជីដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឮដំណឹងនោះថា ពួកស្ដេច ក្នុងដែនវជ្ជី ព្រមព្រៀងគ្នាប្រជុំ ព្រមព្រៀងគ្នាលើកលែងប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ច ក្នុងដែនវជ្ជីដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកស្ដេចក្នុងដែនវជ្ជីនឹងព្រមព្រៀងគ្នាប្រជុំ ព្រមព្រៀងគ្នាលើកលែងប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ច ក្នុងដែនវជ្ជី អស់កាលត្រឹមណា ម្នាលអានន្ទ សេចក្ដីចំរើន តែងមានប្រាកដ ដល់ពួកស្ដេចក្នុងដែនវជ្ជី សេចក្ដីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកស្ដេចក្នុងដែនវជ្ជី មិនបញ្ញត្តច្បាប់ (ដែលពួកស្ដេចពីដើម) មិនបានបញ្ញត្ត មិនដកច្បាប់ដែលបានបញ្ញត្តរួចហើយ កាន់តាម ប្រព្រឹត្តតាមច្បាប់ក្នុងដែនវជ្ជី អំពីបុរាណដែលបានបញ្ញត្តរួចហើយយ៉ាងណា ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឮដំណឹងនោះថា ពួកស្ដេចក្នុងដែនវជ្ជី មិនបញ្ញត្តច្បាប់ (ដែលពួកស្ដេចពីដើម) មិនបានបញ្ញត្ត មិនដកច្បាប់ដែលបានបញ្ញត្តរួចហើយ

យថាបញ្ញត្តេ បោរាណេ វជ្ជីធម្មេ សមាទាយ
វត្តន្តីតិ ។ យាវកីវញ្ច អានន្ទ វជ្ជី អប្បញ្ញត្តំ
ន បញ្ញាបេស្សន្តិ បញ្ញត្តំ ន សមុច្ឆិន្ទិស្សន្តិ
យថាបញ្ញត្តេ បោរាណេ វជ្ជីធម្មេ សមាទាយ
វត្តិស្សន្តិ វុឌ្ឍិយេវ អានន្ទ វជ្ជីនំ បាដិកង្ខា នោ
បរិហានិ ។ កិន្តិ តេ អានន្ទ សុតំ វជ្ជី យេ តេ
វជ្ជីនំ វជ្ជីមហល្លកា តេ សក្ករោន្តិ គរុករោន្តិ
មានេន្តិ បូជេន្តិ តេសញ្ច សោតព្វំ មញ្ញន្តីតិ ។
សុតំ មេ តំ ភន្តេ វជ្ជី យេ តេ វជ្ជីនំ វជ្ជី-
មហល្លកា តេ សក្ករោន្តិ គរុករោន្តិ មានេន្តិ
បូជេន្តិ តេសញ្ច សោតព្វំ មញ្ញន្តីតិ ។

## សុត្តន្តបិដក អង្គុត្តរនិកាយ សត្តកនិបាត

កាន់តាម ប្រព្រឹត្តតាមច្បាប់ក្នុងដែនវជ្ជី អំពីបូរាណ ដែលបានបញ្ញត្តរួចហើយ យ៉ាងណាដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកស្តេច ក្នុងដែនវជ្ជី នឹងមិនបញ្ញត្តច្បាប់ (ដែលពួកស្តេចពីដើម) មិនបានបញ្ញត្តហើយ មិនដកច្បាប់ ដែលបានបញ្ញត្តរួចហើយ កាន់តាម ប្រព្រឹត្តតាមច្បាប់ក្នុងដែនវជ្ជី អំពីបូរាណដែលបានបញ្ញត្តរួចហើយយ៉ាងណា អស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចំរើន តែងមានប្រាកដដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកស្តេចក្នុងដែនវជ្ជី តែងធ្វើសក្ការៈ គោរព កប់អាន បូជាពួកស្តេចក្នុងដែនវជ្ជី ដែលមានព្រះជន្មច្រើនជាងវជ្ជីក្សត្រិយ៍ទាំងឡាយ ទាំងសំគាល់ពាក្យ ដែលគួរស្តាប់របស់ពួកស្តេច ក្នុងដែនវជ្ជី ដែលមានព្រះជន្មច្រើនទាំងនោះដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឮដំណឹងនោះថា ពួកស្តេចក្នុងដែនវជ្ជី តែងធ្វើសក្ការៈ គោរព កប់អាន បូជាពួកស្តេចក្នុងដែនវជ្ជី ដែលមានព្រះជន្មច្រើនជាងវជ្ជីក្សត្រិយ៍ទាំងឡាយ ទាំងសំគាល់ពាក្យ ដែលគួរស្តាប់របស់ពួកស្តេចក្នុងដែនវជ្ជី ដែលមានព្រះជន្មច្រើនទាំងនោះ ដូច្នេះដែរ ។

យាវកីវញ្ច អានន្ទ វជ្ជី យេ តេ វជ្ជីនំ វជ្ជិមហល្លកា តេ សក្ការិស្សន្តិ គរុការិស្សន្តិ មានេស្សន្តិ បូជេស្សន្តិ តេសញ្ច សោតព្វំ មញ្ញិស្សន្តិ វុឌ្ឍិយេវ អានន្ទ វជ្ជីនំ បាដិកង្ខា នោ បរិហានិ ។ កិន្តិ តេ អានន្ទ សុតំ វជ្ជី យា តា កុលិត្ថិយោ កុលកុមារិយោ តា ន ឱក្កស្ស បសយ្ហ វាសេន្តីតិ ។ សុតំ មេតំ ភន្តេ វជ្ជី យា តា កុលិត្ថិយោ កុលកុមារិយោ តា ន ឱក្កស្ស បសយ្ហ វាសេន្តីតិ ។ យាវកីវញ្ច អានន្ទ វជ្ជី យា តា កុលិត្ថិយោ កុលកុមារិយោ តា ន ឱក្កស្ស បសយ្ហ វាសេស្សន្តិ វុឌ្ឍិយេវ អានន្ទ វជ្ជីនំ បាដិកង្ខា នោ បរិហានិ ។ កិន្តិ តេ អានន្ទ សុតំ វជ្ជី យានិ តានិ វជ្ជីនំ វជ្ជិចេតិយានិ អព្ភន្តរានិ ចេវ ពាហិរានិ ច តានិ សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ តេសញ្ច ទិន្នបុព្វំ កតបុព្វំ ធម្មិកំ ពលឹ នោ បរិហាបេន្តីតិ ។

ម្នាលអានន្ទ បើពួកស្តេចក្នុងដែនវជ្ជី នឹងធ្វើសក្ការៈ គោរព រាប់អាន បូជា ពួកស្តេចក្នុងដែនវជ្ជី ដែលមានព្រះជន្មច្រើនជាងវជ្ជីក្សត្រិយ៍ទាំងឡាយ ទាំងសំគាល់ពាក្យ ដែលគួរស្តាប់របស់ពួកស្តេចក្នុងដែនវជ្ជី ដែលមានព្រះជន្មច្រើនទាំងនោះ អស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចំរើន តែងមានប្រាកដ ដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកស្តេចក្នុងដែនវជ្ជី មិនកំហែងបង្ខំពួកស្ត្រីក្នុងត្រកូល ពួកកុមារីក្នុងត្រកូល ឲ្យនៅរួមដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឮដំណឹងនោះថា ពួកស្តេចក្នុងដែនវជ្ជី មិនកំហែងបង្ខំពួកស្ត្រីក្នុងត្រកូល ពួកកុមារីក្នុងត្រកូល ឲ្យនៅរួមដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកស្តេចក្នុងដែនវជ្ជី មិនកំហែងបង្ខំពួកស្ត្រីក្នុងត្រកូល ពួកកុមារីក្នុងត្រកូល ឲ្យនៅរួម អស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចំរើន តែងមានប្រាកដ ដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកស្តេចក្នុងដែនវជ្ជី តែងធ្វើសក្ការៈ គោរព រាប់អាន បូជាចេតិយក្នុងដែនវជ្ជី របស់ពួកស្តេចក្នុងដែនវជ្ជី ដែលនៅខាងក្នុងនគរផង ខាងក្រៅនគរផង ទាំងមិនធ្វើគ្រឿងបូជាប្រកបដោយធម៌ ដែលគេធ្លាប់ថ្វាយ ធ្លាប់ធ្វើដល់ចេតិយទាំងនោះ ឲ្យសាបសូន្យទៅដូច្នេះដែរឬ ។

សុតំ មេ តំ ភន្តេ វជ្ជី យានិ តានិ វជ្ជីនំ វជ្ជិចេតិយានិ អព្ភន្តរានិ ចេវ ពាហិរានិ ច តានិ សក្ការេន្តិ គរុការេន្តិ មានេន្តិ បូជេន្តិ តេសញ្ច ទិន្នបុព្វំ កតបុព្វំ ធម្មិកំ ពលឹ នោ បរិហាបេន្តិ ។ យាវកីវញ្ច អានន្ទ វជ្ជី យានិ តានិ វជ្ជីនំ វជ្ជិចេតិយានិ អព្ភន្តរានិ ចេវ ពាហិរានិ ច តានិ សក្ការិស្សន្តិ គរុការិស្សន្តិ មានេស្សន្តិ បូជេស្សន្តិ តេសញ្ច ទិន្នបុព្វំ កតបុព្វំ ធម្មិកំ ពលឹ នោ បរិហាបេស្សន្តិ វុឌ្ឍិយេវ អានន្ទ វជ្ជីនំ បាដិកង្ខា នោ បរិហានិ ។ កិន្តិ តេ អានន្ទ សុតំ វជ្ជីនំ អរហន្តេសុ ធម្មិការក្ខាវរណគុត្តិ សុសំវិហិតា កិន្តិ អនាគតា ច អរហន្តោ វិជិតំ អាគច្ឆេយ្យុំ អាគតា ច អរហន្តោ វិជិតេ ផាសុំ វិហរេយ្យុន្តិ ។ សុតំ មេ តំ ភន្តេ

បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឮដំណឹងនោះថា ពួកស្តេចក្នុងដែនវជ្ជី តែងធ្វើសក្ការៈ គោរព រាប់អាន បូជាចេតិយក្នុងដែនវជ្ជី របស់ពួកអ្នកដែនវជ្ជី ដែលនៅខាងក្នុងនគរផង ខាងក្រៅនគរផង ទាំងមិនធ្វើគ្រឿងបូជាប្រកបដោយធម៌ ដែលគេធ្លាប់ថ្វាយ ធ្លាប់ធ្វើដល់ចេតិយទាំងនោះឲ្យសាបសូន្យទៅដូច្នេះវិញ ។ ម្នាលអានន្ទ បើពួកស្តេចក្នុងដែនវជ្ជី នឹងធ្វើសក្ការៈគោរព រាប់អាន បូជានូវចេតិយ ក្នុងដែនវជ្ជីរបស់ពួកអ្នកដែនវជ្ជី ដែលនៅខាងក្នុងនគរផង ខាងក្រៅនគរផង ទាំងមិនធ្វើគ្រឿងបូជាប្រកបដោយធម៌ ដែលគេធ្លាប់បូជា ធ្លាប់ធ្វើដល់ចេតិយទាំងនោះ ឲ្យសាបសូន្យទៅ អស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចំរើន តែងមានប្រាកដដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកស្តេចក្នុងដែនវជ្ជី បានចាត់ចែងត្រឹមត្រូវនូវការរក្សាការពារ និងការគ្រប់គ្រង ប្រកបដោយធម៌ក្នុងអរហន្តទាំងឡាយ ដោយបំណងថា ធ្វើម្តេចហ្ន៎ ព្រះអរហន្តទាំងឡាយដែលមិនទាន់មក ក៏សូមឲ្យមកកាន់ដែនរបស់យើង ព្រះអរហន្តទាំងឡាយ ដែលមកស្រាប់ហើយ ក៏សូមឲ្យគង់នៅសប្បាយ ក្នុងដែនរបស់យើងដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឮដំណឹងនោះថា

វជ្ជីនំ អរហន្តេសុ ធម្មិការក្ខាវរណគុត្តិ សុសំវិហិតា កិន្តិ អនាគតា ច អរហន្តោ វិជិតំ អាគច្ឆេយ្យុំ អាគតា ច អរហន្តោ វិជិតេ ផាសុំ វិហរេយ្យុន្តិ ។ យាវកីវញ្ច អានន្ទ វជ្ជីនំ អរហន្តេសុ ធម្មិការក្ខាវរណគុត្តិ សុសំវិហិតា ភវិស្សន្តិ កិន្តិ អនាគតា ច អរហន្តោ វិជិតំ អាគច្ឆេយ្យុំ អាគតា ច អរហន្តោ វិជិតេ ផាសុំ វិហរេយ្យុន្តិ វុឌ្ឍិយេវ អានន្ទ វជ្ជីនំ បាដិកង្ខា នោ បរិហានីតិ ។

អថខោ ភគវា វស្សការំ ព្រាហ្មណំ មគធមហាមត្តំ អាមន្តេសិ ឯកមិទាហំ ព្រាហ្មណ សមយំ វេសាលិយំ វិហរាមិ សារន្ទទេ(១) ចេតិយេ តត្រាហំ វជ្ជីនំ ឥមេ សត្ត អបរិហានិយេ ធម្មេ ទេសេសិំ(២) ។

---

១ ម. អានន្ទកេ ។ ២ ឱ. ម. ទេសេសឹ ។

ពួកស្តេចក្នុងដែនវជ្ជី បានចាត់ចែងត្រឹមត្រូវនូវការរក្សា ការពារ នឹងការគ្រប់គ្រងប្រកបដោយធម៌ ក្នុងព្រះអរហន្តទាំងឡាយ ដោយបំណងថា ធ្វើម្តេចហ្ន៎ ព្រះអរហន្តទាំងឡាយ ដែលមិនទាន់មក ក៏សូមឲ្យមកកាន់ដែនរបស់យើង ព្រះអរហន្តទាំងឡាយ ដែលមកស្រាប់ហើយ ក៏សូមឲ្យគង់នៅសប្បាយ ក្នុងដែនរបស់យើង ដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកស្តេចក្នុងដែនវជ្ជី នឹងបានចាត់ចែងត្រឹមត្រូវនូវការរក្សា ការពារ នឹងការគ្រប់គ្រង ប្រកបដោយធម៌ ក្នុងព្រះអរហន្តទាំងឡាយ ដោយបំណងថា ធ្វើម្តេចហ្ន៎ ព្រះអរហន្តទាំងឡាយ ដែលមិនទាន់មក ក៏សូមឲ្យមកកាន់ដែនរបស់យើង ព្រះអរហន្តទាំងឡាយ ដែលមកស្រាប់ហើយ ក៏សូមឲ្យគង់នៅសប្បាយ ក្នុងដែនរបស់យើង អស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចំរើន តែងមានប្រាកដ ដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅវស្សការព្រាហ្មណ៍ ជាមហាមាត្យ ក្នុងដែនមគធៈថា ម្នាលព្រាហ្មណ៍ សម័យមួយ តថាគត គង់នៅ ក្នុងសារន្ទទចេតិយ ទៀបក្រុងវេសាលី តថាគត បានសំដែងអបរិហានិយធម៌ទាំង ៧ ប្រការ នេះ ដល់ពួកស្តេច ក្នុងដែនវជ្ជី ក្នុងសារន្ទទចេតិយនោះឯង ។

យាវកីវញ្ច ព្រាហ្មណ ឥមេ សត្ត អបរិហានិយា ធម្មា វជ្ជីសុ ឋស្សន្តិ(១) ឥមេសុ ច សត្តសុ អបរិហានិយេសុ ធម្មេសុ វជ្ជី សន្ទិស្សិស្សន្តិ(២) វុឌ្ឍិយេវ ព្រាហ្មណ វជ្ជីនំ បាដិកង្ខា នោ បរិហានីតិ(៣) ។ ឯកមេកេនបិ ភោ គោតម អបរិហានិយេន ធម្មេន សមន្នាគតានំ វជ្ជីនំ វុឌ្ឍិយេវ បាដិកង្ខា នោ បរិហានិ កោ បន វាទោ សត្តហិ អបរិហានិយេហិ ធម្មេហិ ។ អករណីយា ច ភោ គោតម វជ្ជី រញ្ញា មាគធេន អជាតសត្តុនា វេទេហិបុត្តេន យទិទំ យុទ្ធស្ស អញ្ញត្រ ឧបលាបនាយ អញ្ញត្រ មិថុភេទា ។ ហន្ទ ច ទានិ មយំ ភោ គោតម គច្ឆាម ពហុកិច្ចា មយំ ពហុករណីយាតិ ។ យស្សទានិ ត្វំ ព្រាហ្មណ កាលំ មញ្ញសីតិ ។ អថខោ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា បក្កាមីតិ ។

១ ម. វត្តិស្សន្តិ ។ ២ ឱ. ម. សន្ទិស្សន្តិ ។ ៣ ឱ. ឥតោ បរំ ឯវំ វុត្តេ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ ភគវន្តំ ឯតទវោចាតិ ទិស្សន្តិ ។

ម្នាលព្រាហ្មណ៍ អបរិហានិយធម៌ ៧ យ៉ាងនេះ តាំងនៅក្នុងពួកស្តេចក្នុងដែនវជ្ជី ឬថាពួកស្តេចក្នុងដែនវជ្ជី នឹងប្រតិបត្តិក្នុងអបរិហានិយធម៌ ៧ យ៉ាងនេះ អស់កាលត្រឹមណា ម្នាលព្រាហ្មណ៍ សេចក្តីចំរើន តែងមានប្រាកដដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។ បពិត្រព្រះគោតមដ៏ចំរើន សេចក្តីចំរើន តែងមានប្រាកដ សេចក្តីសាបសូន្យ តែងមិនមានដល់ពួកស្តេចក្នុងដែនវជ្ជី ដែលប្រកបដោយអបរិហានិយធម៌ សូម្បីតែមួយៗ ចាំបាច់និយាយទៅថ្វីដល់ទៅគ្រប់អបរិហានិយធម៌ទាំង ៧ (នោះ) ។ បពិត្រព្រះគោតមដ៏ចំរើន មួយទៀត ព្រះបាទអជាតសត្តុវេទេហិបុត្រមាគធរាជ មិនគប្បីចាប់ពួកស្តេចក្នុងដែនវជ្ជីដោយចម្បាំងបានទេ វៀរលែងតែការលួងលោមយកចិត្ត ឬការធ្វើឲ្យបែកគ្នា ។ បពិត្រព្រះគោតមដ៏ចំរើន ណ្ហើយចុះ ខ្ញុំព្រះអង្គសូមលាទៅឥឡូវនេះ (ព្រោះថា) ខ្ញុំព្រះអង្គមានកិច្ចច្រើន មានការងារច្រើន ។ ម្នាលព្រាហ្មណ៍ អ្នកចូរសំគាល់នូវកាលនឹងទៅក្នុងវេលានេះចុះ ។ លំដាប់នោះ វស្សការព្រាហ្មណ៍ ជាមហាមាត្យ ក្នុងដែនមគធៈ ត្រេកអររីករាយ នឹងភាសិតរបស់ព្រះដ៏មានព្រះភាគ ហើយក្រោកចាកអាសនៈចេញទៅ ។

(២១) ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ សត្ត វោ ភិក្ខវេ អបរិហានិយេ ធម្មេ ទេសេស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមេ ច ភិក្ខវេ សត្ត អបរិហានិយា ធម្មា ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ អភិណ្ហសន្និបាតា ភវិស្សន្តិ សន្និបាតពហុលា វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ សមគ្គា សន្និបតិស្សន្តិ សមគ្គា វុដ្ឋហិស្សន្តិ សមគ្គា សង្ឃករណីយានិ ករិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ អប្បញ្ញត្តំ ន បញ្ញាបេស្សន្តិ បញ្ញត្តំ ន សមុច្ឆិន្ទិស្សន្តិ យថាបញ្ញត្តេសុ សិក្ខាបទេសុ សមាទាយ វត្តិស្សន្តិ

[២១] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់លើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ មកក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងអបរិហានិយធម៌ ទាំង ៧ ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរប្រុងស្តាប់នូវភាសិតនោះ ចូរធ្វើទុកក្នុងចិត្តឲ្យជាក់ច្បាស់ចុះ តថាគតនឹងសំដែងប្រាប់ ។ ភិក្ខុទាំងនោះ ក៏ទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចុះអបរិហានិយធម៌ ទាំង ៧ តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុ នឹងប្រជុំគ្នារឿយ ៗ ប្រជុំគ្នាដោយច្រើន អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ១ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុ នឹងព្រមព្រៀងគ្នាប្រជុំ ព្រមព្រៀងគ្នាលើកប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ចរបស់សង្ឃ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុ នឹងមិនបញ្ញត្តសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តហើយ មិនដកសិក្ខាបទដែលតថាគតបញ្ញត្តរួចហើយ កាន់តាម ប្រព្រឹត្តតាមសិក្ខាបទដែលតថាគតបញ្ញត្តហើយយ៉ាងណា អស់កាលត្រឹមណា

វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ យេ តេ ភិក្ខូ ថេរា រត្តញ្ញូ ចិរបព្វជិតា សង្ឃបិតរោ សង្ឃបរិណាយកា តេ សក្ករិស្សន្តិ គរុករិស្សន្តិ មានេស្សន្តិ បូជេស្សន្តិ តេសញ្ច សោតព្វំ មញ្ញិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ ឧប្បន្នាយ តណ្ហាយ បោនោព្ភវិកាយ ន វសំ គច្ឆិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ អារញ្ញកេសុ សេនាសនេសុ សាបេក្ខា ភវិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។

ម្នាលភិក្ខុទាំងឡាយ សេចក្ដីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្ដីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ១ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងធ្វើសក្ការៈ គោរព រាប់អាន បូជាពួកភិក្ខុ ជាថេរៈអ្នកដឹងរាត្រីច្រើន បួសយូរ ជាបិតានៃសង្ឃ ជាបរិនាយករបស់សង្ឃ ជាអ្នកណែនាំសង្ឃ ទាំងសំគាល់ពាក្យដែលគួរស្ដាប់ របស់ភិក្ខុជាថេរៈទាំងនោះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្ដីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្ដីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ១ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមិនលុះក្នុងអំណាចតណ្ហា ជាធម្មជាតិនាំសត្វទៅក្នុងភពថ្មីទៀត ដែលកើតឡើងហើយ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្ដីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្ដីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ១ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុ នឹងមានសេចក្ដីប្រាថ្នា ក្នុងសេនាសនៈទាំងឡាយ ដែលតាំងនៅក្នុងព្រៃ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្ដីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្ដីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ១ ។

យាវកីវញ្ច ភិក្ខវេ ភិក្ខូ បច្ចត្តញ្ញេវ សតិំ ឧបដ្ឋ-បេស្សន្តិ កិន្តិ អនាគតា ច បេសលា សព្រហ្មចារី អាគច្ឆេយ្យុំ អាគតា ច បេសលា សព្រហ្មចារី ផាសុំ វិហរេយ្យុន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិ-កង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ឥមេ សត្ត អបរិហានិយា ធម្មា ភិក្ខូសុ ឋស្សន្តិ ឥមេសុ ច សត្តសុ អបរិហានិយេសុ ធម្មេសុ ភិក្ខូ សន្ទិស្សិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានីតិ ។

[២២] សត្ត វោ ភិក្ខវេ អបរិហានិយេ ធម្មេ ទេសេស្សាមិ ។ បេ ។ កតមេ ច ភិក្ខវេ សត្ត អបរិហានិយា ធម្មា ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ ន កម្មារាមា ភវិស្សន្តិ(១) ន កម្មារាមតំ អនុយុត្តា វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។

១ ឱ. ម. ឯត្ថន្តរេ ន កម្មរតាតិ ទិស្សតិ ។

ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុ នឹងប្រុងស្មារតីក្នុងខ្លួនថា ធ្វើម្ដេចហ្ន៎ ពួកសព្រហ្មចារី មានសីលជាទីស្រឡាញ់ ដែលមិនទាន់មកដល់ ក៏សូមឲ្យ និមន្តមក ពួកសព្រហ្មចារី មានសីលជាទីស្រឡាញ់ ដែលមកដល់ហើយ ក៏សូមឲ្យនៅសប្បាយដូច្នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្ដីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្ដីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ១ ។ ម្នាលភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ៧ នេះ តាំងនៅក្នុងភិក្ខុទាំងឡាយ ឬថា ភិក្ខុទាំងឡាយនឹងប្រតិបត្តិ ក្នុងអបរិហានិយធម៌ទាំង ៧ យ៉ាងនេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្ដីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្ដីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ១ ។

(២២) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងអបរិហានិយធម៌ ៧ យ៉ាង ដល់អ្នកទាំងឡាយ ។បេ។ ម្នាលភិក្ខុទាំងឡាយ ឯអបរិហានិយធម៌ ៧ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុ មិនត្រេកអរនឹងការងារ មិនប្រកបរឿយៗនូវការៈជាអ្នកមានការងារជាទីត្រេកអរ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្ដីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្ដីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ១ ។

យាវកីវញ្ច ភិក្ខវេ ភិក្ខូ ន កម្មារាមា ភវិស្សន្តិ ។ បេ ។ ន និទ្ទារាមា ភវិស្សន្តិ ន សង្គណិការាមា ភវិស្សន្តិ ន បាបិច្ឆា ភវិស្សន្តិ ន បាបិកានំ ឥច្ឆានំ វសំគតា ន បាបមិត្តា ភវិស្សន្តិ ន បាបសហាយា ន បាបសម្បវង្កា ន ឱរមត្តកេន វិសេសាធិគមេន អន្តរា វោសានំ អាបជ្ជិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ឥមេ សត្ត អបរិហានិយា ធម្មា ភិក្ខូសុ ឋស្សន្តិ ឥមេសុ ច សត្តសុ អបរិហានិយេសុ ធម្មេសុ ភិក្ខូ សន្ទិស្សិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានីតិ ។

[២៣] សត្ត វោ ភិក្ខវេ អបរិហានិយេ ធម្មេ ទេសេស្សាមិ ។ បេ ។ កតមេ ច ភិក្ខវេ សត្ត អបរិហានិយា ធម្មា ។

ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុ នឹងមិនជាអ្នកមាននិយាយតិរច្ឆានកថា ជាទីត្រេកអរ ។បេ។ នឹងមិនជាអ្នកមានការដេកលក់ ជាទីត្រេកអរ នឹងមិនជាអ្នកមានគ្នីគ្នា ជាទីត្រេកអរ នឹងមិនជាអ្នកមានសេចក្តីប្រាថ្នាអាក្រក់ មិនលុះក្នុងអំណាចនៃសេចក្តីប្រាថ្នាអាក្រក់ មិនមានមិត្តអាក្រក់ មិនមានសំឡាញ់អាក្រក់ មិនងាកទៅរកបុគ្គលអាក្រក់ មិនដល់នូវសេចក្តីបន្ធូរបន្ថយព្យាយាម ក្នុងចន្លោះ ដោយការត្រាស់ដឹងនូវគុណវិសេស ត្រឹមតែជាន់ក្រោម អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។ ម្នាលភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ៧ នេះ ឋិតនៅក្នុងភិក្ខុទាំងឡាយ ឬថា ភិក្ខុទាំងឡាយ នឹងប្រតិបត្តិ ក្នុងអបរិហានិយធម៌ ៧ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។

( ៨៣ ) ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែងអបរិហានិយធម៌ ៧ យ៉ាង ដល់អ្នកទាំងឡាយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចុះអបរិហានិយធម៌ ៧ យ៉ាង តើអ្វីខ្លះ ។

យាវកីវញ្ច ភិក្ខវេ ភិក្ខូ សទ្ធា ភវិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ ហិរិ-មនា ភវិស្សន្តិ ។ បេ ។ ឱត្តប្បិនោ ភវិស្សន្តិ ពហុស្សុតា ភវិស្សន្តិ អារទ្ធវីរិយា ភវិស្សន្តិ សតិមន្តោ ភវិស្សន្តិ បញ្ញវន្តោ ភវិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ឥមេ សត្ត អបរិហានិយា ធម្មា ភិក្ខូសុ ឋស្សន្តិ ឥមេសុ ច សត្តសុ អបរិហានិយេសុ ធម្មេសុ ភិក្ខូ សន្ទិស្សិ-ស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានីតិ ។

(២៤) សត្ត វោ ភិក្ខវេ អបរិហានិយេ ធម្មេ ទេសេស្សាមិ ។ បេ ។ កតមេ ច ភិក្ខវេ សត្ត អបរិហានិយា ធម្មា ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ សតិសម្ពោជ្ឈង្គំ ភាវេស្សន្តិ

ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមានសេចក្ដីជឿ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្ដីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្ដីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុ ជាអ្នកមានសេចក្ដីខ្មាសបាប ។បេ។ មានសេចក្ដីខ្លាចបាប ជាពហុស្សូត ប្រារព្ធសេចក្ដីព្យាយាម មានស្មារតី មានបញ្ញា អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្ដីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្ដីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ៧ នេះ នឹងឋិតនៅ ក្នុងភិក្ខុទាំងឡាយ ឬថា ភិក្ខុទាំងឡាយ នឹងប្រតិបត្តិ ក្នុងអបរិហានិយធម៌ទាំង ៧ នេះ អស់កាលត្រឹមណា សេចក្ដីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្ដីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។

(២៤) ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែងអបរិហានិយធម៌ ៧ យ៉ាង ដល់អ្នកទាំងឡាយ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចុះអបរិហានិយធម៌ ៧ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុ នឹងចំរើនសតិសម្ពោជ្ឈង្គ អស់កាលត្រឹមណា

វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ ធម្មវិចយសម្ពោជ្ឈង្គំ ភាវេស្សន្តិ ។ បេ ។ វីរិយសម្ពោជ្ឈង្គំ ភាវេស្សន្តិ បីតិសម្ពោជ្ឈង្គំ ភាវេស្សន្តិ បស្សទ្ធិសម្ពោជ្ឈង្គំ ភាវេស្សន្តិ សមាធិសម្ពោជ្ឈង្គំ ភាវេស្សន្តិ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ឥមេ សត្ត អបរិហានិយា ធម្មា ភិក្ខូសុ ឋស្សន្តិ ឥមេសុ ច សត្តសុ អបរិហានិយេសុ ធម្មេសុ ភិក្ខូ សន្ទិស្សិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានីតិ ។

(២៨) សត្ត វោ ភិក្ខវេ អបរិហានិយេ ធម្មេ ទេសេស្សាមិ ។ បេ ។ កតមេ ច ភិក្ខវេ សត្ត អបរិហានិយា ធម្មា ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ អនិច្ចសញ្ញំ ភាវេស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។

ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងចំរើនធម្មវិចយសម្ពោជ្ឈង្គ ។បេ។ នឹងចំរើនវីរិយសម្ពោជ្ឈង្គ នឹងចំរើនបីតិសម្ពោជ្ឈង្គ នឹងចំរើនបស្សទ្ធិសម្ពោជ្ឈង្គ នឹងចំរើនសមាធិសម្ពោជ្ឈង្គ នឹងចំរើនឧបេក្ខាសម្ពោជ្ឈង្គ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ៧ នេះ នឹងឋិតនៅ ក្នុងភិក្ខុទាំងឡាយ ឬថាភិក្ខុទាំងឡាយ នឹងប្រតិបត្តិ ក្នុងអបរិហានិយធម៌ទាំង ៧ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ)។

[២៩] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងអបរិហានិយធម៌ ៧ យ៉ាង ដល់អ្នកទាំងឡាយ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចុះអបរិហានិយធម៌ ៧ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុ នឹងចំរើនអនិច្ចសញ្ញា អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។

បឋមបណ្ណាសកេ វជ្ជីវគ្គោ

យាវកីវញ្ច ភិក្ខវេ ភិក្ខូ អនត្តសញ្ញំ ភាវេស្សន្តិ ។ បេ ។ អសុភសញ្ញំ ភាវេស្សន្តិ អាទីនវសញ្ញំ ភាវេស្សន្តិ បហានសញ្ញំ ភាវេស្សន្តិ វិរាគសញ្ញំ ភាវេស្សន្តិ និរោធសញ្ញំ ភាវេស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ឥមេ សត្ត អបរិហានិយា ធម្មា ភិក្ខូសុ ឋស្សន្តិ ឥមេសុ ច សត្តសុ អបរិហានិយេសុ ធម្មេសុ ភិក្ខូ សន្ទិស្សិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានីតិ ។

(២៦)[១] សត្តិមេ ភិក្ខវេ ធម្មា សេក្ខស្ស ភិក្ខុនោ បរិហានាយ សំវត្តន្តិ ។ កតមេ សត្ត ។ កម្មារាមតា ភស្សារាមតា និទ្ទារាមតា សង្គណិការាមតា ឥន្ទ្រិយេសុ អគុត្តទ្វារតា ភោជនេ អមត្តញ្ញុតា សន្តិ ខោ បន សង្ឃេ សង្ឃករណីយានិ តត្រ[២] ភិក្ខុ ន ឥតិ បដិសញ្ចិក្ខតិ សន្តិ ខោ បន សង្ឃេ ថេរា រត្តញ្ញូ

---

១.ម ឯត្ថន្តរេ ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ។ បេ ។ អាមន្តេសីតិ ទិស្សន្តិ ។

២ ឱ.ម. តត្រ សេខោ ។

ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុ នឹងចំរើនអនត្តសញ្ញា ។បេ។ នឹងចំរើនអសុភសញ្ញា នឹងចំរើនអាទីនវសញ្ញា នឹងចំរើនបហានសញ្ញា នឹងចំរើនវិរាគសញ្ញា នឹងចំរើននិរោធសញ្ញា អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ។ ម្នាលភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ៧ នេះ ឋិតនៅ ក្នុងភិក្ខុទាំងឡាយ ឬថា ភិក្ខុទាំងឡាយ នឹងប្រតិបត្តិ ក្នុងអបរិហានិយទាំង ៧ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។

(២៦) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ៧ នេះ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ ដល់សេក្ខភិក្ខុ ។ ៧ យ៉ាង តើអ្វីខ្លះ ។ គឺសេចក្តីត្រេកអរក្នុងការងារ ១ សេចក្តីត្រេកអរ ក្នុងការនិយាយតិរច្ឆានកថា ១ សេចក្តីត្រេកអរ ក្នុងការដេកលក់ ១ សេចក្តីត្រេកអរក្នុងការប្រកបដោយគ្នា ១ សេចក្តីមិនគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ១ ការមិនដឹងប្រមាណ ក្នុងភោជន ១ កិច្ចរបស់សង្ឃ តែងមានក្នុងសង្ឃ ភិក្ខុមិនពិចារណា ក្នុងកិច្ចនោះថា ពួកព្រះថេរៈ ក្នុងសង្ឃអ្នកដឹងរាត្រីវែង

ចិរប្បព្វជិតា ភារវាហិនោ តេ តេន បញ្ញាយិ-
ស្សន្តីតិ អត្តនា វោយោគំ អាបជ្ជតិ ។ ឥមេ ខោ
ភិក្ខវេ សត្ត ធម្មា សេក្ខស្ស ភិក្ខុនោ បរិហានាយ
សំវត្តន្តីតិ ។ សត្តិមេ ភិក្ខវេ ធម្មា សេក្ខស្ស
ភិក្ខុនោ អបរិហានាយ សំវត្តន្តិ ។ កតមេ សត្ត ។
ន កម្មារាមតា ន ភស្សារាមតា ន និទ្ទារាមតា ន
សង្គណិការាមតា ឥន្ទ្រិយេសុ គុត្តទ្វារតា ភោជនេ
មត្តញ្ញុតា សន្តិ ខោ បន សង្ឃេ សង្ឃករណី-
យានិ តត្រ ភិក្ខុ ឥតិ បដិសញ្ចិក្ខតិ សន្តិ ខោ បន
សង្ឃេ ថេរា រត្តញ្ញូ ចិរប្បព្វជិតា ភារវាហិនោ តេ
តេន បញ្ញាយិស្សន្តីតិ អត្តនា ច វោយោគំ អាបជ្ជតិ ។
ឥមេ ខោ ភិក្ខវេ សត្ត ធម្មា សេក្ខស្ស ភិក្ខុនោ
អបរិហានាយ សំវត្តន្តីតិ ។

(២៧) សត្តិមេ ភិក្ខវេ ធម្មា ឧបាសកស្ស
បរិហានាយ សំវត្តន្តិ ។ កតមេ សត្ត ។

បួសយូរ អ្នកនាំទៅនូវការៈ ពួកថេរៈទាំងនោះ ក៏ទឹងប្រាកដ ដោយការងារនោះដូច្នេះ ហើយដល់នូវការប្រកបដោយខ្លួនឯង ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៧ យ៉ាងនេះឯង រមែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីសាបសូន្យដល់សេក្ខភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីមិនសាបសូន្យ ដល់សេក្ខភិក្ខុឡើយ ។ ៧ យ៉ាង តើអ្វីខ្លះ ។ គឺសេចក្ដីមិនត្រេកអរ ក្នុងការងារ ១ សេចក្ដីមិនត្រេកអរ ក្នុងការនិយាយតិរច្ឆានកថា ១ សេចក្ដីមិនត្រេកអរ ក្នុងការដេកលក់ ១ សេចក្ដីមិនត្រេកអរ ក្នុងការប្រកបដោយគ្នីគ្នា ១ ការគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ១ សេចក្ដីដឹងប្រមាណ ក្នុងភោជន ១ កិច្ចរបស់សង្ឃ តែងមានក្នុងសង្ឃ ភិក្ខុពិចារណា ក្នុងកិច្ចនោះថា ពួកព្រះថេរៈ ក្នុងសង្ឃអ្នកដឹងនូវរាត្រីវែង បួសយូរ អ្នកនាំទៅនូវការៈ ពួកព្រះថេរៈទាំងនោះ ទឹងប្រាកដ ដោយការងារនោះដូច្នេះ ហើយមិនដល់នូវការប្រកប ដោយខ្លួនឯង ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះឯង រមែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់សេក្ខភិក្ខុឡើយ ។

(៤៧) ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីសាបសូន្យដល់ឧបាសក ។ ៧ យ៉ាង តើអ្វីខ្លះ ។

## បឋមបណ្ណាសកេ វជ្ជីវគ្គោ

ភិក្ខុទស្សនំ ហាបេតិ សទ្ធម្មស្សវនំ បមជ្ជតិ អធិសីលេ ន សិក្ខតិ អប្បសាទពហុលោ ហោតិ ភិក្ខូសុ ថេរេសុ នវេសុ ច មជ្ឈិមេសុ ច ឧបារម្ភចិត្តោ ធម្មំ សុណាតិ រន្ធគវេសី ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ តត្ថ ច បុព្វការំ ករោតិ ។ ឥមេ ខោ ភិក្ខវេ សត្ត ធម្មា ឧបាសកស្ស បរិហានាយ សំវត្តន្តិ ។ សត្តិមេ ភិក្ខវេ ធម្មា ឧបាសកស្ស អបរិហានាយ សំវត្តន្តិ ។ កតមេ សត្ត ។ ភិក្ខុទស្សនំ ន ហាបេតិ សទ្ធម្មស្សវនំ នប្បមជ្ជតិ អធិសីលេ សិក្ខតិ បសាទពហុលោ ហោតិ ភិក្ខូសុ ថេរេសុ នវេសុ ច មជ្ឈិមេសុ ច អនុបារម្ភចិត្តោ ធម្មំ សុណាតិ ន រន្ធគវេសី ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ ។ ឥមេ ខោ ភិក្ខវេ សត្ត ធម្មា ឧបាសកស្ស អបរិហានាយ សំវត្តន្តីតិ ។

ឧបាសកញ៉ាំងការឃើញនូវភិក្ខុ ឲ្យសាបសូន្យ ១ ប្រហែសនឹងការស្ដាប់ព្រះសទ្ធម្ម ១ មិនសិក្សាក្នុងអធិសីល(១) ១ ជាអ្នកមិនមានសេចក្ដីជ្រះថ្លាច្រើន ក្នុងពួកភិក្ខុចាស់ ថ្មី កណ្ដាល ១ ជាអ្នកមានចិត្តរិះគន់ ស្វែងរកទោសស្ដាប់ធម៌ ១ ស្វែងរកទក្ខិណេយ្យបុគ្គល ខាងក្រៅសាសនានេះ ១ ធ្វើបុព្វការៈក្នុងទក្ខិណេយ្យបុគ្គល ខាងក្រៅសាសនានោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះឯង រមែងប្រព្រឹត្តទៅ ដើម្បីសាបសូន្យដល់ឧបាសក ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះ រមែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ឧបាសក ។ ៧ យ៉ាង តើអ្វីខ្លះ ។ គឺឧបាសកមិនញ៉ាំងការឃើញភិក្ខុ ឲ្យសាបសូន្យ ១ មិនប្រហែសនឹងការស្ដាប់ព្រះសទ្ធម្ម ១ សិក្សាក្នុងអធិសីល ១ ជាអ្នកមានសេចក្ដីជ្រះថ្លាច្រើន ក្នុងពួកភិក្ខុចាស់ ថ្មី កណ្ដាល ១ ជាអ្នកមានចិត្តមិនរិះគន់ មិនស្វែងរកទោសស្ដាប់ធម៌ ១ មិនស្វែងរកទក្ខិណេយ្យបុគ្គល ខាងក្រៅសាសនានេះ ១ ធ្វើបុព្វការៈក្នុងទក្ខិណេយ្យបុគ្គល ក្នុងសាសនានេះ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះឯង រមែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ឧបាសក ។

---

១ សីល ៥ ឬ សីល ១០ ។ អដ្ឋកថា ។

ទស្សនំ ភាវិតត្តានំ យោ ហាបេតិ ឧបាសកោ
សវនញ្ច អរិយធម្មានំ អធិសីលេ ន សិក្ខតិ
អប្បសាទោ ច ភិក្ខូសុ ភិយ្យោ ភិយ្យោ បវឌ្ឍតិ
ឧបារម្ភចិត្តោ ច សទ្ធម្មំ សោតុមិច្ឆតិ
ឥតោ ច ពហិទ្ធា អញ្ញំ ទក្ខិណេយ្យំ គវេសតិ
តត្ថេវ ច បុព្វការំ យោ ករោតិ ឧបាសកោ
ឯតេ ខោ បរិហានីយេ សត្ត ធម្មេ សុទេសិតេ
ឧបាសកោ សេវមានោ សទ្ធម្មា បរិហាយតិ ។
ទស្សនំ ភាវិតត្តានំ យោ ន ហាបេតិ ឧបាសកោ
សវនញ្ច អរិយធម្មានំ អធិសីលេ ច សិក្ខតិ
បសាទោ ចស្ស ភិក្ខូសុ ភិយ្យោ ភិយ្យោ បវឌ្ឍតិ
អនុបារម្ភចិត្តោ ច សទ្ធម្មំ សោតុមិច្ឆតិ
ន ឥតោ ពហិទ្ធា អញ្ញំ ទក្ខិណេយ្យំ គវេសតិ
ឥធេវ ច បុព្វការំ យោ ករោតិ ឧបាសកោ

ឧបាសកណា ញុំាងការឃើញនូវពួកភិក្ខុ ដែលមានខ្លួនចំរើនហើយ ឲ្យសាបសូន្យ ១ ប្រហែសនឹងការស្តាប់នូវអរិយធម៌ទាំងឡាយ ១ មិនសិក្សាក្នុងអធិសីល ១ មានសេចក្តីមិនជ្រះថ្លា ក្នុងពួកភិក្ខុ ចំរើនឡើង ដោយក្រៃលែង ១ មានចិត្តរិះគន់ ប្រាថ្នាស្តាប់ព្រះសទ្ធម្ម ១ ស្វែងរកទក្ខិណេយ្យ-បុគ្គលដទៃ ខាងក្រៅសាសនានេះ ១ ឧបាសកធ្វើបុព្វការៈចំពោះទក្ខិណេយ្យបុគ្គលនោះ ១ ឧបាសក កាលសេពនូវបរិហានិយធម៌ទាំង ៧ យ៉ាងនេះឯង ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដោយប្រពៃ រមែងសាបសូន្យចាកព្រះសទ្ធម្ម ។ ឧបាសកណា មិនញុំាងការឃើញនូវពួកភិក្ខុ ដែលមានខ្លួនចំរើនហើយ ឲ្យសាបសូន្យ ១ មិនប្រហែសនឹងការស្តាប់នូវអរិយធម៌ទាំងឡាយ ១ សិក្សាក្នុងអធិសីល ១ សេចក្តីជ្រះថ្លា ក្នុងពួកភិក្ខុរបស់ឧបាសកនោះ ចំរើនឡើងដោយក្រៃលែង ១ មានចិត្តមិនរិះគន់ ស្តាប់នូវព្រះសទ្ធម្ម ១ មិនស្វែងរកទក្ខិណេយ្យបុគ្គលដទៃ ខាងក្រៅសាសនានេះ១ ឧបាសកតែងធ្វើបុព្វការៈចំពោះទក្ខិណេយ្យបុគ្គល ក្នុងសាសនានេះ ១

ឯតេ ខោ អបរិហានិយេ សត្ត ធម្មេ សុទេសិតេ
ឧបាសកោ សេវមានោ សទ្ធម្មា ន ច ហាយតីតិ(១)។

(២៨) សត្តិមា ភិក្ខវេ ឧបាសកស្ស វិបត្តិយោ សត្តិមា ភិក្ខវេ ឧបាសកស្ស សម្បទា(២) សត្តិមេ ភិក្ខវេ ឧបាសកស្ស អសម្ភវា(៣) សត្តិមេ ភិក្ខវេ ឧបាសកស្ស សម្ភវា ។ កតមេ សត្ត ។ ភិក្ខុទស្សនំ ន ហាបេតិ សទ្ធម្មស្សវនំ នប្បមជ្ជតិ អធិសីលេ សិក្ខតិ បសាទពហុលោ ហោតិ ភិក្ខូសុ ថេរេសុ ចេវ នវេសុ ច មជ្ឈិមេសុ ច អនុបារម្ភចិត្តោ ធម្មំ សុណាតិ ន រន្ធគវេសី ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ ។ ឥមេ ខោ ភិក្ខវេ សត្ត ឧបាសកស្ស សម្ភវាតិ ។

ទស្សនំ ភាវិតត្តានំ យោ ហាបេតិ ឧបាសកោ
សវនញ្ច អរិយធម្មានំ អធិសីលេ ន សិក្ខតិ

---

១ ឱ. ម. ន បរិហាយតីតិ ។ ២ ឱ. សម្បត្តិយោ ។ ៣ ឱ. ម. បរាភវា ។

ឧបាសក កាលសេពនូវអបរិហានិយធម៌ទាំង ៧ យ៉ាង នេះឯង ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយដោយប្រពៃ រមែងមិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។

(៤៨) ម្នាលភិក្ខុទាំងឡាយ វិបត្តិរបស់ឧបាសកនេះមាន ៧ យ៉ាង ម្នាលភិក្ខុទាំងឡាយ សម្បត្តិរបស់ឧបាសកនេះមាន ៧ យ៉ាង ម្នាលភិក្ខុទាំងឡាយ សេចក្តីវិនាសរបស់ឧបាសកនេះមាន ៧ យ៉ាង ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើនរបស់ឧបាសកនេះមាន ៧ យ៉ាង ។ ៧ យ៉ាងតើអ្វីខ្លះ ។ គឺឧបាសក មិនញុំាងការឃើញនូវភិក្ខុ ឲ្យសាបសូន្យ ១ មិនប្រហែសនឹងការស្តាប់នូវព្រះសទ្ធម្ម ១ សិក្សាក្នុងអធិសីល ១ ជាអ្នកមានសេចក្តីជ្រះថ្លាច្រើនក្នុងពួកភិក្ខុជាស់ ថ្មី កណ្តាល ១ មិនមានចិត្តរិះគន់ មិនស្វែងរកទោសស្តាប់ធម៌ ១ មិនស្វែងរកទក្ខិណេយ្យបុគ្គលខាងក្រៅសាសនានេះ ១ ធ្វើបុព្វការៈចំពោះទក្ខិណេយ្យបុគ្គល ក្នុងសាសនានេះ ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើនរបស់ឧបាសកមាន ៧ យ៉ាងនេះឯង ។

ឧបាសកណា ញុំាងការឃើញនូវពួកភិក្ខុ ដែលមាន
ខ្លួនចំរើនហើយ ឲ្យសាបសូន្យ ១ ប្រហែសក្នុងការស្តាប់
នូវអរិយធម៌ទាំងឡាយ ១ មិនសិក្សា ក្នុងអធិសីល ១

អប្បសាទោ ច ភិក្ខូសុ ភិយ្យោ ភិយ្យោ បវឌ្ឍតិ

ឧបារម្ភចិត្តោ ច សទ្ធម្មំ សោតុមិច្ឆតិ

ឥតោ ច ពហិទ្ធា អញ្ញំ ទក្ខិណេយ្យំ គវេសតិ

តត្ថ ច បុព្វការំ យោ ករោតិ ឧបាសកោ

ឯតេ ខោ បរិហានីយេ សត្ត ធម្មេ សុទេសិតេ

ឧបាសកោ សេវមានោ សទ្ធម្មា បរិហាយតិ ។

ទស្សនំ ភាវិតត្តានំ យោ ន ហាបេតិ ឧបាសកោ

សវនញ្ច អរិយធម្មានំ អធិសីលេ ច សិក្ខតិ

បសាទោ ចស្ស ភិក្ខូសុ ភិយ្យោ ភិយ្យោ បវឌ្ឍតិ

អនុបារម្ភចិត្តោ ច សទ្ធម្មំ សោតុមិច្ឆតិ

ន ឥតោ ពហិទ្ធា អញ្ញំ ទក្ខិណេយ្យំ គវេសតិ

ឥធេវ ច បុព្វការំ យោ ករោតិ ឧបាសកោ

មានសេចក្តីមិនជ្រះថ្លាក្នុងពួកភិក្ខុ បំពេនដោយក្រៃលែង ១
ជាអ្នកមានចិត្តរិះគន់ប្រាថ្នាស្តាប់នូវព្រះសទ្ធម្ម ១ ស្វែងរក
ទក្ខិណេយ្យបុគ្គលដទៃ ខាងក្រៅសាសនានេះ ១ ឧបាសកធ្វើ
បុព្វការៈចំពោះទក្ខិណេយ្យបុគ្គល ខាងក្រៅសាសនានេះ ១
ឧបាសកកាលសេពនូវបរិហានិយធម៌ទាំង ៧ នេះឯង ដែល
ព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយដោយប្រពៃ រមែង
សាបសូន្យចាកព្រះសទ្ធម្ម ។ ឧបាសកណា មិនញុំាងការ
ឃើញនូវពួកភិក្ខុដែលមានខ្លួនចំរើនហើយ ឲ្យសាបសូន្យ ១
មិនប្រហែសចំពោះការស្តាប់នូវអរិយធម៌ទាំងឡាយ ១
សិក្សាក្នុងអធិសីល ១ សេចក្តីជ្រះថ្លា ក្នុងពួកភិក្ខុរបស់
ឧបាសកនោះ បំពេនដោយក្រៃលែង ១ មិនមានចិត្តរិះគន់
ប្រាថ្នាស្តាប់នូវព្រះសទ្ធម្ម ១ មិនស្វែងរកទក្ខិណេយ្យ-
បុគ្គលដទៃ ខាងក្រៅសាសនានេះ ១ ឧបាសកធ្វើបុព្វការៈ
ចំពោះទក្ខិណេយ្យបុគ្គល ក្នុងសាសនានេះ ១

ឃរេ ទ្វេ អបរិហានិយេ សត្ត ធម្មេ សុទេសិតេ
ទុតា សតោ សេវនាតោ សន្ធ្យា ច ធ ហាយតីតិ ។

វជ្ជិវគ្គោ តតិយោ ។

## តស្សុទ្ទានំ

សារន្ទទោ វស្សការោ ភិក្ខុ កម្មា សទ្ធិយំ(១)
ពោធិយ សញ្ញំ សេវនា ច ហានិ វិបត្តិសម្ភវេតិ(២) ។

---

១ ម. អានន្ទ វស្សកាលេ ច តិសត្តកានិ ភិក្ខុកា ។ ២ ឱ. ពោធិសញ្ញំ សេវ្វោ ច ហានិ វិបត្តិ ច បរាភវេតិ ។ ម. ពោធិសញ្ញា ទ្វេ ច ហានិ វិបត្តិ ច បរាភវេតិ ។

ឧបាសកកាលសេពនូវអបរិហានិយធម៌ទាំង ៧ យ៉ាងនេះ ឯង ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយដោយប្រពៃ រមែងមិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។

ចប់ វជ្ជីវគ្គទី ៣ ។

## ឧទ្ទាននៃវជ្ជីវគ្គនោះគឺ

និយាយពីសារន្ទទចេតិយ ១ វស្សការព្រាហ្មណ៍ ១ ភិក្ខុ ១ ការងារ ១ ធម្មជាតដែលគួរជឿ ១ ធម៌ជាបំណែកនៃការត្រាស់ដឹង ១ សញ្ញា ១ សេក្ខភិក្ខុ ១ សេចក្ដីសាបសូន្យ ១ វិបត្តិ ១ សេចក្ដីចំរើន ១ ។

## ទេវតាវគ្គោ

(២៩) អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ ឯតទវោច សត្តិមេ ភន្តេ ធម្មា ភិក្ខុនោ អបរិហានាយ សំវត្តន្តិ ។ កតមេ សត្ត ។ សត្ថុគារវតា ធម្មគារវតា សង្ឃគារវតា សិក្ខាគារវតា សមាធិគារវតា អប្បមាទគារវតា បដិសន្ថារគារវតា ។ ឥមេ ខោ ភន្តេ សត្ត ធម្មា ភិក្ខុនោ អបរិហានាយ សំវត្តន្តីតិ ។ ឥទមវោច សា ទេវតា សមនុញ្ញោ សត្ថា អហោសិ ។ អថខោ សា ទេវតា សមនុញ្ញោ មេ សត្ថាតិ ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយិ ។ អថខោ ភគវា តស្សា រត្តិយា អច្ចយេន ភិក្ខូ អាមន្តេសិ ឥមំ ភិក្ខវេ រត្តឹ

# ទេវតាវគ្គ

[ ២៩ ] លំដាប់នោះឯង ទេវតាមួយអង្គ មានរស្មីដ៏រុងរឿង កាលដែលវេលារាត្រី បឋមយាម កន្លងផុតទៅ ក៏ធ្វើវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ឋិតនៅក្នុងទីសមគួរ ។ លុះទេវតានោះឋិតនៅក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៧ ប្រការនេះ តែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៧ ប្រការ តើដូចម្តេចខ្លះ ។ គឺសេចក្តីគោរពព្រះសាស្តា ១ គោរពព្រះធម៌ ១ គោរពព្រះសង្ឃ ១ គោរពសិក្ខា ១ គោរពសមាធិ ១ គោរពការមិនប្រមាទ ១ គោរពការធ្វើបដិសណ្ឋារៈ ១ ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៧ ប្រការនេះឯង តែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ លុះទេវតានោះ ក្រាបបង្គំទូលសេចក្តីនេះចប់ហើយ ព្រះសាស្តា ក៏ទ្រង់សព្វព្រះហឫទ័យ ។ លំដាប់នោះ ទេវតានោះគិតថា ព្រះសាស្តាទ្រង់សព្វព្រះហឫទ័យនឹងអាត្មាអញ ដូច្នេះហើយ ក៏ថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណរួចបាត់អំពីទីនោះឯង ។ លុះវេលាកន្លងរាត្រីនោះមក ព្រះដ៏មានព្រះភាគបានត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ វេលាយប់មិញនេះ

អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុប-សង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ ឯតទវោច សត្តិមេ ភន្តេ ធម្មា ភិក្ខុនោ អបរិហានាយ សំវត្តន្តិ ។ កតមេ សត្ត ។ សត្ថុគារវតា ធម្មគារវតា សង្ឃគារវតា សិក្ខាគារវតា សមាធិគារវតា អប្បមាទគារវតា បដិសន្ថារគារវតា ។ ឥមេ ខោ ភន្តេ សត្ត ធម្មា ភិក្ខុនោ អបរិហានាយ សំវត្តន្តីតិ ។ ឥទមវោច សា ទេវតា ឥទំ វត្វា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយីតិ ។

សត្ថុគរុ ធម្មគរុ សង្ឃេ ច តិព្វគារវោ
សមាធិគរុ អាតាបី[1] សិក្ខាយ តិព្វគារវោ

---

១ ម. សមាធិគារវតាបិច ។

## បឋមបណ្ណាសក ទេវតាវគ្គ

មានទេវតាមួយអង្គ មានរស្មីដ៏រុងរឿង កាលដែលវេលាកន្លងបឋម-យាម ក្នុងផុតទៅ ក៏ធ្វើវត្តជេតវនទាំងមូល ឲ្យភ្លឺស្វាង ហើយចូលមកគាល់តថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចឋិតនៅក្នុងទីសមគួរ ម្នាលភិក្ខុទាំងឡាយ លុះទេវតានោះ ឋិតនៅក្នុងទីសមគួរហើយ ក៏បាននិយាយសេចក្ដីនេះនឹងតថាគតថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៧ ប្រការនេះ តែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៧ ប្រការ តើដូចម្ដេចខ្លះ ។ គឺសេចក្ដីគោរពព្រះសាស្ដា ១ គោរពព្រះធម៌ ១ គោរពព្រះសង្ឃ ១ គោរពសិក្ខា ១ គោរពសមាធិ ១ គោរពការមិនប្រមាទ ១ គោរពការធ្វើបដិសណ្ឋារៈ ១ ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៧ ប្រការនេះឯង តែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ លុះទេវតានោះ បាននិយាយសេចក្ដីនេះចប់ហើយ លុះថ្លែងសេចក្ដីនេះរួចហើយ ក៏ថ្វាយបង្គំតថាគត ធ្វើប្រទក្សិណហើយ ក៏បាត់អំពីទីនោះឯង ។

ភិក្ខុមានសេចក្ដីព្យាយាមជាគ្រឿងដុតកំដៅកិលេស មានសេចក្ដី
គោរពព្រះសាស្ដាផង គោរពព្រះធម៌ផង គោរពដ៏ក្លៀវក្លាចំពោះ
ព្រះសង្ឃផង គោរពសមាធិផង គោរពដ៏ក្លៀវក្លាចំពោះសិក្ខាផង

អប្បមាទគរុ ភិក្ខុ បដិសន្ថារគារវោ
អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេតិ ។

[៣០] ឥមំ ភិក្ខវេ រត្តិំ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ឯកមន្តំ ឋិតា ខោ ភិក្ខវេ សា ទេវតា មំ ឯតទវោច សត្តិមេ ភន្តេ ធម្មា ភិក្ខុនោ អបរិហានាយ សំវត្តន្តិ ។ កតមេ សត្ត ។ សត្ថុគារវតា ធម្មគារវតា សង្ឃគារវតា សិក្ខាគារវតា សមាធិគារវតា ហិរិគារវតា ឱត្តប្បគារវតា ។ ឥមេ ខោ ភន្តេ សត្ត ធម្មា ភិក្ខុនោ អបរិហានាយ សំវត្តន្តីតិ ។ ឥទមវោច ភិក្ខវេ សា ទេវតា ឥទំ វត្វា

គោរពការមិនប្រមាទផង គោរពការធ្វើបដិសណ្ឋារៈផង (ភិក្ខុនោះ) មិនគួរនឹងសាបសូន្យ (ចាកមគ្គនឹងផលឡើយ រមែងឋិតនៅ) ក្នុងទីជិតព្រះនិព្វាន ។

(៣០) ម្នាលភិក្ខុទាំងឡាយ វេលាយប់មិញនេះ មានទេវតាមួយអង្គ មានរស្មីដ៏រុងរឿង កាលដែលវេលារាត្រី បឋមយាម កន្លងផុតទៅ ក៏ធ្វើវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ហើយចូលមកគាល់តថាគត លុះចូលមកដល់ហើយ ថ្វាយបង្គំតថាគត រួចឋិតនៅក្នុងទីសមគួរ ម្នាលភិក្ខុទាំងឡាយ លុះទេវតានោះ ឋិតនៅក្នុងទីសមគួរហើយ បាននិយាយសេចក្ដីនេះនឹងតថាគតថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៧ ប្រការនេះ តែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៧ ប្រការ តើដូចម្ដេចខ្លះ ។ គឺសេចក្ដីគោរពព្រះសាស្ដា ១ គោរពព្រះធម៌ ១ គោរពព្រះសង្ឃ ១ គោរពសិក្ខា ១ គោរពសមាធិ ១ គោរពសេចក្ដីខ្មាសបាប ១ គោរពសេចក្ដីខ្លាចបាប ១ ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៧ ប្រការនេះឯង តែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ទេវតានោះ បាននិយាយសេចក្ដីនេះចប់ហើយ ថ្វាយសេចក្ដីនេះរួចហើយ

បំ អភិក្កន្តោ បនត្ថិណ្ណំ តត្វា តត្ថោវត្ថរជាយតីតិ ។

សត្ថុគរុ ធម្មគរុ សង្ឃេ ច តិព្វគារវោ
សមាធិគរុ អាតាបី(១) សិក្ខាយ តិព្វគារវោ
ហិរិឱត្តប្បសម្បន្នោ សប្បតិស្សោ សគារវោ
អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេតិ ។

(៣១) ឥមំ ភិក្ខវេ រត្តឹ អញ្ញតរា ទេវតា ។ បេ ។ មំ ឯតទវោច សត្តិមេ ភន្តេ ធម្មា ភិក្ខុនោ អបរិហានាយ សំវត្តន្តិ ។ កតមេ សត្ត ។ សត្ថុគារវតា ធម្មគារវតា សង្ឃគារវតា សិក្ខាគារវតា សមាធិគារវតា សោវចស្សតា កល្យាណមិត្តតា ។

---

១ ម. សមាធិគារវោបិច ។

ក៏ថ្វាយបង្គំតថាគត ធ្វើប្រទក្សិណហើយ ក៏បាត់អំពីទីនោះ ។

ភិក្ខុមានសេចក្តីព្យាយាមជាគ្រឿងដុតកំដៅកិលេស
មានសេចក្តីគោរពព្រះសាស្តាផង គោរពព្រះ
ធម៌ផង គោរពដ៏ក្រៀវក្លា ចំពោះព្រះសង្ឃផង
គោរពសមាធិផង គោរពដ៏ក្រៀវក្លា ក្នុងសិក្ខា
ផង បរិបូណ៌ ដោយសេចក្តីខ្លាសបាប និង
ខ្លាចបាបផង ជាអ្នកប្រកប ដោយសេចក្តីកោត
ក្រែង សេចក្តីគោរព (ភិក្ខុនោះ) មិនគួរ
នឹងសាបសូន្យ ( ចាកមគ្គ និងផលឡើយ
រមែងឋិតនៅ) ក្នុងទីជិតនៃព្រះនិព្វាន ។

( ៣១ ) ម្នាលភិក្ខុទាំងឡាយ វេលាយប់មិញនេះ មានទេវតាមួយអង្គ ។បេ។ បាននិយាយសេចក្តីនេះ នឹងតថាគតថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៧ ប្រការនេះ តែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៧ ប្រការ តើដូចម្តេចខ្លះ ។ គឺសេចក្តីគោរពព្រះសាស្តា ១ គោរពព្រះធម៌ ១ គោរពព្រះសង្ឃ ១ គោរពសិក្ខា ១ គោរពសមាធិ ១ ភាពជាអ្នកប្រដៅងាយ ១ ភាពជាអ្នកមានមិត្រល្អ១ ។

ឥមេ ខោ ភន្តេ សត្ត ធម្មា ភិក្ខុនោ អបរិហានាយ សំវត្តន្តីតិ ។ ឥទមវោច ភិក្ខវេ សា ទេវតា ឥទំ វត្វា មំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយីតិ ។

សត្ថុគរុ ធម្មគរុ សង្ឃេ ច តិព្វគារវោ
សមាធិគរុ អាតាបី(១) សិក្ខាយ តិព្វគារវោ
កល្យាណមិត្តោ សុវចោ សប្បតិស្សោ សគារវោ
អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេតិ ។

[៣២] ឥមំ ភិក្ខវេ រត្តឹ អញ្ញតរា ។ បេ ។ មំ ឯតទវោច សត្តិមេ ភន្តេ ធម្មា ភិក្ខុនោ អបរិហានាយ សំវត្តន្តិ ។ កតមេ សត្ត ។ សត្ថុគារវតា

១ ម. សមាធិគារវភាបិច ។

បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៧ ប្រការនេះឯង តែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ទេវតានោះ បាននិយាយសេចក្តីនេះចប់ហើយ លុះបានថ្វាយសេចក្តីនេះរួចហើយ ក៏ថ្វាយបង្គំតថាគត ធ្វើប្រទក្សិណ ហើយក៏បាត់អំពីទីនោះឯង ។

ភិក្ខុមានសេចក្តីព្យាយាមជាគ្រឿងដុតកំដៅកិលេស
មានសេចក្តីគោរពព្រះសាស្តាផង គោរពព្រះធម៌ផង
គោរពដ៏ក្លៀវក្លា ចំពោះព្រះសង្ឃផង គោរព
សមាធិផង គោរពដ៏ក្លៀវក្លាក្នុងសិក្ខាផង ជាអ្នក
មានមិត្តល្អផង គេប្រដៅងាយផង ជាអ្នកប្រកប
ដោយសេចក្តីកោតក្រែង សេចក្តីគោរព (ភិក្ខុនោះ)
មិនគួរនឹងសាបសូន្យ (ជាកមគ្គនឹងផលទៀយ
រមែងឋិតនៅ) ក្នុងទីជិតនៃព្រះនិព្វាន ។

(៣២) ម្នាលភិក្ខុទាំងឡាយ វេលាយប់មិញនេះ មានទេវតាមួយអង្គ ។បេ។ បាននិយាយសេចក្តីនេះនឹងតថាគតថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៧ ប្រការនេះ តែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌៧ប្រការ តើដូចម្តេចខ្លះ ។ គឺសេចក្តីគោរពព្រះសាស្តា ១ គោរព

ធម្មគារវតា សង្ឃគារវតា សិក្ខាគារវតា សមាធិគារវតា
សោវចស្សតា កល្យាណមិត្តតា ។ ឥមេ ខោ ភន្តេ
សត្ត ធម្មា ភិក្ខុនោ អបរិហានាយ សំវត្តន្តីតិ ។
ឥទមវោច ភិក្ខវេ សា ទេវតា ឥទំ វត្វា មំ អភិ-
វាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយីតិ ។ ឯវំ វុត្តេ
អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច ឥមស្ស ខោ
អហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថា-
រេន អត្ថំ អាជានាមិ ឥធ ភន្តេ ភិក្ខុ អត្តនា ច
សត្ថុគារវោ ហោតិ សត្ថុគារវតាយ ច វណ្ណវាទី យេ
ចញ្ញេ ភិក្ខូ ន សត្ថុគារវា តេ ច សត្ថុគារវតាយ
សមាទបេតិ យេ ចញ្ញេ ភិក្ខូ សត្ថុគារវា តេសញ្ច
វណ្ណំ ភណតិ ភូតំ តច្ឆំ កាលេន ។ អត្តនា ច
ធម្មគារវោ ហោតិ ។ បេ ។ សង្ឃគារវោ ហោតិ សិក្ខា-
គារវោ ហោតិ សមាធិគារវោ ហោតិ សុវចោ ហោតិ

ព្រះធម៌ ១ គោរពព្រះសង្ឃ ១ គោរពសិក្ខា ១ គោរពសមាធិ ១ ភាពជាអ្នកប្រដៅងាយ ១ ភាពជាអ្នកមានមិត្តល្អ ១ ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៧ ប្រការនេះឯង តែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ លុះទេវតានោះ បាននិយាយសេចក្តីនេះចប់ហើយ បានថ្វាយសេចក្តីនេះរួចហើយ ក៏ថ្វាយបង្គំតថាគត ធ្វើប្រទក្សិណ ហើយក៏បាត់អំពីទីនោះឯង ។ កាលបើព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះសារីបុត្តដ៏មានអាយុ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងដោយសេចក្តីសង្ខេបនេះឯង ខ្ញុំព្រះអង្គយល់សេចក្តី ដោយពិស្តារយ៉ាងនេះ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីគោរព ព្រះសាស្តាដោយខ្លួនឯងផង ពណ៌នាគុណនៃសេចក្តីគោរពព្រះសាស្តាផង ភិក្ខុដទៃណា មិនទាន់មានសេចក្តីគោរពព្រះសាស្តា ក៏ដឹកនាំភិក្ខុទាំងនោះ ឲ្យគោរពព្រះសាស្តាផង ភិក្ខុដទៃណា មានសេចក្តីគោរពព្រះសាស្តាហើយ ក៏ពណ៌នាគុណរបស់ភិក្ខុទាំងនោះ តាមសេចក្តីពិតមែន ក្នុងកាលគួរផង ។ ជាអ្នកមានសេចក្តីគោរពព្រះធម៌ដោយខ្លួនឯង ។ បេ ។ ជាអ្នកមានសេចក្តីគោរពព្រះសង្ឃ មានសេចក្តីគោរពសិក្ខា មានសេចក្តីគោរពសមាធិ ជាអ្នកដែលគេប្រដៅងាយ

កល្យាណមិត្តោ ហោតិ កល្យាណមិត្តតាយ ច វណ្ណវាទី យេ ចញ្ញេ ភិក្ខូ ន កល្យាណមិត្តា តេ ច កល្យាណមិត្តតាយ សមាទបេតិ យេ ចញ្ញេ ភិក្ខូ កល្យាណមិត្តា តេសញ្ច វណ្ណំ ភណតិ ភូតំ តច្ឆំ កាលេន ។ ឥមស្ស ខោ អហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមីតិ ។ សាធុ សាធុ សារីបុត្ត សាធុ ខោ ត្វំ សារីបុត្ត ឥមស្ស មយា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាសិ ឥធ សារីបុត្ត ភិក្ខុ អត្តនា ច សត្ថុគារវោ ហោតិ សត្ថុគារវតាយ ច វណ្ណវាទី យេ ចញ្ញេ ភិក្ខូ ន សត្ថុគារវា តេ ច សត្ថុគារវតាយ សមាទបេតិ យេ ចញ្ញេ ភិក្ខូ សត្ថុគារវា តេសញ្ច វណ្ណំ ភណតិ ភូតំ តច្ឆំ កាលេន ។ អត្តនា ច ធម្មគារវោ ហោតិ ។បេ។ សង្ឃគារវោ ហោតិ សិក្ខាគារវោ ហោតិ សមាធិគារវោ ហោតិ សុវចោ ហោតិ កល្យាណមិត្តោ ហោតិ កល្យាណមិត្តតាយ ច វណ្ណវាទី

ជាអ្នកមានមិត្តល្អ ពណ៌នាគុណនៃការមានមិត្តល្អផង ភិក្ខុដទៃណា មិនទាន់មានមិត្តល្អ ក៏ដឹកនាំភិក្ខុទាំងនោះ ឲ្យមានមិត្តល្អផង ភិក្ខុដទៃណា មានមិត្តល្អហើយ ក៏ពណ៌នាគុណ របស់ភិក្ខុទាំងនោះ តាមសេចក្តីពិតមែន ក្នុងកាលគួរផង ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងដោយសេចក្តីសង្ខេបនេះឯង ខ្ញុំព្រះអង្គយល់សេចក្តីដោយពិស្តារយ៉ាងនេះ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់តបថា ម្នាលសារីបុត្ត ប្រពៃហើយ ៗ ម្នាលសារីបុត្ត ប្រពៃណាស់ហើយ ធម៌នេះតថាគតសំដែងហើយដោយសង្ខេប អ្នកយល់សេចក្តីដោយពិស្តារយ៉ាងនេះបាន ម្នាលសារីបុត្ត ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីគោរពព្រះសាស្តា ដោយខ្លួនឯងផង ពណ៌នាគុណនៃសេចក្តីគោរពព្រះសាស្តាផង ភិក្ខុដទៃណា មិនទាន់មានសេចក្តីគោរពព្រះសាស្តា ក៏ដឹកនាំភិក្ខុទាំងនោះ ឲ្យគោរពព្រះសាស្តាផង ភិក្ខុដទៃណា មានសេចក្តីគោរពព្រះសាស្តាហើយ ពណ៌នាគុណរបស់ភិក្ខុទាំងនោះ តាមសេចក្តីពិតមែន ក្នុងកាលគួរផង ។ ជាអ្នកមានសេចក្តីគោរពព្រះធម៌ ដោយខ្លួនឯងផង ។ បេ ។ ជាអ្នកមានសេចក្តីគោរពព្រះសង្ឃ មានសេចក្តីគោរពសិក្ខា មានសេចក្តីគោរពសមាធិ ជាអ្នកដែលគេប្រដៅងាយ ជាអ្នកមានមិត្តល្អផង ពណ៌នាគុណនៃការមានមិត្តល្អផង

យេ ចញ្ញេ ភិក្ខូ ន កល្យាណមិត្តា តេ ច កល្យាណមិត្តតាយ សមាទបេតិ យេ ចញ្ញេ ភិក្ខូ កល្យាណមិត្តា តេសញ្ច វណ្ណំ ភណតិ ភូតំ តច្ឆំ កាលេន ។ ឥមស្ស ខោ សារីបុត្ត មយា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។

(៣៣) សត្តហិ ភិក្ខវេ អង្គេហិ សមន្នាគតោ មិត្តោ សេវិតព្វោ ។ កតមេហិ សត្តហិ ។ ទុទ្ទទំ ទទាតិ ទុក្ករំ ករោតិ ទុក្ខមំ ខមតិ គុយ្ហមស្ស[1] អាវិករោតិ គុយ្ហមស្ស[2] បរិគូហតិ[3] អាបទាសុ ន ជហតិ ខីណេន នាតិមញ្ញតិ ។ ឥមេហិ ខោ ភិក្ខវេ សត្តហង្គេហិ សមន្នាគតោ មិត្តោ សេវិតព្វោតិ ។

ទុទ្ទទំ ទទតិ មិត្តំ　　ទុក្ករញ្ចាបិ កុព្វតិ
អថោបិស្ស ទុរុត្តានិ　　ខមតិ ទុក្ខមានិ ច
គុយ្ហមស្ស ច[4] អក្ខាតិ　　គុយ្ហស្ស បរិគូហតិ

---

១ ម. គុឡ្ហស្ស ។ ២ ម. គុឡ្ហស្ស ។ ៣ ឱ. ម. បរិគុឡ្ហតិ ។ ៤ ឱ. ម. គុឡ្ហញ្ចស្ស ។

ភិក្ខុដទៃណា មិនទាន់មានមិត្តល្អ ក៏ដឹកនាំភិក្ខុទាំងនោះ ឲ្យមានមិត្តល្អផង ភិក្ខុដទៃណា មានមិត្តល្អហើយ ក៏ពណ៌នាគុណរបស់ភិក្ខុទាំងនោះ តាមសេចក្តីពិតមែន ក្នុងកាលគួរផង ។ ម្នាលសារីបុត្ត ធម៌នេះឯង តថាគតសំដែងហើយ ដោយសេចក្តីសង្ខេប គប្បីយល់សេចក្តី ដោយពិស្តារយ៉ាងនេះ ។

[៣៣] ម្នាលភិក្ខុទាំងឡាយ មិត្តប្រកបដោយអង្គ ៧ ប្រការ គួរសេពគប់ ។ ប្រកបដោយអង្គ ៧ ប្រការ តើដូចម្តេចខ្លះ ។ គឺមិត្តឲ្យនូវរបស់ ដែលគេឲ្យបានដោយកម្រ ១ ធ្វើនូវអំពើដែលគេធ្វើបានដោយកម្រ ១ អត់ធន់បំពោះហេតុ ដែលគេអត់ធន់បានដោយកម្រ ១ បើកបង្ហាញសេចក្តីកំបាំងរបស់ខ្លួនដល់គ្នា ១ បិទសេចក្តីកំបាំងរបស់គ្នា ១ មិនលះគ្នា ក្នុងគ្រាមានសេចក្តីអន្តរាយ ១ មិនមើលងាយគ្នា ព្រោះអស់ភោគៈ ១ ។ ម្នាលភិក្ខុទាំងឡាយ មិត្តប្រកបដោយអង្គ ៧ ប្រការនេះឯង គួរសេពគប់ ។

មិត្តឲ្យនូវរបស់ដែលគេឲ្យ បានដោយកម្រផង ធ្វើនូវអំពើដែលគេ
ធ្វើបានដោយកម្រផង មួយទៀត អត់ធន់បំពោះពាក្យដែល
ពោលអាក្រក់ នឹងហេតុដែលអត់ធន់ បានដោយកម្រផង ប្រាប់
សេចក្តីកំបាំងរបស់ខ្លួនដល់គ្នាផង បិទសេចក្តីកំបាំងរបស់គ្នាផង

អាបទាសុ ន ជហាតិ ខីណេន នាតិមញ្ញតិ

យស្មឹ ឯតានិ ឋានានិ សំវិជ្ជន្តីធ បុគ្គលេ

សោ មិត្តោ មិត្តកាមេន ភជិតព្វោ តថាវិធោតិ ។

(៣៦) សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ មិត្តោ សេវិតព្វោ ភជិតព្វោ បយិរុបាសិតព្វោ អបិ បនុជ្ជមានេនបិ ។ កតមេហិ សត្តហិ ។ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ច វត្តា ច វចនក្ខមោ ច គម្ភីរញ្ច កថំ កត្តា ហោតិ នោ ច អដ្ឋានេ និយោជេតិ ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ ធម្មេហិ សមន្នាគតោ ភិក្ខុ មិត្តោ សេវិតព្វោ ភជិតព្វោ បយិរុបាសិតព្វោ អបិ បនុជ្ជមានេនបីតិ ។

មិនលះគ្នាក្នុងគ្រាមានសេចក្តីអន្តរាយផង មិនមើលងាយគ្នា ព្រោះអស់ភោគផង ហេតុទាំងនេះ មានក្នុងបុគ្គលណា ក្នុងលោកនេះ បុគ្គលមានសភាពដូច្នោះនោះ ហៅថាមិត្ត ជនអ្នកមានប្រាជ្ញា នូវមិត្ត គប្បីសេពគប់ ។

(៣៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាមិត្តប្រកបដោយធម៌ ៧ ប្រការ បុគ្គលអ្នកស្វែងមិត្ត ទោះបីលោកបណ្តេញបំបរបង់ចេញ(១) ក៏គួរតែសេពគប់ គប់រក ចូលទៅអង្គុយជិត ។ ប្រកបដោយធម៌ ៧ ប្រការ តើដូចម្តេចខ្លះ ។ គឺភិក្ខុជាអ្នក (ធ្វើខ្លួន) ឲ្យជាទីស្រឡាញ់ ទីនជាទីគាប់ចិត្ត ១ គួរគោរព ១ គួរសរសើរ ១ ខស្វាហ៍ប្រៀនប្រដៅ ១ អត់ធន់បំពោះពាក្យ ១ ជាអ្នកនិយាយពាក្យជ្រៅ(២) ១ មិនដឹកនាំក្នុងហេតុដែលមិនគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាមិត្តប្រកបដោយធម៌ ៧ ប្រការនេះឯង បុគ្គលអ្នកស្វែងមិត្ត បើទុកជាលោកបណ្តេញបំបរបង់ចេញ ក៏គួរតែសេពគប់ គប់រក ចូលទៅអង្គុយជិត ។

---

១ ក្នុងអដ្ឋកថាថា បើអ្នកស្វែងមិត្ត បានបុគ្គលយ៉ាងនេះជាមិត្តហើយ បើទុកជាលោកដាក់ទណ្ឌកម្មឲ្យលីឈើ១០០បាច់ក្តី ឲ្យដងទឹក១០០ក្អមក្តី ឲ្យជញ្ជូនខ្សាច់ ១០០ ស្អកក្តី ឬបណ្តេញមិនឲ្យនៅជាមួយក្តី ក៏ត្រូវតែសុំខមាទោសនឹងលោក ហើយតាមនៅជាមួយ ដរាបដល់អស់ជីវិត ។

២ បានដល់ពាក្យ អាថិកំបាំង គឺពាក្យដែលជាប់ទាក់ទង ដល់ឈានវិបស្សនាមគ្គផលនិព្វាន ។

## បឋមបណ្ណាសកេ ទេវតាវគ្គោ

បិយោ ច គរុ ភាវនីយោ វត្តា ច វចនក្ខមោ
គម្ភីរញ្ច កថំ កត្តា នោ ចដ្ឋានេ និយោជយេ(១)
យស្មឹ ឯតានិ ឋានានិ សំវិជ្ជន្តីធ(២) បុគ្គលេ
សោ មិត្តោ មិត្តកាមេន អត្ថកាមានុកម្បតោ
អបិ នាសិយមានេន ភជិតព្វោ តថាវិធោ ។

(៣៩) សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ នចិរស្សេវ ចតស្សោ បដិសម្ភិទា សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យ ។ កតមេហិ សត្តហិ ។ ឥធ ភិក្ខវេ ភិក្ខុ ឥទំ មេ ចេតសោ លីនត្តន្តិ យថាភូតំ បជានាតិ អជ្ឈត្តំ សង្ខិត្តំ វា ចិត្តំ អជ្ឈត្តំ មេ សង្ខិត្តំ ចិត្តន្តិ យថាភូតំ បជានាតិ ពហិទ្ធា វិក្ខិត្តំ វា ចិត្តំ ពហិទ្ធា មេ វិក្ខិត្តំ ចិត្តន្តិ យថាភូតំ បជានាតិ តស្ស វិទិតា វេទនា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ វិទិតា

---

១ ម. និយោជកោ ។ ២ ម. សំវិជ្ជន្តិ ប ។

ភិក្ខុជាអ្នក ( ធ្វើខ្លួន ) ឲ្យជាទីស្រឡាញ់ផង គួរគោរពផង គួរសរសើរផង ឧស្សាហ៍ប្រៀនប្រដៅផង អត់ធន់ចំពោះពាក្យផង ជាអ្នកនិយាយពាក្យជ្រៅផង ទាំងមិនដឹកនាំក្នុងហេតុដែលមិនគួរផង ហេតុទាំងនេះ មានក្នុងបុគ្គលណាក្នុងលោកនេះ បុគ្គលជាអ្នកប្រាថ្នានូវប្រយោជន៍ អ្នកធ្វើនូវសេចក្តីអនុគ្រោះ មានសភាពដូច្នោះនោះ ឈ្មោះថាជាមិត្ត បុគ្គលអ្នកមានសេចក្តីត្រូវការដោយមិត្ត ទោះបីជាលោកធ្វើឲ្យវិនាស ក៏គួរតែតាមសេពគប់ ។

(៣៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ ប្រការ មិនយូរប៉ុន្មាន នឹងធ្វើឲ្យជាក់ច្បាស់ សម្រេចនូវបដិសម្ភិទា ៤ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងមិនខាន ។ ប្រកបដោយធម៌ ៧ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះជាសេចក្តីប្រអូសចិត្តរបស់អញ ១ ឬចិត្តខាងក្នុងរួញរា ក៏ដឹងច្បាស់តាមពិតថា ចិត្តខាងក្នុងរបស់អញរួញរា ១ ឬចិត្តខាងក្រៅរាយមាយ ក៏ដឹងច្បាស់តាមពិតថា ចិត្តខាងក្រៅរបស់អញរាយមាយ ១ ភិក្ខុនោះដឹងនូវវេទនាទាំងឡាយដែលកើតឡើង ដឹងនូវវេទនាទាំងឡាយប្រាកដឡើង ដឹងនូវវេទនាទាំងឡាយ ដែលដល់នូវសេចក្តីវិនាស ១

សញ្ញា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ វិទិតា វិតក្កា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ សប្បាយាសប្បាយេសុ ខោ បនស្ស ធម្មេសុ ហីនប្បណីតេសុ កណ្ហសុក្កសប្បដិភាគេសុ និមិត្តំ សុគ្គហិតំ ហោតិ សុមនសិកតំ សូបធារិតំ សុប្បដិវិទ្ធំ បញ្ញាយ ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ ធម្មេហិ សមន្នាគតោ ភិក្ខុ នចិរស្សេវ ចតស្សោ បដិសម្ភិទា សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យាតិ ។

(៣៦) សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ សារីបុត្តោ ចតស្សោ បដិសម្ភិទា សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ កតមេហិ សត្តហិ ។ ឥធ ភិក្ខវេ សារីបុត្តោ ឥទម្មេ ចេតសោ លីនត្តន្តិ យថាភូតំ បជានាតិ អជ្ឈត្តំ សង្ខិត្តំ វា ចិត្តំ អជ្ឈត្តំ មេ សង្ខិត្តំ ចិត្តន្តិ យថាភូតំ បជានាតិ ពហិទ្ធា វា វិក្ខិត្តំ ចិត្តំ ពហិទ្ធា មេ វិក្ខិត្តំ ចិត្តន្តិ យថាភូតំ បជានាតិ តស្ស វិទិតា វេទនា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ វិទិតា

ដឹងនូវសញ្ញាទាំងឡាយដែលកើតឡើង ដឹងនូវសញ្ញាទាំងឡាយដែលប្រាកដឡើង ដឹងនូវសញ្ញាទាំងឡាយដែលដល់នូវសេចក្តីវិនាស ១ ដឹងនូវវិតក្កៈទាំងឡាយដែលកើតឡើង ដឹងនូវវិតក្កៈទាំងឡាយដែលប្រាកដឡើង ដឹងនូវវិតក្កៈទាំងឡាយដែលដល់នូវសេចក្តីវិនាស ១ ហេតុក្នុងធម៌ជាទីសប្បាយ ឬមិនជាទីសប្បាយ ថោកទាប ឬខ្ពង់ខ្ពស់ជាចំណែកខ្មៅឬស ភិក្ខុនោះបានកំណត់ទុកល្អ ធ្វើទុកក្នុងចិត្តល្អ ចងចាំល្អ ដឹងច្បាស់ល្អហើយ ដោយប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ ប្រការនេះឯង មិនយូរប៉ុន្មាននឹងធ្វើឲ្យជាក់ច្បាស់ សម្រេចនូវបដិសម្ភិទា ៤ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងមិនខាន ។

(៣៦) ម្នាលភិក្ខុទាំងឡាយ សារីបុត្តប្រកបដោយធម៌ ៧ ប្រការ ទើបធ្វើឲ្យជាក់ច្បាស់ សម្រេចនូវបដិសម្ភិទា ៤ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ។ ប្រកបដោយធម៌ ៧ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ សារីបុត្តដឹងច្បាស់តាមពិតថា នេះជាសេចក្តីប្រួញចិត្តរបស់អញ ១ ឬចិត្តខាងក្នុងរួញរា ក៏ដឹងច្បាស់តាមពិតថា ចិត្តខាងក្នុងរបស់អញរួញរា ១ ឬចិត្តខាងក្រៅរាយមាយ ក៏ដឹងច្បាស់តាមពិតថា ចិត្តខាងក្រៅរបស់អញរាយមាយ ១ ព្រះសារីបុត្តដឹងនូវវេទនាទាំងឡាយដែលកើតឡើង ដឹងនូវវេទនាដែលប្រាកដឡើង ដឹងនូវវេទនាដែលដល់នូវសេចក្តីវិនាស

សញ្ញា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ វិទិតា វិតក្កា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ សប្បាយាសប្បាយេសុ ខោ បនស្ស ធម្មេសុ ហីនប្បណីតេសុ កណ្ហសុក្កសប្បដិភាគេសុ និមិត្តំ សុគ្គហិតំ ហោតិ សុមនសិកតំ សូបធារិតំ សុប្បដិវិទ្ធំ បញ្ញាយ ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ ធម្មេហិ សមន្នាគតោ សារីបុត្តោ ចតស្សោ បដិសម្ភិទា សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។

(៣៧) សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ចិត្តំ វសេ វត្តេតិ នោ ច ភិក្ខុ ចិត្តស្ស វសេន វត្តតិ ។ កតមេហិ សត្តហិ ។ ឥធ ភិក្ខវេ ភិក្ខុ សមាធិកុសលោ ហោតិ សមាធិស្ស សមាបត្តិកុសលោ ហោតិ សមាធិស្ស ឋិតិកុសលោ ហោតិ សមាធិស្ស វុដ្ឋានកុសលោ ហោតិ សមាធិស្ស កល្លិតកុសលោ(១) ហោតិ

---

១ ម. កល្យាណកុសលោ ។ កល្លតាកុសលោតិ អនុត្តរិយវគ្គេ ឆក្កនិបាតវណ្ណនាយំ ទិស្សតិ ។

ដឹងនូវសញ្ញាទាំងឡាយដែលកើតឡើង ដឹងនូវសញ្ញាដែលប្រាកដឡើង ដឹងនូវសញ្ញាដែលដល់នូវសេចក្ដីវិនាស ១ ដឹងនូវវិតក្កៈទាំងឡាយដែលកើតឡើង ដឹងនូវវិតក្កៈដែលប្រាកដឡើង ដឹងនូវវិតក្កៈដែលដល់នូវសេចក្ដីវិនាស ១ ហេតុក្នុងធម៌ជាទីសប្បាយ ឬ មិនជាទីសប្បាយ ថោកទាប ឬខ្ពង់ខ្ពស់ ជាចំណែកខ្មៅ ឬស ក៏សារីបុត្តបានកំណត់ទុកល្អ ធ្វើទុកក្នុងចិត្តល្អ ចងចាំល្អ ដឹងច្បាស់ល្អហើយ ដោយប្រាជ្ញា ១ ៗ ម្នាលភិក្ខុទាំងឡាយ សារីបុត្តប្រកបដោយធម៌៧ ប្រការនេះឯង ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវបដិសម្ភិទា ៤ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ៗ

( ៣៧ ) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ ប្រការ រមែងញុំាងចិត្តឲ្យលុះក្នុងអំណាច ( របស់ខ្លួន ) បាន មិនមែនភិក្ខុលុះអំណាចចិត្តទេ ៗ ប្រកបដោយធម៌ ៧ ប្រការ តើដូចម្ដេចខ្លះ ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកឈ្លាសវៃ ក្នុងសមាធិ ១ ឈ្លាសវៃ ក្នុងវិធីចូលសមាធិ ១ ឈ្លាសវៃ ក្នុងវិធីដំកល់ទុកសមាធិ ១ ឈ្លាសវៃ ក្នុងវិធីចេញចាកសមាធិ ១ ឈ្លាសវៃ ក្នុងវិធីបែករលែកនូវសមាធិ ១

សមាធិស្ស គោចរកុសលោ ហោតិ សមាធិស្ស អភិនីហារកុសលោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ចិត្តំ វសេ វត្តេតិ នោ ច ភិក្ខុ ចិត្តស្ស វសេន វត្តតីតិ ។

(៣៨) សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ សារីបុត្តោ ចិត្តំ វសេ វត្តេតិ នោ ច សារីបុត្តោ ចិត្តស្ស វសេន វត្តតិ ។ កតមេហិ សត្តហិ ។ ឥធ ភិក្ខវេ សារីបុត្តោ សមាធិកុសលោ ហោតិ សមាធិស្ស សមាបត្តិកុសលោ សមាធិស្ស ឋិតិកុសលោ សមាធិស្ស វុដ្ឋានកុសលោ សមាធិស្ស កល្លិតកុសលោ សមាធិស្ស គោចរកុសលោ សមាធិស្ស អភិនីហារ-កុសលោ ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ ធម្មេហិ សមន្នាគតោ សារីបុត្តោ ចិត្តំ វសេ វត្តេតិ នោ ច សារីបុត្តោ ចិត្តស្ស វសេន វត្តតីតិ ។

ឈ្លាសវៃ ក្នុងទីគោចរនៃសមាធិ(១) ១ ឈ្លាសវៃ ក្នុងវិធីនាំមកនូវសមាធិ(២) ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ ប្រការនេះឯង រមែងញ៉ាំងចិត្តឲ្យលុះក្នុងអំណាច (របស់ខ្លួន) បាន មិនមែនភិក្ខុលុះអំណាចចិត្តទេ ។

[ ៣៨ ] ម្នាលភិក្ខុទាំងឡាយ សារីបុត្តប្រកបដោយធម៌ ៧ ប្រការ ទើបញ៉ាំងចិត្តឲ្យលុះក្នុងអំណាច ( របស់ខ្លួន ) មិនមែនសារីបុត្តលុះអំណាចចិត្តទេ ។ ប្រកបដោយធម៌ ៧ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ សារីបុត្ត ជាអ្នកឈ្លាសវៃ ក្នុងសមាធិ ១ ឈ្លាសវៃ ក្នុងវិធីចូលសមាធិ ១ ឈ្លាសវៃ ក្នុងវិធីដំកល់ទុកសមាធិ ១ ឈ្លាសវៃ ក្នុងវិធីចេញចាកសមាធិ ១ ឈ្លាសវៃ ក្នុងវិធីចែករំលែកសមាធិ ១ ឈ្លាសវៃ ក្នុងទីគោចរនៃសមាធិ ១ ឈ្លាសវៃ ក្នុងវិធីនាំមកនូវសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ សារីបុត្តប្រកបដោយធម៌ ៧ ប្រការនេះឯង ទើបញ៉ាំងចិត្តឲ្យលុះទៅក្នុងអំណាច ( របស់ខ្លួន ) មិនមែនសារីបុត្តលុះអំណាចចិត្តទេ ។

---

១- ភិក្ខុណាវៀរសព្វធម៌មិនជាទីសប្បាយ សេពគប់ធម៌ជាទីសប្បាយក្តី ស្គាល់ថាសមាធិនេះមាននិមិត្តជាអារម្មណ៍ នេះមានលក្ខណៈជាអារម្មណ៍ក្តី ឈ្មោះថាអ្នកឈ្លាសវៃ ក្នុងទីគោចរនៃសមាធិ ។ អដ្ឋកថា នៃឆក្កនិបាត ។ ២- ភិក្ខុដែលអាចប្រមូលសមាធិ ដែលកើតអំពីឈានមានបឋមជ្ឈានជាដើម ដើម្បីនឹងចូលកាន់សមាបត្តិជាន់ខ្ពស់ៗ ហៅថាអ្នកឈ្លាសវៃក្នុងការនាំសមាធិ ព្រោះលោកចេញអំពីបឋមជ្ឈាន ចូលទុតិយជ្ឈាន ។បេ។ ចេញអំពីតតិយជ្ឈាន ចូលកាន់ចតុត្ថជ្ឈាន ។ អដ្ឋកថានៃឆក្កនិបាត ។

(៣៩) អថខោ អាយស្មា សារីបុត្តោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ ។ អថខោ អាយស្មតោ សារីបុត្តស្ស ឯតទហោសិ អតិប្បគោ ខោ តាវ សាវត្ថិយំ បិណ្ឌាយ ចរិតុំ យន្នូនាហំ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមេយ្យន្តិ ។ អថខោ អាយស្មា សារីបុត្តោ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមិ ឧបសង្កមិត្វា តេហិ អញ្ញតិត្ថិយេហិ បរិព្វាជកេហិ សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ តេន ខោ បន សមយេន តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ យោ ហិ កោចិ អាវុសោ ទ្វាទស វស្សានិ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរតិ និទ្ទសោ ភិក្ខូតិ អលំ វចនាយាតិ ។ អថខោ អាយស្មា សារីបុត្តោ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ភាសិតំ នេវ អភិនន្ទិ នប្បដិក្កោសិ អនភិនន្ទិត្វា អប្បដិក្កោសិត្វា ឧដ្ឋាយាសនា បក្កាមិ

[ ៣៩ ] គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ដំណើរត្រាច់ទៅ ដើម្បីបិណ្ឌបាតក្នុងក្រុងសាវត្ថីព្រឹកណាស់នៅឡើយ បើដូច្នោះ អញគួរឈៀងចូលទៅ ឯអារាមរបស់បរិព្វាជកជាអន្យតិរ្ថិយសិន ។ ទើបព្រះសារីបុត្តដ៏មានអាយុ ចូលទៅឯអារាមរបស់ពួកបរិព្វាជក ជាអន្យតិរ្ថិយ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យដែលគួររលឹកហើយ ក៏គង់នៅក្នុងទីសមគួរ ។ ក៏ក្នុងសម័យនោះឯង ពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះអង្គុយប្រជុំគ្នា ហើយបានផ្តើមសួរពាក្យ ជាបន្ទោះនេះថា ម្នាលអាវុសោទាំងឡាយ បុគ្គលណាមួយ ប្រព្រឹត្តព្រហ្មចរិយធម៌ បរិសុទ្ធ ពេញលេញអស់ ១២ ឆ្នាំ គេគួរនឹងហៅបុគ្គលនោះ ថាជាភិក្ខុមិនមានអាយុ ១០ ឆ្នាំបានឬទេ ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ មិនបានត្រេកអរ មិនបានហាមឃាត់នូវភាសិតរបស់ពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះឡើយ លុះមិនត្រេកអរ មិនហាមឃាត់ ហើយក្រោកចាកអាសនៈ ដើរចេញទៅ

ភគវតោ សន្តិកេ ឯតស្ស ភាសិតស្ស អត្ថំ អាជានិស្សាមីតិ ។ អថខោ អាយស្មា សារីបុត្តោ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតបដិក្កន្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសឹ តស្ស មយ្ហំ ភន្តេ ឯតទហោសិ អតិប្បគោ ខោ តាវ សាវត្ថិយំ បិណ្ឌាយ ចរិតុំ យន្នូនាហំ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមេយ្យន្តិ អថខ្វាហំ ភន្តេ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមឹ ឧបសង្កមិត្វា តេហិ អញ្ញតិត្ថិយេហិ បរិព្វាជកេហិ សទ្ធឹ សម្មោទឹ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹ តេន ខោ បន ភន្តេ សមយេន

ដោយមានបំណងថា អញគង់នឹងយល់នូវសេចក្តីនៃភាសិតនុ៎ះ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ។ ទើបព្រះសារីបុត្តដ៏មានអាយុ ត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងក្រុងសាវត្ថី លុះត្រឡប់មកអំពីបិណ្ឌបាត ក្នុងកាល ជាខាងក្រោយភត្តវិញ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចគង់នៅក្នុងទីសមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុ គង់នៅក្នុងទីសមគួរហើយ ក៏បានក្រាបបង្គំទូលនូវដំណើរនោះ ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យហើយចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះ មានសេចក្តីត្រិះរិះដូច្នេះថា ដំណើរត្រាច់ទៅដើម្បីបិណ្ឌបាត ក្នុងក្រុងសាវត្ថីព្រឹកណាស់នៅឡើយ បើដូច្នោះ អញគួរជៀងចូលទៅឯអារាមរបស់បរិព្វាជក ជាអន្យតិរ្ថិយសិន បពិត្រព្រះអង្គដ៏ចំរើន លំដាប់នោះ ខ្ញុំព្រះអង្គក៏បានចូលទៅឯអារាមរបស់ពួកបរិព្វាជកជាអន្យតិរ្ថិយ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងពួកបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ លុះបញ្ចប់ពាក្យ ដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ បពិត្រព្រះអង្គដ៏ចំរើន សម័យនោះឯង

តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ យោ ហិ កោចិ អាវុសោ ទ្វាទស វស្សានិ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរតិ និទ្ទសោ ភិក្ខូតិ អលំ វចនាយាតិ អថ ខ្វាហំ ភន្តេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ភាសិតំ នេវ អភិនន្ទឹ នប្បដិក្កោសឹ អនភិនន្ទិត្វា អប្បដិក្កោសិត្វា ឧដ្ឋាយាសនា បក្កាមឹ ភគវតោ សន្តិកេ ឯតស្ស ភាសិតស្ស អត្ថំ អាជានិស្សាមីតិ ។ សក្កា នុ ខោ ភន្តេ ឥមស្មឹ ធម្មវិនយេ កេវលំ វស្សគណនមត្តេន និទ្ទសោ ភិក្ខុ បញ្ញបេតុន្តិ ។ ន ខោ សារីបុត្ត សក្កា ឥមស្មឹ ធម្មវិនយេ កេវលំ វស្សគណនមត្តេន និទ្ទសោ ភិក្ខុ បញ្ញបេតុំ ។ សត្ត ខោ ឥមានិ សារីបុត្ត និទ្ទសវត្ថូនិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានិ ។ កតមានិ សត្ត ។ ឥធ សារីបុត្ត ភិក្ខុ

ពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ អង្គុយប្រជុំគ្នា បានផ្តើមពាក្យជាបន្ទោះនេះថា ម្នាលអាវុសោទាំងឡាយ បុគ្គលណាមួយប្រព្រឹត្តព្រហ្មចរិយធម៌ បរិសុទ្ធ ពេញលេញ អស់ ១២ ឆ្នាំ គេគួរនឹងហៅបុគ្គលនោះ ថាជាភិក្ខុមិនមានអាយុ ១០ ឆ្នាំ បានឬទេ បពិត្រព្រះអង្គដ៏ចំរើន វេលានោះ ខ្ញុំព្រះអង្គ មិនបានត្រេកអរ មិនបានហាមឃាត់នូវភាសិតរបស់ពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះឡើយ លុះមិនបានត្រេកអរ មិនបានហាមឃាត់ហើយ ក៏ក្រោកចាកអាសនៈដើរចេញទៅ ដោយមានបំណងថា អញនឹងយល់នូវសេចក្តីនៃភាសិតនុ៎ះ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចំរើន ចុះក្នុងធម្មវិន័យនេះ បុគ្គលអាចនឹងបញ្ញត្ត (ខ្លួន) ថាជាភិក្ខុមិនមានអាយុ ១០ ឆ្នាំ ដោយគ្រាន់តែរាប់ឆ្នាំប៉ុណ្ណោះ បានដែរឬ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់តបថា ម្នាលសារីបុត្ត ក្នុងធម្មវិន័យនេះ បុគ្គលមិនអាចនឹងបញ្ញត្ត (ខ្លួន) ថាជាភិក្ខុមិនមានអាយុ ១០ ឆ្នាំ ដោយគ្រាន់តែរាប់ឆ្នាំប៉ុណ្ណោះបានឡើយ ។ ម្នាលសារីបុត្ត និទ្ទសវត្ថុ ៧ ប្រការនេះឯង តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយប្រកាសទុក ។ និទ្ទសវត្ថុ ៧ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលសារីបុត្ត ភិក្ខុក្នុងសាសនានេះ

សិក្ខាសមាទានេ តិព្វច្ឆន្ទោ ហោតិ អាយតិញ្ច សិក្ខាសមាទានេ អវិគតប្បេមោ ធម្មនិសន្តិយា តិព្វច្ឆន្ទោ ហោតិ អាយតិញ្ច ធម្មនិសន្តិយា អវិគតប្បេមោ ឥច្ឆាវិនយេ តិព្វច្ឆន្ទោ ហោតិ អាយតិញ្ច ឥច្ឆាវិនយេ អវិគតប្បេមោ បដិសល្លានេ តិព្វច្ឆន្ទោ ហោតិ អាយតិញ្ច បដិសល្លានេ អវិគតប្បេមោ វីរិយារម្ភេ តិព្វច្ឆន្ទោ ហោតិ អាយតិញ្ច វីរិយារម្ភេ អវិគតប្បេមោ សតិនេបក្កេ តិព្វច្ឆន្ទោ ហោតិ អាយតិញ្ច សតិនេបក្កេ អវិគតប្បេមោ ទិដ្ឋិប្បដិវេធេ តិព្វច្ឆន្ទោ ហោតិ អាយតិញ្ច ទិដ្ឋិប្បដិវេធេ អវិគតប្បេមោ ។ ឥមានិ ខោ សារីបុត្ត សត្ត និទ្ទសវត្ថូនិ

ជាអ្នកមានសេចក្តីពេញចិត្តខ្លាំងក្នុងការសមាទាននូវសិក្ខា តទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការសមាទាននូវសិក្ខា ១ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំង ក្នុងការពិចារណានូវធម៌ តទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការពិចារណានូវធម៌ ១ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំង ក្នុងការកំចាត់បង់នូវឥច្ឆា គឺតណ្ហា តទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការកំចាត់បង់នូវឥច្ឆា ១ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំង ក្នុងការពួនសម្ងំ តទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការពួនសម្ងំ ១ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំង ក្នុងការប្រារព្ធព្យាយាម តទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការប្រារព្ធព្យាយាម ១ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំង ក្នុងការតាំងស្មារតី នឹងការជាអ្នកមានប្រាជ្ញាចាស់ក្លា តទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការតាំងស្មារតី នឹងការជាអ្នកមានប្រាជ្ញាចាស់ក្លា ១ ជាអ្នកមានសេក្តីពេញចិត្តខ្លាំង ក្នុងការចាក់ធ្លុះដោយទិដ្ឋិ គឺឃើញច្បាស់នូវមគ្គ តទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការចាក់ធ្លុះដោយទិដ្ឋិ ១ ។ ម្នាលសារីបុត្ត និទ្ទសវត្ថុ ៧ ប្រការនេះឯង

មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានិ ។ ឥមេហិ ខោ សារីបុត្ត សត្តហិ និទ្ទសវត្ថូហិ សមន្នាគតោ ភិក្ខុ ទ្វាទស ចេបិ វស្សានិ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរតិ និទ្ទសោ ភិក្ខូតិ អលំ វចនាយ ចតុវីសតិ ចេបិ វស្សានិ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរតិ និទ្ទសោ ភិក្ខូតិ អលំ វចនាយ ឆត្តឹសតិ ចេបិ វស្សានិ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរតិ និទ្ទសោ ភិក្ខូតិ អលំ វចនាយ អដ្ឋចត្តាឡីសញ្ចេបិ វស្សានិ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរតិ និទ្ទសោ ភិក្ខូតិ អលំ វចនាយាតិ ។

(៤០) ឯកំ សមយំ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ អថខោ អាយស្មា អានន្ទោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ កោសម្ពឹ បិណ្ឌាយ បាវិសិ ។ អថខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ អតិប្បគោ ខោ តាវ កោសម្ពិយំ បិណ្ឌាយ ចរិតុំ យន្នូនាហំ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមេយ្យន្តិ ។ អថខោ អាយស្មា អានន្ទោ

ដែលតថាគតធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងហើយ ប្រកាសទុក ។ ម្នាលសារីបុត្ត កិច្ចប្រកបដោយនិទ្ទសវត្ថុ ៧ ប្រការនេះ បើទុកជាប្រព្រឹត្តព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ ពេញលេញ អស់ ១២ ឆ្នាំ ក៏គួរហៅថា កិច្ចមិនមានអាយុ ១២ ឆ្នាំបាន បើទុកជាប្រព្រឹត្តព្រហ្មចរិយ-ធម៌ ដ៏បរិសុទ្ធពេញលេញ អស់ ២៤ ឆ្នាំ ក៏គួរហៅថា កិច្ចមិនមានអាយុ ១០ ឆ្នាំបាន បើទុកជាប្រព្រឹត្តព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ពេញលេញ អស់ ៣៦ ឆ្នាំ ក៏គួរហៅថា កិច្ចមិនមានអាយុ ១០ ឆ្នាំបាន បើទុកជាប្រព្រឹត្តព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ពេញលេញ អស់ ៤៨ ឆ្នាំ ក៏គួរហៅថា កិច្ចមិនមានអាយុ ១០ ឆ្នាំបាន ។

(៤០) សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ គ្រានោះឯង ព្រះអានន្ទដ៏មានអាយុស្លៀកស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ក្រុងកោសម្ពី ដើម្បីបិណ្ឌបាត ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុមានសេចក្តីត្រិះរិះថា ដំណើរត្រាច់ទៅ ដើម្បីបិណ្ឌបាត ក្នុងក្រុងកោសម្ពីព្រឹកណាស់នៅឡើយ បើដូច្នោះ អញគួរតៀងចូលទៅឯអារាមរបស់ពួកបរិព្វាជក ជាអន្យតិរ្ថិយសិន ។ ទើបព្រះអានន្ទ ដ៏មានអាយុ

យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុប-សង្កមិ ឧបសង្កមិត្វា តេហិ អញ្ញតិត្ថិយេហិ បរិ-ព្វាជកេហិ សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ តេន ខោ បន សមយេន តេសំ អញ្ញតិត្ថិយានំ បរិ-ព្វាជកានំ សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ យោ ហិ កោចិ អាវុសោ ទ្វាទស វស្សានិ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរតិ និទ្ទេសោ ភិក្ខូតិ អលំ វចនាយាតិ ។ អថខោ អាយស្មា អានន្ទោ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ភាសិតំ នេវ អភិ-នន្ទិ នប្បដិក្កោសិ អនភិនន្ទិត្វា អប្បដិក្កោសិត្វា ឧដ្ឋាយាសនា បក្កាមិ ភគវតោ សន្តិកេ ឯតស្ស ភាសិតស្ស អត្ថំ អាជានិស្សាមីតិ ។ អថខោ អាយស្មា អានន្ទោ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ

ចូលទៅឯអាកាមរបស់ពួកបរិព្វាជក ជាអន្យតិរ្ថិយ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកហើយ ក៏គង់ក្នុងទីសមគួរ ។ ក៏ក្នុងសម័យនោះឯង ពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ អង្គុយប្រជុំគ្នា ហើយបានផ្តើមសួរពាក្យ ជាបន្ទោះនេះថា ម្នាលអាវុសោទាំងឡាយ បុគ្គលណាមួយ ប្រព្រឹត្តព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ ពេញលេញ អស់ ១២ ឆ្នាំ តើគួរនឹងហៅ (បុគ្គលនោះ) ថាជាភិក្ខុមិនមានអាយុ ១០ ឆ្នាំ បានដែរឬ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ មិនត្រេកអរ មិនហាមឃាត់នូវភាសិតរបស់ពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះឡើយ លុះមិនត្រេកអរ មិនហាមឃាត់ ហើយក្រោកចាកអាសនៈដើរចេញទៅ ដោយមានបំណងថា អញគង់នឹងយល់នូវសេចក្តីនៃភាសិតនុ៎ះ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ។ ទើបព្រះអានន្ទដ៏មានអាយុ ត្រាច់ទៅ ដើម្បីបិណ្ឌបាត ក្នុងក្រុងកោសម្ពី លុះត្រឡប់មក អំពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយភត្ត ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចគង់ក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ គង់ក្នុងទីសមគួរហើយ

## បឋមបណ្ណាសកេ ទេវតាវគ្គោ

ភគវន្តំ ឯតទវោច ឯកាហំ ភន្តេ បុព្វណ្ហសមយំ
និវាសេត្វា បត្តចីវរមាទាយ កោសម្ពឹ បិណ្ឌាយ បាវិសឹ
តស្ស មយ្ហំ ភន្តេ ឯតទហោសិ អតិប្បគោ ខោ
តាវ កោសម្ពិយំ បិណ្ឌាយ ចរិតុំ យន្នូនាហំ យេន
អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្ក-
មេយ្យន្តិ អថខ្វាហំ ភន្តេ យេន អញ្ញតិត្ថិយានំ បរិ-
ព្វាជកានំ អារាមោ តេនុបសង្កមឹ ឧបសង្កមិត្វា តេហិ
អញ្ញតិត្ថិយេហិ បរិព្វាជកេហិ សទ្ធឹ សម្មោទឹ សម្មោ
ទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ
និសីទឹ តេន ខោ បន ភន្តេ សមយេន តេសំ
អញ្ញតិត្ថិយានំ បរិព្វាជកានំ សន្និសិន្នានំ សន្និបតិតានំ
អយមន្តរាកថា ឧទបាទិ យោ ហិ កោចិ អាវុសោ
ទ្វាទស វស្សានិ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ
ចរតិ និទ្ទសោ ភិក្ខូតិ អលំ វចនាយាតិ
អថខ្វាហំ ភន្តេ តេសំ អញ្ញតិត្ថិយានំ បរិ-
ព្វាជកានំ ភាសិតំ នេវ អភិនន្ទឹ នប្បដិក្កោសឹ

## បឋមបណ្ណាសក ទេវតាវគ្គ

កំបានក្រាបបង្គំទូលនូវដំណើរនោះចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ក្រុងកោសម្ពី ដើម្បីបិណ្ឌបាត បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះ មានសេចក្តីត្រិះរិះដូច្នេះថា ដំណើរគ្រាប់ទៅ ដើម្បីបិណ្ឌបាត ក្នុងក្រុងកោសម្ពី ព្រឹកណាស់ទៅទៀយ បើដូច្នោះ អញគួរតែនឹងចូលទៅឯអារាមរបស់ពួកបរិព្វាជក ជាអន្យតិរ្ថិយសិន បពិត្រព្រះអង្គដ៏ចំរើន លំដាប់នោះ ខ្ញុំព្រះអង្គបានចូលទៅឯអារាមរបស់បរិព្វាជក ជាអន្យតិរ្ថិយ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យ ដែលគួររលឹកហើយ ក៏អង្គុយ ក្នុងទីសមគួរ បពិត្រព្រះអង្គដ៏ចំរើន ក្នុងសម័យនោះឯង ពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ អង្គុយប្រជុំគ្នា ហើយបានផ្តើមនូវពាក្យ ជាចន្លោះនេះថា ម្នាលអាវុសោទាំងឡាយ បុគ្គលណាមួយ ប្រព្រឹត្តព្រហ្មចរិយធម៌បរិសុទ្ធ ពេញលេញអស់ ១២ ឆ្នាំ គេគួរនឹងហៅបុគ្គលនោះ ថាជាភិក្ខុមិនមានអាយុ ១០ ឆ្នាំបានដែរឬ បពិត្រព្រះអង្គដ៏ចំរើន លំដាប់នោះ ខ្ញុំព្រះអង្គ មិនត្រេកអរ មិនហាមឃាត់នូវភាសិតរបស់ពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះទៀយ

អនភិនន្ទិត្វា អប្បដិក្កោសិត្វា ឧដ្ឋាយាសនា បក្កាមិ ភគវតោ សន្តិកេ ឯតស្ស ភាសិតស្ស អត្ថំ អាជានិស្សាមីតិ ។ សក្កា នុ ខោ ភន្តេ ឥមស្មឹ ធម្មវិនយេ កេវលំ វស្សគណនមត្តេន និទ្ទសោ ភិក្ខុ បញ្ញាបេតុន្តិ ។ ន ខោ អានន្ទ សក្កា ឥមស្មឹ ធម្មវិនយេ កេវលំ វស្សគណនមត្តេន និទ្ទសោ ភិក្ខុ បញ្ញាបេតុំ ។ សត្ត ខោ ឥមានិ អានន្ទ និទ្ទស-វត្ថូនិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានិ ។ កតមានិ សត្ត ។ ឥធានន្ទ ភិក្ខុ សទ្ធោ ហោតិ ហិរិមា ហោតិ ឱត្តប្បី ហោតិ ពហុស្សុតោ ហោតិ អារទ្ធវិរិយោ ហោតិ សតិមា ហោតិ បញ្ញវា ហោតិ ។ ឥមានិ ខោ អានន្ទ សត្ត និទ្ទសវត្ថូនិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានិ ។ ឥមេហិ ខោ អានន្ទ សត្តហិ និទ្ទសវត្ថូហិ សមន្នាគតោ ភិក្ខុ

លុះមិនត្រេកអរ មិនហាមឃាត់ហើយ ក៏ក្រោកចាកអាសនៈ ដើរចេញទៅដោយមានបំណងថា អញគង់នឹងយល់នូវសេចក្តីនៃភាសិតនុ៎ះ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចំរើន ចុះក្នុងធម្មវិន័យនេះ បុគ្គលអាចប្តេជ្ញា (ខ្លួន) ថាជាភិក្ខុ មិនមានអាយុ ១០ ឆ្នាំ ដោយគ្រាន់តែកប់ឆ្នាំប៉ុណ្ណោះបានដែរឬ ។ ព្រះដ៏មានព្រះភាគត្រាស់តបថា ម្នាលអានន្ទ ក្នុងធម្មវិន័យនេះ បុគ្គលមិនអាចនឹងប្តេជ្ញាខ្លួនថាជាភិក្ខុមិនមានអាយុ ១០ ឆ្នាំ ដោយគ្រាន់តែកប់ឆ្នាំប៉ុណ្ណោះបានឡើយ ។ ម្នាលអានន្ទ និទ្ទសវត្ថុ ៧ ប្រការនេះឯង តថាគតបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងហើយប្រកាសទុក ។ និទ្ទសវត្ថុ ៧ ប្រការតើដូចម្តេចខ្លះ ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីជឿ ១ មានសេចក្តីខ្មាសបាប ១ មានសេចក្តីខ្លាចបាប ១ មានការចេះដឹងច្រើន ១ ជាអ្នកប្រារព្ធសេចក្តីព្យាយាម ១ មានស្មារតី ១ មានប្រាជ្ញា ១ ។ ម្នាលអានន្ទ និទ្ទសវត្ថុ ៧ ប្រការនេះឯង ដែលតថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយប្រកាសទុក ។ ម្នាលអានន្ទ ភិក្ខុប្រកបដោយនិទ្ទសវត្ថុ ៧ ប្រការនេះឯង

ទ្វាទស ចេបិ វស្សានិ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរតិ និទ្ទសោ ភិក្ខូតិ អលំ វចនាយ ចតុវីសតិ ចេបិ វស្សានិ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរតិ និទ្ទសោ ភិក្ខូតិ អលំ វចនាយ ឆត្តឹសតិ ចេបិ វស្សានិ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរតិ និទ្ទសោ ភិក្ខូតិ អលំ វចនាយ អដ្ឋចត្តាឡីសញ្ចេបិ វស្សានិ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរតិ និទ្ទសោ ភិក្ខូតិ អលំ វចនាយាតិ ។

ទេវតាវគ្គោ ចតុត្ថោ ។

## តស្សុទ្ទានំ

អប្បមាទោ ហិរីមា ច ទ្វេ សុវចា ទុវេ សខា

ទ្វេ បដិសម្ភិទា ទ្វេ វសា និទ្ទសវត្ថុបរេ ទ្វេតិ(១) ។

---

១ ម. អប្បមាទំ ហិរោត្តប្បំ សុវចោ ច គារវចស្សំ វិត្ថតំ ទ្វេ មិត្តា ទ្វេ បដិសម្ភិទា ទ្វេ សមាធិ ច និទ្ទិដ្ឋា និទ្ទសវត្ថុ អបរេ ទ្វេតិ ។

បើទុកជាប្រព្រឹត្តព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ ពេញលេញ អស់១២ ឆ្នាំ ក៏គួរហៅថា ភិក្ខុមិនមានអាយុ ១០ ឆ្នាំបាន បើទុកជាប្រព្រឹត្ត ព្រហ្ម-ចរិយធម៌ ដ៏បរិសុទ្ធ ពេញលេញ អស់ ២៤ ឆ្នាំ ក៏គួរហៅថាភិក្ខុមិនមានអាយុ ១០ ឆ្នាំបាន បើទុកជាប្រព្រឹត្តព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ ពេញលេញអស់ ៣៦ ឆ្នាំ ក៏គួរហៅថាភិក្ខុមិនមានអាយុ ១០ ឆ្នាំបាន បើទុកជាប្រព្រឹត្តព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ ពេញលេញ អស់ ៤៨ ឆ្នាំ ក៏គួរហៅថា ភិក្ខុមិនមានអាយុ ១០ ឆ្នាំបាន ។

ចប់ ទេវតាវគ្គទី ៤ ។

## ឧទ្ទាននៃទេវតាវគ្គនោះគឺ

និយាយពីភិក្ខុមិនមានសេចក្តីប្រមាទ ១ ភិក្ខុមានសេចក្តីខ្មាសបាប ១ ភិក្ខុអ្នកប្រដៅងាយ ២ លើក សំឡាញ់ ២ លើក បដិសម្ភិទា ២ លើក ភិក្ខុលុះអំណាចចិត្ត ២ លើក និទ្ទសវត្ថុ ២ លើក ។

# មហាយញ្ញវគ្គោ

(៤១) សត្តិមា ភិក្ខវេ វិញ្ញាណដ្ឋិតិយោ ។ កតមា សត្ត ។ សន្តិ ភិក្ខវេ សត្តា នានត្តកាយា នានត្តសញ្ញិនោ សេយ្យថាបិ មនុស្សា ឯកច្ចេ ច ទេវា ឯកច្ចេ ច វិនិបាតិកា អយំ បឋមា វិញ្ញាណដ្ឋិតិ ។ សន្តិ ភិក្ខវេ សត្តា នានត្តកាយា ឯកត្តសញ្ញិនោ សេយ្យថាបិ ទេវា ព្រហ្មកាយិកា បឋមាភិនិព្វត្តា អយំ ទុតិយា វិញ្ញាណដ្ឋិតិ ។ សន្តិ ភិក្ខវេ សត្តា ឯកត្តកាយា នានត្តសញ្ញិនោ សេយ្យថាបិ ទេវា អាភស្សរា អយំ តតិយា វិញ្ញាណដ្ឋិតិ ។ សន្តិ ភិក្ខវេ សត្តា ឯកត្តកាយា ឯកត្តសញ្ញិនោ សេយ្យថាបិ ទេវា សុភកិណ្ហា អយំ ចតុត្ថា វិញ្ញាណដ្ឋិតិ ។ សន្តិ ភិក្ខវេ សត្តា សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនូបគា អយំ បញ្ចមា វិញ្ញាណដ្ឋិតិ ។

# មហាយញ្ញវគ្គ

(៤១) ម្នាលភិក្ខុទាំងឡាយ វិញ្ញាណដ្ឋិតិ ( ទីតាំងនៃវិញ្ញាណ ) នេះមាន ៧ ប្រការ ។ វិញ្ញាណដ្ឋិតិ ៧ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វ មានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកមនុស្សខ្លះ ទេវតាពួកខ្លះ និងវិនិបាតពួកខ្លះ នេះជាវិញ្ញាណ-ដ្ឋិតិ ទី១ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វ មានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដូចទេវតាក្នុងពួកព្រហ្ម ដែលកើតក្នុងជាន់បឋមជ្ឈានភូមិ នេះជាវិញ្ញាណដ្ឋិតិ ទី២ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វ មានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកទេវតាក្នុងជាន់អាភស្សរៈ នេះជាវិញ្ញាណដ្ឋិតិ ទី៣ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វ មានកាយដូចគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតាក្នុងជាន់សុភកិណ្ហៈ នេះជាវិញ្ញាណដ្ឋិតិ ទី៤ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយគិតថា អាកាសមិនមានទីបំផុត ព្រោះកន្លងបង់នូវរូបសញ្ញា ព្រោះវិនាសទៅនៃបដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង នេះជាវិញ្ញាណដ្ឋិតិទី៥ ។

អត្ថិ ភិក្ខវេ សត្តា សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនូបគា អយំ ឆដ្ឋា(១) វិញ្ញាណដ្ឋិតិ ។ អត្ថិ ភិក្ខវេ សត្តា សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនូបគា អយំ សត្តមា(២) វិញ្ញាណដ្ឋិតិ ។ ឥមា ខោ ភិក្ខវេ សត្ត វិញ្ញាណដ្ឋិតិយោតិ ។

(៤២) សត្តិមេ ភិក្ខវេ សមាធិបរិក្ខារា ។ កតមេ សត្ត ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ ។ យា ខោ ភិក្ខវេ ឥមេហិ សត្តហង្គេហិ ចិត្តស្សេកគ្គតា បរិក្ខតា អយំ វុច្ចតិ ភិក្ខវេ អរិយោ សម្មាសមាធិ(៣) សឧបនិសោ ឥតិបិ សបរិក្ខារោ ឥតិបីតិ ។

---

១- ឆដ្ឋី ។ ២ សត្តមីតិ សង្គីតិសុត្តេ ទីឃនិកាយស្ស បាដិកវគ្គេ ទិស្សតិ ។ ៣ ឱ. សម្មាសមាធិ ។ ម. សម្មាសមាធិស្ស ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វ កន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយគិតថា វិញ្ញាណមិនមានទីបំផុត នេះជាវិញ្ញាណដ្ឋិតិទី ៦ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វ កន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយគិតថា វត្ថុតិចតួចមិនមាន នេះជាវិញ្ញាណដ្ឋិតិ ទី ៧ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណដ្ឋិតិ មាន ៧ យ៉ាងនេះឯង ។

(៤៦) ម្នាលភិក្ខុទាំងឡាយ សមាធិបរិក្ខារ (អង្គរបស់សមាធិ) នេះមាន ៧ ប្រការ ។ សមាធិបរិក្ខារ ៧ ប្រការ តើដូចម្តេចខ្លះ ។ គឺ សម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ ។ ម្នាលភិក្ខុទាំងឡាយ ភាពនៃចិត្ត ដែលមានអារម្មណ៍ មួយតែមួយឯណា ដែលអង្គទាំង ៧ ប្រការនេះហោមរោមហើយ ម្នាលភិក្ខុទាំងឡាយ ភាពនៃចិត្តដែលមានអារម្មណ៍មួយតែមួយនេះ ហៅថា អរិយសមាធិ មានឧបនិស្ស័យដូច្នេះខ្លះ មានបរិក្ខារដូច្នេះខ្លះ ។

[៤៣] សត្តិមេ ភិក្ខវេ អគ្គី ។ កតមេ សត្ត ។ រាគគ្គិ ទោសគ្គិ មោហគ្គិ អាហុនេយ្យគ្គិ គហបតគ្គិ ទក្ខិណេយ្យគ្គិ កដ្ឋគ្គិ ។ ឥមេ ខោ ភិក្ខវេ សត្ត អគ្គីតិ ។

[៤៤] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឧគ្គតសរីរស្ស ព្រាហ្មណស្ស មហាយញ្ញោ ឧបក្ខដោ ហោតិ បញ្ច ឧសភសតានិ ថូណូបនីតានិ ហោន្តិ យញ្ញត្ថាយ បញ្ច វច្ឆតរសតានិ ថូណូបនីតានិ ហោន្តិ យញ្ញត្ថាយ បញ្ច វច្ឆតរីសតានិ ថូណូបនីតានិ ហោន្តិ

(៤៣) ម្នាលភិក្ខុទាំងឡាយ ភ្លើងនេះមាន ៧ ប្រការ ។ ភ្លើង ៧ ប្រការ តើដូចម្តេចខ្លះ ។ ភ្លើងគឺរាគៈ ១ ភ្លើងគឺទោសៈ ១ ភ្លើងគឺមោហៈ ១ ភ្លើងគឺអាហុនេយ្យបុគ្គល[1] ១ ភ្លើងគឺបុគ្គលជាម្ចាស់ផ្ទះ[2] ១ ភ្លើងគឺទក្ខិណេយ្យបុគ្គល[3] ១ ភ្លើងឧស ១ ។ ម្នាលភិក្ខុទាំងឡាយ ភ្លើងមាន ៧ ប្រការនេះឯង ។

(៤៤) សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ឧគ្គតសរីរ-ព្រាហ្មណ៍ ប្រុងទុកមហាយញ្ញ គឺចងក្រៀកគោបា ៥០០ នឹងឈើសន្ទូង ដើម្បីសម្លាប់បូជា ចងក្រៀកកូនគោឈ្មោល ៥០០ នឹងឈើសន្ទូង ដើម្បីសម្លាប់បូជា ចងក្រៀកកូនគោញី ៥០០ នឹងឈើសន្ទូង ដើម្បីសម្លាប់បូជា

---

១- បុគ្គលអ្នកគួរទទួលនូវគ្រឿងសក្ការបូជា ហៅថា អាហុនេយ្យបុគ្គល ក្នុងទីនេះ សំដៅយកមាតាបិតា ព្រោះលោកមានឧបការៈច្រើន ដល់បុត្តធីតា សមគួរជាអ្នកទទួលនូវគ្រឿងគំនាប់គាប់គួរ របស់បុត្តធីតាបាន ត្រង់ដែលទុកលោកថាដូចភ្លើង ព្រោះថា បើបុត្តធីតាប្រតិបត្តិខុសឆ្គងនឹងមាតាបិតា រមែងទៅកើតក្នុងអបាយមាននរកជាដើម ។ ២- បុគ្គលជាម្ចាស់ផ្ទះ ក្នុងទីនេះបានដល់ស្វាមី ព្រោះជាមនុស្សមានឧបការៈច្រើនដល់មាតុគ្រាមដោយការប្រគល់ឲ្យនូវវត្ថុផ្សេងៗ មានសំពត់នឹងគ្រឿងអលង្ការជាដើម ត្រង់ដែលទុកស្វាមីថាដូចជាភ្លើង ព្រោះថាបើមាតុគ្រាមប្រព្រឹត្តកន្លងចិត្តប្តី តែងទៅកើតក្នុងអបាយមាននរកជាដើម ។ តែន័យខ្លះថា ពួកអន្តោជនមានកូននឹងប្រពន្ធជាដើម ក៏ហៅថាភ្លើងគឺបុគ្គលជាម្ចាស់ផ្ទះដែរ ។ ៣- បុគ្គលគួរទទួលទក្ខិណាទាន ហៅថាទក្ខិណេយ្យបុគ្គល បានដល់ភិក្ខុសង្ឃ ។ អដ្ឋកថា ។

យញ្ញាយ បញ្ច អជសតានិ ថូណុបនីតានិ ហោន្តិ យញ្ញាយ បញ្ច ឧរព្ភសតានិ ថូណុបនីតានិ ហោន្តិ យញ្ញាយ ។ អថខោ ឧគ្គតសរីរោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ឧគ្គតសរីរោ ព្រាហ្មណោ ភគវន្តំ ឯតទវោច សុតំ មេ តំ ភោ គោតម អគ្គិស្ស អាធានំ យូបស្ស ឧស្សាបនំ មហប្ផលំ ហោតិ មហានិសំសន្តិ ។ មយាបិ ខោ ឯតំ ព្រាហ្មណ សុតំ អគ្គិស្ស អាធានំ យូបស្ស ឧស្សាបនំ មហប្ផលំ ហោតិ មហានិសំសន្តិ ។ ទុតិយម្បិ ខោ ។ បេ ។ តតិយម្បិ ខោ ឧគ្គតសរីរោ ព្រាហ្មណោ ភគវន្តំ ឯតទវោច សុតំ មេ តំ ភោ គោតម អគ្គិស្ស អាធានំ(១) យូបស្ស ឧស្សាបនំ មហប្ផលំ ហោតិ មហានិសំសន្តិ ។ មយាបិ ខោ ឯតំ ព្រាហ្មណ សុតំ

---

១ ម. អាទានំ ។

ចងក្រៀកពពែ ៥០០ នឹងឈើសន្ទូង ដើម្បីសម្លាប់បូជា ចងក្រៀកកែះ ៥០០ នឹងឈើសន្ទូង ដើម្បីសម្លាប់បូជា ។ វេលានោះ ឧគ្គតសរីរព្រាហ្មណ៍ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យដែលគួររលឹក ហើយក៏អង្គុយក្នុងទីសមគួរ ។ លុះឧគ្គតសរីរព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គបានឮថា ការតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទូង (ដើម្បីបូជាយញ្ញ) ជាកិច្ចមានផលច្រើន មានអានិសង្សច្រើន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ដំណើរនោះ តថាគតក៏បានឮថា ការតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទូង ជាកិច្ចមានផលច្រើន មានអានិសង្សច្រើនដែរ ។ ជាគំរប់ពីរដង ។ បេ ។ ឧគ្គតសរីរព្រាហ្មណ៍ ក៏បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ជាគំរប់បីដងដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គបានឮថា ការតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទូង ជាកិច្ចមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលព្រាហ្មណ៍ ដំណើរនុ៎ះ តថាគតក៏បានឮថា

អគ្គិស្ស អាធានំ យូបស្ស ឧស្សាបនំ មហប្ផលំ ហោតិ មហានិសំសន្តិ ។ តយិទំ ភោ គោតម សមេតិ ភោតោ ចេវ គោតមស្ស អម្ហាកញ្ច យទិទំ សព្វេន សព្វន្តិ ។ ឯវំ វុត្តេ អាយស្មា អានន្ទោ ឧគ្គតសរីរំ ព្រាហ្មណំ ឯតទវោច ន ខោ ព្រាហ្មណ តថាគតា ឯវំ បុច្ឆិតព្វា សុតំ មេ តំ ភោ គោតម អគ្គិស្ស អាធានំ យូបស្ស ឧស្សាបនំ មហប្ផលំ ហោតិ មហានិសំសន្តិ ឯវញ្ច ខោ ព្រាហ្មណ តថាគតា បុច្ឆិតព្វា អហញ្ហិ ភន្តេ អគ្គឹ អាធាតុកាមោ(១) យូបំ ឧស្សាបេតុកាមោ ឱវទតុ មំ ភន្តេ ភគវា អនុសាសតុ មំ ភន្តេ ភគវា យំ មម អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។ អថខោ ឧគ្គតសរីរោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អហញ្ហិ ភោ គោតម

១ ម. អាទាតុកាមោ ។

ការតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទូង ជាកិច្ចមានផលច្រើន មានអានិសង្សច្រើនដែរ ។ បពិត្រព្រះគោតមដ៏ចំរើន ដំណើរទាំងអស់ណា ដែលព្រះគោតមដ៏ចំរើន ឮហើយក្តី ដែលខ្ញុំព្រះអង្គឮហើយក្តី ដំណើរនោះត្រូវគ្នា ( តែបែបមួយ ) កាលបើ ឧគ្គតសរីរព្រាហ្មណ៍និយាយយ៉ាងនេះហើយ ទើបព្រះអានន្ទដ៏មានអាយុ រំលឹកឧគ្គតសរីរព្រាហ្មណ៍ដូច្នេះថា ម្នាលព្រាហ្មណ៍ ព្រះតថាគតទាំងឡាយ បុគ្គលមិនគប្បីសួរថា បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គបានឮមកថា ការតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទូង ជាកិច្ចមានផលច្រើន មានអានិសង្សច្រើន យ៉ាងនេះឡើយ ម្នាលព្រាហ្មណ៍ ព្រះតថាគតទាំងឡាយ បុគ្គលគប្បីសួរយ៉ាងនេះវិញថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ មានប្រាថ្នានឹងតាំងទុកនូវភ្លើង មានប្រាថ្នាលើកឡើងនូវឈើសន្ទូង បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគទូន្មានខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ប្រៀនប្រដៅខ្ញុំព្រះអង្គ ដោយពាក្យដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ខ្ញុំព្រះអង្គ អស់កាលយូរអង្វែង ។ លំដាប់នោះ ឧគ្គតសរីរព្រាហ្មណ៍ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គ

អគ្គិំ អាធាតុកាមោ យូបំ ឧស្សាបេតុកាមោ
ឱវទតុ មំ ភវំ គោតមោ អនុសាសតុ
មំ ភវំ គោតមោ យំ មម អស្ស ទីឃរត្តំ
ហិតាយ សុខាយាតិ ។ អគ្គិំ ព្រាហ្មណ អាធេន្តោ
យូបំ ឧស្សាបេន្តោ បុព្វេវ យញ្ញា តីណិ សត្ថានិ
ឧស្សាបេតិ អកុសលានិ ទុក្ខុទ្រយានិ ទុក្ខវិបាកានិ ។
កតមានិ តីណិ ។ កាយសត្ថំ វចីសត្ថំ មនោសត្ថំ ។
អគ្គិំ ព្រាហ្មណ អាធេន្តោ យូបំ ឧស្សាបេន្តោ
បុព្វេវ យញ្ញា ឯវំ ចិត្តំ ឧប្បាទេតិ ឯត្តកា ឧសភា
ហញ្ញន្តុ យញ្ញត្ថាយ ឯត្តកា វច្ឆតរា ហញ្ញន្តុ យញ្ញត្ថាយ
ឯត្តកា វច្ឆតរិយោ ហញ្ញន្តុ យញ្ញត្ថាយ ឯត្តកា
អជា ហញ្ញន្តុ យញ្ញត្ថាយ ឯត្តកា ឧរព្ភា ហញ្ញន្តុ
យញ្ញត្ថាយាតិ សោ បុញ្ញំ ករោមីតិ អបុញ្ញំ ករោតិ
កុសលំ ករោមីតិ អកុសលំ ករោតិ សុគតិយា
មគ្គំ បរិយេសាមីតិ ទុគ្គតិយា មគ្គំ បរិយេសតិ

មានប្រាថ្នានឹងតាំងទុកនូវភ្លើង មានប្រាថ្នានឹងលើកឡើងនូវឈើសន្ទុង សូមព្រះគោតមដ៏ចំរើន ទូន្មានខ្ញុំព្រះអង្គ សូមព្រះគោតមដ៏ចំរើនប្រៀនប្រដៅខ្ញុំព្រះអង្គ ដោយពាក្យដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ខ្ញុំព្រះអង្គ អស់កាលយូរអង្វែង ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បុគ្គលកាលតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទុង ក្នុងវិធីបូជាជាដម្បូងនុ៎ះឯង រមែងលើកឡើងនូវគ្រឿងសស្ត្រា ៣ យ៉ាង ដែលជាអកុសល មានតែចំរើនសេចក្តីទុក្ខ មានទុក្ខជាផល ។ គ្រឿងសស្ត្រា ៣ យ៉ាងតើដូចម្តេចខ្លះ ។ គ្រឿងសស្ត្រា គឺកាយ ១ គ្រឿងសស្ត្រាគឺវាចា ១ គ្រឿងសស្ត្រាគឺចិត្ត ១ ។ ម្នាលព្រាហ្មណ៍ បុគ្គលកាលតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទុងក្នុងវិធីបូជាជាដម្បូងនុ៎ះឯង រមែងញុំាងចិត្តឲ្យកើតឡើងយ៉ាងនេះថា ជនទាំងឡាយចូរសម្លាប់គោបាប៉ុណ្ណោះដើម្បីបូជា ចូរសម្លាប់កូនគោឈ្មោលប៉ុណ្ណោះដើម្បីបូជា ចូរសម្លាប់កូនគោញីប៉ុណ្ណោះដើម្បីបូជា ចូរសម្លាប់ពពែប៉ុណ្ណោះដើម្បីបូជា ចូរសម្លាប់សត្វកែះប៉ុណ្ណោះ ដើម្បីបូជា បុគ្គលនោះធ្វើបាបដោយសំគាល់ថា អញធ្វើបុណ្យ ធ្វើអំពើអកុសល ដោយសំគាល់ថា អញធ្វើអំពើកុសល ស្វែងរកផ្លូវទុគ្គតិ ដោយសំគាល់ថា អញស្វែងរកផ្លូវសុគតិ

អគ្គឹ ព្រាហ្មណ អាទហន្តោ យូបំ ឧស្សាបេន្តោ
បុរេ យញ្ញា ឥទំ បឋមំ មនោសត្ថំ ឧស្សាបេតិ
អកុសលំ ទុក្ខុទ្រយំ ទុក្ខវិបាកំ ។ បុន ចបរំ
ព្រាហ្មណ អគ្គឹ អាទហន្តោ យូបំ ឧស្សាបេន្តោ បុរេ
យញ្ញា ឯវំ វាចំ ភាសតិ ឯត្តកា ឧសភា ហញ្ញន្តុ
យញ្ញត្ថាយ ឯត្តកា វច្ឆតរា ហញ្ញន្តុ យញ្ញត្ថាយ ឯត្តកា
វច្ឆតរិយោ ហញ្ញន្តុ យញ្ញត្ថាយ ឯត្តកា អជា ហញ្ញន្តុ
យញ្ញត្ថាយ ឯត្តកា ឧរព្ភា ហញ្ញន្តុ យញ្ញត្ថាយាតិ
សោ បុញ្ញំ ករោមីតិ អបុញ្ញំ ករោតិ កុសលំ
ករោមីតិ អកុសលំ ករោតិ សុគតិយា មគ្គំ
បរិយេសាមីតិ ទុគ្គតិយា មគ្គំ បរិយេសតិ អគ្គឹ
ព្រាហ្មណ អាទហន្តោ យូបំ ឧស្សាបេន្តោ បុរេ យញ្ញា
ឥទំ ទុតិយំ វចីសត្ថំ ឧស្សាបេតិ អកុសលំ
ទុក្ខុទ្រយំ ទុក្ខវិបាកំ ។ បុន ចបរំ
ព្រាហ្មណ អគ្គឹ អាទហន្តោ យូបំ ឧស្សាបេន្តោ
បុរេ យញ្ញា សយំ បឋមំ សមារភតិ

ម្នាលព្រាហ្មណ៍ បុគ្គលកាលតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទុះ ក្នុងពិធីបូជាយញ្ញ ជាដម្បូងនុ៎ះឯង រមែងលើកឡើងនូវគ្រឿងសស្ត្រាគឺចិត្ត ដែលជាអកុសល មានតែចំរើនសេចក្តីទុក្ខ មានទុក្ខជាផល នេះជាគ្រឿងសស្ត្រាទី ១ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលកាលតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទុះ ក្នុងពិធីបូជា ជាដម្បូងនុ៎ះឯង រមែងពោលនូវពាក្យយ៉ាងនេះថា ជនទាំងឡាយចូរសម្លាប់គោបាប៉ុណ្ណេះ ដើម្បីបូជា ចូរសម្លាប់កូនគោឈ្មោលប៉ុណ្ណេះ ដើម្បីបូជា ចូរសម្លាប់កូនគោញីប៉ុណ្ណេះ ដើម្បីបូជា ចូរសម្លាប់ពពែប៉ុណ្ណេះ ដើម្បីបូជា ចូរសម្លាប់សត្វកែះប៉ុណ្ណេះ ដើម្បីបូជា បុគ្គលនោះធ្វើបាបដោយសំគាល់ថា អញធ្វើបុណ្យ ធ្វើអំពើអកុសល ដោយសំគាល់ថា អញធ្វើអំពើជាកុសល ស្វែងរកផ្លូវទុគ្គតិដោយសំគាល់ថា អញស្វែងរកផ្លូវសុគតិ ម្នាលព្រាហ្មណ៍ បុគ្គលកាលតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទុះ ក្នុងពិធីបូជា ជាដម្បូងនុ៎ះឯង រមែងលើកឡើងនូវគ្រឿងសស្ត្រាគឺពាក្យដែលជាអកុសល មានតែចំរើនសេចក្តីទុក្ខ មានទុក្ខជាផល នេះជាគ្រឿងសស្ត្រាទី ២ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលកាលតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទុះ ក្នុងពិធីបូជា ជាដម្បូងនុ៎ះឯង រមែងប្រុងប្រៀបខ្លួនឯងជាមុនថា

ឧសភា ហញ្ញន្តុ យញ្ញត្ថាយ សយំ បឋមំ សមារភតិ វច្ឆតរា ហញ្ញន្តុ យញ្ញត្ថាយ សយំ បឋមំ សមារភតិ វច្ឆតរិយោ ហញ្ញន្តុ យញ្ញត្ថាយ សយំ បឋមំ សមារភតិ អជា ហញ្ញន្តុ យញ្ញត្ថាយ សយំ បឋមំ សមារភតិ ឧរព្ភា ហញ្ញន្តុ យញ្ញត្ថាយាតិ សោ បុញ្ញំ ករោមីតិ អបុញ្ញំ ករោតិ កុសលំ ករោមីតិ អកុសលំ ករោតិ សុគតិយា មគ្គំ បរិយេសាមីតិ ទុគ្គតិយា មគ្គំ បរិយេសតិ អគ្គឹ ព្រាហ្មណ អាទេន្តោ យូបំ ឧស្សាបេន្តោ បុព្វេ យញ្ញា ឥទំ តតិយំ កាយសត្ថំ ឧស្សាបេតិ អកុសលំ ទុក្ខុទ្រយំ ទុក្ខវិបាកំ ។ អគ្គឹ ព្រាហ្មណ អាទេន្តោ យូបំ ឧស្សាបេន្តោ បុព្វេ យញ្ញា ឥមានិ តីណិ សត្ថានិ ឧស្សាបេតិ អកុសលានិ ទុក្ខុទ្រយានិ ទុក្ខវិបាកានិ ។ តយោមេ ព្រាហ្មណ អគ្គី បហាតព្វា បរិវជ្ជេតព្វា ន សេវិតព្វា ។ កតមេ តយោ ។

ជនទាំងឡាយ ចូរសម្លាប់គោបា ដើម្បីបូជា ប្រើប្រៀបខ្លួនឯងជាមុនថា ជនទាំងឡាយ ចូរសម្លាប់កូនគោឈ្មោល ដើម្បីបូជា ប្រើប្រៀបខ្លួនឯងជាមុនថា ជនទាំងឡាយ ចូរសម្លាប់កូនគោញី ដើម្បីបូជា ប្រើប្រៀបខ្លួនឯងជាមុនថា ជនទាំងឡាយ ចូរសម្លាប់ពពែ ដើម្បីបូជា ប្រើប្រៀបខ្លួនឯងជាមុនថា ជនទាំងឡាយ ចូរសម្លាប់សត្វកែះដើម្បីបូជា បុគ្គលនោះធ្វើបាបដោយសំគាល់ថា អញធ្វើបុណ្យ ធ្វើអំពើអកុសល ដោយសំគាល់ថា អញធ្វើអំពើកុសល ស្វែងរកផ្លូវទុគ្គតិ ដោយសំគាល់ថា អញស្វែងរកផ្លូវសុគតិ ម្នាលព្រាហ្មណ៍ បុគ្គលកាលតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទុង ក្នុងវិធីបូជា ជាដម្បូងនុ៎ះឯង រមែងលើកឡើងនូវគ្រឿងសស្ត្រាគឺកាយដែលជាអកុសល មានតែចំរើនដោយសេចក្តីទុក្ខ មានទុក្ខជាផល នេះជាគ្រឿងសស្ត្រាទី ៣ ។ ម្នាលព្រាហ្មណ៍ បុគ្គលកាលតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទុង ក្នុងវិធីបូជា ជាដម្បូងនុ៎ះឯង រមែងលើកឡើងនូវគ្រឿងសស្ត្រា ៣ ប្រការនេះ ដែលជាអកុសល មានតែចំរើនដោយសេចក្តីទុក្ខ មានទុក្ខជាផល ។ ម្នាលព្រាហ្មណ៍ ភ្លើង ៣ ប្រការនេះ បុគ្គលគួរលះបង់ចេញ គួរវៀសវាងចេញ មិនគួរសេពគប់ឡើយ ។ ភ្លើង ៣ ប្រការ តើដូចម្តេចខ្លះ ។

រាគគ្គិ ទោសគ្គិ មោហគ្គិ ។ កស្មា ចាយំ ព្រាហ្មណ
រាគគ្គិ បហាតព្វោ បរិវជ្ជេតព្វោ ន សេវិតព្វោ រត្តោ ខោ
ព្រាហ្មណ រាគេន អភិភូតោ បរិយាទិន្នចិត្តោ កាយេន
ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា
ទុច្ចរិតំ ចរតិ សោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ
ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា កាយស្ស
ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ
ឧបបជ្ជតិ តស្មា ចាយំ រាគគ្គិ បហាតព្វោ បរិ-
វជ្ជេតព្វោ ន សេវិតព្វោ ។ កស្មា ចាយំ ព្រាហ្មណ
ទោសគ្គិ បហាតព្វោ បរិវជ្ជេតព្វោ ន សេវិតព្វោ
ទុដ្ឋោ ខោ ព្រាហ្មណ ទោសេន អភិភូតោ បរិយា-
ទិន្នចិត្តោ កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ
ចរតិ មនសា ទុច្ចរិតំ ចរតិ សោ កាយេន
ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា
ទុច្ចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា
អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ

ភ្លើងគឺ រាគៈ ១ ភ្លើងគឺ ទោសៈ ១ ភ្លើងគឺ មោហៈ ១ ។ ម្នាលព្រាហ្មណ៍ ចុះភ្លើងគឺ រាគៈនេះ បុគ្គលគួរលះបង់ចេញ គួរវៀរវាងចេញ មិនគួរសេពគប់ឡើយ តើព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ ព្រោះបុគ្គលជារាគចរិត ត្រូវរាគៈគ្របសង្កត់ រួបរឹតចិត្តហើយ រមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុនោះ ភ្លើងគឺរាគៈនេះ បុគ្គលគួរលះបង់ចេញ គួរវៀរវាងចេញ មិនគួរសេពគប់ឡើយ ។ ម្នាលព្រាហ្មណ៍ ចុះភ្លើងគឺទោសៈនេះ បុគ្គលគួរលះបង់ចេញ គួរវៀរវាងចេញ មិនគួរសេពគប់ តើព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ ព្រោះបុគ្គលជាទោសចរិត ត្រូវទោសៈគ្របសង្កត់ រួបរឹតចិត្តហើយ រមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក

តស្មា តាយំ ទោសគ្គិ បហាតព្វោ បរិវជ្ជេតព្វោ ន សេវិតព្វោ ។ តស្មា តាយំ ព្រាហ្មណ មោហគ្គិ បហាតព្វោ បរិវជ្ជេតព្វោ ន សេវិតព្វោ មូឡ្ហោ ខោ ព្រាហ្មណ មោហេន អភិភូតោ បរិយាទិន្នចិត្តោ កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ សោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តស្មា តាយំ មោហគ្គិ បហាតព្វោ បរិវជ្ជេតព្វោ ន សេវិតព្វោ ។ ឥមេ ខោ ព្រាហ្មណ តយោ អគ្គី បហាតព្វា បរិវជ្ជេតព្វា ន សេវិតព្វា ។ តយោមេ ព្រាហ្មណ អគ្គី សក្កត្វា គរុកត្វា មានេត្វា បូជេត្វា សម្មា សុខំ បរិហាតព្វា ។ កតមេ តយោ ។ អាហុនេយ្យគ្គិ គហបតគ្គិ ទក្ខិណេយ្យគ្គិ ។ កតមោ ច ព្រាហ្មណ អាហុនេយ្យគ្គិ ។

ព្រោះហេតុនោះ ភ្លើងគឺទោសៈនេះ បុគ្គលគួរលះបង់ចេញ គួរវៀសវាងចេញ មិនគួរសេពគប់ឡើយ ។ ម្នាលព្រាហ្មណ៍ ចុះភ្លើងគឺមោហៈនេះ បុគ្គលគួរលះបង់ចេញ គួរវៀសវាងចេញ មិនគួរសេពគប់ តើព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ ព្រោះបុគ្គលជាមោហចរិត ត្រូវមោហៈគ្របសង្កត់ រួបរិតចិត្តហើយ រមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះបុគ្គលនោះប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុនោះ ភ្លើងគឺមោហៈនេះ បុគ្គលគួរលះបង់ចេញ គួរវៀសវាងចេញ មិនគួរសេពគប់ឡើយ ។ ម្នាលព្រាហ្មណ៍ ភ្លើងទាំង ៣ ប្រការនេះឯង បុគ្គលគួរលះបង់ចេញ គួរវៀសវាងចេញ មិនគួរសេពគប់ឡើយ ។ ម្នាលព្រាហ្មណ៍ ភ្លើង ៣ ប្រការនេះ បុគ្គលគួរធ្វើសក្ការៈ គោរព រាប់អាន បូជា រក្សា បម្រើឲ្យល្អដោយប្រពៃ ។ ភ្លើង ៣ ប្រការ តើដូចម្តេចខ្លះ ។ ភ្លើងគឺអាហុនេយ្យបុគ្គល ១ ភ្លើងគឺបុគ្គលជាម្ចាស់ផ្ទះ ១ ភ្លើងគឺទក្ខិណេយ្យបុគ្គល ១ ។ ម្នាលព្រាហ្មណ៍ ចុះភ្លើងគឺអាហុនេយ្យបុគ្គល តើដូចម្តេច ។

ឥធ ព្រាហ្មណ យស្ស តេ ហោន្តិ មាតាតិ វា បិតាតិ វា អយំ វុច្ចតិ ព្រាហ្មណ អាហុនេយ្យគ្គិ តំ កិស្ស ហេតុ អតោ ហាយំ ព្រាហ្មណ អាហុតោ សម្ភូតោ តស្មា ចាយំ អាហុនេយ្យគ្គិ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា សម្មា សុខំ បរិហាតព្វោ ។ កតមោ ច ព្រាហ្មណ គហបតគ្គិ ។ ឥធ ព្រាហ្មណ យស្ស តេ ហោន្តិ បុត្តាតិ វា ទារាតិ វា ទាសាតិ វា បេស្សាតិ វា អយំ វុច្ចតិ ព្រាហ្មណ គហបតគ្គិ តស្មា ចាយំ គហបតគ្គិ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា សម្មា សុខំ បរិហាតព្វោ ។ កតមោ ច ព្រាហ្មណ ទក្ខិណេយ្យគ្គិ ។ ឥធ ព្រាហ្មណ យេ តេ សមណព្រាហ្មណា មទប្បមាទា(១) បដិវិរតា ខន្តិសោរច្ចេ និវិដ្ឋា ឯកមត្តានំ ទមេន្តិ ឯកមត្តានំ សមេន្តិ ឯកមត្តានំ បរិនិព្វាបេន្តិ អយំ វុច្ចតិ ព្រាហ្មណ ទក្ខិណេយ្យគ្គិ តស្មា

១ ម. បរប្យភិតា ។

ម្នាលព្រាហ្មណ៍ ជនទាំងឡាយនោះ គឺជាមាតា ឬបិតា របស់បុគ្គលណាក្នុងលោកនេះ ម្នាលព្រាហ្មណ៍ នេះហៅថា ភ្លើងគឺអាហុនេយ្យបុគ្គល ( របស់បុគ្គលនោះ ) ដំណើរនោះ តើព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ ព្រោះបុគ្គលនោះ ដែលបានកើតមកដោយសារមាតាបិតានោះ ហេតុនោះ ភ្លើងគឺអាហុនេយ្យបុគ្គលនេះ បុគ្គលគួរធ្វើសក្ការៈ គោរព រាប់អាន បូជា រក្សា បម្រើឲ្យល្អដោយប្រពៃ ៗ ម្នាលព្រាហ្មណ៍ ចុះភ្លើងគឺបុគ្គលជាម្ចាស់ផ្ទះ តើដូចម្ដេច ។ ម្នាលព្រាហ្មណ៍ ជនទាំងឡាយនោះ គឺជាកូន ឬប្រពន្ធ ឬខ្ញុំ ឬកម្មករ អ្នកបម្រើ របស់បុគ្គលណា ក្នុងលោកនេះ ម្នាលព្រាហ្មណ៍ នេះហៅថា ភ្លើងគឺបុគ្គលជាម្ចាស់ផ្ទះរបស់បុគ្គលនោះ ព្រោះហេតុនោះ ភ្លើងគឺបុគ្គលជាម្ចាស់ផ្ទះ បុគ្គលគួរធ្វើសក្ការៈ គោរព រាប់អាន បូជា រក្សា បម្រើឲ្យល្អដោយប្រពៃ ៗ ម្នាលព្រាហ្មណ៍ ចុះភ្លើងគឺទក្ខិណេយ្យបុគ្គល តើដូចម្ដេច ៗ ម្នាលព្រាហ្មណ៍ សមណៈ ឬ ព្រាហ្មណ៍ណា ក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកសេចក្ដីស្រវឹង និងសេចក្ដីប្រមាទ ឋិតនៅក្នុងខន្តិ និងសោរច្ចៈ ទូន្មានខ្លួនចិត្តមួយ រម្ងាប់ខ្លួនចិត្តមួយ រំលត់ខ្លួនចិត្តមួយ ម្នាលព្រាហ្មណ៍ នេះហៅថា ភ្លើងគឺទក្ខិណេយ្យបុគ្គល ព្រោះហេតុនោះ

ចាយំ ទក្ខិណេយ្យគ្គិ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា សម្មា សុខំ បរិហាតព្វោ ។ ឥមេ ខោ ព្រាហ្មណ តយោ អគ្គី សក្កត្វា គរុកត្វា មានេត្វា បូជេត្វា សម្មា សុខំ បរិហាតព្វា ។ អយំ ខោ បន ព្រាហ្មណ កដ្ឋគ្គិ កាលេន កាលំ ឧជ្ជលេតព្វោ កាលេន កាលំ អជ្ឈុបេក្ខិតព្វោ កាលេន កាលំ និព្វាបេតព្វោ កាលេន កាលំ និក្ខិបិតព្វោតិ ។ ឯវំ វុត្តេ ឧគ្គតសរីរោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ឯសាហំ ភោ គោតម បញ្ច ឧសភសតានិ មុញ្ចាមិ ជីវិតំ ទេមិ បញ្ច វច្ឆតរសតានិ មុញ្ចាមិ ជីវិតំ ទេមិ បញ្ច វច្ឆតរីសតានិ មុញ្ចាមិ ជីវិតំ ទេមិ បញ្ច អជសតានិ មុញ្ចាមិ ជីវិតំ ទេមិ បញ្ច ឧរព្ភសតានិ មុញ្ចាមិ ជីវិតំ ទេមិ ហរិតានិ ចេវ តិណានិ ខាទន្តុ សីតានិ ច បានីយានិ បិវន្តុ សីតោ ច នេសំ វាតោ ឧបវាយតូតិ ។

ភ្លើងគឺទក្ខិណេយ្យបុគ្គលនេះ បុគ្គលគួរធ្វើសក្ការៈ គោរព រាប់អាន បូជា រក្សា បម្រើឲ្យល្អដោយប្រពៃ ។ ម្នាលព្រាហ្មណ៍ ភ្លើង ៣ ប្រការនេះឯង បុគ្គលគួរធ្វើសក្ការៈ គោរព រាប់អាន បូជា រក្សា បម្រើឲ្យល្អដោយប្រពៃ ។ ម្នាលព្រាហ្មណ៍ ចំណែកឯភ្លើងឧសនេះសោត បុគ្គលក៏គួរដុតតាមកាលគួរ បង្អន់មើលតាមកាលគួរ គួរលត់តាមកាលគួរ គួរទុកដាក់តាមកាលគួរ កាលបើព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ឧគ្គតសរីរព្រាហ្មណ៍ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ភ្លឺច្បាស់ណាស់ ។ បេ ។ សូមព្រះគោតម ដ៏ចំរើន ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសក ដល់នូវសរណៈស្មើដោយជីវិត ចាប់ដើម តាំងអំពីថ្ងៃនេះទៅ បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គនុះ នឹងលែងគោបា ៥០០ ឲ្យជីវិត នឹងលែងកូនគោឈ្មោល ៥០០ ឲ្យជីវិត នឹងលែងកូនគោញី ៥០០ ឲ្យជីវិត នឹងលែងពពែ ៥០០ ឲ្យជីវិត នឹងលែងសត្វកែះ ៥០០ ឲ្យជីវិត ចូរសត្វទាំងនោះ ទំពាស៊ីស្មៅខ្ចីផង ផឹកទឹកត្រជាក់ផង ទាំងខ្យល់ដ៏ត្រជាក់ ចូរបក់ផ្សាយ ដល់ពួកសត្វទាំងនោះចុះ ។

(៤៥) សត្តិមា ភិក្ខវេ សញ្ញា ភាវិតា ពហុលីកតា មហប្ផលា ហោន្តិ មហានិសំសា អមតោគធា អមតបរិយោសានា ។ កតមា សត្ត ។ អសុភសញ្ញា មរណសញ្ញា អាហារេ បដិកូលសញ្ញា សព្វលោកេ អនភិរតសញ្ញា អនិច្ចសញ្ញា អនិច្ចេ ទុក្ខសញ្ញា ទុក្ខេ អនត្តសញ្ញា ។ ឥមា ខោ ភិក្ខវេ សត្ត សញ្ញា ភាវិតា ពហុលីកតា មហប្ផលា ហោន្តិ មហានិសំសា អមតោគធា អមតបរិយោសានាតិ ។

(៤៦) សត្តិមា ភិក្ខវេ សញ្ញា ភាវិតា ពហុលីកតា មហប្ផលា ហោន្តិ មហានិសំសា អមតោគធា អមតបរិយោសានា ។ កតមា សត្ត ។ អសុភសញ្ញា មរណសញ្ញា

(៤៥) ម្នាលភិក្ខុទាំងឡាយ សញ្ញា (សេចក្តីសំគាល់)នេះមាន ៧ ប្រការដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ។ សេចក្តីសំគាល់ ៧ ប្រការ តើដូចម្តេចខ្លះ ។ គឺសេចក្តីសំគាល់ថា មិនស្អាត ១ សេចក្តីសំគាល់ក្នុងការស្លាប់ ១ សេចក្តីសំគាល់ក្នុងអាហារថាជារបស់គួរខ្ពើម ១ សេចក្តីសំគាល់ក្នុងលោកទាំងពួងថា មិនគួរត្រេកអរ ១ សេចក្តីសំគាល់ថា មិនទៀង ១ សេចក្តីសំគាល់ថាជាទុក្ខ ក្នុងការមិនទៀង ១ សេចក្តីសំគាល់ថា មិនមែនរបស់ខ្លួនក្នុងរបស់ជាទុក្ខ ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសំគាល់ ៧ ប្រការនេះឯង ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ។

(៤៦) ម្នាលភិក្ខុទាំងឡាយ សញ្ញា ៧ ប្រការនេះ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ។ សញ្ញា ៧ ប្រការ តើដូចម្តេចខ្លះ ។ គឺអសុភសញ្ញា ១ មរណសញ្ញា ១

## បឋមបណ្ណាសកេ មហាយញ្ញវគ្គោ

អាហារេ បដិក្កូលសញ្ញា សព្វលោកេ អនភិរតសញ្ញា អនិច្ចសញ្ញា អនិច្ចេ ទុក្ខសញ្ញា ទុក្ខេ អនត្តសញ្ញា ។ អសុភសញ្ញា ភិក្ខវេ ភាវិតា ពហុលីកតា មហប្ផលា ហោតិ មហានិសំសា អមតោគធា អមតបរិយោសានាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ អសុភសញ្ញាបរិចិតេន ភិក្ខវេ ភិក្ខុនោ ចេតសា ពហុលំ វិហរតោ មេថុនធម្មសមាបត្តិយា ចិត្តំ បដិលីយតិ បដិកុដ្ឋតិ(១) បដិវត្តតិ(២) ន សម្បសារិយតិ ឧបេក្ខា វា បាដិក្កូល្យតា វា សណ្ឋាតិ សេយ្យថាបិ ភិក្ខវេ កុក្កុដបត្តំ វា ន្ហារុទទ្ទុលំ វា អគ្គិម្ហិ បក្ខិត្តំ បដិលីយតិ បដិកុដ្ឋតិ បដិវត្តតិ ន សម្បសារិយតិ ឯវមេវ ខោ ភិក្ខវេ ភិក្ខុនោ អសុភសញ្ញាបរិចិតេន ចេតសា ពហុលំ វិហរតោ មេថុនធម្មសមាបត្តិយា ចិត្តំ បដិលីយតិ បដិកុដ្ឋតិ បដិវត្តតិ ន សម្បសារិយតិ ឧបេក្ខា វា បាដិក្កូល្យតា វា សណ្ឋាតិ

---

១ ឱ. ម. បដិកុដតិ ។ ២ ឱ. បដិវដ្ដតិ ។

អាហារេ បដិកូលសញ្ញា ១ សព្វលោកេ អនភិរតសញ្ញា ១ អនិច្ចសញ្ញា ១ អនិច្ចេ ទុក្ខសញ្ញា ១ ទុក្ខេ អនត្តសញ្ញា ១ ។ ពាក្យថា ម្នាលភិក្ខុទាំងឡាយ អសុភសញ្ញា ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ដូច្នេះនេះឯង តថាគតបានពោលហើយ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុមានចិត្តសន្សំអសុភសញ្ញារឿយ ៗ ហើយ ចិត្តរមែងរួញ ខ្វួរ បែរចេញ ចាកការជួបប្រសព្វដោយមេថុនធម្ម មិនលាវិញឡើយ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី រមែងតាំងឡើង ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចស្លាបមាន់ ឬ ទងសរសៃ ដែលបុគ្គលដាក់ចុះក្នុងភ្លើង រមែងរួញ ខ្វួរ ងរឡើង មិនលាវិញឡើយ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តសន្សំអសុភសញ្ញារឿយ ៗ ហើយ ចិត្តរមែងរួញ ខ្វួរ បែរចេញ ចាកការជួបប្រសព្វដោយមេថុនធម្ម មិនលាវិញឡើយ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី រមែងតាំងឡើង ក៏មានឧបមេយ្យ យ៉ាងនោះឯង

សចេ ភិក្ខវេ ភិក្ខុនោ អសុភសញ្ញាបរិចិតេន ចេតសា ពហុលំ វិហរតោ មេថុនធម្មសមាបត្តិយា ចិត្តំ អនុសន្ទតិ អប្បដិក្កុល្យតា វា សណ្ឋាតិ វេទិតព្វមេតំ ភិក្ខវេ ភិក្ខុនា អភាវិតា មេ អសុភសញ្ញា នត្ថិ មេ បុព្វេនាបរំ វិសេសោ អប្បត្តំ មេ ភាវនាពលន្តិ ឥតិហ តត្ថ សម្បជានោ ហោតិ សចេ បន ភិក្ខវេ ភិក្ខុនោ អសុភសញ្ញាបរិចិតេន ចេតសា ពហុលំ វិហរតោ មេថុនធម្មសមាបត្តិយា ចិត្តំ បដិលីយតិ បដិកុដ្ឋតិ បដិវត្តតិ ន សម្បសារិយតិ ឧបេក្ខា វា បាដិក្កុល្យតា វា សណ្ឋាតិ វេទិតព្វមេតំ ភិក្ខវេ ភិក្ខុនា សុភាវិតា មេ អសុភសញ្ញា អត្ថិ មេ បុព្វេនាបរំ វិសេសោ បត្តំ មេ ភាវនាពលន្តិ ឥតិហ តត្ថ សម្បជានោ ហោតិ ។ អសុភសញ្ញា ភិក្ខវេ ភាវិតា ពហុលីកតា មហប្ផលា ហោតិ មហានិសំសា អមតោគធា

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ ភិក្ខុមានចិត្តសន្សំអសុភសញ្ញារឿយ ៗ ហើយ ចិត្តនៅតែត្រាច់ទៅរកការជួបប្រសព្វដោយមេថុនធម្ម ឬ ការមិនខ្ពើមរអើម នៅតែតាំងឡើងបាន ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុគប្បីដឹងថា អសុភសញ្ញា អញបំរើន មិនទាន់បានទេ កាលខាងដើមនឹងកាលខាងចុង របស់អញមិនទាន់ប្លែកគ្នាទេ ផលនៃការចំរើនរបស់អញ មិនទាន់សម្រេចទេ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងច្បាស់ ក្នុងអសុភសញ្ញានោះ ដោយប្រការដូច្នេះ ម្នាលភិក្ខុទាំងឡាយ តែបើភិក្ខុមានចិត្តសន្សំអសុភសញ្ញារឿយ ៗ ហើយ ចិត្តក៏រួញ ខ្ទួរ បែរចេញចាកការជួបប្រសព្វដោយមេថុនធម្ម មិនលាវិញឡើយ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី ក៏តាំងឡើង ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុគប្បីដឹងថា អសុភសញ្ញា អញបំរើនបានហើយ កាលខាងដើមនឹងកាលខាងចុង របស់អញមាន សេចក្តីប្លែកគ្នា ផលនៃការចំរើន អញបានសម្រេចហើយ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងច្បាស់ក្នុងអសុភសញ្ញានោះ ដោយប្រការដូច្នេះ ។ ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ អសុភសញ្ញា ដែលភិក្ខុចំរើនហើយ ធ្វើឲ្យច្រើនហើយ មានផលច្រើន មានអានិសង្សច្រើន ឈមទៅរកព្រះនិព្វាន

អមតបរិយោសានាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ មរណសញ្ញា ភិក្ខវេ ភាវិតា ពហុលីកតា មហប្ផលា ហោតិ មហានិសំសា អមតោគធា អមតបរិយោសានាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ មរណសញ្ញាបរិចិតេន ភិក្ខវេ ភិក្ខុនោ ចេតសា ពហុលំ វិហរតោ ជីវិត-និកន្តិយា ចិត្តំ បដិលីយតិ បដិកុដ្ឋតិ បដិវត្តតិ ន សម្បសារិយតិ ឧបេក្ខា វា បាដិកុល្យតា វា សណ្ឋាតិ សេយ្យថាបិ ភិក្ខវេ កុក្កុដបត្តំ វា ន្ហារុ-ទទ្ទុលំ វា អគ្គិម្ហិ បក្ខិត្តំ បដិលីយតិ បដិកុដ្ឋតិ បដិវត្តតិ ន សម្បសារិយតិ ឯវមេវ ខោ ភិក្ខវេ ភិក្ខុនោ មរណសញ្ញាបរិចិតេន ចេតសា ពហុលំ វិហរតោ ជីវិត-និកន្តិយា ចិត្តំ បដិលីយតិ បដិកុដ្ឋតិ បដិវត្តតិ ន សម្បសារិយតិ ឧបេក្ខា វា បាដិកុល្យតា វា សណ្ឋាតិ សចេ ភិក្ខវេ ភិក្ខុនោ មរណសញ្ញាបរិចិតេន ចេតសា

មានព្រះនិព្វានជាទីបំផុតដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ពាក្យថា ម្នាលភិក្ខុទាំងឡាយ មរណសញ្ញា ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុតដូច្នេះនេះឯង តថាគតបានពោលហើយ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុមានចិត្តសន្សំមរណសញ្ញារឿយ ៗ ហើយ ចិត្តរមែងរួញ ខ្ញើរ បែរចេញ ចាកការត្រេកអរ ក្នុងជីវិតមិនលាវិញឡើយ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី រមែងតាំងឡើង ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចស្លាបមាន់ ឬ ទង់សរសៃដែលបុគ្គលដាក់ចុះក្នុងភ្លើង រមែងរួញ ខ្ញើរ ងើរឡើង មិនលាវិញឡើយមានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តសន្សំមរណសញ្ញារឿយ ៗ ហើយ ចិត្តរមែងរួញ ខ្ញើរ បែរចេញចាកការត្រេកអរក្នុងជីវិត មិនលាវិញឡើយ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី រមែងតាំងឡើង មានឧបមេយ្យយ៉ាងនោះឯង ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ ភិក្ខុមានចិត្តសន្សំមរណសញ្ញារឿយ ៗ ហើយ

ពហុលំ វិហរតោ ជីវិតនិកន្តិយា ចិត្តំ អនុសន្ទតិ អប្បាដិក្កូល្យតា វា សណ្ឋាតិ វេទិតព្វមេតំ ភិក្ខវេ ភិក្ខុនា អភាវិតា មេ មរណសញ្ញា នត្ថិ មេ បុព្វេនាបរំ វិសេសោ អប្បត្តំ មេ ភាវនាពលន្តិ ឥតិហ តត្ថ សម្បជានោ ហោតិ ។ សចេ បន ភិក្ខវេ ភិក្ខុនោ មរណសញ្ញាបរិចិតេន ចេតសា ពហុលំ វិហរតោ ជីវិតនិកន្តិយា ចិត្តំ បដិលីយតិ បដិកុដតិ បដិវត្តតិ ន សម្បសារីយតិ ឧបេក្ខា វា បាដិក្កូល្យតា វា សណ្ឋាតិ វេទិតព្វមេតំ ភិក្ខវេ ភិក្ខុនា ភាវិតា មេ មរណសញ្ញា អត្ថិ មេ បុព្វេនាបរំ វិសេសោ បត្តំ មេ ភាវនាពលន្តិ ឥតិហ តត្ថ សម្បជានោ ហោតិ ។ មរណសញ្ញា ភិក្ខវេ ភាវិតា ពហុលីកតា មហប្ផលា ហោតិ មហានិសំសា អមតោគធា អមតបរិយោសានាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

តែចិត្តនៅតែត្រាប់ទៅរកសេចក្តីត្រេកអរ ក្នុងជីវិត ឬ ការមិនខ្ពើមរអើម នៅតែតាំងឡើងបាន ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុគប្បីដឹងថា មរណសញ្ញា អញបំរើនមិនទាន់បានទេ កាលខាងដើមនិងកាលខាងចុង របស់អញ មិនទាន់ប្លែកគ្នាទេ ផលនៃការបំរើនរបស់អញមិនទាន់សម្រេច ទេ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងខ្លួន ក្នុងមរណសញ្ញានោះ ដោយ ប្រការដូច្នេះ ម្នាលភិក្ខុទាំងឡាយ តែបើ ភិក្ខុមានចិត្តសន្សំមរណសញ្ញារឿយៗហើយ ចិត្តរមែងរួញ ខ្វរ បែរចេញចាកការត្រេកអរ ក្នុង ជីវិត មិនលាវិញឡើយ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី ក៏ តាំងឡើង ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុគប្បីដឹងថា មរណសញ្ញា អញបំរើនបានហើយ កាលខាងដើមនិងកាលខាងចុងរបស់អញ មាន សេចក្តីប្លែកគ្នា ផលនៃការបំរើនរបស់អញសម្រេចហើយ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងខ្លួន ក្នុងមរណសញ្ញានោះ ដោយប្រការដូច្នេះៗ ក៏ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ មរណសញ្ញាដែលភិក្ខុបានបំរើន ហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជា គុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុតដូច្នេះដែលតថាគត ពោលហើយ ពាក្យនុ៎ះតថាគតពោល ព្រោះអាស្រ័យហេតុនេះឯងៗ

អាហារេ បដិក្កូលសញ្ញា ភិក្ខវេ ភាវិតា ពហុលី-
កតា មហប្ផលា ហោតិ មហានិសំសា អមតោគធា
អមតបរិយោសានាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ
បដិច្ច វុត្តំ អាហារេ បដិក្កូលសញ្ញាបរិចិតេន
ភិក្ខវេ ភិក្ខុនោ ចេតសា ពហុលំ វិហរតោ
រសតណ្ហាយ ចិត្តំ បដិលីយតិ បដិកុដ្ឋតិ បដិវត្តតិ
ន សម្បសារិយតិ ឧបេក្ខា វា បាដិក្កូល្យតា វា
សណ្ឋាតិ សេយ្យថាបិ ភិក្ខវេ កុក្កុដបត្តំ វា ន្ហារុ-
ទទ្ទុលំ វា អគ្គិម្ហិ បក្ខិត្តំ បដិលីយតិ បដិកុដ្ឋតិ បដិ-
វត្តតិ ន សម្បសារិយតិ ឯវមេវ ខោ ភិក្ខវេ ភិក្ខុនោ
អាហារេ បដិក្កូលសញ្ញាបរិចិតេន ចេតសា ពហុលំ
វិហរតោ រសតណ្ហាយ ចិត្តំ បដិលីយតិ បដិកុដ្ឋតិ
បដិវត្តតិ ន សម្បសារិយតិ ឧបេក្ខា វា បាដិក្កូល្យតា
វា សណ្ឋាតិ សចេ ភិក្ខវេ ភិក្ខុនោ អាហារេ បដិក្កូល-
សញ្ញាបរិចិតេន ចេតសា ពហុលំ វិហរតោ រសតណ្ហាយ
ចិត្តំ អនុសន្ទតិ អប្បដិក្កូល្យតា វា សណ្ឋាតិ

ពាក្យថា ម្នាលភិក្ខុទាំងឡាយ អាហារ បដិកូលសញ្ញា ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ដូច្នេះនេះឯង តថាគតបានពោលហើយ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុមានចិត្តសន្សំអាហារ បដិកូលសញ្ញារឿយ ៗ ហើយ ចិត្តរមែងរួញ ខ្វរ បែរចេញចាករសតណ្ហា (បំណងក្នុងរស) មិនលាវិញឡើយ សេចក្ដីព្រងើយកន្តើយក្ដី ការខ្ពើមរអើមក្ដី រមែងតាំងឡើង ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចស្លាបមាន់ ឬទងសរសៃ ដែលបុគ្គលដាក់ចុះក្នុងភ្លើង រមែងរួញ ខ្វរ ងរឡើង មិនលាវិញឡើយ មានឧបមាយ៉ាងណាមិញ ម្នាល ភិក្ខុទាំងឡាយ ភិក្ខុមានចិត្តសន្សំអាហារ បដិកូលសញ្ញារឿយ ៗ ហើយ ចិត្តរមែងរួញ ខ្វរ បែរចេញចាករសតណ្ហា មិនលាវិញឡើយ សេចក្ដីព្រងើយកន្តើយក្ដី ការខ្ពើមរអើមក្ដី រមែងតាំងឡើងព្រម មានឧបមេយ្យយ៉ាងនោះឯង ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ ភិក្ខុមានចិត្តសន្សំអាហារ បដិកូលសញ្ញារឿយៗហើយ តែចិត្តនៅតែត្រាច់ទៅរករសតណ្ហា ឬការមិនខ្ពើមរអើមនៅតែតាំងឡើងបាន

វេទិតព្វមេតំ ភិក្ខវេ ភិក្ខុនា អភាវិតា មេ អាហារេ បដិក្កូលសញ្ញា នត្ថិ មេ បុព្វេនាបរំ វិសេសោ អប្បត្តំ មេ ភាវនាពលន្តិ ឥតិហ តត្ថ សម្បជានោ ហោតិ សចេ បន ភិក្ខវេ ភិក្ខុនោ អាហារេ បដិក្កូលសញ្ញាបរិចិតេន ចេតសា ពហុលំ វិហរតោ រសតណ្ហាយ ចិត្តំ បដិលីយតិ ។ បេ ។ ឧបេក្ខា វា បាដិក្កុល្យតា វា សណ្ឋាតិ វេទិតព្វមេតំ ភិក្ខវេ ភិក្ខុនា ភាវិតា មេ អាហារេ បដិក្កូលសញ្ញា អត្ថិ មេ បុព្វេនាបរំ វិសេសោ បត្តំ មេ ភាវនាពលន្តិ ឥតិហ តត្ថ សម្បជានោ ហោតិ ។ អាហារេ បដិក្កូលសញ្ញា ភិក្ខវេ ភាវិតា ពហុលីកតា មហប្ផលា ហោតិ មហានិសំសា អមតោគធា អមតបរិយោសានាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុគប្បីដឹងថា អាហារេ បដិកូលសញ្ញា អញបំរើនមិនទាន់បានទេ កាលខាងដើមនឹងកាលខាងចុងរបស់អញ មិនទាន់ប្លែកគ្នាទេ ផលនៃការបំរើនរបស់អញ មិនទាន់សម្រេចទេ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងច្បាស់ ក្នុងអាហារេ បដិកូលសញ្ញា នោះ ដោយប្រការដូច្នេះ ម្នាលភិក្ខុទាំងឡាយ តែបើភិក្ខុមានចិត្តសន្សំអាហារេ បដិកូលសញ្ញារឿយ ៗ ហើយ ចិត្តក៏រួញរាករសតណ្ហា ។ បេ ។ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី ក៏តាំងឡើង ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុគប្បីដឹងថា អាហារេ បដិកូលសញ្ញាអញបំរើនបានហើយ កាលខាងដើមនឹងកាលខាងចុងរបស់អញ មានសេចក្តីប្លែកគ្នា ផលនៃការបំរើនរបស់អញបានសម្រេចហើយ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងច្បាស់ ក្នុងអាហារេ បដិកូលសញ្ញានោះ ដោយប្រការ ដូច្នេះឯង ។ ក៏ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ អាហារេ បដិកូលសញ្ញា ដែលបុគ្គលបានបំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។

សព្វលោកេ អនភិរតសញ្ញា ភិក្ខវេ ភាវិតា ពហុលីកតា មហប្ផលា ហោតិ មហានិសំសា អមតោគធា អមតបរិយោសានាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ សព្វលោកេ អនភិរតសញ្ញាបរិចិតេន ភិក្ខវេ ភិក្ខុនោ ចេតសា ពហុលំ វិហរតោ លោកចិត្តេសុ ចិត្តំ បដិលីយតិ បដិកុដតិ បដិវត្តតិ ន សម្បសារិយតិ ឧបេក្ខា វា បាដិកុល្យតា វា សណ្ឋាតិ សេយ្យថាបិ ភិក្ខវេ កុក្កុដបត្តំ វា ន្ហារុទទ្ទុលំ វា អគ្គិម្ហិ បក្ខិត្តំ បដិលីយតិ បដិកុដតិ បដិវត្តតិ ន សម្បសារិយតិ ឯវមេវ ខោ ភិក្ខវេ ភិក្ខុនោ សព្វលោកេ អនភិរតសញ្ញាបរិចិតេន ចេតសា ពហុលំ វិហរតោ លោកចិត្តេសុ ចិត្តំ បដិលីយតិ បដិកុដតិ បដិវត្តតិ ន សម្បសារិយតិ ឧបេក្ខា វា បាដិកុល្យតា វា សណ្ឋាតិ សចេ ភិក្ខវេ ភិក្ខុនោ សព្វលោកេ អនភិរតសញ្ញាបរិចិតេន ចេតសា ពហុលំ វិហរតោ លោកចិត្តេសុ ចិត្តំ អនុសន្ទតិ អប្បដិកុល្យតា វា សណ្ឋាតិ

(៥១) គ្រានោះ ភិក្ខុមួយរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យវិចិកិច្ឆារបស់អរិយសាវក អ្នកមានសេចក្ដីចេះដឹងមិនកើតឡើង ក្នុងអព្យាកតវត្ថុទាំងឡាយ ។ ម្នាលភិក្ខុ វិចិកិច្ឆារបស់អរិយសាវក អ្នកមានសេចក្ដីចេះដឹង រមែងមិនកើតឡើង ក្នុងអព្យាកតវត្ថុទាំងឡាយ ព្រោះរលត់ទិដ្ឋិ ។ ម្នាលភិក្ខុ ទិដ្ឋិកើតឡើងថា សត្វស្លាប់ទៅរមែងកើតទៀត ម្នាលភិក្ខុ ទិដ្ឋិកើតឡើងថា សត្វស្លាប់ទៅ មិនកើតទៀត

ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ ខោ ភិក្ខវេ ទិដ្ឋិគតមេតំ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ ខោ ភិក្ខវេ ទិដ្ឋិគតមេតំ ។ អស្សុតវា ភិក្ខវេ បុថុជ្ជនោ ទិដ្ឋឹ នប្បជានាតិ ទិដ្ឋិសមុទយំ នប្បជានាតិ ទិដ្ឋិនិរោធំ នប្បជានាតិ ទិដ្ឋិនិរោធគាមិនឹ បដិបទំ នប្បជានាតិ តស្ស សា ទិដ្ឋិ បវឌ្ឍតិ សោ ន បរិមុច្ចតិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ន បរិមុច្ចតិ ទុក្ខស្មាតិ វទាមិ ។ សុតវា ច ខោ ភិក្ខវេ អរិយសាវកោ ទិដ្ឋឹ បជានាតិ ទិដ្ឋិសមុទយំ បជានាតិ ទិដ្ឋិនិរោធំ បជានាតិ ទិដ្ឋិនិរោធគាមិនឹ បដិបទំ បជានាតិ តស្ស សា ទិដ្ឋិ និរុជ្ឈតិ សោ បរិមុច្ចតិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ បរិមុច្ចតិ ទុក្ខស្មាតិ វទាមិ ។ ឯវំ ជានំ ខោ ភិក្ខវេ សុតវា អរិយសាវកោ ឯវំ បស្សំ ហោតិ

ម្នាលភិក្ខុ ទិដ្ឋិកើតឡើងថា សត្វស្លាប់ទៅ រមែងកើតទៀតក៏មាន មិនកើតទៀតក៏មាន ម្នាលភិក្ខុ ទិដ្ឋិកើតឡើងថា សត្វស្លាប់ទៅកើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ។ ម្នាលភិក្ខុ បុថុជ្ជនអ្នកមិនចេះដឹង រមែងមិនដឹងច្បាស់នូវទិដ្ឋិ មិនដឹងច្បាស់នូវហេតុ ជាទីកើតឡើងនៃទិដ្ឋិ មិនដឹងច្បាស់នូវសេចក្ដីរលត់ទៅនៃទិដ្ឋិ មិនដឹងច្បាស់នូវបដិបទា ដែលដល់នូវការរលត់ទៅនៃទិដ្ឋិ ទិដ្ឋិនោះរមែងចំរើនដល់បុថុជ្ជននោះ បុថុជ្ជននោះ រមែងមិនរួចចាកជាតិ ជរា មរណៈ សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីទុក្ខ ទោមនស្ស សេចក្ដីតានតឹង តថាគតហៅថា រមែងមិនរួចចាកវដ្ដទុក្ខឡើយ ។ ម្នាលភិក្ខុ អរិយសាវក អ្នកមានសេចក្ដីចេះដឹង រមែងដឹងច្បាស់នូវទិដ្ឋិ ដឹងច្បាស់នូវហេតុ ជាទីកើតឡើងនៃទិដ្ឋិ ដឹងច្បាស់នូវសេចក្ដីរលត់ទៅនៃទិដ្ឋិ ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ទីរលត់ទៅនៃទិដ្ឋិ ទិដ្ឋិនោះរបស់អរិយសាវកនោះ រមែងរលត់ទៅ អរិយសាវកនោះ ទើបរួចស្រឡះចាកជាតិ ជរា មរណៈ សេចក្ដីសោកខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្ដីតានតឹង តថាគតហៅថា រមែងរួចស្រឡះចាកវដ្ដទុក្ខ ។ ម្នាលភិក្ខុ អរិយសាវក អ្នកមានសេចក្ដីចេះដឹង កាលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ

តថាគតោ បរម្មរណាតិបិ ន ព្យាករោតិ ន ហោតិ តថាគតោ បរម្មរណាតិបិ ន ព្យាករោតិ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិបិ ន ព្យាករោតិ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិបិ ន ព្យាករោតិ ។ ឯវំ ជានំ ខោ ភិក្ខុ សុតវា អរិយសាវកោ ឯវំ បស្សំ ឯវំ អព្យាករណធម្មោ ហោតិ អព្យាកតវត្ថូសុ ។ ឯវំ ជានំ ខោ ភិក្ខុ សុតវា អរិយសាវកោ ឯវំ បស្សំ ន ឆម្ភតិ ន កម្បតិ ន វេធតិ ន សន្តាសំ អាបជ្ជតិ អព្យាកតវត្ថូសុ ។ ហោតិ តថាគតោ បរម្មរណាតិ ខោ ភិក្ខុ តណ្ហាគតមេតំ សញ្ញាគតមេតំ មញ្ញិតមេតំ បបញ្ចិតមេតំ ឧបាទានគតមេតំ វិប្បដិសារោ ឯសោ ន ហោតិ តថាគតោ បរម្មរណាតិ ខោ ភិក្ខុ វិប្បដិសារោ ឯសោ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ ខោ ភិក្ខុ វិប្បដិសារោ ឯសោ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ ខោ ភិក្ខុ វិប្បដិសារោ ឯសោ ។ អស្សុតវា ភិក្ខុ បុថុជ្ជនោ វិប្បដិសារំ នប្បជានាតិ

រមែងមិនពោលថា សត្វស្លាប់ទៅ កើតទៀតដូច្នេះខ្លះ មិនពោលថា សត្វស្លាប់ទៅ មិនកើតទៀតដូច្នេះខ្លះ មិនពោលថា សត្វស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះខ្លះ ។ ម្នាលភិក្ខុ អរិយសាវក អ្នកមានសេចក្តីចេះដឹង កាលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ជាអ្នកមានកិរិយាមិនពោលជាធម្មតា ក្នុងអព្យាកតវត្ថុទាំងឡាយយ៉ាងនេះឯង ។ ម្នាលភិក្ខុ អរិយសាវក អ្នកមានសេចក្តីចេះដឹង កាលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ទើបមិនរន្ធត់ មិនបំប្រប់ មិនញាប់ញ័រ មិនដល់នូវសេចក្តីតក់ស្លុតក្នុងអព្យាកតវត្ថុទាំងឡាយទេ ។ ម្នាលភិក្ខុ តណ្ហា សញ្ញា មានៈ បបញ្ចធម៌ (សេចក្តីយឺតយូរ) ឧបាទាន នឹងវិប្បដិសារៈនុ៎ះកើតឡើងថា សត្វស្លាប់ទៅ កើតទៀតក៏មាន ម្នាលភិក្ខុ វិប្បដិសារៈនុ៎ះកើតឡើងថា សត្វស្លាប់ទៅ មិនកើតទៀតក៏មាន ម្នាលភិក្ខុ វិប្បដិសារៈនុ៎ះកើតឡើងថា សត្វស្លាប់ទៅ កើតទៀតក៏មាន មិនកើតទៀតក៏មាន ម្នាលភិក្ខុ វិប្បដិសារៈនុ៎ះកើតឡើងថា សត្វស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ។ ម្នាលភិក្ខុ បុថុជ្ជន អ្នកមិនមានសេចក្តីចេះដឹង រមែងមិនដឹងច្បាស់នូវវិប្បដិសារៈ

ទិដ្ឋិសមុទយំ នប្បជានាតិ ទិដ្ឋិនិរោធំ នប្បជានាតិ ទិដ្ឋិនិរោធគាមិនឹ បដិបទំ នប្បជានាតិ តស្ស សា ទិដ្ឋិ បវឌ្ឍតិ សោ ន បរិមុច្ចតិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ន បរិមុច្ចតិ ទុក្ខស្មាតិ វទាមិ ។ សុតវា ច ខោ ភិក្ខវេ អរិយសាវកោ ទិដ្ឋិំ បជានាតិ ទិដ្ឋិសមុទយំ បជានាតិ ទិដ្ឋិនិរោធំ បជានាតិ ទិដ្ឋិនិរោធគាមិនឹ បដិបទំ បជានាតិ តស្ស សា ទិដ្ឋិ និរុជ្ឈតិ ។ បេ ។ ឯវំ ជានំ ខោ ភិក្ខវេ សុតវា អរិយសាវកោ ឯវំ បស្សំ នឆម្ភតិ ន កម្បតិ ន វេធតិ ន សន្តាសំ អាបជ្ជតិ អព្យាកតវត្ថូសុ ។ អយំ ខោ ភិក្ខវេ ហេតុ អយំ បច្ចយោ យេន សុតវតោ អរិយសាវកស្ស វិចិកិច្ឆា នុប្បជ្ជតិ អព្យាកតវត្ថូសូតិ ។

មិនដឹងច្បាស់នូវហេតុ ជាទីកើតឡើងនៃវិប្បដិសារៈ មិនដឹងច្បាស់នូវសេចក្ដីរលត់ទៅនៃវិប្បដិសារៈ មិនដឹងច្បាស់នូវបដិបទា ដែលដល់នូវការរលត់ទៅនៃវិប្បដិសារៈ វិប្បដិសារៈនោះ របស់បុថុជ្ជននោះ រមែងចំរើនឡើង បុថុជ្ជននោះ រមែងមិនរួចចាកជាតិ ជរា មរណៈ សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីទុក្ខ ទោមនស្ស សេចក្ដីតានតឹង តថាគតពោលថា រមែងមិនរួចចាកវដ្ដទុក្ខឡើយ ។ ម្នាលភិក្ខុ លុះតែអរិយសាវក អ្នកមានសេចក្ដីចេះដឹង ទើបដឹងច្បាស់នូវវិប្បដិសារៈ ដឹងច្បាស់ នូវហេតុជាទីកើតឡើងនៃវិប្បដិសារៈ ដឹងច្បាស់នូវសេចក្ដីរលត់នៃវិប្បដិសារៈ ដឹងច្បាស់ នូវបដិបទា ដែលដល់នូវការរលត់នូវវិប្បដិសារៈ វិប្បដិសារៈនោះ របស់អរិយសាវកនោះ រមែងរលត់ទៅ ។បេ។ ម្នាលភិក្ខុ អរិយសាវក អ្នកមានសេចក្ដីចេះដឹង កាលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ទើបមិនរន្ធត់ មិនបំប្រប់ មិនញាប់ញ័រ មិនដល់នូវសេចក្ដីតក់ស្លុត ក្នុងអព្យាកតវត្ថុទាំងឡាយទេ ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យវិចិកិច្ឆារបស់អរិយសាវក អ្នកមានសេចក្ដីចេះដឹងមិនកើតឡើងក្នុងអព្យាកតវត្ថុទាំងឡាយ ។

(៤២) សត្ត ច ភិក្ខវេ បុរិសគតិយោ ទេសេស្សាមិ អនុបាទា ច បរិនិព្វានំ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមា ច ភិក្ខវេ សត្ត បុរិសគតិយោ ។ ឥធ ភិក្ខវេ ភិក្ខុ ឯវំ បដិបន្នោ ហោតិ នោ ចស្ស នោ ច មេ សិយា ន ភវិស្សតិ ន មេ ភវិស្សតិ យទត្ថិ យំ ភូតំ តំ បជហាមីតិ ឧបេក្ខំ បដិលភតិ ។ សោ ភវេ ន រជ្ជតិ សម្ភវេ ន សជ្ជតិ(១) អត្ថុត្តរិ បទំ សន្តំ សម្មប្បញ្ញាយ បស្សតិ តញ្ច ខ្វស្ស បទំ ន សព្វេន សព្វំ សច្ឆិកតំ ហោតិ

១ ឱ. ម ន រជ្ជតិ ។

(៥២) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវគតិរបស់បុរស ទាំង ៧ ប្រការផង នូវអនុបាទាបរិនិព្វានផង ចូរអ្នកទាំងឡាយស្តាប់ នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះគតិរបស់បុរស ៧ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ រមែងបានឧបេក្ខាថា បើកម្ម (ដែលញុំាងសត្វឲ្យកើតក្នុងអត្តភាពនេះ) មិនធ្លាប់មានទេ អត្តភាពរបស់អញក៏មិនមាន (ក្នុងកាលឥឡូវនេះដែរ) បើកម្ម (ដែលញុំាងសត្វឲ្យកើតក្នុងអនាគត) របស់អញមិនមាន (ក្នុងកាលឥឡូវនេះ) ទេ អត្តភាពរបស់អញ (ក្នុងអនាគត) ក៏មិនមានដែរ ខន្ធបញ្ចកៈណា ដែលកើតមាន អញលះបង់នូវខន្ធបញ្ចកៈនោះចេញ ។ ភិក្ខុនោះ មិនត្រេកអរក្នុងភព មិនជាប់ជំពាក់ក្នុងសម្ភវៈ រមែងឃើញនូវព្រះនិព្វានជាចំណែកដ៏ស្ងប់ក្រៃលែង ដោយបញ្ញាដ៏ប្រពៃ តែព្រះនិព្វាននោះ ភិក្ខុនោះ មិនទាន់បានធ្វើឲ្យជាក់ច្បាស់ ដោយសព្វគ្រប់នៅឡើយ

តស្ស ន សព្វេន សព្វំ មានានុសយោ បហីនោ ហោតិ ន សព្វេន សព្វំ ភវរាគានុសយោ បហីនោ ហោតិ ន សព្វេន សព្វំ អវិជ្ជានុសយោ បហីនោ ហោតិ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អន្តរាបរិនិព្វាយី ហោតិ ។ សេយ្យថាបិ ភិក្ខវេ ទិវសសន្តត្តេ អយោកបាលេ ហញ្ញមានេ បបដិកា និព្វត្តិត្វា និព្វាយេយ្យ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឯវំ បដិបន្នោ ហោតិ នោ ចស្ស នោ ច មេ សិយា ន ភវិស្សតិ ន មេ ភវិស្សតិ យទត្ថិ យំ ភូតំ តំ បជហាមីតិ ឧបេក្ខំ បដិលភតិ ។ សោ ភវេ ន រជ្ជតិ សម្ភវេ ន រជ្ជតិ អត្ថុត្តរិ បទំ សន្តំ សម្មប្បញ្ញាយ បស្សតិ តញ្ច ខ្វស្ស បទំ ន សព្វេន សព្វំ សច្ឆិកតំ ហោតិ តស្ស ន សព្វេន សព្វំ មានានុសយោ បហីនោ ហោតិ ន សព្វេន សព្វំ ភវរាគានុសយោ បហីនោ ហោតិ ន សព្វេន សព្វំ អវិជ្ជានុសយោ បហីនោ ហោតិ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា

ភិក្ខុនោះ មិនទាន់លះបង់មានានុស័យ ដោយសព្វគ្រប់នៅឡើយ មិនទាន់លះបង់ ភវរាគានុស័យ ដោយសព្វគ្រប់នៅឡើយ មិនទាន់លះបង់អវិជ្ជានុស័យ ដោយសព្វគ្រប់នៅឡើយ ។ ភិក្ខុនោះឈ្មោះថា អន្តរាបរិនិញ្វាយី ព្រោះអស់ទៅនៃសំយោជនៈ ជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាអម្បែងដែកដែលក្តៅអស់មួយថ្ងៃ កាលបុគ្គលដំ ក្រមរផ្កាភ្លើងខ្ទាតឡើង ហើយរលត់ទៅវិញយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ រមែងបាននូវឧបេក្ខាថា បើកម្ម (ដែលញ៉ាំងសត្វឲ្យកើតក្នុងអត្តភាព កន្លងមកហើយ) មិនធ្លាប់មានទេ អត្តភាពរបស់អញ (ក្នុងកាលឥឡូវនេះ) ក៏មិនមានដែរ បើកម្ម (ដែលញ៉ាំងសត្វឲ្យកើតក្នុងអនាគត) មិនមានទេ អត្តភាពរបស់អញ (ក្នុងអនាគត) ក៏មិនមានដែរ ខន្ធបញ្ចកៈណាដែលកើតមាន អញលះបង់នូវខន្ធបញ្ចកៈនោះចេញ ។ ភិក្ខុនោះមិនត្រេកអរក្នុងភព មិនជាប់ជំពាក់ក្នុងសម្ភវៈ រមែងឃើញនូវព្រះនិញ្វាន ជាចំណែកស្ងប់ដ៏ក្រៃលែង ដោយបញ្ញាដ៏ប្រពៃ តែព្រះនិញ្វាននោះ ភិក្ខុនោះមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ដោយសព្វគ្រប់នៅឡើយ មិនទាន់បានលះបង់មានានុស័យ ដោយសព្វគ្រប់នៅឡើយ មិនទាន់បានលះបង់ភវរាគានុស័យ ដោយសព្វគ្រប់នៅឡើយ មិនទាន់បានលះបង់អវិជ្ជានុស័យ ដោយសព្វគ្រប់នៅឡើយ ។

អន្តរាបរិនិព្វាយី ហោតិ ។ ឥធ បន ភិក្ខវេ ភិក្ខុ ឯវំ បដិបន្នោ ហោតិ នោ ចស្ស នោ ច មេ សិយា ន ភវិស្សតិ ន មេ ភវិស្សតិ យទត្ថិ យំ ភូតំ តំ បជហាមីតិ ឧបេក្ខំ បដិលភតិ ។ សោ ភវេ ន រជ្ជតិ សម្ភវេ ន រជ្ជតិ អត្ថុត្តរិ បទំ សន្តំ សម្មប្បញ្ញាយ បស្សតិ តញ្ច ខ្វស្ស បទំ ន សព្វេន សព្វំ សច្ឆិកតំ ហោតិ តស្ស ន សព្វេន សព្វំ មានានុសយោ បហីនោ ហោតិ ន សព្វេន សព្វំ ភវរាគានុសយោ បហីនោ ហោតិ ន សព្វេន សព្វំ អវិជ្ជានុសយោ បហីនោ ហោតិ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អន្តរាបរិនិព្វាយី ហោតិ ។ សេយ្យថាបិ ភិក្ខវេ ទិវសសន្តត្តេ អយោកបាលេ ហញ្ញមានេ បបដិកា និព្វត្តិត្វា ឧប្បតិត្វា និព្វាយេយ្យ

ភិក្ខុនោះឈ្មោះថា អន្តរាបរិនិព្វាយី ព្រោះអស់ទៅនៃសំយោជនៈ ជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ រមែងបាននូវឧបេក្ខាថា បើកម្ម (ដែលញ៉ាំងសត្វឲ្យកើតក្នុងអត្តភាពនេះ) មិនធ្លាប់មានទេ អត្តភាពរបស់អញ ក៏មិនមាន (ក្នុងកាលឥឡូវនេះដែរ) បើកម្ម (ដែលញ៉ាំងសត្វឲ្យកើតក្នុងអនាគត) របស់អញ មិនមាន (ក្នុងកាលឥឡូវនេះទេ) អត្តភាពរបស់អញ (ក្នុងអនាគត) ក៏មិនមាន ខន្ធបញ្ចកៈណា ដែលកើតមាន អញលះបង់នូវខន្ធបញ្ចកៈនោះចេញ ។ ភិក្ខុនោះមិនត្រេកអរក្នុងភព មិនជាប់ជំពាក់ ក្នុងសម្ភវៈ រមែងឃើញនូវព្រះនិព្វាន ជាចំណែកដ៏ស្ងប់ក្រៃលែង ដោយបញ្ញាដ៏ប្រពៃ តែព្រះនិព្វាននោះ ភិក្ខុនោះ មិនទាន់បានធ្វើឲ្យជាក់ច្បាស់ ដោយសព្វគ្រប់ទៅឡើយ មិនទាន់លះបង់មានានុស័យ ដោយសព្វគ្រប់ទៅឡើយ មិនទាន់លះបង់ភវរាគានុស័យ ដោយសព្វគ្រប់ទៅឡើយ មិនទាន់លះបង់អវិជ្ជានុស័យ ដោយសព្វគ្រប់ទៅឡើយ ភិក្ខុនោះឈ្មោះថា អន្តរាបរិនិព្វាយី ព្រោះអស់ទៅនៃសំយោជនៈ ជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអម្បែងដែក ដែលគេដុតអស់មួយថ្ងៃ កាលបើគេដំ ក្រមផ្កាភ្លើងខ្ទាតអណ្តាតឡើង ហើយរលត់បាត់ទៅវិញ យ៉ាងណាមិញ

ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឯវំ បដិបន្នោ ហោតិ ។ បេ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អន្តរាបរិនិព្វាយី ហោតិ ។ ឥធ បន ភិក្ខវេ ភិក្ខុ ឯវំ បដិបន្នោ ហោតិ ។ បេ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អន្តរាបរិនិព្វាយី ហោតិ ។ សេយ្យថាបិ ភិក្ខវេ ទិវសសន្តត្តេ អយោកដាហេ ហញ្ញមានេ បបដិកា និព្វត្តិត្វា ឧប្បតិត្វា អនុបហច្ចតលំ និព្វាយេយ្យ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឯវំ បដិបន្នោ ហោតិ ។ បេ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អន្តរាបរិនិព្វាយី ហោតិ ។ ឥធ បន ភិក្ខវេ ភិក្ខុ ឯវំ បដិបន្នោ ហោតិ ។ បេ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឧបហច្ចបរិនិព្វាយី ហោតិ ។ សេយ្យថាបិ ភិក្ខវេ ទិវសសន្តត្តេ អយោកដាហេ ហញ្ញមានេ បបដិកា និព្វត្តិត្វា ឧប្បតិត្វា ឧបហច្ចតលំ និព្វាយេយ្យ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ ។ បេ ។ ភិក្ខុនោះឈ្មោះថា អន្តរាបរិនិព្វាយី ព្រោះអស់ទៅនៃសំយោជនៈ ជាចំណែកខាងក្រោម ៥ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ ។ បេ ។ ភិក្ខុនោះឈ្មោះថា អន្តរា-បរិនិព្វាយី ព្រោះអស់ទៅនៃសំយោជនៈ ជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអំបែងដែក ដែលក្តៅអស់ មួយថ្ងៃ កាលបុគ្គលដំ ក្រមផ្កាភ្លើង ខ្ទាតអណ្តែតឡើងទៅទល់ផ្ទៃ (ខាងលើ) ហើយរលត់បាត់ទៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ ។ បេ ។ ភិក្ខុនោះឈ្មោះថា អន្តរាបរិនិព្វាយី ព្រោះអស់ទៅនៃសំយោជនៈ ជាចំណែកខាងក្រោម ៥ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ ។ បេ ។ ភិក្ខុនោះឈ្មោះថា ឧបហច្ចបរិនិព្វាយី ព្រោះអស់ទៅនៃសំយោជនៈ ជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអំបែងដែក ដែលក្តៅអស់ មួយ ថ្ងៃ កាលបុគ្គលដំ ក្រមផ្កាភ្លើង ខ្ទាតអណ្តែតឡើងទៅទល់ផ្ទៃ ( ខាងលើ ) ហើយរលត់បាត់ទៅ យ៉ាងណាមិញ

ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឯវំ បដិបន្នោ ហោតិ ។ បេ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឧបហច្ចបរិនិព្វាយី ហោតិ ។ ឥធ បន ភិក្ខវេ ភិក្ខុ ឯវំ បដិបន្នោ ហោតិ ។ បេ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អសង្ខារបរិនិព្វាយី ហោតិ ។ សេយ្យថាបិ ភិក្ខវេ ទិវសសន្តត្តេ អយោកបាលេ ហញ្ញមានេ បបដិកា និព្វត្តិត្វា ឧប្បតិត្វា បរិត្តេ តិណបុញ្ជេ វា កដ្ឋបុញ្ជេ វា និបតេយ្យ សា តត្ថ អគ្គិម្បិ ជនេយ្យ ធូមម្បិ ជនេយ្យ អគ្គិម្បិ ជនេត្វា ធូមម្បិ ជនេត្វា តមេវ បរិត្តំ តិណបុញ្ជំ វា កដ្ឋបុញ្ជំ វា បរិយាទិយិត្វា អនាហារា និព្វាយេយ្យ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឯវំ បដិបន្នោ ហោតិ ។ បេ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អសង្ខារបរិនិព្វាយី ហោតិ ។ ឥធ បន ភិក្ខវេ ភិក្ខុ ឯវំ បដិបន្នោ ហោតិ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះឈ្មោះថា ឧបហច្ចបរិនិព្វាយី ព្រោះអស់ទៅនៃសំយោជនៈ ជាចំណែកខាងក្រោម ៥ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះឈ្មោះថា អសង្ខារបរិនិព្វាយី ព្រោះអស់ទៅនៃសំយោជនៈ ជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអម្បែងដែក ដែលក្តៅអស់មួយថ្ងៃ កាលបុគ្គលបង់ ក្រមះផ្កាភ្លើងខ្ទាត អណ្តែតឡើង ហើយធ្លាក់ទៅលើគំនរស្មៅ ឬគំនរឧសដែលមានប្រមាណតិច ផ្កាភ្លើងនោះ គប្បីញុំាងភ្លើង ក្នុងគំនរទាំងនោះ ឲ្យកើតឡើងផង ញុំាងផ្សែងឲ្យកើតឡើងផង លុះញុំាងភ្លើងឲ្យកើត ញុំាងផ្សែងឲ្យកើតឡើងហើយក៏ឆាបឆេះនូវគំនរស្មៅ ឬគំនរឧសមានប្រមាណតិចនោះឯង ឲ្យទៅជារបស់ខ្ទេចខ្ទីហើយរលត់ទៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះឈ្មោះថា អសង្ខារបរិនិព្វាយី ព្រោះអស់ទៅនៃសំយោជនៈ ជាចំណែកខាងក្រោម ៥ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ

។ បេ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា សសង្ខារបរិនិព្វាយី ហោតិ ។ សេយ្យថាបិ ភិក្ខវេ ទិវសសន្តត្តេ អយោកដាហេ ហញ្ញមានេ បបដិកា និព្វត្តិត្វា ឧប្បតិត្វា វិបុលេ តិណបុញ្ជេ វា កដ្ឋបុញ្ជេ វា និបតេយ្យ សា តត្ថ អគ្គិម្បិ ជនេយ្យ ធូមម្បិ ជនេយ្យ អគ្គិម្បិ ជនេត្វា ធូមម្បិ ជនេត្វា តមេវ វិបុលំ តិណបុញ្ជំ វា កដ្ឋបុញ្ជំ វា បរិយាទិយិត្វា អនាហារា និព្វាយេយ្យ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឯវំ បដិបន្នោ ហោតិ ។ បេ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា សសង្ខារបរិនិព្វាយី ហោតិ ។ ឥទ បន ភិក្ខវេ ភិក្ខុ ឯវំ បដិបន្នោ ហោតិ ។ បេ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឧទ្ធំសោតោ ហោតិ អកនិដ្ឋគាមី ។

។ បេ ។ ភិក្ខុនោះឈ្មោះថា សសង្ខារបរិនិព្វាយី ព្រោះអស់ទៅនៃសំយោជនៈ ជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអំបែងដែក ដែលក្តៅអស់មួយថ្ងៃ កាលបុគ្គលដំ ក្រមផ្កាភ្លើងខ្ទាតអណ្តែតឡើងទៅ ហើយធ្លាក់ចុះលើគំនរស្មៅ ឬគំនរចំបើងធំ ផ្កាភ្លើងនោះ គប្បីញុំាងភ្លើង ក្នុងគំនរទាំងនោះឲ្យកើតឡើងផង ញុំាងផ្សែងឲ្យកើតឡើងផង លុះញុំាងភ្លើងឲ្យកើត ញុំាងផ្សែងឲ្យកើតឡើងហើយ ក៏ឆាបឆេះនូវគំនរស្មៅ ឬ គំនរចំបើងធំនោះឯង ឲ្យទៅជារបស់ខ្ចបខ្ចី ហើយរលត់ទៅយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ ។ បេ ។ ភិក្ខុនោះឈ្មោះថា សសង្ខារបរិនិព្វាយី ព្រោះអស់ទៅនៃសំយោជនៈ ជាចំណែកខាងក្រោម ៥ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ ។ បេ ។ ភិក្ខុនោះ ឈ្មោះថា ឧទ្ធំសោត-អកនិដ្ឋគាមី ព្រោះអស់ទៅនៃសំយោជនៈ ជាចំណែកខាងក្រោម ៥ ។

សេយ្យថាបិ ភិក្ខវេ ទិវសសន្តត្តេ អយោកបាលេ ហញ្ញមានេ បប្បដិកា និព្វត្តិត្វា ឧប្បតិត្វា មហន្តេ តិណបុញ្ជេ វា កដ្ឋបុញ្ជេ វា និបតេយ្យ សា តត្ថ អគ្គិម្បិ ជនេយ្យ ធូមម្បិ ជនេយ្យ អគ្គិម្បិ ជនេត្វា ធូមម្បិ ជនេត្វា[១] តិណបុញ្ជំ វា កដ្ឋបុញ្ជំ វា បរិយាទិយិត្វា គច្ឆម្បិ ទហេយ្យ ទាយម្បិ ទហេយ្យ គច្ឆម្បិ ទហិត្វា ទាយម្បិ ទហិត្វា ហរិតន្តំ វា[២] សេលន្តំ វា ឧទកន្តំ វា រមណីយំ វា ភូមិភាគំ អាគម្ម អនាហារា និព្វាយេយ្យ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឯវំ បដិបន្នោ ហោតិ ។ បេ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា ឧទ្ធំសោតោ ហោតិ អកនិដ្ឋគាមី ។ ឥមា ភិក្ខវេ សត្ត បុរិសគតិយោ ។ កតមញ្ច ភិក្ខវេ អនុបាទា បរិនិព្វានំ ។ ឥធ ភិក្ខវេ ភិក្ខុ ឯវំ បដិបន្នោ ហោតិ

---

១ ឱ. ជនេត្វា តមេវ មហន្តំ ។ ២ ឱ. អ. ឯត្តន្តរេ បថន្តំ វាតិ ទិស្សតិ ។

ម្នាលភិក្ខុ ប្រៀបដូចអម្បែងដែក ដែលក្តៅអស់ មួយ ថ្ងៃ កាលបុគ្គលដំ ក្រមផ្កាភ្លើង ខ្ទាតអណ្តែតឡើង ហើយធ្លាក់ចុះលើគំនរស្មៅ ឬ គំនរឧសច្រើន ផ្កាភ្លើងនោះ គប្បីញុំាងភ្លើង ក្នុងគំនរទាំងនោះ ឲ្យកើតឡើងផង ញុំាងផ្សែងឲ្យកើតឡើងផង លុះញុំាងភ្លើងឲ្យកើតឡើង ញុំាងផ្សែងឲ្យកើតឡើងហើយ ក៏ឆាបឆេះនូវគំនរស្មៅ ឬ គំនរឧស គប្បីឆេះគុម្ពឈើ (ដែលគ្មានគេរក្សា) ខ្លះ ឆេះព្រៃ (ដែលគេរក្សា) ខ្លះ លុះឆេះគុម្ពឈើ (ដែលគ្មានគេរក្សា) ឆេះព្រៃ (ដែលគេរក្សា) ហើយ ក៏ទៅដល់របស់ខៀវខ្ចី ហើយរលត់ទៅ ព្រោះអាស្រ័យនូវវត្ថុមានពណ៌ខៀវខ្លះ នូវថ្មខ្លះ នូវទឹកខ្លះ នូវបំណែកនៃផែនដី ជាទីតម្រេកខ្លះ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះឈ្មោះថា ឧទ្ធំសោតអកនិដ្ឋគាមី ព្រោះអស់ទៅនៃសំយោជនៈ ជាចំណែកខាងក្រោម ៥ ក៏យ៉ាងនោះឯង ។

ម្នាលភិក្ខុទាំងឡាយ គតិនៃបុរសមាន ៧ យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ចុះអនុបាទាបរិនិព្វាន តើដូចម្តេច ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ

នោ ចស្ស នោ ច មេ សិយា ន ភវិស្សតិ ន មេ ភវិស្សតិ យទត្ថិ យំ ភូតំ តំ បជហាមីតិ ឧបេក្ខំ បដិលភតិ ។ សោ ភវេ ន រជ្ជតិ សម្ភវេ ន រជ្ជតិ អត្ថុត្តរិំ បទំ សន្តំ សម្មប្បញ្ញាយ បស្សតិ តញ្ច ខ្វស្ស បទំ សព្វេន សព្វំ សច្ឆិកតំ ហោតិ តស្ស សព្វេន សព្វំ មានានុសយោ បហីនោ ហោតិ សព្វេន សព្វំ ភវរាគានុសយោ បហីនោ ហោតិ សព្វេន សព្វំ អវិជ្ជានុសយោ បហីនោ ហោតិ ។ សោ អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥទំ វុច្ចតិ ភិក្ខវេ អនុបាទា បរិនិព្វានំ ។ ឥមា ខោ ភិក្ខវេ សត្ត បុរិសគតិយោ អនុបាទា ច បរិនិព្វានន្តិ ។

(៥៣) ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ អថខោ ទ្វេ ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ គិជ្ឈកូដំ ឱភាសេត្វា

រមែងបាននូវឧបេក្ខាថា បើកម្ម (ដែលញុំាងសត្វឲ្យកើតក្នុងអត្តភាព) មិនធ្លាប់មានទេ អត្តភាពរបស់អញក៏មិនមាន (ក្នុងកាលឥឡូវនេះ) បើកម្ម (ដែលញុំាងសត្វឲ្យកើតក្នុងអនាគត) របស់អញមិនមាន (ក្នុងកាលឥឡូវនេះទេ) អត្តភាពរបស់អញ (ក្នុងអនាគត) ក៏មិនមានដែរ ខន្ធបញ្ចកៈណាដែលកើតមាន អញលះបង់នូវខន្ធបញ្ចកៈនោះចេញ ។ ភិក្ខុនោះមិនត្រេកអរក្នុងភព មិនជាប់ជំពាក់ក្នុងសម្ភវៈ រមែងឃើញនូវព្រះនិព្វានជាបំណែកស្ងប់ដ៏ក្រៃលែង ដោយបញ្ញាដ៏ប្រពៃ ទាំងព្រះនិព្វាននោះ ភិក្ខុនោះ ក៏បានធ្វើឲ្យជាក់ច្បាស់ ដោយសព្វគ្រប់ ភិក្ខុនោះ បានលះបង់មានានុស័យ ដោយសព្វគ្រប់ បានលះបង់នូវភវរាគានុស័យ ដោយសព្វគ្រប់ បានលះបង់នូវអវិជ្ជានុស័យ ដោយសព្វគ្រប់ ។ ភិក្ខុនោះ ព្រោះអស់ទៅនៃអាសវៈ ។បេ។ រមែងបានធ្វើឲ្យជាក់ច្បាស់សម្រេច ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អនុបាទាបរិនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ គតិនៃបុរសមាន ៧ យ៉ាង ទង់អនុបាទាបរិនិព្វាន យ៉ាងនេះឯង ។

(៥៣) សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់លើគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ គ្រានោះ ទេវតាពីរអង្គ កាលរាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏ល្អ បានធ្វើភ្នំគិជ្ឈកូដ ទាំងអស់ឲ្យភ្លឺហើយ

## បណ្ណាសកាសង្គហិតោ អព្យាកតវគ្គោ

យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ ឯកា ទេវតា ភគវន្តំ ឯតទវោច ឯតា ភន្តេ ភិក្ខុនិយោ វិមុត្តាតិ អបរា ទេវតា ភគវន្តំ ឯតទវោច ឯតា ភន្តេ អនុបាទិសេសា សុវិមុត្តាតិ ឥទមវោចុំ តា ទេវតា សមនុញ្ញោ សត្ថា អហោសិ ។ អថខោ តា ទេវតា សមនុញ្ញោ សត្ថាតិ ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយឹសុ ។ អថខោ ភគវា តស្សា រត្តិយា អច្ចយេន ភិក្ខូ អាមន្តេសិ ឥមំ ភិក្ខវេ រត្តឹ ទ្វេ ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវល-កប្បំ គិជ្ឈកូដំ ឱភាសេត្វា យេនាហំ តេនុបសង្កមឹសុ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ ភិក្ខវេ ឯកា ទេវតា មំ ឯតទវោច ឯតា ភន្តេ ភិក្ខុនិយោ វិមុត្តាតិ អបរា ទេវតា

ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ៗ លុះទេវតាមួយអង្គ ឋិតនៅក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនីទាំងនោះ រួចស្រឡះហើយ (ចាកកិលេស) ទេវតាមួយអង្គទៀត បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនីទាំងនោះបានជាអនុបាទិសេសនិព្វាន រួចស្រឡះដោយប្រពៃ (ចាកកិលេស) លុះទេវតាទាំងនោះ បានពោលពាក្យនេះហើយ ព្រះសាស្តាក៏ទ្រង់ពេញព្រះហឫទ័យ ៗ គ្រានោះ ទេវតាទាំងនោះគិតថា ព្រះសាស្តាពេញព្រះហឫទ័យ ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ រួចក៏បាត់ចាកទីនោះឯង ៗ លំដាប់នោះ កាលរាត្រីនោះកន្លងទៅ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ក្នុងរាត្រីនេះ ទេវតាពីរអង្គ កាលរាត្រីបឋមយាម កន្លងទៅហើយ មានរស្មីដ៏ល្អ ធ្វើភ្នំគិជ្ឈកូដទាំងអស់ឲ្យភ្លឺ ហើយចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគតហើយ ឋិតនៅក្នុងទីដ៏សមគួរ ៗ ម្នាលភិក្ខុទាំងឡាយ លុះទេវតាមួយអង្គ ឋិតក្នុងទីសមគួរហើយ បានពោលនឹងតថាគតដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនីទាំងនោះរួចស្រឡះ (ចាកកិលេស) ទេវតា មួយអង្គទៀត

មំ ឯតទវោច ឯតា ភន្តេ អនុបាទិសេសា សុវិមុត្តាតិ ឥទមវោចុំ ភិក្ខវេ តា ទេវតា ឥទំ វត្វា មំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយិំសូតិ ។ តេន ខោ បន សមយេន អាយស្មា មហាមោគ្គល្លានោ ភគវតោ អវិទូរេ និសិន្នោ ហោតិ ។ អថខោ អាយស្មតោ មហាមោគ្គល្លានស្ស ឯតទហោសិ កេសំ ខោ ទេវានំ ឯវំ ញាណំ ហោតិ សឧបាទិសេសេ វា សឧបាទិសេសោតិ អនុបាទិសេសេ វា អនុបាទិសេសោតិ ។ តេន ខោ បន សមយេន តិស្សោ នាម ភិក្ខុ អចិរកាលកតោ អញ្ញតរំ ព្រហ្មលោកំ ឧបបន្នោ ហោតិ ។ តត្រាបិ នំ ឯវំ ជានន្តិ តិស្សោ ព្រហ្មា មហិទ្ធិកោ មហានុភាវោតិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ សេយ្យថាបិ នាម ពលវា បុរិសោ សមិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សមិញ្ជេយ្យ ឯវមេវ គិជ្ឈកូដេ បព្វតេ អន្តរហិតោ តស្មឹ ព្រហ្មលោកេ បាតុរហោសិ ។ អទ្ទសា ខោ តិស្សោ ព្រហ្មា

ក៏ពោលនឹងតថាគតដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនីទាំងនោះ ជាអនុបាទិសេសនិព្វាន រួចស្រឡះដោយប្រពៃ ( ចាកកិលេស ) ម្នាលភិក្ខុទាំងឡាយ លុះទេវតាទាំងនោះ បានពោលពាក្យដូច្នេះហើយពោលនូវហេតុនេះហើយ ក៏ថ្វាយបង្គំតថាគត ធ្វើប្រទក្សិណ រួចក៏បាត់បាកទីនោះឯង ។ សម័យនោះឯង ព្រះមហាមោគ្គល្លានដ៏មានអាយុ អង្គុយក្នុងទីជិតព្រះដ៏មានព្រះភាគដែរ ។ លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ពួកទេវតាដូចម្តេច មានញាណកើតឡើងយ៉ាងនេះថា សឧបាទិសេសៈ ក្នុងសឧបាទិសេសៈដូច្នេះខ្លះ អនុបាទិសេសៈក្នុងអនុបាទិសេសៈដូច្នេះខ្លះ ។ សម័យនោះឯង ភិក្ខុឈ្មោះតិស្សៈធ្វើមរណកាល ក្នុងកាលឥឡូវនេះ បានទៅកើតក្នុងព្រហ្មលោកណាមួយ ជនទាំងឡាយតែងដឹងនូវព្រហ្មនោះក្នុងរឿងនោះយ៉ាងនេះថា ព្រហ្មឈ្មោះតិស្ស ជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ។ លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏ស្រាប់តែបាត់ពីភ្នំគិជ្ឈកូដ ទៅប្រាកដឯព្រហ្មលោកនោះឯង ដូចជាបុរសមានកំឡាំងលានូវដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញដូច្នោះឯង។ លុះព្រហ្មឈ្មោះតិស្សៈបានឃើញ

អាយស្មន្តំ មហាមោគ្គល្លានំ ទូរតោ វ អាគច្ឆន្តំ ទិស្វា អាយស្មន្តំ មហាមោគ្គល្លានំ ឯតទវោច ឯហិ ខោ មារិស មោគ្គល្លាន ស្វាគតំ មារិស មោគ្គល្លាន ចិរស្សំ ខោ មារិស មោគ្គល្លាន ឥមំ បរិយាយមកាសិ យទិទំ ឥធាគមនាយ និសីទ មារិស មោគ្គល្លាន ឥទមាសនំ បញ្ញត្តន្តិ ។ និសីទិ ខោ អាយស្មា មហាមោគ្គល្លានោ បញ្ញត្តេ អាសនេ ។ តិស្សោបិ ខោ ព្រហ្មា អាយស្មន្តំ មហាមោគ្គល្លានំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ តិស្សំ ព្រហ្មានំ អាយស្មា មហាមោគ្គល្លានោ ឯតទវោច កតមេសានំ ខោ តិស្ស ទេវានំ ឯវំ ញាណំ ហោតិ សឧបាទិសេសេ វា សឧបាទិសេសោតិ អនុបាទិសេសេ វា អនុបាទិសេសោតិ ។ ព្រហ្មកាយិកានំ ខោ មារិស មោគ្គល្លាន ទេវានំ ឯវំ ញាណំ ហោតិ សឧបាទិសេសេ វា សឧបាទិសេសោតិ អនុបាទិសេសេ វា អនុបាទិសេសោតិ ។ សព្ពេសញ្ញេវ ខោ តិស្ស ព្រហ្មកាយិកានំ ទេវានំ ឯវំ ញាណំ ហោតិ សឧបាទិសេសេ វា សឧបាទិសេសោតិ

ព្រះមហាមោគ្គល្លានដ៏មានអាយុ មកពីចម្ងាយ លុះឃើញហើយ បាន ពោលនឹងព្រះមហាមោគ្គល្លានដ៏មានអាយុដូច្នេះថា បពិត្រព្រះមោគ្គល្លាន អ្នកនិរទុក្ខលោកម្ចាស់ ចូរនិមន្តមក បពិត្រព្រះមោគ្គល្លាន អ្នកនិរទុក្ខ លោកម្ចាស់និមន្តមកស្រួលហើយ បពិត្រព្រះមោគ្គល្លាន អ្នកនិរទុក្ខ លោកម្ចាស់ខានធ្វើនូវបរិយាយ ដែលជាបរិយាយអំពីដំណើរមកក្នុងទីនេះ អស់កាលយូរហើយ បពិត្រព្រះមហាមោគ្គល្លានអ្នកនិរទុក្ខលោកម្ចាស់ចូរ គង់ចុះ នេះជាអាសនៈដែលខ្ញុំម្ចាស់ក្រាលទុក ។ ព្រះមហាមោគ្គល្លានដ៏មាន អាយុ ក៏គង់លើអាសនៈដែលព្រហ្មក្រាលហើយ ។ តិស្សព្រហ្ម បានថ្វាយ បង្គំព្រះមហាមោគ្គល្លានដ៏មានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះ តិស្សព្រហ្មអង្គុយក្នុងទីសមគួរហើយ ព្រះមហាមោគ្គល្លាន ដ៏មានអាយុ បានសួរដូច្នេះថា ម្នាលតិស្សៈ ទេវតាពួកណាខ្លះ មានញាណកើតឡើង យ៉ាងនេះថា សឧបាទិសេសៈ ក្នុងសឧបាទិសេសៈដូច្នេះខ្លះ អនុបាទិសេ-សៈក្នុងអនុបាទិសេសៈដូច្នេះខ្លះ ។ បពិត្រព្រះមោគ្គល្លាន អ្នកនិរទុក្ខ ញាណ រមែងកើតដល់ទេវតា ក្នុងពួកព្រហ្មយ៉ាងនេះថា សឧបាទិសេសៈ ក្នុងសឧបាទិសេសៈដូច្នេះខ្លះ អនុបាទិសេសៈក្នុងអនុបាទិសេសៈ ដូច្នេះ ខ្លះ ។ ម្នាលតិស្ស ពួកទេវតាក្នុងពួកព្រហ្មទាំងអស់ ឬដែលមានញាណ កើតឡើងយ៉ាងនេះថា សឧបាទិសេសៈ ក្នុងសឧបាទិសេសៈដូច្នេះខ្លះ

អនុបាទិសេសេ វា អនុបាទិសេសោតិ ។ ន ខោ មារិស មោគ្គល្លាន សព្វេសំ ព្រហ្មកាយិកានំ ទេវានំ ឯវំ ញាណំ ហោតិ សឧបាទិសេសេ វា សឧបាទិសេសោតិ អនុបាទិសេសេ វា អនុបាទិសេសោតិ ។ យេ ខោ តេ មារិស មោគ្គល្លាន ព្រហ្មកាយិកា ទេវា ព្រហ្មេន អាយុនា សន្តុដ្ឋា ព្រហ្មេន វណ្ណេន ព្រហ្មេន សុខេន ព្រហ្មេន យសេន ព្រហ្មេន អាធិបតេយ្យេន សន្តុដ្ឋា តស្ស ច ឧត្តរឹ និស្សរណំ យថាភូតំ នប្បជានន្តិ តេសំ ន ឯវំ ញាណំ ហោតិ សឧបាទិសេសេ វា សឧបា-ទិសេសោតិ អនុបាទិសេសេ វា អនុបាទិសេសោតិ ។ យេ ច ខោ តេ មារិស មោគ្គល្លាន ព្រហ្មកាយិកា ទេវា ព្រហ្មេន អាយុនា អសន្តុដ្ឋា ព្រហ្មេន វណ្ណេន ព្រហ្មេន សុខេន ព្រហ្មេន យសេន ព្រហ្មេន អាធិបតេយ្យេន អសន្តុដ្ឋា តស្ស ច ឧត្តរឹ និស្សរណំ យថាភូតំ បជានន្តិ តេសំ ឯវំ ញាណំ ហោតិ សឧបាទិសេសេ វា សឧបាទិសេសោតិ អនុបាទិសេសេ វា អនុបាទិសេសោតិ ។ ឥធ មារិស មោគ្គល្លាន ភិក្ខុ

អនុបាទិសេសៈ ក្នុងអនុបាទិសេសៈដូច្នេះ ។ បពិត្រព្រះមោគ្គល្លាន អ្នកនិទុក្ខ មិនមែនទេវតាក្នុងពួកព្រហ្មទាំងអស់ទេ ដែលមានញាណកើតឡើងយ៉ាងនេះថា សឧបាទិសេសៈ ក្នុងសឧបាទិសេសៈដូច្នេះ អនុបាទិសេសៈក្នុងអនុបាទិសេសៈដូច្នេះ ។ បពិត្រព្រះមោគ្គល្លាន អ្នកនិទុក្ខ ទេវតាក្នុងពួកព្រហ្មដែលត្រេកអរ ដោយអាយុដ៏ប្រសើរ ដោយពណ៌សម្បុរដ៏ប្រសើរ ដោយសេចក្តីសុខដ៏ប្រសើរ ដោយយសដ៏ប្រសើរ ដោយអធិបតេយ្យដ៏ប្រសើរ រមែងមិនដឹងនូវការរលាស់ចេញនូវធម៌នោះ តទៅតាមសេចក្តីពិតទេ ទេវតានោះ មិនមែនមានញាណកើតឡើងយ៉ាងនេះថា សឧបាទិសេសៈក្នុងសឧបាទិសេសៈ ដូច្នេះខ្លះអនុបាទិសេសៈក្នុងអនុបាទិសេសៈដូច្នេះខ្លះទេ ។ បពិត្រព្រះមោគ្គល្លាន អ្នកនិទុក្ខ ពួកទេវតាក្នុងពួកព្រហ្មណា ដែលមិនត្រេកអរ ដោយអាយុដ៏ប្រសើរ ដោយពណ៌សម្បុរដ៏ប្រសើរ ដោយសេចក្តីសុខដ៏ប្រសើរ ដោយយសដ៏ប្រសើរ មិនត្រេកអរ ដោយអាធិបតេយ្យដ៏ប្រសើរ ទើបដឹងនូវការរលាស់ចេញនូវធម៌នោះតទៅទៀត តាមសេចក្តីពិត ទេវតាទាំងនោះ ទើបមានញាណ កើតឡើងយ៉ាងនេះថា សឧបាទិសេសៈ ក្នុងសឧបាទិសេសៈ ដូច្នេះ អនុបាទិសេសៈ ក្នុងអនុបាទិសេសៈ ដូច្នេះ ។ បពិត្រព្រះមោគ្គល្លាន អ្នកនិទុក្ខ ក៏ក្នុងសាសនានេះ

ឧភតោភាគវិមុត្តោ ហោតិ តមេនំ តេ ទេវា ឯវំ ជានន្តិ អយំ ខោ អាយស្មា ឧភតោភាគវិមុត្តោ យាវស្ស កាយោ ឋស្សតិ តាវ នំ ទក្ខន្តិ ទេវមនុស្សា កាយស្ស ភេទា ន នំ ទក្ខន្តិ ទេវមនុស្សាតិ ។ ឯវម្បិ ខោ មារិស មោគ្គល្លាន តេសំ ទេវានំ ញាណំ ហោតិ អនុបាទិសេសេ វា អនុបាទិសេសោតិ ។ ឥធ បន មារិស មោគ្គល្លាន ភិក្ខុ បញ្ញាវិមុត្តោ ហោតិ តមេនំ តេ ទេវា ឯវំ ជានន្តិ អយំ ខោ អាយស្មា បញ្ញាវិមុត្តោ យាវស្ស កាយោ ឋស្សតិ តាវ នំ ទក្ខន្តិ ទេវមនុស្សា កាយស្ស ភេទា ន នំ ទក្ខន្តិ ទេវមនុស្សាតិ ។ ឯវម្បិ ខោ មារិស មោគ្គល្លាន តេសំ ទេវានំ ញាណំ ហោតិ អនុបាទិសេសេ វា អនុបាទិសេសោតិ ។ ឥធ បន មារិស មោគ្គល្លាន ភិក្ខុ កាយសក្ខី ហោតិ

ជាឧភតោភាគវិមុត្ត (រួចចាកកិលេសដោយចំណែកទាំងពីរ) ទេវតាទាំងនោះ រមែងដឹងច្បាស់នូវភិក្ខុនោះយ៉ាងនេះថា លោកដ៏មានអាយុអង្គនេះឯង ជាឧភតោភាគវិមុត្ត កាយរបស់ភិក្ខុនោះ ឋិតនៅត្រឹមណា ពួកទេវតានិងមនុស្ស រមែងឃើញនូវភិក្ខុនោះត្រឹមណោះ លុះបែកធ្លាយកងកាយស្លាប់ទៅ ពួកទេវតានិងមនុស្ស មិនបានឃើញនូវភិក្ខុនោះឡើយ ។ បពិត្រព្រះមោគ្គល្លាន អ្នកនិរទុក្ខ ពួកទេវតាទាំងនោះ រមែងមានញាណកើតឡើងយ៉ាងនេះថា អនុបាទិសេសៈ ក្នុងអនុបាទិសេសៈ ដូច្នេះ ។ បពិត្រព្រះមោគ្គល្លាន អ្នកនិរទុក្ខ ភិក្ខុក្នុងសាសនានេះ ជាបញ្ញាវិមុត្ត ពួកទេវតាទាំងនោះ រមែងដឹងនូវភិក្ខុនោះ យ៉ាងនេះថា លោកដ៏មានអាយុនេះឯង ជាបញ្ញាវិមុត្ត កាយរបស់ភិក្ខុនោះ ឋិតនៅត្រឹមណា ពួកទេវតានិងមនុស្ស តែងឃើញនូវភិក្ខុនោះត្រឹមណោះ លុះបែកធ្លាយកងកាយស្លាប់ទៅ ពួកទេវតានិងមនុស្ស មិនបានឃើញនូវភិក្ខុនោះឡើយ ។ បពិត្រព្រះមោគ្គល្លាន អ្នកនិរទុក្ខ ពួកទេវតាទាំងនោះ រមែងមានញាណកើតឡើងយ៉ាងនេះថា អនុបាទិសេសៈ ក្នុងអនុបាទិសេសៈដូច្នេះ ។ បពិត្រព្រះមោគ្គល្លាន អ្នកនិរទុក្ខ ភិក្ខុក្នុងសាសនានេះ ជាកាយសក្ខី

តមេនំ តេ ទេវា ឯវំ ជានន្តិ អយំ ខោ អាយស្មា កាយសក្ខី អប្បេវនាម អយមាយស្មា អនុលោមិកានិ សេនាសនានិ បដិសេវមានោ កល្យាណមិត្តេ ភជមានោ ឥន្ទ្រិយានិ សមន្នានយមានោ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យាតិ ។ ឯវម្បិ ខោ មារិស មោគ្គល្លាន តេសំ ទេវានំ ញាណំ ហោតិ សឧបាទិសេសេ វា សឧបាទិសេសោតិ ។ ឥធ បន មារិស មោគ្គល្លាន ភិក្ខុ ទិដ្ឋិប្បត្តោ ហោតិ ។ បេ ។ សទ្ធាវិមុត្តោ ហោតិ ធម្មានុសារី ហោតិ តមេនំ តេ ទេវា ឯវំ ជានន្តិ អយំ ខោ អាយស្មា ធម្មានុសារី អប្បេវ នាម អយមាយស្មា អនុលោមិកានិ សេនាសនានិ បដិសេវមានោ កល្យាណមិត្តេ ភជមានោ ឥន្ទ្រិយានិ សមន្នានយមានោ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ

ពួកទេវតាទាំងនោះ រមែងដឹងនូវភិក្ខុនោះយ៉ាងនេះថា លោកដ៏មានអាយុនេះឯង ជាកាយសក្ខិ ធ្វើម្ដេចទៅហ្ន៎ លោកដ៏មានអាយុនេះ អាស្រ័យសេពនូវសេនាសនៈដ៏សមគួរ គប់រកនូវកល្យាណមិត្ត ប្រមូលនូវឥន្ទ្រិយទាំងឡាយ កុលបុត្រទាំងឡាយ ចេញចាកផ្ទះ បួសកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់គុណវិសេសណា ក៏ធ្វើឲ្យជាក់ច្បាស់សម្រេចនូវគុណវិសេសនោះ មានព្រហ្មចរិយធម៌ជាទីបំផុត ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។ បពិត្រព្រះមោគ្គល្លាន អ្នកនិរុទ្ធ ពួកទេវតាទាំងនោះ រមែងមានញាណកើតឡើងយ៉ាងនេះថា សឧបាទិសេស ក្នុងឧបាទិសេស ដូច្នេះ ។ បពិត្រព្រះមោគ្គល្លាន អ្នកនិរុទ្ធ ភិក្ខុក្នុងសាសនានេះ ជាទិដ្ឋិប្បត្ត ។បេ។ ជាសទ្ធាវិមុត្ត ជាធម្មានុសារី ពួកទេវតាទាំងនោះ តែងដឹងនូវភិក្ខុនោះយ៉ាងនេះថា លោកដ៏មានអាយុនេះឯង ជាធម្មានុសារី ធ្វើម្ដេចទៅហ្ន៎ លោកដ៏មានអាយុនេះ អាស្រ័យសេពនូវសេនាសនៈដ៏សមគួរ គប់រកនូវកល្យាណមិត្ត ប្រមូលនូវឥន្ទ្រិយទាំងឡាយ កុលបុត្រទាំងឡាយ ចេញចាកផ្ទះ បួសកាន់ផ្នួស ដោយប្រពៃ ដើម្បីប្រយោជន៍ ដល់គុណវិសេសណា

តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យាតិ ។ ឯវម្បិ ខោ មារិស មោគ្គល្លាន តេសំ ទេវានំ ញាណំ ហោតិ សឧបាទិសេសេ វា សឧបាទិសេសោតិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ តិស្សស្ស ព្រហ្មុនោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ព្រហ្មលោកេ អន្តរហិតោ គិជ្ឈកូដេ បព្វតេ បាតុរហោសិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មហាមោគ្គល្លានោ យាវតកោ អហោសិ តិស្សេន ព្រហ្មុនា សទ្ធឹ កថាសល្លាបោ តំ សព្វំ ភគវតោ អារោចេសិ ។ ន ហិ បន តេ មោគ្គល្លាន តិស្សោ ព្រហ្មា សត្តមំ អនិមិត្តវិហារឹ បុគ្គលំ ទេសេសីតិ ។

កំធ្វើឲ្យជាក់ច្បាស់ សម្រេចនូវគុណវិសេសនោះ មានព្រហ្មចរិយ-ធម៌ជាទីបំផុត ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន បវិត្រព្រះមោគ្គល្លាន អ្នកនិវេទក ទេវតាទាំងនោះ មានញាណកើតឡើងយ៉ាងនេះថា សមុប្បាទវិសេសៈក្នុងសមុប្បាទវិសេសៈ ដូច្នេះ ៗ លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏ត្រេកអរ រីករាយចំពោះភាសិត របស់ព្រហ្មឈ្មោះតិស្សៈ ហើយស្រាប់តែបាត់ អំពីព្រហ្មលោក មកប្រាកដ ឯភ្នំឈ្មោះគិជ្ឈកូដក្ងាម ដូចបុរសមានកំឡាំងលានូវដៃ ដែលបត់ចូល ឬ បត់ចូលនូវដៃ ដែលលាចេញដូច្នោះឯង ៗ លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយក្នុងទីដ៏សមគួរ ៗ លុះព្រះមហាមោគ្គល្លានដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលដំណើរដែលបានចរចាត្រឹមណា ជាមួយនឹងព្រហ្មឈ្មោះតិស្សៈ ដោយសព្វគ្រប់ ចំពោះព្រះដ៏មានព្រះភាគ ៗ ម្នាលមោគ្គល្លាន តិស្សព្រហ្ម សំដែងនូវបុគ្គលអ្នកនៅ ដោយអនិមិត្តសមាធិ ៧ ដល់អ្នកមិនបានទេ ៗ

ឯតស្ស ភគវា កាលោ ឯតស្ស សុគត កាលោ យំ ភគវា សត្តមំ អនិមិត្តវិហារឹ បុគ្គលំ ទេសេយ្យ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហិ មោគ្គល្លាន សុណាហិ សាធុកំ មនសិការោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា មហាមោគ្គល្លានោ ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទវោច ឥធ មោគ្គល្លាន ភិក្ខុ សព្វនិមិត្តានំ អមនសិការា អនិមិត្តំ ចេតោសមាធឹ ឧបសម្បជ្ជ វិហរតិ តមេនំ តេ ទេវា ឯវំ ជានន្តិ អយំ ខោ អាយស្មា សព្វនិមិត្តានំ អមនសិការា អនិមិត្តំ ចេតោ-សមាធឹ ឧបសម្បជ្ជ វិហរតិ អប្បេវនាម អយមាយស្មា អនុលោមិកានិ សេនាសនានិ បដិសេវមានោ កល្យា-ណមិត្តេ ភជមានោ ឥន្ទ្រិយានិ សមន្នានយមានោ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យាតិ ។

ព្រះដ៏មានព្រះភាគ គប្បីសំដែងនូវបុគ្គលអ្នកទៅ ដោយអនិមិត្តសមាធិ ទី ៧ ណា បពិត្រព្រះដ៏មានព្រះភាគ កាលនេះ ជាកាលគួរដល់សេចក្ដីនោះ បពិត្រព្រះសុគត កាលនេះ ជាកាលគួរដល់សេចក្ដីនោះហើយ ភិក្ខុទាំងឡាយ បានស្ដាប់ព្រះដ៏មានព្រះភាគ ហើយនឹងចាំទុក ។ ម្នាលមោគ្គល្លាន បើដូច្នោះ ចូរអ្នកស្ដាប់ចុះ ចូរធ្វើទុកក្នុងចិត្តដោយល្អចុះ តថាគតនឹងសំដែង ។ ព្រះមហាមោគ្គល្លានដ៏មានអាយុ បានទទួលស្ដាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ បានត្រាស់ដូច្នេះថា ម្នាលមោគ្គល្លាន ភិក្ខុក្នុងសាសនានេះ បានដល់នូវចេតោសមាធិ ដែលមិនមាននិមិត្ត ព្រោះមិនធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងអស់ ទេវតាទាំងនោះ តែងដឹងនូវភិក្ខុនោះយ៉ាងនេះថា លោកដ៏មានអាយុនេះឯង បានដល់នូវចេតោសមាធិ ដែលមិនមាននិមិត្ត ព្រោះមិនធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងអស់ ធ្វើម្ដេចហ្ន៎ លោកដ៏មានអាយុនេះ អាស្រ័យសេពនូវសេនាសនៈដ៏សមគួរ គប់រកនូវកល្យាណមិត្ត. ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ កុលបុត្រទាំងឡាយចេញចាកផ្ទះ បួលការផ្នួស ដើម្បីប្រយោជន៍ដល់គុណវិសេសណា ក៏បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវគុណវិសេសនោះ មានព្រហ្មចរិយធម៌ជាទីបំផុត ដោយប្រាជ្ញាដ៏ឧត្ដម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។

ឯវំ ខោ មោគ្គល្លាន តេសំ ទេវានំ ញាណំ ហោតិ សឧបាទិសេសេ វា សឧបាទិសេសោតិ ។

(៤៦) ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថ ខោ សីហោ សេនាបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សីហោ សេនាបតិ ភគវន្តំ ឯតទវោច សក្កា នុ ខោ ភន្តេ សន្ទិដ្ឋិកំ ទានផលំ បញ្ញាបេតុន្តិ ។ តេនហិ សីហ តញ្ញេវេត្ថ បដិបុច្ឆាមិ យថា តេ ខមេយ្យ តថា នំ ព្យាករេយ្យាសិ ។ តំ កឹ មញ្ញសិ សីហ ។ ឥធស្សុ ទ្វេ បុរិសា ឯកោ បុរិសោ អស្សទ្ធោ មច្ឆរី កទរិយោ បរិភាសកោ ឯកោ បុរិសោ សទ្ធោ ទានបតិ អនុប្បទានរតោ ។ តំ កឹ មញ្ញសិ សីហ ។ កំ នុ ខោ អរហន្តោ បឋមំ អនុកម្បន្តា អនុកម្បេយ្យុំ

ម្នាលមោគ្គល្លាន ពួកទេវតាទាំងនោះ មានញាណកើតឡើងយ៉ាងនេះថា សឧបាទិសេសៈ ក្នុងសឧបាទិសេសៈ ដូច្នេះ ។

(៥៤) សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវន ជិតក្រុងវេសាលី ។ គ្រានោះ សីហសេនាបតី (សេនាបតីឈ្មោះសីហៈ) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះសីហសេនាបតី អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គអាចនឹងពន្យល់នូវផលនៃទានដែលបុគ្គលឃើញ ដោយខ្លួនឯងបានដែរឬ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលសីហៈ បើដូច្នោះ តថាគតនឹងត្រឡប់សួរអ្នកក្នុងរឿងនុ៎ះវិញ អ្នកគាប់ចិត្តយ៉ាងណា គប្បីដោះស្រាយនូវរឿងនោះយ៉ាងនោះចុះ ។ ម្នាលសីហៈ អ្នកសំគាល់នូវរឿងនោះដូចម្តេច ។ ក្នុងលោកនេះ មានបុរសពីរនាក់ បុរសម្នាក់មិនមានសទ្ធា មានសេចក្តីកំណាញ់ ស្វិតស្វាញ ជាអ្នកជេរប្រទេច បុរសម្នាក់ មានសទ្ធា ជាម្ចាស់ទាន ជាអ្នកត្រេកអរក្នុងការឲ្យទានរឿយ ៗ ។ ម្នាលសីហៈ អ្នកសំគាល់នូវរឿងនោះដូចម្តេច ។ ព្រះអរហន្តទាំងឡាយ កាលអនុគ្រោះ តើគួរនឹងអនុគ្រោះបុរសណាមុន

យោ ច សោ បុរិសោ អស្សទ្ធោ មច្ឆរី កទរិយោ បរិភាសកោ. យោ ច សោ បុរិសោ សទ្ធោ ទានបតិ អនុប្បទានរតោតិ ។ យោ សោ ភន្តេ បុរិសោ អស្សទ្ធោ មច្ឆរី កទរិយោ បរិភាសកោ កិន្តំ អរហន្តោ បឋមំ អនុកម្បន្តា អនុកម្បិស្សន្តិ ។ យោ ច ខោ សោ ភន្តេ បុរិសោ សទ្ធោ ទានបតិ អនុប្បទានរតោ តញ្ញេវ អរហន្តោ បឋមំ អនុកម្បន្តា អនុកម្បេយ្យុំ ។ តំ កិំ មញ្ញសិ សីហ ។ កំ នុ ខោ អរហន្តោ បឋមំ ឧបសង្កមន្តា ឧបសង្កមេយ្យុំ យោ ច សោ បុរិសោ អស្សទ្ធោ មច្ឆរី កទរិយោ បរិភាសកោ យោ ច សោ បុរិសោ សទ្ធោ ទានបតិ អនុប្បទានរតោតិ ។ យោ សោ ភន្តេ បុរិសោ អស្សទ្ធោ មច្ឆរី កទរិយោ បរិភាសកោ កិន្តំ អរហន្តោ បឋមំ ឧបសង្កមន្តា ឧបសង្កមិស្សន្តិ ។ យោ ច ខោ សោ ភន្តេ បុរិសោ សទ្ធោ ទានបតិ

(អនុគ្រោះ) បុរសដែលមិនមានសទ្ធា មានសេចក្តីកំណាញ់ ស្វិតស្វាញ ជាអ្នកជេរ ប្រទេច ឬ (អនុគ្រោះ) បុរសដែលមានសទ្ធា ជាម្ចាស់ទាន ជាអ្នកត្រេកអរ ក្នុងការឲ្យទានហើយ ៗ ។ បពិត្រព្រះអង្គដ៏ចំរើន បុរសណា មិនមានសទ្ធា មានសេចក្តីកំណាញ់ ស្វិតស្វាញ ជាអ្នកជេរ ប្រទេច ព្រះអរហន្តទាំងឡាយ កាលអនុគ្រោះ នឹងអនុគ្រោះបុរសនោះមុនដូចម្តេចបាន ។ បពិត្រព្រះអង្គដ៏ចំរើន បុរសណា មានសទ្ធា ជាម្ចាស់ទាន ជាអ្នកត្រេកអរ ក្នុងការឲ្យទានហើយ ៗ ព្រះអរហន្តទាំងឡាយ កាលអនុគ្រោះ គួរអនុគ្រោះបុរសនោះឯងមុន ។ ម្នាលសីហៈ អ្នកសំគាល់នូវហេតុនោះដូចម្តេច ។ ព្រះអរហន្តទាំងឡាយ កាលចូលទៅរក តើគួរចូលទៅរកបុរសណាមុន (ចូលទៅរក) បុរសដែលមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច ឬ (ចូលទៅរក) បុរសដែលមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឲ្យទានហើយ ៗ ។ បពិត្រព្រះអង្គដ៏ចំរើន បុរសណា មិនមានសទ្ធា មានសេចក្តីកំណាញ់ ស្វិតស្វាញ ជាអ្នកជេរប្រទេច ព្រះអរហន្តទាំងឡាយ កាលចូលទៅរក នឹងចូលទៅរកបុរសនោះមុន ដូចម្តេចបាន ។ បពិត្រព្រះអង្គដ៏ចំរើន បុរសណាមានសទ្ធា ជាម្ចាស់នៃទាន

អនុប្បទានរតោ តញ្ញេវ អរហន្តោ បឋមំ ឧបសង្កមន្តា ឧបសង្កមេយ្យុំ ។ តំ កឹ មញ្ញសិ សីហ ។ កស្ស នុ ខោ អរហន្តោ បឋមំ បដិគ្គណ្ហន្តា បដិគ្គណ្ហេយ្យុំ យោ វា សោ បុរិសោ អស្សទ្ធោ មច្ឆរី កទរិយោ បរិភាសកោ យោ វា សោ បុរិសោ សទ្ធោ ទានបតិ អនុប្បទានរតោតិ ។ យោ សោ ភន្តេ បុរិសោ អស្សទ្ធោ មច្ឆរី កទរិយោ បរិភាសកោ កឹ តស្ស អរហន្តោ បឋមំ បដិគ្គណ្ហន្តា បដិគ្គណ្ហិស្សន្តិ ។ យោ ច ខោ សោ ភន្តេ បុរិសោ សទ្ធោ ទានបតិ អនុប្បទានរតោ តញ្ញេវ អរហន្តោ បឋមំ បដិគ្គណ្ហន្តា បដិគ្គណ្ហេយ្យុំ ។ តំ កឹ មញ្ញសិ សីហ ។ កស្ស នុ ខោ អរហន្តោ បឋមំ ធម្មំ ទេសេន្តា ទេសេយ្យុំ យោ វា សោ បុរិសោ អស្សទ្ធោ មច្ឆរី កទរិយោ បរិភាសកោ យោ វា សោ បុរិសោ សទ្ធោ ទានបតិ អនុប្បទានរតោតិ ។

ជាអ្នកត្រេកអរក្នុងការឲ្យទានហើយ ។ ព្រះអរហន្តទាំងឡាយ កាលចូលទៅរក គួរចូលទៅរកបុរសនោះឯងមុន ។ ម្នាលសីហៈ អ្នកសំគាល់នូវរឿងនោះដូចម្តេច ។ ព្រះអរហន្តទាំងឡាយ កាលទទួលយក (ទាន) គួរទទួលយក (ទាន) របស់បុរសណាមុន (ទទួលយកទាន) របស់បុរសដែលមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច ឬ (ទទួលយកទាន) របស់បុរសដែលមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឲ្យទានហើយ ។ ។ បពិត្រព្រះអង្គដ៏ចំរើន បុរសណា ដែលមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច ព្រះអរហន្តទាំងឡាយ កាលទទួលយក (ទាន) នឹងទទួលយក (ទាន) របស់បុរសនោះមុន ដូចម្តេចបាន ។ បពិត្រព្រះអង្គដ៏ចំរើន បុរសណា ដែលមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរ ក្នុងការឲ្យទានហើយ ។ ព្រះអរហន្តទាំងឡាយ កាលទទួលយក (ទាន) គួរទទួលយក (ទាន) របស់បុរសនោះឯងមុន ។ ម្នាលសីហៈ អ្នកសំគាល់នូវរឿងនោះដូចម្តេច ។ ព្រះអរហន្តទាំងឡាយ កាលសំដែងធម៌ តើគួរសំដែងដល់បុរសណាមុន (សំដែង) ដល់បុរសដែលមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច ឬ (សំដែង) ដល់បុរសដែលមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរ ក្នុងការឲ្យទានហើយ ។

យោ សោ ភន្តេ បុរិសោ អស្សទ្ធោ មច្ឆរី កទរិយោ បរិភាសកោ កឹ តស្ស អរហន្តោ បឋមំ ឧបសង្កមន្តា ឧបសង្កមិស្សន្តិ[១] ។ យោ ច ខោ សោ ភន្តេ បុរិសោ សទ្ធោ ទានបតិ អនុប្បទានរតោ តស្សេវ អរហន្តោ បឋមំ ឧបសង្កមន្តា ឧបសង្កមេយ្យុំ ។ តំ កឹ មញ្ញសិ សីហ ។ កស្ស នុ ខោ កល្យាណោ កិត្តិ-សទ្ទោ អព្ភុគ្គច្ឆេយ្យ យោ វា សោ បុរិសោ អស្សទ្ធោ មច្ឆរី កទរិយោ បរិភាសកោ យោ វា សោ បុរិសោ សទ្ធោ ទានបតិ អនុប្បទានរតោតិ ។ យោ សោ ភន្តេ បុរិសោ អស្សទ្ធោ មច្ឆរី កទរិយោ បរិភាសកោ កឹ តស្ស កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆិស្សតិ ។ យោ ច ខោ សោ ភន្តេ បុរិសោ សទ្ធោ ទានបតិ អនុប្បទានរតោ តស្សេវ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆេយ្យ ។ តំ កឹ មញ្ញសិ សីហ ។ កោ នុ ខោ

១ ឱ. ម. ទេសិស្សន្តិ ។

បពិត្រព្រះអង្គដ៏ចំរើន បុរសណា ដែលមិនមានសទ្ធា មានសេចក្ដីកំណាញ់ ស្វិតស្វាញ ជាអ្នកជេរប្រទេច ព្រះអរហន្តទាំងឡាយ កាលសំដែងធម៌ នឹងសំដែងដល់បុរសនោះមុន ដូចម្ដេចបាន ។ បពិត្រព្រះអង្គដ៏ចំរើន បុរសណាដែលមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឲ្យទានរឿយ ៗ ព្រះអរហន្តទាំងឡាយ កាលសំដែងធម៌ គួរសំដែងដល់បុរសនោះឯងមុន ។ ម្នាលសីហៈ អ្នកសំគាល់នូវរឿងនោះដូចម្ដេច ។ កិត្តិសព្ទដ៏ពីរោះរបស់បុរសណាហ្ន៎ គប្បីខ្ចរខ្ចាយទៅ (កិត្តិសព្ទ) របស់បុរសដែលមិនមានសទ្ធា មានសេចក្ដីកំណាញ់ ស្វិតស្វាញ ជាអ្នកជេរប្រទេច (ខ្ចរខ្ចាយទៅ) ឬ (កិត្តិសព្ទ) របស់បុរសដែលមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឲ្យទានរឿយ ៗ (ខ្ចរខ្ចាយទៅ) ។ បពិត្រព្រះអង្គដ៏ចំរើន បុរសណា ដែលមិនមានសទ្ធា មានសេចក្ដីកំណាញ់ ស្វិតស្វាញ ជាអ្នកជេរប្រទេច កិត្តិសព្ទដ៏ពីរោះរបស់បុរសនោះ នឹងខ្ចរខ្ចាយទៅដូចម្ដេចបាន ។ បពិត្រព្រះអង្គដ៏ចំរើន បុរសណា មានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរ ក្នុងការឲ្យទានរឿយ ៗ កិត្តិសព្ទដ៏ពីរោះរបស់បុរសនោះឯង គួរនឹងខ្ចរខ្ចាយទៅបាន ។ ម្នាលសីហៈ អ្នកសំគាល់នូវរឿងនោះដូចម្ដេច ។ បុរសដូចម្ដេចហ្ន៎

យញ្ញទេវ បរិសំ ឧបសង្កមេយ្យ យទិ ខត្តិយ-បរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិ-បរិសំ យទិ សមណបរិសំ វិសារទោ ឧបសង្កមេយ្យ អមង្កុភូតោ យោ វា សោ បុរិសោ អស្សទ្ធោ មច្ឆរី កទរិយោ បរិភាសកោ យោ វា សោ បុរិសោ សទ្ធោ ទានបតិ អនុប្បទានរតោតិ ។ យោ សោ ភន្តេ បុរិសោ អស្សទ្ធោ មច្ឆរី កទរិយោ បរិភាសកោ កឹ សោ យញ្ញទេវ បរិសំ ឧបសង្កមិស្សតិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សមណ-បរិសំ វិសារទោ ឧបសង្កមិស្សតិ អមង្កុភូតោ ។ យោ ច ខោ សោ ភន្តេ បុរិសោ សទ្ធោ ទានបតិ អនុប្បទានរតោ សោ យញ្ញទេវ បរិសំ ឧបសង្កមេយ្យ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហ-បតិបរិសំ យទិ សមណបរិសំ វិសារទោ ឧបសង្កមេយ្យ អមង្កុភូតោ ។ តំ កឹ មញ្ញសិ សីហ ។ កោ នុ ខោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យ យោ វា សោ បុរិសោ អស្សទ្ធោ មច្ឆ

គប្បីចូលទៅរកបរិស័ទណា ទោះជាខត្តិយបរិស័ទក្តី ព្រាហ្មណ-បរិស័ទក្តី គហបតីបរិស័ទក្តី សមណបរិស័ទក្តី ជាអ្នកក្លៀវក្លា មិនញញើតញញើម គប្បីចូលទៅរកបរិស័ទនោះបាន បុរសដែលមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច ឬ បុរសដែលមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរ ក្នុងការឲ្យទានរឿយៗ (គប្បីចូលទៅរកបរិស័ទនោះបាន) ៗ បពិត្រព្រះអង្គដ៏ចំរើន បុរសណាដែលមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេចបុរសនោះ នឹងចូលទៅរកបរិស័ទណា ទោះជាខត្តិយបរិស័ទក្តី ព្រាហ្មណបរិស័ទក្តី គហបតីបរិស័ទក្តី សមណបរិស័ទក្តី ជាអ្នកក្លៀវក្លា មិនញញើតញញើម នឹងចូលទៅរកបរិស័ទនោះ ដូចម្តេចបាន ៗ បពិត្រព្រះអង្គដ៏ចំរើន បុរសណាដែលមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរ ក្នុងការឲ្យទានរឿយៗ បុរសនោះ គប្បីចូលទៅរកបរិស័ទណា ទោះជាខត្តិយបរិស័ទក្តី ព្រាហ្មណបរិស័ទក្តី គហបតីបរិស័ទក្តី សមណរិស័ទក្តី ជាអ្នកក្លៀវក្លា មិនញញើតញញើម គប្បីចូលទៅរកបរិស័ទនោះបាន ៗ ម្នាលសីហៈ អ្នកសំគាល់នូវរឿងនោះដូចម្តេច ៗ បុរសណាហ្ន៎ លុះបែកធ្លាយរាងកាយស្លាប់ទៅ គប្បីទៅកើតក្នុងសុគតិសួគ៌ទេវលោកបាន បុរសដែលមិនមានសទ្ធា មានសេចក្តីកំណាញ់

កទរិយោ បរិភាសកោ យោ ច សោ-បុរិសោ សទ្ធោ ទានបតិ អនុប្បទានរតោតិ ។ យោ សោ ភន្តេ បុរិសោ អស្សទ្ធោ មច្ឆរី កទរិយោ បរិភាសកោ កឹ សោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សតិ ។ យោ ច ខោ សោ ភន្តេ បុរិសោ សទ្ធោ ទានបតិ អនុប្បទានរតោ សោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យ ។ យានិមានិ ភន្តេ ភគវតា ឆ សន្ទិដ្ឋិកានិ ទានផលានិ អក្ខាតានិ នាហំ ឯត្ថ ភគវតោ សទ្ធាយ គច្ឆាមិ អហំបិ ឯតានិ ជានាមិ អហំ ភន្តេ ទាយកោ ទានបតិ មំ អរហន្តោ បឋមំ អនុកម្បន្តា អនុកម្បន្តិ ។ អហំ ភន្តេ ទាយកោ ទានបតិ មំ អរហន្តោ បឋមំ ឧបសង្កមន្តា ឧបសង្កមន្តិ ។ អហំ ភន្តេ ទាយកោ ទានបតិ មយ្ហំ អរហន្តោ បឋមំ បដិគ្គណ្ហន្តា បដិគ្គណ្ហន្តិ ។

ស្អិតស្អាញ ជាអ្នកជេរប្រទេចឬ បុរសដែលមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរ ក្នុងការឲ្យទានរឿយ ៗ (គប្បីទៅកើតក្នុងសុគតិសួគ៌ទេវ-លោក)។ បពិត្រព្រះអង្គដ៏ចំរើន បុរសណាដែលមិនមានសទ្ធា មានសេចក្តីកំណាញ់ស្អិតស្អាញ ជាអ្នកជេរប្រទេច បុរសនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងសុគតិសួគ៌ទេវលោក ដូចម្តេចបាន ។ បពិត្រព្រះអង្គដ៏ចំរើន បុរសណាដែលមានសទ្ធា ជាម្ចាស់ទាន ជាអ្នកត្រេកអរ ក្នុងការឲ្យទានរឿយ ៗ បុរសនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ គប្បីទៅកើត ក្នុងសុគតិសួគ៌ទេវលោកបាន ។ បពិត្រព្រះអង្គដ៏ចំរើន ផលនៃទានដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯងទាំង ៦ នេះ ព្រះដ៏មានព្រះភាគសំដែងហើយ ខ្ញុំព្រះអង្គមិនបានដល់នូវសេចក្តីជឿព្រះដ៏មានព្រះភាគ ក្នុងហេតុនុ៎ះទេ ខ្ញុំព្រះអង្គក៏បានដឹងច្បាស់នូវផលនៃទានទាំងនោះដែរ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គជាទាយក ជាម្ចាស់ទាន ព្រះអរហន្តទាំងឡាយ កាលអនុគ្រោះ រមែងអនុគ្រោះនូវខ្ញុំព្រះអង្គមុន ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ជាទាយក ជាម្ចាស់ទាន ព្រះអរហន្តទាំងឡាយ កាលចូលទៅរក រមែងចូលទៅរកខ្ញុំព្រះអង្គមុន ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ជាទាយក ជាម្ចាស់ទាន ព្រះអរហន្តទាំងឡាយ កាលទទួលយកទាន រមែងទទួលយកទានរបស់ខ្ញុំព្រះអង្គមុន ។

អហំ ភន្តេ ទាយកោ ទានបតិ មយ្ហំ អរហន្តោ បឋមំ ធម្មំ ទេសេន្តា ទេសេន្តិ ។ អហំ ភន្តេ ទាយកោ ទានបតិ មយ្ហំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ សីហោ សេនាបតិ ទាយកោ ការកោ សង្ឃុបដ្ឋាកោតិ ។ អហំ ភន្តេ ទាយកោ ទានបតិ យញ្ញទេវ បរិសំ ឧបសង្កមាមិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សមណបរិសំ វិសារទោ ឧបសង្កមាមិ អមង្កុភូតោ ។ យានីមានិ ភន្តេ ភគវតា ច សន្ទិដ្ឋិកានិ ទានផលានិ អក្ខាតានិ នាហំ ឯត្ថ ភគវតោ សទ្ធាយ គច្ឆាមិ អហំបិ ឯតានិ ជានាមិ យញ្ច ខោ មំ ភគវា ឯវមាហ ទាយកោ សីហ ទានបតិ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតីតិ ឯតាហំ ន ជានាមិ

បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ជាទាយក ជាម្ចាស់ទាន ព្រះអរហន្តទាំងឡាយ កាលសំដែងធម៌ រមែងសំដែងដល់ខ្ញុំព្រះអង្គមុន ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ជាទាយក ជាម្ចាស់ទាន កិត្តិសព្ទដ៏ពីរោះរបស់ខ្ញុំព្រះអង្គ ខ្ចរខ្ចាយទៅថា សីហសេនាបតី ជាទាយក ជាអ្នកធ្វើ ជាអ្នកបម្រើសង្ឃ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ជាទាយក ជាម្ចាស់ទាន ចូលទៅកាន់បរិសទ្យណា ទោះជា ខត្តិយបរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី គហបតិបរិសទ្យក្តី សមណបរិសទ្យក្តី ខ្ញុំព្រះអង្គ ជាអ្នកក្លៀវក្លា មិនញញើតញញើម រមែងចូលទៅកាន់បរិសទ្យនោះបាន ។ បពិត្រព្រះអង្គដ៏ចំរើន ផលនៃទានដែលបុគ្គលឃើញច្បាស់ ដោយខ្លួនឯង ទាំង ៤ នេះ ព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ខ្ញុំព្រះអង្គមិនដល់នូវសេចក្តីជឿព្រះដ៏មានព្រះភាគក្នុងហេតុនុះទេ ខ្ញុំព្រះអង្គក៏បានដឹងច្បាស់នូវផលនៃទានទាំងនុះដែរ ចំណែកដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នូវផលនៃទានណា នឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលសីហៈ បុគ្គលជាទាយក ជាម្ចាស់ទាន លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងចូលទៅកើតក្នុងសុគតិសួគ៌ទេវលោក ខ្ញុំព្រះអង្គ មិនបានដឹងច្បាស់នូវផលនៃទាននោះទេ

ឯត្ថ ច បនាហំ ភគវតោ សទ្ធាយ គច្ឆាមីតិ ។ ឯវមេតំ សីហ ឯវមេតំ សីហ ទាយកោ សីហ ទានបតិ កាយស្ស ភេទា បរម្មរណា សុគតិំ សគ្គំ លោកំ ឧបបជ្ជតីតិ ។

(៥៥) ចត្តារិមានិ ភិក្ខវេ តថាគតស្ស អរក្ខេយ្យានិ តីហិ ច អនុបវជ្ជោ ។ កតមានិ ចត្តារិ តថាគតស្ស អរក្ខេយ្យានិ ។ បរិសុទ្ធកាយសមាចារោ ភិក្ខវេ តថា-គតោ នត្ថិ តថាគតស្ស កាយទុច្ចរិតំ យំ តថាគតោ រក្ខេយ្យ មា មេ ឥទំ បរោ អញ្ញាសីតិ ។ បរិសុទ្ធវចី-សមាចារោ ភិក្ខវេ តថាគតោ នត្ថិ តថាគតស្ស វចីទុច្ចរិតំ យំ តថាគតោ រក្ខេយ្យ មា មេ ឥទំ បរោ អញ្ញាសីតិ ។ បរិសុទ្ធមនោសមាចារោ ភិក្ខវេ តថាគតោ នត្ថិ តថាគតស្ស មនោទុច្ចរិតំ យំ តថាគតោ រក្ខេយ្យ មា មេ ឥទំ បរោ អញ្ញាសីតិ ។ បរិសុទ្ធាជីវោ ភិក្ខវេ តថាគតោ នត្ថិ តថាគតស្ស មិច្ឆាអាជីវោ យំ តថាគតោ រក្ខេយ្យ

ឥឡូវ ខ្ញុំព្រះអង្គ ដល់នូវសេចក្តីជឿព្រះដ៏មានព្រះភាគ ត្រង់ផលនៃទាននុះ ៗ ម្នាលសីហៈ ដំណើរនុះ យ៉ាងហ្នឹងហើយ ម្នាលសីហៈ ដំណើរនុះ យ៉ាងហ្នឹងហើយ ម្នាលសីហៈ បុគ្គលជាទាយក ជាម្ចាស់ទាន លុះបែកធ្លាយកងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ៗ

(៥៥) ម្នាលភិក្ខុទាំងឡាយ ហេតុទាំងឡាយ ៤ យ៉ាងនេះ តថា-គត មិនបាច់រក្សាផង មិនមានការតិះដៀលដោយហេតុ ៣ យ៉ាងផង ៗ ហេតុទាំង ៤ យ៉ាង ដែលតថាគតមិនបាច់រក្សាតើដូចម្តេច ម្នាលភិក្ខុទាំងឡាយ តថាគត មានកាយសមាចារបរិសុទ្ធហើយ កាយទុច្ចរិតរបស់តថាគតមិនមានទេ ដែលតថាគតគួររក្សាថា កុំឲ្យបុគ្គលដទៃ ដឹងនូវកាយទុច្ចរិតនេះរបស់តថាគតឡើយ ៗ ម្នាលភិក្ខុទាំងឡាយ តថាគត មានវចីសមាចារបរិសុទ្ធហើយ វចីទុច្ចរិតរបស់តថាគតមិនមានទេ ដែលតថាគតគួររក្សាថា កុំឲ្យបុគ្គលដទៃ ដឹងនូវវចីទុច្ចរិតនេះ របស់តថាគតឡើយ ៗ ម្នាលភិក្ខុទាំងឡាយ តថាគត មានមនោសមាចារបរិសុទ្ធហើយ មនោទុច្ចរិត របស់តថាគតមិនមានទេ ដែលតថាគតគួររក្សាថា កុំឲ្យបុគ្គលដទៃ ដឹងនូវមនោទុច្ចរិតនេះ របស់តថាគតឡើយ ៗ ម្នាលភិក្ខុទាំងឡាយ តថាគត មានការចិញ្ចឹមជីវិតបរិសុទ្ធហើយ ការចិញ្ចឹមជីវិតខុស របស់តថាគត មិនមានទេ ដែលតថាគតគួររក្សាថា

មា មេ ឥទំ បរោ អញ្ញាសីតិ ។ ឥមានិ ចត្តារិ តថាគតស្ស អរក្ខេយ្យានិ ។ កតមេហិ តីហិ អនុបវជ្ជោ ។ ស្វាក្ខាតធម្មោ ភិក្ខវេ តថាគតោ តត្រ វត មំ សមណោ វា ព្រាហ្មណោ វា ទេវោ វា មារោ វា ព្រហ្មា វា កោចិ វា លោកស្មឹ សហធម្មេន បដិចោទេស្សតិ ឥតិបិ ត្វំ ន ស្វាក្ខាត-ធម្មោតិ(១) ។ និមិត្តមេតំ ភិក្ខវេ ន សមនុបស្សាមិ ឯតំបហំ ភិក្ខវេ និមិត្តំ អសមនុបស្សន្តោ ខេមប្បត្តោ អភយប្បត្តោ វេសារជ្ជប្បត្តោ វិហរាមិ ។ សុបញ្ញត្តា ខោ បន មេ ភិក្ខវេ សាវកានំ និព្វានគាមិនី បដិ-បទា យថាបដិបន្នា មម សាវកា អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។ តត្រ វត មំ សមណោ វា ព្រាហ្មណោ វា ទេវោ វា មារោ វា ព្រហ្មា វា កោចិ វា លោកស្មឹ សហធម្មេន បដិចោទេស្សតិ

---

១ ឱ. តេ ន ស្វាក្ខាតធម្មោ ។

កុំឲ្យបុគ្គលដទៃ ដឹងនូវការចិញ្ចឹមជីវិតខុសនេះ របស់តថាគតឡើយ ។ ហេតុទាំង ៤ យ៉ាងនេះ តថាគតមិនបាច់រក្សាទេ ។ តថាគតមិនមានការតិះដៀលដោយហេតុ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានធម៌សំដែងល្អហើយ សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកណាមួយក្តី ក្នុងលោក នឹងចោទចំពោះតថាគត ក្នុងរឿងនោះ ប្រកបដោយហេតុថា ព្រះអង្គមិនមែនមានធម៌សំដែងដោយល្អដូច្នេះក្តី ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលឃើញនូវនិមិត្តនុ៎ះ ម្នាលភិក្ខុទាំងឡាយ កាលតថាគត មិនបានឃើញនូវនិមិត្តនុ៎ះហើយ ក៏ដល់នូវសេចក្តីក្សេមក្សាន្ត ដល់នូវសេចក្តីមិនមានភ័យ ដល់នូវសេចក្តីក្លាហាន ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រតិបត្តិ ជាទីទៅកាន់ព្រះនិព្វាន ដែលតថាគតបញ្ញត្តហើយ ដោយប្រពៃដល់ពួកសាវករបស់តថាគត ពួកសាវករបស់តថាគត ដែលប្រតិបត្តិតាម រមែងមានអាសវៈអស់ហើយ បានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្នហើយ បានដល់នូវចេតោវិមុត្តិនឹងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ ។ សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកណាមួយក្តី ក្នុងលោក នឹងចោទចំពោះតថាគត ក្នុងរឿងនោះប្រកបដោយហេតុថា

ឥតិបិ តេ ន សុប្បញ្ញត្តា សាវកានំ និព្វានគាមិនី បដិបទា យថាបដិបន្នា តេ សាវកា អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។ និមិត្តមេតំ ភិក្ខវេ ន សមនុបស្សាមិ ឯតំបហំ ភិក្ខវេ និមិត្តំ អសមនុបស្សន្តោ ខេមប្បត្តោ អភយប្បត្តោ វេសារជ្ជប្បត្តោ វិហរាមិ ។ អនេកសតា ខោ បន មេ ភិក្ខវេ សាវកបរិសា អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។ តត្រ វត មំ សមណោ វា ព្រាហ្មណោ វា ទេវោ វា មារោ វា ព្រហ្មា វា កោចិ វា លោកស្មឹ សហធម្មេន បដិចោទេស្សតិ ឥតិបិ តេ ន អនេកសតា សាវកបរិសា អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។ និមិត្តមេតំ ភិក្ខវេ ន សមនុបស្សាមិ ឯតំបហំ ភិក្ខវេ និមិត្តំ អសមនុបស្សន្តោ ខេមប្បត្តោ

សេចក្តីប្រតិបត្តិ ជាទីទៅកាន់ព្រះនិព្វាន ព្រោះអង្គមិនមែនជាបញ្ញត្ត ដោយប្រពៃ ដល់ពួកសាវក គួរឲ្យពួកសាវករបស់ព្រះអង្គ ដែលប្រតិបត្តិតាមហើយ បានធ្វើឲ្យជាក់ច្បាស់ បានដល់ ។ បេ ។ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅដូច្នេះក្តី ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលឃើញនូវនិមិត្តនុ៎ះ ម្នាលភិក្ខុទាំងឡាយ កាលតថាគតមិនឃើញនូវនិមិត្តនុ៎ះ ក៏ដល់នូវសេចក្តីក្សេមក្សាន្ត ដល់នូវសេចក្តីមិនមានភ័យ ដល់នូវសេចក្តីក្លាហាន ។ ម្នាលភិក្ខុទាំងឡាយ ពួកសាវកបរិសទ្យរបស់តថាគត ជាច្រើនរយ បានធ្វើឲ្យជាក់ច្បាស់ បានដល់ ។ បេ ។ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ ។ សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកណាមួយក្តី ក្នុងលោកនឹងចោទតថាគត ក្នុងរឿងនោះប្រកបដោយហេតុថា ពួកសាវករបស់ព្រះអង្គជាច្រើនរយ មិនមែនបានធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្នហើយ បានដល់នូវចេតោវិមុត្តិនឹងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅដូច្នេះក្តី ។ ម្នាលភិក្ខុទាំងឡាយ តថាគត មិនដែលឃើញនូវនិមិត្តនុ៎ះ ម្នាលភិក្ខុទាំងឡាយ កាលតថាគត មិនឃើញនូវនិមិត្តនុ៎ះហើយ ក៏ដល់នូវសេចក្តីក្សេមក្សាន្ត

អភយប្បត្តោ វេសារជ្ជប្បត្តោ វិហរាមិ ។ ឥមេហិ តីហិ អនុបវជ្ជោ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ តថាគតស្ស អរក្ខេយ្យានិ ឥមេហិ ច តីហិ អនុបវជ្ជោតិ ។

(៥៦) ឯកំ សមយំ ភគវា កិមិលាយំ(១) វិហរតិ វេឡុវនេ ។ អថ ខោ អាយស្មា កិមិលោ(២) យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា កិមិលោ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន តថាគតេ បរិនិព្វុតេ សទ្ធម្មោ ន ចិរដ្ឋិតិកោ ហោតីតិ ។ ឥធ កិមិល តថាគតេ បរិនិព្វុតេ ភិក្ខូ ភិក្ខុនិយោ ឧបាសកា ឧបាសិកាយោ សត្ថរិ អគារវា វិហរន្តិ អប្បតិស្សា ធម្មេ អគារវា វិហរន្តិ អប្បតិស្សា សង្ឃេ អគារវា វិហរន្តិ អប្បតិស្សា សិក្ខាយ អគារវា វិហរន្តិ អប្បតិស្សា សមាធិស្មឹ អគារវា វិហរន្តិ

---

១ ឱ. កិម្ពិលាយំ ។ ២ ឱ. កិម្ពិលោ ។

ដល់នូវសេចក្តីមិនមានភ័យ ដល់នូវសេចក្តីក្លាហាន ហើយសម្រេចសម្រាន្តនៅ ។ តថាគតមិនមានការតិះដៀលដោយហេតុ ៣ យ៉ានេះ ។ ម្នាលភិក្ខុទាំងឡាយ ហេតុទាំង ៤ យ៉ាងនេះឯង ព្រះតថាគតមិនបាច់រក្សាផង មិនមានការតិះដៀលដោយហេតុ ៣ យ៉ាងនេះផង ។

(៥៦) សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តវេឡុវន ជិតក្រុងកិមិលា ។ គ្រានោះ ព្រះកិមិលៈដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះកិមិលៈដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន អ្វីជាហេតុ អ្វីជាបច្ច័យ កាលបើព្រះតថាគតបរិនិព្វានហើយ ព្រះសទ្ធម្ម មិនតាំងនៅអស់កាលយូរបាន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលកិមិលៈ ក្នុងសាសនានេះ កាលតថាគតបរិនិព្វានហើយ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា មិនមានសេចក្តីគោរព កោតក្រែង ក្នុងព្រះសាស្តា មិនមានសេចក្តីគោរព កោតក្រែង ក្នុងព្រះធម៌ មិនមានសេចក្តីគោរព កោតក្រែង ក្នុងព្រះសង្ឃ មិនមានសេចក្តីគោរព កោតក្រែង ក្នុងសិក្ខា មិនមានសេចក្តីគោរព កោតក្រែង ក្នុងសមាធិ

អប្បតិស្សា អប្បមាទេ អគារវា វិហរន្តិ អប្បតិស្សា បដិសន្ថារេ អគារវា វិហរន្តិ អប្បតិស្សា ។ អយំ ខោ កិមិល ហេតុ អយំ បច្ចយោ យេន តថាគតេ បរិនិព្វុតេ សទ្ធម្មោ ន ចិរដ្ឋិតិកោ ហោតីតិ ។ កោ បន ភន្តេ ហេតុ កោ បច្ចយោ យេន តថាគតេ បរិនិព្វុតេ សទ្ធម្មោ ចិរដ្ឋិតិកោ ហោតីតិ ។ ឥធ កិមិល តថាគតេ បរិនិព្វុតេ ភិក្ខូ ភិក្ខុនិយោ ឧបាសកា ឧបាសិកាយោ សត្ថរិ សគារវា វិហរន្តិ សប្បតិស្សា ធម្មេ សគារវា វិហរន្តិ សប្បតិស្សា សង្ឃេ សគារវា វិហរន្តិ សប្បតិស្សា សិក្ខាយ សគារវា វិហរន្តិ សប្បតិស្សា សមាធិស្មឹ សគារវា វិហរន្តិ សប្បតិស្សា អប្បមាទេ សគារវា វិហរន្តិ សប្បតិស្សា បដិសន្ថារេ សគារវា វិហរន្តិ សប្បតិស្សា ។ អយំ ខោ កិមិល ហេតុ អយំ បច្ចយោ យេន តថាគតេ បរិនិព្វុតេ សទ្ធម្មោ ចិរដ្ឋិតិកោ ហោតីតិ ។

(៥៧) សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ

មិនមានសេចក្តីគោរព កោតក្រែង ក្នុងអប្បមាទៈ មិនមានសេចក្តីគោរព កោតក្រែង ក្នុងបដិសណ្ឋារៈ ។ ម្នាលកិមិលៈ នេះជាហេតុ នេះជាបច្ច័យ កាលតថាគតបរិនិព្វានហើយ ព្រះសទ្ធម្មមិនតាំងនៅអស់កាលយូរ ។ បពិត្រព្រះអង្គដ៏ចំរើន អ្វីជាហេតុ អ្វីជាបច្ច័យ កាលបើព្រះតថាគត បរិនិព្វានហើយ ព្រះសទ្ធម្មតាំងនៅអស់កាលយូរបាន ។ ម្នាលកិមិលៈ ក្នុងសាសនានេះ កាលបើតថាគតបរិនិព្វានហើយ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា មានសេចក្តីគោរពកោតក្រែង ក្នុងព្រះសាស្តា មានសេចក្តីគោរពកោតក្រែង ក្នុងព្រះធម៌ មានសេចក្តីគោរពកោតក្រែង ក្នុងព្រះសង្ឃ មានសេចក្តីគោរពកោតក្រែងក្នុងសិក្ខា មានសេចក្តីគោរព កោតក្រែង ក្នុងសមាធិ មានសេចក្តីគោរពកោតក្រែង ក្នុងអប្បមាទៈ មានសេចក្តីគោរពកោតក្រែង ក្នុងបដិសណ្ឋារៈ ។ ម្នាលកិមិលៈ នេះជាហេតុ នេះជាបច្ច័យ កាលបើតថាគតបរិនិព្វានហើយ ទើបព្រះសទ្ធម្ម តាំងនៅអស់កាលយូរបាន ។

( ៥៧ ) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង

ន ចិរស្សេវ អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យ ។ កតមេហិ សត្តហិ ។ ឥធ ភិក្ខវេ ភិក្ខុ សទ្ធោ ហោតិ សីលវា ហោតិ ពហុស្សុតោ ហោតិ បដិសល្លីនោ ហោតិ អារទ្ធវីរិយោ ហោតិ សតិមា ហោតិ បញ្ញវា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ន ចិរស្សេវ អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យាតិ ។

(៩៨) ឯកំ សមយំ ភគវា ភគ្គេសុ វិហរតិ សុំសុមារគិរេ(១) ភេសកឡាវនេ មិគទាយេ ។ តេន ខោ បន សមយេន អាយស្មា មហាមោគ្គល្លានោ ភគ្គេសុ កល្លវាលមុត្តគាមេ(២) ចបលាយមានោ(៣) និសិន្នោ ហោតិ ។ អទ្ទសា ខោ ភគវា ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន អាយស្មន្តំ មហាមោគ្គល្លានំ ភគ្គេសុ កល្លវាលមុត្តគាមេ ចបលាយមានំ និសិន្នំ

---

១ សុសុមារគិរេតិបិ ឈាហេ ។ ២ ម. កល្លវាលបុត្តគាមេ ។ ៣ ឱ. ម. បចលាយមានោ ។

មិនយូរប៉ុន្មាន នឹងបានធ្វើឲ្យជាក់ច្បាស់ បានដល់ ។ បេ ។ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ ។ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ១ មានសីល ១ ជាពហុស្សូត ១ ជាអ្នកសម្ងំនៅក្នុងទីស្ងាត់ ១ ជាអ្នកប្រារព្ធសេចក្តីព្យាយាម ១ មានសតិ ១ មានបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាងនេះឯង មិនយូរប៉ុន្មាន នឹងបានធ្វើឲ្យជាក់ច្បាស់ បានដល់ ។ បេ ។ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ ។

( ៥៨ ) សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងសុំសុមារគិរី នាភេសកឡាវន ជាទីឲ្យនូវអភ័យដល់ម្រឹគជិតក្រុងភគ្គៈ ។ សម័យនោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ អង្គុយងោកងក់ ក្នុងកល្លវាលមុត្តគ្រាម ក្នុងដែនមគធៈ ។ ព្រះដ៏មានព្រះភាគ ទ្រង់មានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុរបស់មនុស្សធម្មតា ទ្រង់បានឃើញនូវព្រះមហាមោគ្គល្លានដ៏មានអាយុ កំពុងអង្គុយងោកងក់ ក្នុងកល្លវាលមុត្តគ្រាម ក្នុងដែនមគធៈ

ទិស្វា សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ភគ្គេសុ សុំសុមារគិរេ ភេសកលាវនេ មិគទាយេ អន្តរហិតោ មគធេសុ កល្លវាលមុត្តគាមេ អាយស្មតោ មហាមោគ្គល្លានស្ស បមុខេ បាតុរហោសិ ។ និសីទិ ភគវា បញ្ញត្តេ អាសនេ ។ និសជ្ជ ខោ ភគវា អាយស្មន្តំ មហាមោគ្គល្លានំ ឯតទវោច បចលាយសិ នោ ត្វំ មោគ្គល្លាន បចលាយសិ នោ ត្វំ មោគ្គល្លានាតិ ។ ឯវំ ភន្តេ ។ តស្មាតិហ មោគ្គល្លាន យថាសញ្ញិស្ស តេ វិហរតោ តំ មិទ្ធំ ឱក្កមតិ តំ សញ្ញំ មនសិការេយ្យាសិ(១) តំ សញ្ញំ ពហុលំ ការេយ្យាសិ(២) ឋានំ ខោ បនេតំ វិជ្ជតិ យន្តេ ឯវំ វិហរតោ តំ មិទ្ធំ បហីយេថ ។ នោ ចេ តេ ឯវំ វិហរតោ តំ មិទ្ធំ បហីយេថ តតោ ត្វំ មោគ្គល្លាន យថាសុតំ យថាបរិយត្តំ ធម្មំ ចេតសា អនុវិតក្កេយ្យាសិ អនុវិចារេយ្យាសិ មនសានុបេក្ខេយ្យាសិ

---

១ ឱ. ម. មនសាកាសិ ។ ២ ពហុលមកាសិ ។

លុះឃើញហើយ ក៏ទ្រង់បាត់អំពីភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់ម្រឹគ ជិតក្រុងសុំសុមារគិរី ក្នុងដែនភគ្គៈ ទៅប្រាកដក្នុងទីចំពោះមុខនៃមហា-មោគ្គល្លានដ៏មានអាយុ ក្នុងកល្លវាលមុត្តគ្រាម ក្នុងដែនមគធៈ ប្រៀបដូចបុរសមានកំឡាំង គប្បីលានូវដៃដែលបត់ចូល ឬគប្បីបត់ចូលនូវដៃដែលលាចេញ ក៏យ៉ាងនោះដែរ ។ ព្រះដ៏មានព្រះភាគ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគ ទ្រង់គង់ហើយ ក៏ត្រាស់ទៅនឹងព្រះមហាមោគ្គល្លានដ៏មានអាយុដូច្នេះថា នែមោគ្គល្លាន អ្នកងោកងក់ ឬ នែមោគ្គល្លាន អ្នកងោកងក់ ឬ ។ ព្រះមហាមោគ្គល្លាន តបថា ព្រះករុណាព្រះអង្គ ។ នែមោគ្គល្លាន ព្រោះហេតុនោះ ក្នុងសាសនានេះ កាលបើអ្នកមានសញ្ញាយ៉ាងណាហើយ សេចក្តីងងុយងោក នៅតែគ្របសង្កត់អ្នក អ្នកគប្បីធ្វើទុកក្នុងចិត្តនូវសញ្ញានោះ គប្បីធ្វើនូវសញ្ញានោះឲ្យក្រាស់ក្រែលឡើង ។ ហេតុនុ៎ះ រមែងមានជាប្រាកដ កាលបើអ្នកធ្វើយ៉ាងនេះហើយ នឹងលះសេចក្តីងងុយងោកនោះបានមិនខាន ។ បើអ្នកធ្វើយ៉ាងនេះហើយ នៅតែលះសេចក្តីងងុយងោកនោះមិនបានទេ នែមោគ្គល្លាន តពីនោះទៅ អ្នកគប្បីត្រិះរិះរឿយ ៗ គប្បីពិចារណារឿយ ៗ គប្បីរំពឹងរឿយ ៗ នូវធម៌ដែលធ្លាប់ស្តាប់ហើយ ធ្លាប់រៀនសូត្រហើយ ដោយចិត្ត

ឋានំ ខោ បនេតំ វិជ្ជតិ យន្តេ ឯវំ វិហរតោ តំ មិទ្ធំ បហីយេថ ។ នោ ចេ តេ ឯវំ វិហរតោ តំ មិទ្ធំ បហីយេថ តតោ ត្វំ មោគ្គល្លាន យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន សជ្ឈាយំ ករេយ្យាសិ ឋានំ ខោ បនេតំ វិជ្ជតិ យន្តេ ឯវំ វិហរតោ តំ មិទ្ធំ បហីយេថ ។ នោ ចេ តេ ឯវំ វិហរតោ តំ មិទ្ធំ បហីយេថ តតោ ត្វំ មោគ្គល្លាន ឧភោ កណ្ណសោតានិ អាវិជេយ្យាសិ បាណិនា គត្តានិ អនុមជ្ជេយ្យាសិ ឋានំ ខោ បនេតំ វិជ្ជតិ យន្តេ ឯវំ វិហរតោ តំ មិទ្ធំ បហីយេថ ។ នោ ចេ តេ ឯវំ វិហរតោ តំ មិទ្ធំ បហីយេថ តតោ ត្វំ មោគ្គល្លាន ឧដ្ឋាយាសនា ឧទកេន អក្ខីនិ អនុមជ្ជិត្វា ទិសា អនុវិលោកេយ្យាសិ នក្ខត្តានិ តារការូបានិ ឧល្លោកេយ្យាសិ ឋានំ ខោ បនេតំ វិជ្ជតិ យន្តេ ឯវំ វិហរតោ តំ មិទ្ធំ បហីយេថ ។ នោ ចេ តេ ឯវំ វិហរតោ តំ មិទ្ធំ បហីយេថ តតោ ត្វំ មោគ្គល្លាន អាលោកសញ្ញំ មនសិករេយ្យាសិ

ហេតុនុ៎ះ រមែងមានជាប្រាកដ កាលបើអ្នកធ្វើយ៉ាងនេះ នឹងអាចលះសេចក្តីងងុយដេកនោះបានមិនខាន ។ បើអ្នកធ្វើយ៉ាងនេះហើយ នៅតែលះសេចក្តីងងុយដេកនោះមិនបានទេ នែមោគ្គល្លាន តពីនោះទៅ អ្នកគប្បីស្វាធ្យាយនូវធម៌ដែលអ្នកធ្លាប់ស្តាប់ហើយ ធ្លាប់រៀនសូត្រហើយ ដោយពិស្តារ ហេតុនុ៎ះ រមែងមានជាប្រាកដ កាលបើអ្នកបានធ្វើយ៉ាងនេះ នឹងលះសេចក្តីងងុយដេកនោះបានមិនខាន ។ កាលបើអ្នកធ្វើយ៉ាងនេះ នៅតែលះសេចក្តីងងុយដេកនោះមិនបានទេ នែមោគ្គល្លាន តពីនោះទៅ អ្នកគប្បីខ្វៀលនូវប្រហោងត្រចៀកទាំងពីរ ហើយគប្បីស្ទាបអង្អែលខ្លួនដោយដៃ ហេតុនុ៎ះ រមែងមានជាប្រាកដ កាលបើអ្នកធ្វើយ៉ាងនេះ នឹងលះសេចក្តីងងុយដេកនោះបានមិនខាន ។ បើអ្នកធ្វើយ៉ាងនេះហើយ នៅតែលះសេចក្តីងងុយដេកនោះមិនបានទេ នែមោគ្គល្លាន តពីនោះទៅ អ្នកគប្បីក្រោកពីអាសនៈ ហើយយកទឹកលាបភ្នែក រួចគប្បីក្រឡេកមើលទិសទាំងឡាយ គប្បីក្រឡេកមើលផ្កាយនក្ខត្តឫក្ស ហេតុនុ៎ះ រមែងមានជាប្រាកដ កាលបើអ្នកបានធ្វើយ៉ាងនេះ នឹងអាចលះសេចក្តីងងុយដេកនោះបានមិនខាន ។ កាលបើអ្នកបានធ្វើយ៉ាងនេះ នៅតែលះសេចក្តីងងុយដេកនោះមិនបាន នែមោគ្គល្លាន តពីនោះទៅ អ្នកគប្បីធ្វើទុកក្នុងចិត្តនូវអាលោកសញ្ញា ( សេចក្តីសំគាល់នូវពន្លឺ )

ទិវាសញ្ញំ អធិដ្ឋហេយ្យាសិ យថា ទិវា តថា រត្តិំ យថា រត្តិំ តថា ទិវា ឥតិ វិវដេន[1] ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេយ្យាសិ ឋានំ ខោ បនេតំ វិជ្ជតិ យំ តេ ឯវំ វិហរតោ តំ មិទ្ធំ បហីយេថ ។ នោ ចេ តេ ឯវំ វិហរតោ តំ មិទ្ធំ បហីយេថ តតោ ត្វំ មោគ្គល្លាន បច្ឆាបុរេសញ្ញី ចង្កមំ អធិដ្ឋហេយ្យាសិ អន្តោគតេហិ ឥន្ទ្រិយេហិ អពហិគតេន មានសេន ឋានំ ខោ បនេតំ វិជ្ជតិ យំ តេ ឯវំ វិហរតោ តំ មិទ្ធំ បហីយេថ ។ នោ ចេ តេ ឯវំ វិហរតោ តំ មិទ្ធំ បហីយេថ តតោ ត្វំ មោគ្គល្លាន ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេយ្យាសិ បាទេ បាទំ អច្ចាធាយ សតោ សម្បជានោ ឧដ្ឋានសញ្ញំ មនសិករិត្វា បដិពុទ្ធេន ច តេ មោគ្គល្លាន ខិប្បញ្ញេវ បច្ចុដ្ឋាតព្វំ ន សេយ្យសុខំ ន បស្សសុខំ

១ ម. មិទ្ធវិគតេន ។

គប្បីអធិដ្ឋាននូវសញ្ញាថា វេលាថ្ងៃ គឺអធិដ្ឋានថា វេលាថ្ងៃ យ៉ាងណា វេលាយប់ ក៏យ៉ាងនោះ វេលាយប់ យ៉ាងណា វេលាថ្ងៃ ក៏យ៉ាងនោះដែរ គប្បីមានចិត្តបើកស្រឡះដូច្នេះ មិនមានអ្វីរួបរិត បំរើននូវចិត្តប្រកបដោយពន្លឺ ហេតុនោះ រមែងមានជាប្រាកដ កាលបើអ្នកបានធ្វើយ៉ាងនេះ នឹងលះសេចក្តីងងុយដេកនោះបានមិនខាន ។ កាលបើអ្នកបានធ្វើយ៉ាងនេះ នៅតែលះសេចក្តីងងុយដេកនោះមិនបានទេ នែមោគ្គល្លាន តពីនោះទៅ អ្នកគប្បីមានសេចក្តីសំគាល់ ក្នុងខាងក្រោយ នឹងខាងមុខ មានឥន្ទ្រិយតាំងនៅខាងក្នុង មានចិត្តមិនប្រព្រឹត្តទៅខាងក្រៅ ហើយគប្បីអធិដ្ឋាននូវចង្ក្រម ហេតុនុ៎ះ រមែងមានជាប្រាកដ កាលបើអ្នកធ្វើយ៉ាងនេះ នឹងលះសេចក្តីងងុយដេកនោះបានមិនខាន ។ កាលបើអ្នកបានធ្វើយ៉ាងនេះ នៅតែលះសេចក្តីងងុយដេកនោះមិនបានទេ នែមោគ្គល្លាន តពីនោះទៅ អ្នកគប្បីសម្រេចនូវសីហសេយ្យ គឺដេកដូចជាសត្វសីហៈ ផ្អៀងទៅខាងស្តាំ គប្បីតម្រួតជើងដោយជើង ជាអ្នកមានសតិ មានសម្បជញ្ញៈ គប្បីធ្វើទុកក្នុងចិត្តនូវឧដ្ឋានសញ្ញា គឺសេចក្តីសំគាល់ថា នឹងក្រោកឡើង នែមោគ្គល្លាន កាលបើអ្នកភ្ញាក់ហើយ គប្បីក្រោកឡើងឲ្យឆាប់ ដោយគិតថា អាត្មាអញនឹងមិនប្រកបរឿយ ៗ នូវសេចក្តីសុខព្រោះការដេក មិនប្រកបរឿយ ៗ នូវសេចក្តីសុខ ព្រោះការទំរេត

ន មិទ្ធសុខំ អនុយុត្តោ វិហរិស្សាមីតិ ។ ឯវញ្ហិ តេ មោគ្គល្លាន សិក្ខិតព្វំ ។ តស្មាតិហ មោគ្គល្លាន ឯវំ សិក្ខិតព្វំ ន ឧច្ចាសោណ្ឌំ បគ្គហេត្វា កុលានិ ឧបសង្កមិស្សាមីតិ ។ ឯវញ្ហិ តេ មោគ្គល្លាន សិក្ខិតព្វំ ។ សចេ មោគ្គល្លាន ភិក្ខុ ឧច្ចាសោណ្ឌំ បគ្គហេត្វា កុលានិ ឧបសង្កមតិ សន្តិ ហិ មោគ្គល្លាន កុលេសុ កិច្ចករណីយានិ យេន មនុស្សា អាគតំ ភិក្ខុំ ន មនសិករោន្តិ ។ តត្រ ភិក្ខុស្ស ឯវំ ហោតិ កោ សុ ទានិ មំ ឥមស្មិំ កុលេ បរិភិន្ទិ វិរត្តរូបាទានិមេ មយិ មនុស្សាតិ ។ ឥតិស្ស អលាភេន មង្កុភាវោ មង្កុភូតស្ស ឧទ្ធច្ចំ ឧទ្ធតស្ស អសំវរោ អសំវុតស្ស អារា ចិត្តំ សមាធិម្ហា ។ តស្មាតិហ មោគ្គល្លាន ឯវំ សិក្ខិតព្វំ ន វិគ្គាហិកកថំ កថេស្សាមីតិ ។

មិនប្រកបរឿយ ៗ នូវសេចក្ដីសុខ ព្រោះសេចក្ដីងងុយងោកទេ ៗ នែមោគ្គល្លាន អ្នកត្រូវសិក្សាយ៉ាងនេះឯង ៗ នែមោគ្គល្លាន ព្រោះហេតុនោះក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា អាត្មាអញមិនលើកឡើងនូវប្រមាយគឺចិត្តឲ្យខ្ពស់ហើយ ចូលទៅរកត្រកូលទាំងឡាយទេ ៗ នែមោគ្គល្លាន អ្នកគប្បីសិក្សាយ៉ាងនេះ ៗ នែមោគ្គល្លាន បើភិក្ខុលើកឡើងនូវប្រមាយគឺចិត្តឲ្យខ្ពស់ ចូលទៅរកត្រកូលទាំងឡាយហើយ នែមោគ្គល្លាន ព្រោះក្នុងត្រកូលទាំងឡាយ រមែងមានកិច្ចដែលគួរធ្វើច្រើន មនុស្សទាំងឡាយ រមែងមិនយកចិត្តទុកដាក់ នឹងភិក្ខុដែលមកដល់ទេ ៗ ក្នុងរឿងនោះ ភិក្ខុមានសេចក្ដីត្រិះរិះយ៉ាងនេះថា ក្នុងវេលានេះ អ្នកណាហ្ន៎ បំបែកអាត្មាអញចេញពីត្រកូលនេះ បានជាមនុស្សទាំងនេះមានសេចក្ដីធុញទ្រាន់ក្នុងអាត្មាអញ ៗ សេចក្ដីអៀនខ្មាស រមែងមានដល់ភិក្ខុនោះ ដោយមិនមានលាភ កាលបើភិក្ខុមានសេចក្ដីអៀនខ្មាសកើតឡើងហើយ សេចក្ដីរាយមាយ ក៏កើតឡើង កាលបើភិក្ខុមានសេចក្ដីរាយមាយ កើតឡើងហើយ សេចក្ដីមិនសង្រួម ក៏កើតឡើង កាលបើសេចក្ដីមិនសង្រួមកើតឡើងហើយ ចិត្តក៏ឆ្ងាយអំពីសមាធិ ៗ នែមោគ្គល្លាន ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា អាត្មាអញ នឹងមិនពោលនូវពាក្យទាស់ទែង ៗ

ឯវញ្ហិ តេ មោគ្គល្លាន សិក្ខិតព្វំ វិគ្គាហិកាយ មោគ្គល្លាន កថាយ សតិ កថាពាហុល្លំ បាដិកង្ខំ កថាពាហុល្លេ សតិ ឧទ្ធច្ចំ ឧទ្ធតស្ស អសំវរោ អសំវុតស្ស អារា ចិត្តំ សមាធិម្ហា ។ នាហំ មោគ្គល្លាន សព្វេហេវ សំសគ្គំ វណ្ណយាមិ ន បនាហំ មោគ្គល្លាន សព្វេហេវ សំសគ្គំ ន វណ្ណយាមិ សគហដ្ឋបព្វជិតេហិ ខោ អហំ មោគ្គល្លាន សំសគ្គំ ន វណ្ណយាមិ យានិ ច ខោ តានិ សេនាសនានិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហសេយ្យកានិ បដិសល្លានសារុប្បានិ តថារូបេហិ សេនាសនេហិ សំសគ្គំ វណ្ណយាមីតិ ។ ឯវំ វុត្តេ អាយស្មា មហាមោគ្គល្លានោ ភគវន្តំ ឯតទវោច

ម្នាលមោគ្គល្លាន អ្នកគប្បីសិក្សាយ៉ាងនេះចុះ ម្នាលមោគ្គល្លាន កាលបើពាក្យចាស់ទែងមានហើយ ការលោកនិយាយច្រើន ក៏ប្រាកដឡើង កាលបើការលោកនិយាយច្រើនមានហើយ សេចក្តីរាយមាយ ក៏ប្រាកដឡើង កាលបើសេចក្តីរាយមាយមានហើយ សេចក្តីមិនសង្រួម ក៏ប្រាកដឡើង កាលបើសេចក្តីមិនសង្រួមមានហើយ ចិត្តក៏ឆ្ងាយអំពីសមាធិ ។ ម្នាលមោគ្គល្លាន តថាគត មិនបានសរសើរនូវការជាប់ជំពាក់ដោយវត្ថុទាំងអស់ ម្នាលមោគ្គល្លាន ប៉ុន្តែ តថាគត មិនមែនជាមិនសរសើរការជាប់ជំពាក់ដោយវត្ថុទាំងអស់ទេ ម្នាលមោគ្គល្លាន តថាគត មិនបានសរសើរនូវការជាប់ជំពាក់ ដោយគ្រហស្ថ នឹងបព្វជិតទាំងឡាយប៉ុណ្ណោះ ឯសេនាសនៈណា មានសំឡេងតិច មិនមានសំឡេងគឹកកង មានខ្យល់បក់ហើយ គួរជាទីធ្វើនូវការកំបាំងរបស់មនុស្ស សមគួរដល់ការពួនសម្ងំ តថាគត រមែងសរសើរនូវការជាប់ជំពាក់ដោយសេនាសនៈ មានសភាពដូច្នោះ ។ កាលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា

កិត្តាវតា នុ ខោ ភន្តេ ភិក្ខុ សង្ខិត្តេន តណ្ហាសង្ខយវិមុត្តោ ហោតិ អច្ចន្តនិដ្ឋោ អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានន្តិ ។ ឥធ មោគ្គល្លាន ភិក្ខុនោ សុតំ ហោតិ សព្វេ ធម្មា នាលំ អភិនិវេសាយាតិ ឯវញ្ចេតំ មោគ្គល្លាន ភិក្ខុនោ សុតំ ហោតិ សព្វេ ធម្មា នាលំ អភិនិវេសាយាតិ ។ សោ សព្វំ ធម្មំ អភិជានាតិ សព្វំ ធម្មំ អភិញ្ញាយ សព្វំ ធម្មំ បរិជានាតិ សព្វំ ធម្មំ បរិញ្ញាយ យំកិញ្ចិ វេទនំ វេទិយតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា ។ សោ តាសុ វេទនាសុ អនិច្ចានុបស្សី វិហរតិ វិរាគានុបស្សី វិហរតិ និរោធានុបស្សី វិហរតិ បដិនិស្សគ្គានុបស្សី វិហរតិ ។ សោ តាសុ វេទនាសុ អនិច្ចានុបស្សី វិហរន្តោ វិរាគានុបស្សី វិហរន្តោ និរោធានុបស្សី វិហរន្តោ

បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុមានចិត្តផុតស្រឡះពិត ក្នុងការអស់ទៅនៃតណ្ហា មានសេចក្ដីសម្រេចដ៏ទៀង មានសេចក្ដីក្សេមចាកយោគៈដ៏ទៀង មានព្រហ្មចារ្យដ៏ទៀង មានទីបំផុតដ៏ទៀង ជាបុគ្គលប្រសើរ ជាងទេវតានិងមនុស្សទាំងឡាយ យ៉ាងសង្ខេប តើដោយហេតុប៉ុន្មានហ្ន៎ ។ នៃមោគ្គល្លាន ភិក្ខុក្នុងសាសនានេះ មានការបេះដឹងថា ធម៌ទាំងអស់ មិនគួរប្រព្រឹត្តទៅ ដើម្បីសេចក្ដីប្រកាន់មាំឡើយ នៃមោគ្គល្លាន ភិក្ខុមានការបេះដឹងនុ៎ះថា ធម៌ទាំងអស់ មិនគួរប្រព្រឹត្តទៅ ដើម្បីសេចក្ដីប្រកាន់មាំ យ៉ាងនេះឡើយ ។ ភិក្ខុនោះ រមែងដឹងច្បាស់នូវធម៌ទាំងអស់ លុះដឹងច្បាស់នូវធម៌ទាំងអស់ហើយ ក៏កំណត់ដឹងនូវធម៌ទាំងអស់ លុះកំណត់ដឹងនូវធម៌ទាំងអស់ហើយ ក៏ទទួលនូវវេទនាណាមួយ គឺវេទនាជាសុខ ឬ ជាទុក្ខ ឬ មិនមែនជាទុក្ខមិនមែនជាសុខ ។ ភិក្ខុនោះ ជាអ្នកពិចារណាឃើញរឿយ ៗ ថា មិនទៀង ក្នុងវេទនាទាំងនោះ ពិចារណាឃើញរឿយ ៗ នូវការប្រាសចាកតម្រេក ពិចារណាឃើញរឿយ ៗ នូវការរលត់ទុក្ខ ពិចារណាឃើញរឿយ ៗ នូវកិរិយាលះបង់ ។ កាលភិក្ខុនោះ ពិចារណាឃើញរឿយ ៗ ថា មិនទៀង ក្នុងវេទនាទាំងនោះ ពិចារណាឃើញរឿយ ៗ នូវការប្រាសចាកតម្រេក ពិចារណាឃើញរឿយ ៗ នូវការរលត់ទុក្ខ

បដិនិស្សគ្គានុបស្សី វិហរន្តោ ន ច កិញ្ចិ លោកេ ឧបាទិយតិ អនុបាទិយំ ន បរិតស្សតិ អបរិតស្សំ បច្ចត្តញ្ញេវ បរិនិព្ពាយតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ ឯត្តាវតា ខោ មោគ្គល្លាន ភិក្ខុ សង្ខិត្តេន តណ្ហាសង្ខយវិមុត្តោ ហោតិ អច្ចន្តនិដ្ឋោ អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានន្តិ ។

(៥៩) មា ភិក្ខវេ បុញ្ញានំ ភាយិត្ថ សុខស្សេតំ ភិក្ខវេ អធិវចនំ យទិទំ បុញ្ញានិ ។ អភិជានាមិ ខោ បនាហំ ភិក្ខវេ ទីឃរត្តំ ឥដ្ឋំ កន្តំ មនាបំ វិបាកំ បច្ចនុភូតំ សត្ត វស្សានិ មេត្តចិត្តំ ភាវេសឹ សត្ត វស្សានិ មេត្តចិត្តំ ភាវេត្វា សត្ត សំវដ្ដវិវដ្ដកប្បេ ន ឥមំ លោកំ បុនាគមាសឹ សំវដ្ដមានេ សុទាហំ ភិក្ខវេ លោកេ

ពិចារណាឃើញហើយ ៗ នូវកិរិយាលះបង់ ក៏លែងប្រកាន់មាំនូវវត្ថុណាមួយក្នុងលោក កាលបើមិនប្រកាន់មាំហើយ រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុតហើយ ក៏រមែងបរិនិព្វានដោយពិត (ភិក្ខុនោះ) ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបានអប់រំហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលមោគ្គល្លាន ភិក្ខុមានចិត្តផុតស្រឡះ ព្រោះធ្វើធម៌នោះឲ្យជាអារម្មណ៍ ក្នុងការអស់ទៅនៃតណ្ហា មានសេចក្តីសម្រេចដ៏ទៀង មានសេចក្តីក្សេមចាកយោគៈដ៏ទៀង មានព្រហ្មចរិយៈដ៏ទៀង មានទីបំផុតដ៏ទៀង ជាបុគ្គលប្រសើរជាងទេវតានិងមនុស្សទាំងឡាយយ៉ាងសង្ខេប ដោយហេតុប៉ុណ្ណេះឯង ។

(៥៩) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំខ្លាចនូវបុណ្យឡើយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា បុណ្យនេះជាឈ្មោះនៃសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ តថាគតដឹងច្បាស់ថា តថាគតបានចំរើនមេត្តា-ចិត្តដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាផលដែលបុគ្គលទទួលហើយ ៗ អស់ឆ្នាំ ៧ ជាយូរអង្វែង លុះតថាគតចំរើននូវមេត្តាចិត្តអស់ឆ្នាំ ៧ ហើយ ក៏មិនបានមកកាន់លោកនេះទៀត អស់សំវដ្តកប្បនិងវិវដ្តកប្ប ៧ ម្នាលភិក្ខុទាំងឡាយ កាលដែលលោកវិនាសទៅ

អាភស្សរូបគោ ហោមិ វិវដ្ដមានេ លោកេ សុញ្ញំ ព្រហ្មវិមានំ ឧបបជ្ជាមិ ។ តត្រ សុទំ ភិក្ខវេ ព្រហ្មា ហោមិ មហាព្រហ្មា អភិភូ អនភិភូតោ អញ្ញទត្ថុទសោ វសវត្តី ។ ឆត្តឹសក្ខត្តុំ ខោ បនាហំ ភិក្ខវេ សក្កោ អហោសឹ ទេវានមិន្ទោ ។ អនេកសតក្ខត្តុំ រាជា អហោសឹ ចក្កវត្តី ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី ជនបទត្ថាវរិយប្បត្តោ សត្តរតនសមន្នាគតោ ។ តស្ស មយ្ហំ ភិក្ខវេ ឥមានិ សត្ត រតនានិ អហេសុំ សេយ្យថីទំ ចក្ករតនំ ហត្ថិរតនំ អស្សរតនំ មណិរតនំ ឥត្ថិរតនំ គហបតិរតនំ បរិណាយករតនមេវ សត្តមំ ។ បរោសហស្សំ ខោ បន មេ ភិក្ខវេ បុត្តា អហេសុំ សូរា វីរង្គរូបា បរសេនប្បមទ្ទនា ។ សោ ឥមំ បឋវឹ សាគរបរិយន្តំ អទណ្ឌេន អសត្ថេន ធម្មេន អភិវិជិយ អជ្ឈាវសិំ ។

តថាគត បានទៅកើតក្នុងអាភស្សរព្រហ្ម កាលដែលលោកចំរើនឡើង តថាគតបានទៅកាន់ព្រហ្មវិមានដែលសូន្យ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងព្រហ្មវិមាននោះ តថាគតជាព្រហ្ម ជាមហាព្រហ្ម គ្របសង្កត់លើព្រហ្មឯទៀត ព្រហ្មឯទៀត មិនអាចគ្របសង្កត់តថាគតបាន តថាគតជាអ្នកឃើញហេតុសព្វគ្រប់ ជាអ្នកធ្វើព្រហ្មទាំងពួង ឲ្យលុះក្នុងអំណាចខ្លួន ។ ម្នាលភិក្ខុទាំងឡាយ តថាគតកើតជាសក្កទេវរាជ ៣៦ ដង ។ តថាគតបានជាស្តេចចក្រពត្តិ ប្រកបដោយធម៌ ជាធម្មរាជ ជាឥស្សរៈក្នុងផែនដីមានព្រំប្រទល់ ក្នុងទីបំផុតនៃសមុទ្រទាំង ៤ មានជ័យជំនះដល់នូវការៈទាំងមួយក្នុងជនបទ បរិបូណ៌ដោយរតនៈទាំង ៧ ប្រការ ជាច្រើនរយដង ។ ម្នាលភិក្ខុទាំងឡាយ រតនៈ ៧ ប្រការនេះ កើតដល់តថាគតនោះ គឺចក្ករតនៈ ១ ហត្ថិរតនៈ ១ អស្សរតនៈ ១ មណិរតនៈ ១ ឥត្ថីរតនៈ ១ គហបតិរតនៈ ១ បរិនាយករតនៈ ១ ជាគំរប់ ៧ ។ ម្នាលភិក្ខុទាំងឡាយ តថាគត មានកូនច្រើនពាន់ ជាអ្នកក្លៀវក្លា មានសភាពជាអ្នកមានសេចក្តីព្យាយាម អាចញាំញីនូវសេនានៃស្តេចដទៃបាន ។ តថាគតបានឈ្នះហើយ នៅគ្រប់គ្រងនូវផែនដីនេះ ដែលមានសាគរជាទីបំផុត ដោយធម៌មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រាទេ ។

បស្ស បុញ្ញានំ វិបាកំ កុសលានំ សុខេសិនំ
មេត្តចិត្តំ ភាវេត្វា សត្ត វស្សានិ ភិក្ខវេ
សត្ត សំវដ្ដវិវដ្ដកប្បេ ន យិមំ លោកំ បុនាគមិំ
សំវដ្ដមានេ លោកម្ហិ ហោមិ អាភស្សរូបគោ
វិវដ្ដមានេ លោកម្ហិ សុញ្ញព្រហ្មូបគោ អហុំ
សត្តក្ខត្តុំ មហាព្រហ្មា វសវត្តី តទា អហុំ
ឆត្តឹសក្ខត្តុំ ទេវិន្ទោ ទេវរជ្ជមការយិំ
ចក្កវត្តី អហុំ រាជា ជម្ពុសណ្ឌស្ស ឥស្សរោ ។
មុទ្ធាភិសិត្តោ ខត្តិយោ មនុស្សាធិបតី អហុំ
អទណ្ឌេន អសត្ថេន វិជេយ្យ បថវឹ ឥមំ
អសាហសេន ធម្មេន សមេន មនុសាសិ តំ
ធម្មេន រជ្ជំ ការេត្វា អស្មឹ បថវិមណ្ឌលេ
មហទ្ធនេ មហាភោគេ អឌ្ឍេ អជាយិសំ កុលេ
សព្វកាមេហិ សម្បន្នេ រតនេហិ ច សត្តហិ

ម្នាលភិក្ខុទាំងឡាយ តថាគត បានឃើញនូវផលនៃបុណ្យ ជាកុសលហើយ ក៏បានប្រាប់ពួកសត្វអ្នកស្វែងរកនូវសេចក្ដីសុខ ហើយចំរើននូវមេត្តាចិត្ត អស់ ៧ ឆ្នាំ មិនបានមកកាន់លោកនេះទៀត អស់សំវដ្តកប្បនិងវិវដ្តកប្ប ៧ ដង កាលដែលលោកវិនាស តថាគតទៅកើតក្នុងអាភស្សរព្រហ្ម កាលដែលលោកចំរើន តថាគត ចូលទៅកាន់ព្រហ្មលោកដែលសូន្យ ក្នុងកាលនោះ តថាគត បានជាមហាព្រហ្ម ជាអ្នកធ្វើព្រហ្មឯទៀត ឲ្យលុះក្នុងអំណាចនៃខ្លួនអស់ ៧ ដង បានជាស្ដេចនៃទេវតា ជាកំពូលនៃទេវតាអស់ ៣៦ ដង បានជាស្ដេចចក្រពត្តិ ជាធំក្នុងជម្ពូទ្វីប ។ បានជាក្សត្រដែលបានមុទ្ធាភិសេក ជាអធិបតីរបស់មនុស្ស បានឈ្នះនូវផែនដីនេះ ដោយធម៌ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រា មិនបាច់កំហែងកំហល់ទេ បានប្រៀនប្រដៅដោយធម៌ដ៏ស្មើ ហើយបានសោយរាជសម្បត្តិនោះ លើមណ្ឌលនៃផែនដីនេះ ដោយធម៌ តែងបានកើតក្នុងត្រកូលស្ដុកស្ដម្ភ មានទ្រព្យច្រើន មានភោគៈច្រើន បរិបូណ៌ដោយកាមទាំងពួងផង ដោយរតនៈទាំង ៧ ផង

ពុទ្ធា សង្ខ្យាហាតា លោកេ តេហិ ឯតំ សុទេសិតំ
ឯស ហេតុ មហន្តស្ស បជេព្យា យេន វុឌ្ឍិ
បហុតវិត្តូបការោ ភជោ ហោមិ បតាបវា
ឥទ្ធិមា យសវា ហោមិ ជម្ពុសណ្ឌស្ស ឥស្សរោ ។
កោ សុត្វា នប្បសីទេយ្យ អបិ កណ្ហាភិជាតិយោ
តស្មា ហិ អត្តកាមេន មហត្តមភិកង្ខតា
សទ្ធម្មោ គរុកាតព្វោ សរំ ពុទ្ធានសាសនន្តិ ។

(៦០) អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន អនាថបិណ្ឌិកស្ស គហបតិស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ តេន ខោ បន សមយេន អនាថបិណ្ឌិ-កស្ស គហបតិស្ស និវេសនេ មនុស្សា ឧច្ចាសទ្ទា មហាសទ្ទា ហោន្តិ ។ អថខោ អនាថបិណ្ឌិកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អនាថបិណ្ឌិកំ គហបតិំ ភគវា ឯតទវោច

ព្រះពុទ្ធទាំងឡាយ ជាអ្នកសង្គ្រោះពួកសត្វលោក ព្រះពុទ្ធទាំងនោះ ទ្រង់សំដែងដោយប្រពៃ នូវហេតុនុ៎ះ នេះជាហេតុហៅថា ជាម្ចាស់នៃផែនដីរបស់ជនដ៏ច្រើន តថាគតជាស្ដេចមានទ្រព្យសម្បត្តិច្រើន ជាអ្នកអធិរាជ ជាអ្នកមានឫទ្ធិ មានយស ជាឥស្សរៈក្នុងជម្ពូទ្វីប ។ បុគ្គលណាស្ដាប់ហើយមិនជ្រះថ្លា ចាត់ជាកណ្ហាភិជាតិ ព្រោះហេតុនោះ បុគ្គលមានប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវភារៈជាធំ រលឹកនូវពុទ្ធ-សាសនា គប្បីធ្វើនូវសេចក្ដីគោរពនូវព្រះសទ្ធម្មនុ៎ះ ។

(៦០) គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅលំនៅ របស់អនាថបិណ្ឌិក-គហបតី លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ សម័យនោះឯង មនុស្សទាំងឡាយ មានសំឡេងហោកញ្ជ្រៀវក្នុងលំនៅនៃអនាថបិណ្ឌិកគហបតី ។ លំដាប់នោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតីអង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ត្រាស់ដូច្នេះថា

កឹ នុ តេ គហបតិ និវេសនេ មនុស្សា ឧច្ចាសទ្ទា មហាសទ្ទា កេវដ្ដា មញ្ញេ មច្ឆវិលោបេតីតិ ។ អយំ ភន្តេ សុជាតា ឃរសុណ្ហា អឌ្ឍា កុលា អានីតា សា នេវ សស្សុំ អាទិយតិ ន សសុរំ អាទិយតិ ន សាមិកំ អាទិយតិ ភគវន្តម្បិ ន សក្ការោតិ ន គរុការោតិ ន មានេតិ ន បូជេតីតិ ។ អថខោ ភគវា សុជាតំ ឃរសុណ្ហំ អាមន្តេសិ ឯហិ សុជាតេតិ ។ ឯវំ ភន្តេតិ ខោ សុជាតា ឃរសុណ្ហា ភគវតោ បដិស្សុណិត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ សុជាតំ ឃរសុណ្ហំ ភគវា ឯតទវោច សត្ត ខោ ឥមា សុជាតេ បុរិសស្ស ភរិយា ។ កតមា សត្ត ។ វធសមា[១] ចោរសមា[២] អយ្យសមា

---

១ ឱ. ម. វធកសមា ។ ២ ចោរីសមា ។

ម្នាលគហបតី មនុស្សទាំងឡាយ មានសំឡេងហ៊ោកញ្ជ្រៀវ ក្នុងលំនៅនៃអ្នក ទំនងដូចជាព្រានសន្ទូចចាប់ត្រីដូចម្តេចហ្ន៎ ។ បពិត្រព្រះអង្គដ៏ចំរើន នាងសុជាតានេះ ជាយសុណ្ហា (កូនប្រសាស្រីក្នុងផ្ទះ) ខ្ញុំព្រះអង្គបាននាំមក អំពីត្រកូលស្តុកស្តម្ភ នាងសុជាតានោះ មិនអើពើនឹងឪពុកក្មេក មិនអើពើនឹងម្តាយក្មេក មិនអើពើនឹងស្វាមី ទាំងមិនបានធ្វើសក្ការ មិនបានគោរព. មិនបានរាប់អាន មិនបានបូជាព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅនាងសុជាតាជាយសុណ្ហាថា ម្នាលនាងសុជាតា ចូរនាងមកនេះ ។ នាងសុជាតា ជាយសុណ្ហា បានទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះនាងសុជាតា ជាយសុណ្ហា អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលនាងសុជាតា ភរិយារបស់បុរសនេះ មាន ៧ ពួក ។ ភរិយា ៧ ពួក តើដូចម្តេចខ្លះ ។ គឺវធកសមាភរិយា (ភរិយាស្មើដោយអ្នកសម្លាប់) ១ ចោរសមាភរិយា (ភរិយាស្មើដោយចោរ) ១ អយ្យសមាភរិយា (ភរិយាស្មើដោយម្ចាស់) ១

មាតុសមា ភគិនិសមា សខីសមា ទាសីសមា ។ ឥមា ខោ សុជាតេ សត្ត បុរិសស្ស ភរិយា ។ តាសំ ត្វំ នុ កាតមាសិ ។ នាហំ ភន្តេ ឥមស្ស ភគវតោ សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាមិ ។ សាធុ មេ ភន្តេ ភគវា តថា ធម្មំ ទេសេតុ យថាហំ ឥមស្ស ភគវតោ សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានេយ្យន្តិ ។ តេនហិ សុជាតេ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ សុជាតា ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទវោច

បទុដ្ឋចិត្តា អហិតានុកម្បិនី
អញ្ញេសុ រត្តា អតិមញ្ញតេ បតឹ
ធនេន កីតស្ស វធាយ ឧស្សុកា

មាតុសមាភរិយា (ភរិយាស្មើដោយមាតា) ១ ភគិនិសមាភរិយា (ភរិយាស្មើដោយប្អូនស្រី) ១ សខីសមាភរិយា (ភរិយាស្មើដោយសំឡាញ់) ១ ទាសីសមាភរិយា (ភរិយាស្មើដោយខ្ញុំស្រី ១ ។ ម្នាលនាងសុជាតា នេះជាភរិយា ៧ ពួក របស់បុរស ។ បណ្ដាភរិយាទាំង ៧ ពួកនោះ នាងជាភរិយាដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនបានដឹងនូវអត្ថនៃភាសិតនេះ ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងដោយសេចក្ដីសង្ខេប ឲ្យពិស្ដារបានទេ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គគប្បីដឹងនូវអត្ថនៃភាសិតនេះ ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដោយសេចក្ដីសង្ខេប ឲ្យពិស្ដារបាន យ៉ាងណា សូមព្រះដ៏មានព្រះភាគសំដែងនូវធម៌ឲ្យប្រពៃដល់ខ្ញុំព្រះអង្គ យ៉ាងនោះ ។ ម្នាលនាងសុជាតា បើដូច្នោះ ចូរនាងចាំស្ដាប់ ចូរធ្វើទុកក្នុងចិត្ត ដោយប្រពៃ តថាគតនឹងសំដែង ។ នាងសុជាតា ជាយសុណ្ហា បានទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា

ភរិយាដែលស្វាមីលោះមកដោយទ្រព្យ ស្ត្រីមានចិត្តប្រទូស្ត (នឹង
ស្វាមី) មានសេចក្ដីមិនអនុគ្រោះនូវប្រយោជន៍ ជាអ្នកត្រេកត្រ
អាលក្នុងបុរសដទៃ មើលងាយប្ដី ខ្វល់ខ្វាយដើម្បីសម្លាប់ (ប្ដី)

យា ឯវរូបា បុរិសស្ស ភរិយា
វធកា ច ភរិយាតិ ច សា បវុច្ចតិ ។
យំ ឥត្ថិយោ វិន្ទតិ សាមិកោ ធនំ
សិប្បំ វណិជ្ជញ្ច កសិមធិដ្ឋហំ
អប្បម្បិ តស្មា អបហាតុមិច្ឆតិ
យា ឯវរូបា បុរិសស្ស ភរិយា
ចោរី ច ភរិយាតិ ច សា បវុច្ចតិ ។
អកម្មកាមា អលសា មហគ្ឃសា
ផរុសា ច ចណ្ឌី ច ទុរុត្តវាទិនី
ឧដ្ឋាយកានំ អភិភុយ្យ វត្តតិ
យា ឯវរូបា បុរិសស្ស ភរិយា
អយ្យា ច ភរិយាតិ ច សា បវុច្ចតិ ។
យា សព្វទា ហោតិ ហិតានុកម្បិនី
មាតាវ បុត្តំ អនុរក្ខតេ បតឹ
តតោ ធនំ សម្ភតមស្ស រក្ខតិ
យា ឯវរូបា បុរិសស្ស ភរិយា
មាតា ច ភរិយាតិ ច សា បវុច្ចតិ

ស្ត្រីណា ជាភរិយានៃបុរស មានសភាពដូច្នេះ ស្ត្រីនោះ ហៅថា វធកាភរិយា ១ ស្វាមីនៃស្ត្រីបាននូវទ្រព្យណា ហើយដាក់ទុក ដើម្បីធ្វើនូវសិល្បៈក្តី នូវជំនួញក្តី នូវកសិកម្មក្តី ស្ត្រីនោះ ប្រាថ្នាដើម្បីលួចកិបយកនូវទ្រព្យសូម្បីបន្តិចបន្តួចអំពីទ្រព្យនោះ ស្ត្រីណា ជាភរិយានៃបុរសមានសភាពដូច្នេះ ស្ត្រីនោះ ហៅថា ចោរីភរិយា ១ ស្ត្រីមិនមានសេចក្តីប្រាថ្នានឹងធ្វើនូវការងារ ជាអ្នកខ្ជិលច្រអូស ស៊ីច្រើន រឹងរូស កាច ពោលនូវពាក្យអាក្រក់ ប្រព្រឹត្តគ្របសង្កត់នូវស្វាមី ដែលមានព្យាយាម ប្រឹងប្រែង ស្ត្រីណា ជាភរិយានៃបុរសមានសភាពដូច្នេះ ស្ត្រីនោះ ហៅថា អយ្យាភរិយា ១ ស្ត្រីណា មានសេចក្តីអនុគ្រោះនូវប្រយោជន៍សព្វ ៗ កាល បេះរក្សាប្តី ដូចជាមាតារក្សាកូន ទាំងរក្សានូវទ្រព្យដែលស្វាមីនោះ បានមកអំពីទីនោះ ៗ ស្ត្រីណា ជាភរិយានៃបុរសមានសភាពដូច្នេះ ស្ត្រីនោះ ហៅថា មាតាភរិយា ១

យថាបិ ជេដ្ឋា ភគិនី កនិដ្ឋា

សគារវា ហោតិ សកម្ហិ សាមិកេ

ហិរីមនា ភត្តុវសានុវត្តិនី

យា ឯវរូបា បុរិសស្ស ភរិយា

ភគិនី ច ភរិយាតិ ច សា បវុច្ចតិ ។

យាចីធ ទិស្វាន បតិំ បមោទតិ

សខី សខារំ ចិរស្សមាគតំ

កោលេយ្យកា សីលវតី បតិព្វតា

យា ឯវរូបា បុរិសស្ស ភរិយា

សខី ច ភរិយាតិ ច សា បវុច្ចតិ ។

អក្កុទ្ធសន្តា វធទណ្ឌតជ្ជិតា

អទុដ្ឋចិត្តា បតិនោ តិតិក្ខតិ

អក្កោធនា ភត្តុវសានុវត្តិនី

យា ឯវរូបា បុរិសស្ស ភរិយា

ទាសី ច ភរិយាតិ ច សា បវុច្ចតិ ។

ស្ត្រីមានសេចក្តីគោរព ក្នុងស្វាមីរបស់ខ្លួន ដូចប្អូនស្រីគោរពបងប្រុស មានសេចក្តីអៀនខ្មាស ប្រព្រឹត្តទៅតាមអំណាចនៃភស្តា ស្ត្រីណា ជាភរិយានៃបុរស មានសភាពដូច្នេះ ស្ត្រីនោះ ហៅថា ភគិនីភរិយា ។ ស្ត្រីណា ក្នុងលោកនេះ បានឃើញនូវប្តីហើយ ក៏រីករាយ ដូចជាសំឡាញ់ បានឃើញសំឡាញ់ ដែលមកអស់កាលយូរ ស្ត្រីនោះ បរិបូណ៌ដោយត្រកូល មានសីលធម៌ ជាស្ត្រីមានវត្តប្រតិបត្តិ ក្នុងប្តី ស្ត្រីណា ជាភរិយានៃបុរស មានសភាពដូច្នេះ ស្ត្រីនោះ ហៅថា សខីភរិយា ។ ស្ត្រីដែលស្វាមីជេរ វាយ គំរាមដោយដំបង មិនមានចិត្តប្រទូស្តវិញ ចេះអត់សង្កត់ដល់ប្តី មិនក្រោធ ប្រព្រឹត្តទៅតាមអំណាចនៃភស្តា ស្ត្រីណាជាភរិយានៃបុរសមានសភាពដូច្នេះ ស្ត្រីនោះ ហៅថា ទាសីភរិយា ។

យា ចីធ ភរិយា វធកាតិ វុច្ចតិ
ចោរី ច អយ្យាតិ ច យា បវុច្ចតិ
ទុស្សីលរូបា ផរុសា អនាទរា
កាយស្ស ភេទា និរយំ វជន្តិ តា ។
យា ចីធ មាតា ភគិនី សខី[១] ច
ទាសី ច ភរិយាតិ ច យា បវុច្ចតិ
សីលេ ឋិតត្តា ចិររត្តសំវុតា
កាយស្ស ភេទា សុគតឹ វជន្តិ តាតិ ។

ឥមា ខោ សុជាតេ សត្ត បុរិសស្ស ភរិយា តាសំ ត្វំ កតមាតិ ។ អជ្ជតគ្គេ មំ ភន្តេ ភគវា ទាសីសមំ សាមិកស្ស ភរិយំ ធារេតូតិ ។

(៦១) សត្តិមេ ភិក្ខវេ ធម្មា សបត្តកន្តា សបត្តករណា កោធនំ អាគច្ឆន្តិ ឥត្ថឹ វា បុរិសំ វា ។ កតមេ សត្ត ។ ឥធ ភិក្ខវេ សបត្តោ សបត្តស្ស ឯវំ ឥច្ឆតិ អហោ វតាយំ ទុព្វណ្ណោ អស្សាតិ ។

---

១ ឱ. សខីតិ ច ។ អយំ បាឋោ យុត្តតរោ ។

ភរិយាណា ក្នុងលោកនេះ ដែលហៅថា វធកាក្តី ហៅថា ចោរីក្តី ហៅថាអយ្យាក្តី ភរិយាទាំងនោះ មានសភាពជាស្ត្រីទ្រុស្តសីល រឹងរូស មិនមានសេចក្តីគោរព លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកាន់នរក ។ ភរិយាណា ក្នុងលោកនេះ ដែលហៅថាមាតាក្តី ភគិនីក្តី សខីក្តី ទាសីក្តី ភរិយាទាំងនោះ ជាស្ត្រីសង្រួមអស់កាលជាយូរអង្វែង ព្រោះតាំងនៅក្នុងសីលធម៌ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកាន់សុគតិ ។

ម្នាលនាងសុជាតា នេះជាភរិយា របស់បុរស ៧ ពួក បណ្តាភរិយាទាំង ៧ ពួកនោះ នាងតើជាភរិយាដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ សំគាល់ទុកនូវខ្ញុំព្រះអង្គ ថាជាភរិយា ស្មើដោយទាសីរបស់ស្វាមី ចាប់ដើមអំពីថ្ងៃនេះតទៅ ។

[ ៦១ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះ ជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវ រមែងមកកាន់ស្ត្រីភាព ឬបុរសភាពដែលមានសេចក្តីក្រោធ ។ ធម៌ ៧ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សត្រូវក្នុងលោកនេះ រមែងប្រាថ្នានូវហេតុ យ៉ាងនេះដល់សត្រូវថា ឱហ្ន សូមឱ្យបុគ្គលនេះ មានវណ្ណៈអាក្រក់ ។

តំ កិស្ស ហេតុ ។ ន ភិក្ខវេ សបត្តោ សបត្តស្ស វណ្ណវតាយ នន្ទតិ កោធនោយំ ភិក្ខវេ បុរិសបុគ្គលោ កោធាភិភូតោ កោធបរេតោ កិញ្ចាបិ សោ ហោតិ សុន្ហាតោ សុវិលិត្តោ កប្បិតកេសមស្សុ ឱទាតវត្ថវសនោ អថខោ សោ ទុព្វណ្ណោ ច ហោតិ កោធាភិភូតោ ។ អយំ ភិក្ខវេ បឋមោ ធម្មោ សបត្តកន្តោ សបត្តករណោ កោធនំ អាគច្ឆតិ ឥត្ថឹ វា បុរិសំ វា ។ បុន ចបរំ ភិក្ខវេ សបត្តោ សបត្តស្ស ឯវំ ឥច្ឆតិ អហោ វតាយំ ទុក្ខំ សយេយ្យាតិ ។ តំ កិស្ស ហេតុ ។ ន ភិក្ខវេ សបត្តោ សបត្តស្ស សុខសេយ្យាយ នន្ទតិ កោធនោយំ ភិក្ខវេ បុរិសបុគ្គលោ កោធាភិភូតោ កោធបរេតោ

រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ សត្រូវ រមែងមិនត្រេកអរដល់សត្រូវ ព្រោះវណ្ណៈទេ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលនេះ (កាលបើ) មានសេចក្តីក្រោធ មានសេចក្តីក្រោធគ្របសង្កត់ មានសេចក្តីក្រោធរួបរឹតហើយ បុរសបុគ្គលនោះ ទុកជាលាបស្រឡាបល្អ បានកោរសក់និងពុកមាត់ ហើយស្លៀកសំពត់មានពណ៌ស ក៏មែនពិតហើយ ប៉ុន្តែបុរសបុគ្គលនោះ ឈ្មោះថា មានវណ្ណៈអាក្រក់ ជាអ្នកមានសេចក្តីក្រោធគ្របសង្កត់ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាធម៌ទី ១ ជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវ រមែងមកកាន់ស្ត្រីភាព ឬបុរសភាពដែលមានសេចក្តីក្រោធ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សត្រូវ រមែងប្រាថ្នានូវហេតុយ៉ាងនេះ ដល់សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនេះ ដេកជាទុក្ខ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ សត្រូវ រមែងមិនត្រេកអរ ក្នុងការដេក ជាសុខរបស់សត្រូវទេ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលនេះ មានសេចក្តីក្រោធ មានសេចក្តីក្រោធគ្របសង្កត់ មានសេចក្តីក្រោធរួបរឹតហើយ

កិញ្ចាបិ សោ បល្លង្កេ សេតិ គោនកត្ថតេ បដិ-កត្ថតេ បដលិកត្ថតេ កាទលិមិគបវរបច្ចត្ថរណេ សឧត្តរច្ឆទេ ឧភតោលោហិតកូបធានេ អថខោ សោ ទុក្ខញ្ញេវ សេតិ កោធាភិភូតោ ។ អយំ ភិក្ខវេ ទុតិយោ ធម្មោ សបត្តកន្តោ សបត្ត-ករណោ កោធនំ អាគច្ឆតិ ឥត្ថឹ វា បុរិសំ វា ។ បុន ចបរំ ភិក្ខវេ សបត្តោ សបត្តស្ស ឯវំ ឥច្ឆតិ អហោ វតាយំ ន បចុរត្ថោ អស្សាតិ ។ តំ កិស្ស ហេតុ ។ ន ភិក្ខវេ សបត្តោ សបត្តស្ស បចុរត្ថតាយ នន្ទតិ កោធនោយំ ភិក្ខវេ បុរិសបុគ្គលោ កោធាភិភូតោ កោធបរេតោ អនត្ថំបិ គហេត្វា អត្ថោ មេ គហិតោតិ មញ្ញតិ អត្ថំបិ គហេត្វា អនត្ថោ មេ គហិតោតិ មញ្ញតិ ។

បុរសបុគ្គលនោះ ទុកជាដេកលើបល្ល័ង្ក លើកម្រាលព្រំ ដែលមានរោមវែងជាង ៤ ធ្នាប់ លើកម្រាលមានពណ៌ស ដែលធ្វើដោយរោមសត្វ លើកម្រាលដែលគេធ្វើដោយរោមសត្វជាផ្កាបង្កោម លើកម្រាលដ៏ឧត្តម ដែលគេធ្វើដោយស្បែកឈ្លូស មានខ្នើយមានពណ៌ក្រហមទាំងពីរខាង ព្រមទាំងពិតានដែលមានពណ៌ក្រហម ក៏មែនពិតហើយ ប៉ុន្តែ បុរសបុគ្គលនោះ ត្រូវសេចក្តីក្រោធ គ្របសង្កត់ហើយ ក៏ឈ្មោះថា ដេកជាទុក្ខ ដោយពិត ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវ រមែងមកកាន់ស្ត្រីភាព ឬ បុរសភាព ដែលមានសេចក្តីក្រោធ ។ ម្នាលភិក្ខុទាំងឡាយមួយទៀត សត្រូវ រមែងប្រាថ្នាយ៉ាងនេះដល់សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនេះ កុំមានប្រយោជន៍ច្រើនឡើយ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ សត្រូវ រមែងមិនត្រេកអរ ក្នុងប្រយោជន៍ដ៏ច្រើនរបស់សត្រូវទេ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលនេះ ជាអ្នកមានសេចក្តីក្រោធ មានសេចក្តីក្រោធគ្របសង្កត់ មានសេចក្តីក្រោធរួបរឹតហើយ គាត់យកនូវហេតុមិនមែនជាប្រយោជន៍ សំគាល់ថាប្រយោជន៍ អាត្មាអញបានកាន់យកហើយផង កាន់យកនូវហេតុជាប្រយោជន៍ សំគាល់ថាហេតុមិនមែនជាប្រយោជន៍ អាត្មាអញបានកាន់យកហើយផង ។

តស្សិមេ ធម្មា អញ្ញមញ្ញបច្ចនីកា តហិតា ទីឃរត្តំ អហិតាយ ទុក្ខាយ សំវត្តន្តិ កោធាភិភូតស្ស ។ អយំ ភិក្ខវេ តតិយោ ធម្មោ សបត្តកន្តោ សបត្តការណោ កោធនំ អាគច្ឆតិ ឥត្ថឹ វា បុរិសំ វា ។ បុន ចបរំ ភិក្ខវេ សបត្តោ សបត្តស្ស ឯវំ ឥច្ឆតិ អហោ វតាយំ ន ភោគវា អស្សាតិ ។ តំ កិស្ស ហេតុ ។ ន ភិក្ខវេ សបត្តោ សបត្តស្ស ភោគវតាយ នន្ទតិ កោធនស្សា ភិក្ខវេ បុរិសបុគ្គលស្ស កោធាភិភូតស្ស កោធបរេតស្ស យេបិស្ស តេ ហោន្តិ ភោគា ឧដ្ឋានវីរិយាធិគតា ពាហាពលបរិចិតា សេទាវក្ខិត្តា ធម្មិកា ធម្មលទ្ធា តេបិ រាជានោ រាជកោសំ បវេសេន្តិ កោធាភិភូតស្ស ។ អយំ ភិក្ខវេ ចតុត្ថោ ធម្មោ សបត្តកន្តោ សបត្តការណោ កោធនំ អាគច្ឆតិ ឥត្ថឹ វា បុរិសំ វា ។

នេះជាធម៌ ជាសត្រូវដល់គ្នានឹងគ្នា ដែលសត្រូវនោះ មានសេចក្តីក្រោធគ្របសង្កត់ កាន់យកហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលជាយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ដែលជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវរមែងមកកាន់ស្ត្រីភាព ឬ បុរសភាពដែលមានសេចក្តីក្រោធ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សត្រូវរមែងប្រាថ្នាយ៉ាងនេះដល់សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនេះ កុំមានភោគៈឡើយ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ សត្រូវ រមែងមិនត្រេកអរដល់សត្រូវ ព្រោះមានភោគៈទេ ម្នាលភិក្ខុទាំងឡាយ កាលបើបុរសបុគ្គល មានសេចក្តីក្រោធ មានសេចក្តីក្រោធគ្របសង្កត់ មានសេចក្តីក្រោធរួបរឹតហើយ ភោគៈទាំងឡាយណា ដែលបុគ្គលនោះ បានមកដោយសេចក្តីប្រឹងប្រែងព្យាយាម សន្សំដោយកំឡាំងដៃ បែកញើសហូរញើស ប្រកបដោយធម៌ បានមកដោយធម៌ ព្រះរាជាទាំងឡាយ រមែងញុំាងភោគៈទាំងនោះ របស់បុគ្គលដែលមានសេចក្តីក្រោធគ្របសង្កត់ ឲ្យចូលទៅកាន់ព្រះឃ្លាំង ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ដែលជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវ រមែងមកកាន់ស្ត្រីភាព ឬ បុរសភាព ដែលមានសេចក្តីក្រោធ ។

បុន ចបរំ ភិក្ខវេ សបត្តោ សបត្តស្ស ឯវំ ឥច្ឆតិ អហោ វតាយំ ន យសវា អស្សាតិ ។ តំ កិស្ស ហេតុ ន ភិក្ខវេ សបត្តោ សបត្តស្ស យសវតាយ នន្ទតិ កោធនោយំ ភិក្ខវេ បុរិសបុគ្គលោ កោធាភិភូតោ កោធបរេតោ យោបិស្ស សោ ហោតិ យសោ អប្បមាទាធិគតោ តម្ហាបិ ធំសតិ កោធាភិភូតោ ។ អយំ ភិក្ខវេ បញ្ចមោ ធម្មោ សបត្តកន្តោ សបត្តការណោ កោធនំ អាគច្ឆតិ ឥត្ថឹ វា បុរិសំ វា ។

បុន ចបរំ ភិក្ខវេ សបត្តោ សបត្តស្ស ឯវំ ឥច្ឆតិ អហោ វតាយំ ន មិត្តវា អស្សាតិ ។ តំ កិស្ស ហេតុ ។ ន ភិក្ខវេ សបត្តោ សបត្តស្ស មិត្តវតាយ នន្ទតិ កោធនោយំ ភិក្ខវេ បុរិសបុគ្គលោ កោធាភិភូតោ កោធបរេតោ យេបិស្ស តេ ហោន្តិ មិត្តាមច្ចា ញាតិសាលោហិតា តេបិ អារកា តំ បរិវជ្ជន្តិ កោធាភិភូតំ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត សត្រូវ រមែងប្រាថ្នាយ៉ាងនេះ ដល់សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនេះ កុំមានយសឡើយ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ សត្រូវ រមែងមិនត្រេកអរដល់សត្រូវ ព្រោះមានយសទេ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលនេះ មានសេចក្តីក្រោធ មានសេចក្តីក្រោធគ្របសង្កត់ មានសេចក្តីក្រោធរួបរឹតហើយ យសណា របស់បុគ្គលនោះ ដែលបានមកដោយសេចក្តីមិនប្រមាទ (កាលបើ) មានសេចក្តីក្រោធគ្របសង្កត់ហើយ ក៏រមែងភ្លាត់ចេញចាកយសនោះមិនខានឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ដែលជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវ រមែងមកកាន់ស្ត្រីភាព ឬ បុរសភាពដែលមានសេក្តីក្រោធ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សត្រូវ រមែងប្រាថ្នាយ៉ាងនេះ ដល់សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនេះ កុំមានមិត្តឡើយ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ សត្រូវ រមែងមិនត្រេកអរដល់សត្រូវ ព្រោះមានមិត្តទេ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលនេះ មានសេចក្តីក្រោធ មានសេចក្តីក្រោធគ្របសង្កត់ មានសេចក្តីក្រោធរួបរឹតហើយ ពួកមិត្ត អាមាត្យ ញាតិសាលោហិតណា របស់បុរសបុគ្គលនោះ ពួកជនទាំងនោះ រមែងវៀរបង់នូវបុរសបុគ្គល ដែលមានសេចក្តីក្រោធគ្របសង្កត់នោះ អំពីចម្ងាយ ។

អយំ ភិក្ខវេ ឆដ្ឋោ ធម្មោ សបត្តកន្តោ សបត្តករណោ កោធនំ អាគច្ឆតិ ឥត្ថឹ វា បុរិសំ វា ។ បុន ចបរំ ភិក្ខវេ សបត្តោ សបត្តស្ស ឯវំ ឥច្ឆតិ អហោ វតាយំ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យាតិ ។ តំ កិស្ស ហេតុ ។ ន ភិក្ខវេ សបត្តោ សបត្តស្ស សុគតិគមនេន នន្ទតិ ។ កោធនោយំ ភិក្ខវេ បុរិសបុគ្គលោ កោធាភិភូតោ កោធបរេតោ កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ ។ សោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ កោធាភិភូតោ ។ អយំ ភិក្ខវេ សត្តមោ ធម្មោ សបត្តកន្តោ សបត្តករណោ កោធនំ អាគច្ឆតិ ឥត្ថឹ វា បុរិសំ វា ។ ឥមេ ខោ ភិក្ខវេ សត្ត ធម្មា សបត្តកន្តា

ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៦ ដែលជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវ រមែងមកកាន់ស្ត្រីភាព ឬ បុរិសភាពដែលមានសេចក្តីក្រោធ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សត្រូវ រមែងប្រាថ្នាយ៉ាងនេះដល់សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ គប្បីចូលទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ សត្រូវ រមែងមិនត្រេកអរដល់សត្រូវ ដោយដំណើរទៅកាន់សុគតិទេ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែបុរសបុគ្គលនេះ បានសេចក្តីក្រោធ មានសេចក្តីក្រោធគ្របសង្កត់ មានសេចក្តីក្រោធរួបរឹតហើយ ក៏ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិត ដោយវាចា ប្រព្រឹត្តទុច្ចរិត ដោយចិត្ត ។ លុះបុគ្គលដែលមានសេចក្តីក្រោធគ្របសង្កត់នោះ ប្រព្រឹត្តទុច្ចរិត ដោយកាយ ប្រព្រឹត្តទុច្ចរិត ដោយវាចា ប្រព្រឹត្តទុច្ចរិត ដោយចិត្តហើយ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៧ ដែលជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវ រមែងមកកាន់ស្ត្រីភាព ឬ បុរិសភាពដែលមានសេចក្តីក្រោធ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ ប្រការនេះ ជាទីត្រេកអរនៃសត្រូវ

សបត្តករណា កោធនំ អាគច្ឆន្តិ ឥត្ថឹ វា បុរិសំ វាតិ ។

កោធនោ ទុព្វណ្ណោ ហោតិ អថោ ទុក្ខម្បិ សេតិ សោ
អថោ អត្ថំ គហេត្វាន អនត្ថំ បដិបជ្ជតិ[១]
តតោ កាយេន វាចាយ វធំ កត្វាន កោធនោ
កោធាភិភូតោ បុរិសោ ធនជានឹ និគច្ឆតិ
កោធសម្មទសម្មត្តោ អាយសក្ខំ[២] និគច្ឆតិ
ញាតិមិត្តា សុហជ្ជា ច បរិវជ្ជន្តិ កោធនំ ។
អនត្ថជននោ កោធោ កោធោ ចិត្តប្បកោបនោ
ភយមន្តរតោ ជាតំ តំ ជនោ នាវពុជ្ឈតិ ។
កុទ្ធោ អត្ថំ ន ជានាតិ កុទ្ធោ ធម្មំ ន បស្សតិ
អន្ធតមំ តទា ហោតិ យំ កោធោ សហតេ នរំ ។

---

១ ឱ. ម. អធិបជ្ជតិ ។ ២ ឱ. ម. អាយសក្យំ ។

ជាហេតុនៃសត្រូវ រមែងមកកាន់ស្ត្រីភាព ឬ បុរសភាព ដែលមាន សេចក្តីក្រោធជាប្រក្រតី ។

បុគ្គលមានសេចក្តីក្រោធ រមែងមានវណ្ណៈអាក្រក់ ទាំង បុគ្គលនោះ រមែងដេកជាទុក្ខ ទោះបីកាន់យកនូវប្រយោជន៍ ហើយ រមែងប្រតិបត្តិ មិនជាប្រយោជន៍វិញ បុរសមាន សេចក្តីក្រោធ ត្រូវសេចក្តីក្រោធ គ្របសង្កត់ ធ្វើនូវការ សម្លាប់ដោយកាយ ដោយវាចា ក្នុងកាលនោះហើយ រមែង ដល់នូវសេចក្តីសាបសូន្យ បាកទ្រព្យមិនខាន បុរសដែល ស្រវឹង ព្រោះស្រវឹងដោយសេចក្តីក្រោធហើយ រមែងដល់នូវ សេចក្តីអាប់យស ពួកញាតិ មិត្តនឹងអ្នកមានចិត្តល្អ សំឡាញ់ រមែងចៀសវាងនូវបុគ្គលអ្នកមានសេចក្តីក្រោធ ។ សេចក្តី ក្រោធ ជាហេតុឲ្យកើតសេចក្តីវិនាស សេចក្តីក្រោធ ជាហេតុញុំាងចិត្ត ឲ្យកម្រើក ភ័យកើតឡើង ក្នុងសន្តាន ជនមិនបានដឹងនូវភ័យនោះឡើយ ។ បុគ្គលអ្នកក្រោធ មិនដឹងនូវសេចក្តីចំរើន បុគ្គលអ្នកក្រោធ មិនឃើញនូវធម៌ សេចក្តីក្រោធ គ្របសង្កត់នូវជនណា សេចក្តីងងឹត រមែងមានប្រាកដ ដល់ជននោះ ក្នុងកាលនោះដែរ ។

### បណ្ណាសកាសង្គហិតោ អព្យាកតវគ្គោ

យំ កុទ្ធោ ឧបរោធេតិ សុករំ វិយ ទុក្ករំ
បច្ឆា សោ វិគតេ កោធេ អគ្គិទឌ្ឍោវ តប្បតិ ។
ទុម្មង្កុយំ បឋមំ ទស្សេតិ(១) ធូមគ្គីវ បាវកោ
យតោ បតាយតី កោធោ យេន កុជ្ឈន្តិ មាណវា ។
នាស្ស ហិរី ន ឱត្តប្បំ ន វា សោ ហោតិ គារវោ
កោធេន អភិភូតស្ស ន ទីបំ ហោតិ កិញ្ចនំ ។
តបនីយានិ កម្មានិ យានិ ធម្មេហិ អារកា
តានិ អារោចយិស្សាមិ តំ សុណាថ យថា កថំ ។
កុទ្ធោ ហិ បិតរំ ហន្តិ ហន្តិ កុទ្ធោ សមាតរំ
កុទ្ធោ ហិ ព្រាហ្មណំ ហន្តិ ហន្តិ កុទ្ធោ បុថុជ្ជនំ ។
យាយ មាតុ ភតោ បោសោ ឥមំ លោកំ អវេក្ខតិ
តម្បិ បាណទទឹ សន្តឹ ហន្តិ កុទ្ធោ បុថុជ្ជនោ ។

---

១ ទុម្មង្កុយំ បទស្សេតីតិបិ អយំ យុត្តតរោ ។

បុគ្គលអ្នកក្រោធ បៀតបៀននូវបុគ្គលណា កាលធ្វើនូវអំពើអាក្រក់ ហាក់ដូចជាអំពើល្អ បុគ្គលអ្នកក្រោធនោះ កាលបើសេចក្តីក្រោធ ប្រាសចេញហើយ រមែងក្តៅក្រហាយជាខាងក្រោយ ដូចជាភ្លើងឆេះ ។ សេចក្តីក្រោធ ផុសឡើងក្នុងវេលាណា មាណពតាំងឡាយ ឯងក្នុងវេលាណា រមែងសំដែងនូវមុខក្រញូវជាដម្បូង ក្នុងវេលានោះ ដូចភ្លើងកាលបង្ហុយនូវផ្សែង ។ បុគ្គលនោះ មិនមានហិរិ មិនមានឱត្តប្បៈ មិនមានសេចក្តីគោរពឡើយ បុគ្គលត្រូវសេចក្តីក្រោធ គ្របសង្កត់ហើយ រមែងរកទីពឹងបន្តិចបន្តួចគ្មាន ។ កម្មទាំងឡាយណា ជាទីតាំងនៃសេចក្តីក្តៅក្រហាយ ក៏រមែងឆ្ងាយអំពីធម៌ តថាគត នឹងសំដែងប្រាប់នូវកម្មទាំងនោះ ចូរអ្នកទាំងឡាយចាំស្តាប់នូវធម៌នោះ តាមសេចក្តីពិត ។ បុគ្គលក្រោធ សម្លាប់នូវបិតាក៏មាន បុគ្គលក្រោធ សម្លាប់នូវមាតារបស់ខ្លួនក៏មាន បុគ្គលក្រោធ សម្លាប់នូវខីណាសវព្រាហ្មណ៍ក៏មាន បុគ្គលក្រោធ សម្លាប់នូវបុថុជ្ជនក៏មាន ។ បុរសដែលមាតាណាចិញ្ចឹមហើយ បានឃើញច្បាស់នូវលោកនេះ បុថុជ្ជនដែលក្រោធ រមែងសម្លាប់នូវមាតា ដែលឲ្យនូវជីវិតនោះក៏មាន ។

អត្តូបមា ហិ តេ សត្តា  អត្តា ហិ បរមំ បិយោ
ហន្តិ កុទ្ធោ បុថុត្តានំ  នានារូបេសុ មុច្ឆិតោ ។
អសិនា ហន្តិ អត្តានំ  វិសំ ខាទន្តិ មុច្ឆិតា
រជ្ជុយា ពទ្ធា មិយ្យន្តិ  បព្វតាមបិ កន្ទរេ ។
ភូនហច្ចានិ កម្មានិ  អត្តមារណិយានិ ច
ករោន្តា នាវពុជ្ឈន្តិ  កោធជាតោ បរាភវោ ។
ឥតាយំ កោធរូបេន  មច្ចុបាសោ គុហាសយោ
ំ ទមេន សមុច្ឆិន្ទេ  បញ្ញាវីរិយេន ទិដ្ឋិយា ។
ឯកមេតំ អកុសលំ  សមុច្ឆិន្ទេថ បណ្ឌិតោ ។
តថេវ ធម្មេ សិក្ខេថ  មា នោ ទុម្មង្កុយំ អហុ ។

សត្វទាំងនោះ មានខ្លួនជាឧបមា ព្រោះខ្លួនជាទីស្រឡាញ់ដ៏ឧត្តម បុគ្គលក្រោធ ដែលជាប់ទៅក្នុងរូបផ្សេង ៗ រមែងសម្លាប់នូវខ្លួន ដោយហេតុផ្សេងៗ ។ ពួកជនដែលជាប់ទៅ (ក្នុងរូបផ្សេងៗ) ហើយ រមែងសម្លាប់ខ្លួន ដោយដាវ ទំពាស៊ីនូវថ្នាំពិស ចងកសម្លាប់ ទម្លាក់ខ្លួនក្នុងជ្រោះភ្នំ ។ ជនទាំងឡាយ កាលធ្វើនូវអំពើ ជាហេតុនាំឲ្យសាបសូន្យបាតសេចក្តីចំរើនផង ជាហេតុនៃសម្លាប់ខ្លួនផង រមែងមិនបានដឹងខ្លួនទេ បុគ្គលដែលមានសេចក្តីក្រោធ កើតឡើងហើយ រមែងវិនាសមិនខាន ។ អន្ទាក់គឺសេចក្តីស្លាប់នេះ ជាគុហាជាទីអាស្រ័យនៅ ដោយសភាពនៃសេចក្តីក្រោធ ដោយប្រការដូច្នេះ បុគ្គលគួរផ្តាច់ផ្តិលនូវសេចក្តីក្រោធនោះចេញ ដោយទមបញ្ញា ព្យាយាម និងមគ្គសម្មាទិដ្ឋិ បណ្ឌិតគប្បីផ្តាច់ផ្តិលនូវអកុសលមួយៗ ។ បុគ្គលគប្បីសិក្សានូវធម៌ទាំងឡាយដូច្នោះថា យើងទាំងឡាយ កុំមានមុខក្រញូវឡើយ ។

វីតកោធា អនាយាសា វីតលោភា អនិស្សុកា
ទន្តា កោធំ បហាត្វាន បរិនិព្វិស្សថានាសវាតិ(១) ។

អព្យាកតវគ្គោ បឋមោ ។

## តស្សុទ្ទានំ

អព្យាកតោ បុរិសគតិ តិស្សសីហរក្ខិតបញ្ចមំ
ទត្រាវតំ កិម្ពិលោ សត្តភរិយាយ កោធនា(២) ។

---

១ ឱ. ម. បរិនិព្វិស្សុ អនាសវាតិ អយមេវ យុត្តតរោ ។ ២ ឱ. កិម្ពិលំ សត្តបចលា សត្តភរិយា កោធនាតិ ។ ម. កិម្ពិលំ សត្តបាវលា មេត្តាភរិយា កោធេកាទសាតិ ។

កាលបើអ្នក មិនមាសេចក្តីក្រោធ មិនមានសេចក្តីប៉ុនប៉ង មិនមានសេចក្តីលោភ មិនមានសេចក្តីខ្វល់ខ្វាយ មានខ្លួនទូន្មានហើយ សម្លាប់បង់នូវសេចក្តីក្រោធហើយ នឹងបានជាអនាសវបុគ្គល បរិនិព្វានពុំខាន ។

ចប់ អព្យាកតវគ្គទី ១ ។

## ឧទ្ទាននៃអព្យាកតវគ្គនោះគឺ

និយាយអំពីវត្ថុ ដែលគេមិនបានពោល ១ អំពីញាណគតិរបស់បុរស ១ អំពីភិក្ខុឈ្មោះតិស្សៈ ១ អំពីសេនាបតីឈ្មោះសីហៈ ១ អំពីហេតុដែលព្រះដ៏មានព្រះភាគ មិនបាច់រក្សា ជាគំរប់ប្រាំ អំពីព្រះកិមិលៈ ១ អំពីភរិយា ៧ ពួក ១ អំពីសេចក្តីក្រោធ ១ ។

# មហាវគ្គោ

[៦២] ហិរោត្តប្បេ ភិក្ខវេ អសតិ ហិរោត្តប្បវិបន្នស្ស ហតុបនិសោ ហោតិ ឥន្ទ្រិយសំវរោ ឥន្ទ្រិយសំវរេ អសតិ ឥន្ទ្រិយសំវរវិបន្នស្ស ហតុបនិសំ ហោតិ សីលំ សីលេ អសតិ សីលវិបន្នស្ស ហតុបនិសោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ អសតិ សម្មាសមាធិវិបន្នស្ស ហតុបនិសំ ហោតិ យថាភូតញាណទស្សនំ យថាភូតញាណទស្សនេ អសតិ យថាភូតញាណទស្សនវិបន្នស្ស ហតុបនិសោ ហោតិ និព្វិទាវិរាគោ និព្វិទាវិរាគេ អសតិ និព្វិទាវិរាគវិបន្នស្ស ហតុបនិសំ ហោតិ វិមុត្តិញាណទស្សនំ ។ សេយ្យថាបិ ភិក្ខវេ រុក្ខោ សាខាបលាសវិបន្នោ តស្ស បបដិកាបិ ន បារិបូរឹ គច្ឆតិ តចោបិ ផេគ្គុបិ សារោបិ ន បារិបូរឹ គច្ឆតិ ឯវមេវ ខោ ភិក្ខវេ ហិរោត្តប្បេ អសតិ ហិរោត្តប្បវិបន្នស្ស ហតុបនិសោ ហោតិ ឥន្ទ្រិយសំវរោ ។ បេ ។ វិមុត្តិញាណទស្សនំ ។

# មហាវគ្គ

[ ៦៦ ] ម្នាលភិក្ខុទាំងឡាយ កាលបើហិរោត្តប្បៈ មិនមាន ឥន្ទ្រិយសំវរៈនៃបុគ្គលអ្នកវិបត្តិ ចាកហិរោត្តប្បៈ ឈ្មោះថា មានហេតុសាបសូន្យ កាលបើឥន្ទ្រិយសំវរៈមិនមាន សីលនៃបុគ្គលអ្នកវិបត្តិ ចាកឥន្ទ្រិយសំវរៈ ឈ្មោះថា មានហេតុសាបសូន្យ កាលបើសីលមិនមាន សម្មាសមាធិនៃបុគ្គលអ្នកវិបត្តិ ចាកសីល ឈ្មោះថា មានហេតុសាបសូន្យ កាលបើសម្មាសមាធិមិនមាន យថាភូតញាណទស្សនៈនៃបុគ្គលអ្នកវិបត្តិ ចាកសម្មាសមាធិ ឈ្មោះថា មានហេតុសាបសូន្យ កាលបើយថាភូត-ញាណទស្សនៈមិនមាន និព្វិទាវិរាគៈនៃបុគ្គលអ្នកវិបត្តិ ចាកយថាភូត-ញាណទស្សនៈ ឈ្មោះថា មានហេតុសាបសូន្យ កាលបើនិព្វិទា-វិរាគៈមិនមាន វិមុត្តិញាណទស្សនៈ នៃបុគ្គលអ្នកវិបត្តិ ចាកនិព្វិទា-វិរាគៈ ឈ្មោះថា មានហេតុសាបសូន្យ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាដើមឈើដែលវិបត្តិ ចាកមែកនិងស្លឹក ក្រមរនៃឈើនោះក្តី ក៏មិនសូវបរិបូណ៌ សំបកក្តី ស្រាយក្តី ខ្លឹមក្តី ក៏មិនសូវបរិបូណ៌ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើហិរោត្តប្បៈ មិនមាន ឥន្ទ្រិយសំវរៈនៃបុគ្គលអ្នកវិបត្តិ ចាកហិរោត្តប្បៈ ឈ្មោះថា មានហេតុសាបសូន្យ ។ បេ ។ វិមុត្តិញាណទស្សនៈ ក៏យ៉ាងនោះដែរ ។

ហិរោត្តប្បេ ភិក្ខវេ សតិ ហិរោត្តប្បសម្បន្នស្ស ឧបនិ-សសម្បន្នោ ហោតិ ឥន្ទ្រិយសំវរោ ឥន្ទ្រិយសំវរេ សតិ ឥន្ទ្រិយសំវរសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ សីលំ សីលេ សតិ សីលសម្បន្នស្ស ឧបនិស-សម្បន្នោ ហោតិ សម្មាសមាធិ សម្មាសមាធិស្មឹ សតិ សម្មាសមាធិសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ យថាភូតញាណទស្សនំ យថាភូតញាណ-ទស្សនេ សតិ យថាភូតញាណទស្សនសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ និព្វិទាវិរាគោ និព្វិទាវិរាគេ សតិ និព្វិទាវិរាគសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ វិមុត្តិញាណទស្សនំ ។ សេយ្យថាបិ ភិក្ខវេ រុក្ខោ សាខាបលាសសម្បន្នោ តស្ស បបដិកាបិ បារិបូរឹ គច្ឆតិ តចោបិ ផេគ្គុបិ សារោបិ បារិបូរឹ គច្ឆតិ ឯវមេវ ខោ ភិក្ខវេ ហិរោត្តប្បេ សតិ ហិរោត្តប្ប-សម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ ឥន្ទ្រិយសំវរោ ។ បេ ។ វិមុត្តិញាណទស្សនន្តិ ។

ម្នាលភិក្ខុទាំងឡាយ កាលបើហិរិនិងឱត្តប្បៈមាន ឥន្ទ្រិយសំវរៈនៃបុគ្គលអ្នកបរិបូណ៌ ដោយហិរិនិងឱត្តប្បៈឈ្មោះថា បរិបូណ៌ដោយហេតុ កាលបើឥន្ទ្រិយសំវរៈមាន សីលនៃបុគ្គលអ្នកបរិបូណ៌ ដោយឥន្ទ្រិយសំវរៈ ឈ្មោះថា បរិបូណ៌ដោយហេតុ កាលបើសីលមាន សម្មាសមាធិនៃបុគ្គល អ្នកបរិបូណ៌ដោយសីល ឈ្មោះថា បរិបូណ៌ដោយហេតុ កាលបើសម្មាសមាធិមាន យថាភូតញ្ញាណទស្សនៈ នៃបុគ្គលអ្នកបរិបូណ៌ដោយសម្មាសមាធិ ឈ្មោះថា បរិបូណ៌ដោយហេតុ កាលបើយថា-ភូតញ្ញាណទស្សនៈមាន និព្វិទាវិរាគៈនៃបុគ្គលអ្នកបរិបូណ៌ ដោយយថា-ភូតញ្ញាណទស្សនៈ ឈ្មោះថា បរិបូណ៌ ដោយហេតុ កាលបើនិព្វិទា-វិរាគៈមាន វិមុត្តិញ្ញាណទស្សនៈនៃបុគ្គលអ្នកបរិបូណ៌ ដោយនិព្វិទា-វិរាគៈ ឈ្មោះថា បរិបូណ៌ ដោយហេតុ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាដើមឈើ ដែលបរិបូណ៌ដោយមែកនិងស្លឹក ក្រមរនៃឈើនោះក្តី ក៏បរិបូណ៌ សំបកក្តី ស្រាយក្តី ខ្លឹមក្តី ក៏បរិបូណ៌ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើហិរិនិងឱត្តប្បៈមាន ឥន្ទ្រិយសំវរៈនៃបុគ្គល អ្នកបរិបូណ៌ ដោយហិរិនិងឱត្តប្បៈ ឈ្មោះថាបរិបូណ៌ ដោយហេតុ ។បេ។ វិមុត្តិញ្ញាណទស្សន ក៏យ៉ាងនោះដែរ ។

(៦៣) ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ អម្ពបាលិវនេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច អនិច្ចា ភិក្ខវេ សង្ខារា អទ្ធុវា ភិក្ខវេ សង្ខារា អនស្សាសិកា ភិក្ខវេ សង្ខារា យាវញ្ចិទំ ភិក្ខវេ អលមេវ សព្វសង្ខារេសុ និព្វិន្ទិតុំ អលំ វិរជ្ជិតុំ អលំ វិមុច្ចិតុំ សិនេរុ ភិក្ខវេ បព្វតរាជា ចតុរាសីតិយោជនសហស្សានិ អាយាមេន ចតុរាសីតិយោជនសហស្សានិ វិត្ថារេន ចតុរាសីតិយោជនសហស្សានិ មហាសមុទ្ទេ អជ្ឈោគាឡ្ហោ ចតុរាសីតិយោជនសហស្សានិ មហាសមុទ្ទា អច្ចុគ្គតោ ។ ហោតិ ខោ សោ ភិក្ខវេ សមយោ យំ ពហូនិ វស្សានិ ពហូនិ វស្សសតានិ ពហូនិ វស្សសហស្សានិ ពហូនិ វស្សសតសហស្សានិ ទេវោ ន វស្សតិ

(៦៣) សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងអម្ពបាលិវ័ន ទៀបក្រុងវេសាលី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ទទួលស្ដាប់ព្រះពុទ្ធដីកា នៃព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ សង្ខារ[១]ទាំងឡាយ មិនទៀងទាត់ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនខ្ជាប់ខ្ជួន ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនឋិតថេរ ម្នាលភិក្ខុទាំងឡាយ ហេតុនោះ បុគ្គលគួរនឿយណាយ គួរធុញទ្រាន់ គួររួចស្រឡះ ចាកសង្ខារទាំងពួង ម្នាលភិក្ខុទាំងឡាយ ដូចយ៉ាង ស្ដេចភ្នំឈ្មោះសិនេរុ ទទឹង ៨ ម៉ឺន ៤ ពាន់យោជន៍ បណ្ដោយ ៨ ម៉ឺន ៤ ពាន់យោជន៍ លិចចុះក្នុងមហាសមុទ្រ ៨ ម៉ឺន ៤ ពាន់យោជន៍ ផុសឡើងអំពីមហាសមុទ្រ ៨ ម៉ឺន ៤ ពាន់យោជន៍ ។ ម្នាលភិក្ខុទាំងឡាយ មានសម័យដែលភ្លៀង មិនបង្អុរចុះ អស់ច្រើនឆ្នាំ ច្រើនរយឆ្នាំ ច្រើនពាន់ឆ្នាំ ច្រើនសែនឆ្នាំ

---

១ សង្ខារដែលមានចិត្តគ្រប់គ្រង និងសង្ខារដែលមិនមានចិត្តគ្រប់គ្រង ។ អដ្ឋកថា ។

ទេវេ ខោ បន ភិក្ខវេ អវស្សន្តេ យេកេចិមេ វីជគាមភូតគាមឱសធិតិណវនប្បតយោ(១) តេ ឧស្សុស្សន្តិ វិសុស្សន្តិ ន ភវន្តិ ។ ឯវំ អនិច្ចា ភិក្ខវេ សង្ខារា ឯវំ អទ្ធុវា ភិក្ខវេ សង្ខារា ឯវំ អនស្សាសិកា ភិក្ខវេ សង្ខារា យាវញ្ចិទំ ភិក្ខវេ អលមេវ សព្វសង្ខារេសុ និព្វិន្ទិតុំ អលំ វិរជ្ជិតុំ អលំ វិមុច្ចិតុំ ។ ហោតិ ខោ សោ ភិក្ខវេ សមយោ យំ កទាចិ ករហចិ ទីឃស្ស អទ្ធុនោ អច្ចយេន ទុតិយោ សុរិយោ បាតុភវតិ ។ ទុតិយស្ស ភិក្ខវេ សុរិយស្ស បាតុភាវា យា កាចិ កុន្នទិយោ កុស្សោព្ភា សព្វា តា ឧស្សុស្សន្តិ វិសុស្សន្តិ ន ភវន្តិ ។ ឯវំ អនិច្ចា ភិក្ខវេ សង្ខារា... អលំ វិមុច្ចិតុំ ។ ហោតិ ខោ សោ ភិក្ខវេ សមយោ យំ កទាចិ ករហចិ ទីឃស្ស អទ្ធុនោ អច្ចយេន តតិយោ សុរិយោ បាតុ-ភវតិ ។ តតិយស្ស ភិក្ខវេ សុរិយស្ស បាតុភាវា យា តា(១) មហានទិយោ សេយ្យថីទំ គង្គា យមុនា

---

១ ឱ. ពីជគាមភូតគាមឱសធិតិណវនប្បតយោ ។ ម. ពីជគាមភូតគាមឱសធិតិណវនប្បតិយោ ។ ១ ឱ. ម. យា កាចិ ។

ម្នាលភិក្ខុទាំងឡាយ កាលបើភ្លៀងមិនបង្អុរចុះ ពីជគាម ភូតគាម ឈើជាថ្នាំ ស្មៅ នឹងឈើជាធំ ក្នុងព្រៃណាមួយ ពីជគាម ភូតគាម នឹងឈើជាថ្នាំ ស្មៅ នឹងឈើជាធំក្នុងព្រៃទាំងនោះ នឹងស្វិត ស្ងួត មិនកើតឡើង ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនទៀងយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនខ្ជាប់ខ្ជួនយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនឋិតថេរយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ហេតុនោះ បុគ្គលគួរនឿយណាយ គួរធុញទ្រាន់ គួររួចស្រឡះ ចាកសង្ខារទាំងពួង ម្នាលភិក្ខុទាំងឡាយ មានសម័យដែលព្រះអាទិត្យ ជាគំរប់ពីរ កើតប្រាកដ ដោយអំណើះនៃកាលដ៏វែងម្ដង ៗ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះអាទិត្យ ជាគំរប់ពីរ កើតប្រាកដហើយ ស្ទឹងតូចទាំងឡាយ បាពយណ៍ទឹកតូចទាំងឡាយ ណាមួយ ស្ទឹងនឹងបាពយណ៍តូចទាំងអស់នោះនឹងគោក រីងស្ងួត មិនមានប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនទៀងយ៉ាងនេះ...គួររួចស្រឡះ ។ ម្នាលភិក្ខុទាំងឡាយ មានសម័យដែលព្រះអាទិត្យ ជាគំរប់បី កើតប្រាកដ ដោយអំណើះនៃកាលដ៏វែងម្ដង ៗ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះអាទិត្យ ជាគំរប់បី កើតមានប្រាកដ ទន្លេធំទាំងឡាយណា គឺទន្លេគង្គា យមុនា

អចិរវតី សរភូ មហី សព្វា តា ឧស្សុស្សន្តិ វិសុស្សន្តិ ន ភវន្តិ ។ ឯវំ អនិច្ចា ភិក្ខវេ សង្ខារា... អលំ វិមុច្ចិតុំ ។ ហោតិ សោ ភិក្ខវេ សមយោ យំ កទាចិ ករហចិ ទីឃស្ស អទ្ធុនោ អច្ចយេន ចតុត្ថោ សុរិយោ បាតុភវតិ ។ ចតុត្ថស្ស ភិក្ខវេ សុរិយស្ស បាតុភាវា យេ តេ មហាសរា យតោ ឥមា មហា-នទិយោ សន្ទន្តិ សេយ្យថីទំ គង្គា យមុនា អចិរវតី សរភូ មហី សព្វេ តេ ឧស្សុស្សន្តិ វិសុស្សន្តិ ន ភវន្តិ(១) ។ ឯវំ អនិច្ចា ភិក្ខវេ សង្ខារា... អលំ វិមុច្ចិតុំ ។ ហោតិ សោ ភិក្ខវេ សមយោ យំ កទាចិ ករហចិ ទីឃស្ស អទ្ធុនោ អច្ចយេន បញ្ចមោ សុរិយោ បាតុភវតិ ។ បញ្ចមស្ស ភិក្ខវេ សុរិយស្ស បាតុភាវា យោជនសតិកានិបិ មហាសមុទ្ទេ ឧទកានិ ឱគច្ឆន្តិ ទ្វិយោជនសតិកានិបិ

---

១ ឱ ម. យេ តេ មហាសរា យតោ ឥមា មហានទិយោ សន្ទន្តិ សេយ្យថីទំ អនោតត្តា សីហបបាតា រថការា កណ្ណមុណ្ឌា កុណាលា ឆទ្ទន្តា មន្ទាកិនិយោ តា ឧស្សុស្សន្តិ វិសុស្សន្តិ ន ភវន្តីតិ បាឋោ ទិស្សតិ ។

អចិរវតី សរភូ មហី ទន្លេធំទាំងអស់នោះ គង់រីងរីងស្ងួត មិនមានប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនទៀងយ៉ាងនេះ ... គួរប្រស្រឡះ ។ ម្នាលភិក្ខុទាំងឡាយ មានសម័យ ដែលព្រះអាទិត្យ ជាគំរប់ ៤ កើតមានប្រាកដ ដោយអំណាះនៃកាលដ៏វែងម្តង ៗ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះអាទិត្យ ជាគំរប់ ៤ កើតប្រាកដហើយ ស្រះធំទាំងឡាយណា (គឺ) ទន្លេធំទាំងឡាយនេះ គឺទន្លេគង្គា យមុនា អចិរវតី សរភូ មហី រមែងកើតអំពីស្រះធំណា (គឺ) ស្រះធំ និងទន្លេធំទាំងអស់នោះ ក៏គោករីងស្ងួត មិនមានប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនទៀងយ៉ាងនេះ ... គួរប្រស្រឡះ ។ ម្នាលភិក្ខុទាំងឡាយ មានសម័យដែលព្រះអាទិត្យ ជាគំរប់៥ កើតប្រាកដ ដោយអំណាះនៃកាលដ៏វែងម្តង ៗ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះអាទិត្យ ជាគំរប់ ៥ កើតប្រាកដហើយ ទឹកក្នុងមហាសមុទ្រ ស្រកអស់មួយយោជន៍ខ្លះ ទឹកក្នុងមហាសមុទ្រ ស្រកអស់ ២ យោជន៍ខ្លះ

តិយោជនសតិកានិបិ ចតុយោជនសតិកានិបិ បញ្ច-
យោជនសតិកានិបិ ឆយោជនសតិកានិបិ សត្ត-
យោជនសតិកានិបិ មហាសមុទ្ទេ ឧគ្គតានិ ទិស្សន្តិ
សត្តតាលម្បិ មហាសមុទ្ទេ ឧគ្គតំ ទិស្សតិ
ឆតាលម្បិ បញ្ចតាលម្បិ ចតុតាលម្បិ តិតាលម្បិ
ទ្វិតាលម្បិ តាលមត្តម្បិ មហាសមុទ្ទេ ឧគ្គតំ ទិស្សតិ
សត្តបោរិសម្បិ មហាសមុទ្ទេ ឧគ្គតំ ទិស្សតិ
ឆបោរិសម្បិ បញ្ចបោរិសម្បិ ចតុបោរិសម្បិ តិបោរិសម្បិ
ទ្វិបោរិសម្បិ បោរិសមត្តម្បិ អឌ្ឍបោរិសម្បិ កដិមត្តម្បិ
ជណ្ណុកមត្តម្បិ គោប្ផកមត្តម្បិ មហាសមុទ្ទេ ឧគ្គតំ
ទិស្សតិ ។ សេយ្យថាបិ ភិក្ខវេ សរទសមយេ
ថុល្លផុសិតកេ ទេវេ វស្សន្តេ តត្ថ តត្ថ គោបទេសុ(១)
ឧទកានិ ឋិតានិ ហោន្តិ ឯវមេវ ខោ ភិក្ខវេ តត្ថ
តត្ថ គោបទមត្តានិ មហាសមុទ្ទេ ឧទកានិ ឋិតានិ
ហោន្តិ បញ្ចមស្ស ភិក្ខវេ សុរិយស្ស បាតុភាវា
អង្គុលិបព្វមត្តម្បិ មហាសមុទ្ទេ ឧទកំ ន ហោតិ ។

---

១ ម. គោប្ផកបទេសុ ។

៣ រយយោជន៍ខ្លះ ៤ រយយោជន៍ខ្លះ ៥ រយយោជន៍ខ្លះ ៦ រយយោជន៍ខ្លះ ៧ រយយោជន៍ខ្លះ ទឹករមែងដក់នៅ ក្នុងមហាសមុទ្រ ៧ ដំហារដើមត្នោតខ្លះ ទឹកក្នុងមហាសមុទ្រ រមែងដក់នៅ ៦ ដំហារដើមត្នោតខ្លះ ៥ ដំហារដើមត្នោតខ្លះ ៤ ដំហារដើមត្នោតខ្លះ ៣ ដំហារដើមត្នោតខ្លះ ២ ដំហារដើមត្នោតខ្លះ ១ ដំហារដើមត្នោតខ្លះ ទឹកក្នុងមហាសមុទ្រ រមែងដក់នៅ ៧ ដំហារបុរសខ្លះ ទឹកក្នុងមហាសមុទ្រ រមែងដក់នៅ ៦ ដំហារបុរសខ្លះ ៥ ដំហារបុរសខ្លះ ៤ ដំហារបុរសខ្លះ ៣ ដំហារបុរសខ្លះ ២ ដំហារបុរសខ្លះ ១ ដំហារបុរសខ្លះ ពាក់កណ្ដាលដំហារបុរសខ្លះ ត្រឹមបង្កេះខ្លះ ត្រឹមជង្គង់ខ្លះ ត្រឹមកែងគោខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភ្លៀងមានគ្រាប់ធ្លាស ៗ បង្អុរចុះ ក្នុងសារទសម័យ ទឹករមែងដក់នៅ ក្នុងស្នាមជើងគោ ក្នុងប្រទេសនោះៗ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ទឹកក្នុងមហាសមុទ្រ ដក់នៅប៉ុនប្រឡង់ជើងគោ ក្នុងប្រទេសនោះ ៗ ក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ លុះព្រះអាទិត្យ ជាគំរប់ ៥ កើតប្រាកដហើយ ទឹកក្នុងមហាសមុទ្រ សូម្បីត្រឹមតែមួយធ្នាង នៃម្រាមដៃ ក៏មិនមានឡើយ

ឯវំ អនិច្ចា ភិក្ខវេ សង្ខារា... អលំ វិមុច្ចិតុំ ។
ហោតិ សោ សោ ភិក្ខវេ សមយោ យំ
កទាចិ ករហចិ ទីឃស្ស អទ្ធុនោ អច្ចយេន ឆដ្ឋោ
សុរិយោ បាតុភវតិ ។ ឆដ្ឋស្ស ភិក្ខវេ សុរិយស្ស
បាតុភាវា អយញ្ច មហាបថវី សិនេរុ ច បព្វតរាជា
ធូមាយន្តិ សន្ធូមាយន្តិ សម្បធូមាយន្តិ ។ សេយ្យថាបិ
ភិក្ខវេ កុម្ភការបាកោ អាលិម្បិតោ ធូបេតិ(១) សន្ធូ-
បេតិ សម្បធូបេតិ ឯវមេវ ខោ ភិក្ខវេ ឆដ្ឋស្ស
សុរិយស្ស បាតុភាវា អយញ្ច មហាបថវី សិនេរុ ច
បព្វតរាជា ធូមាយន្តិ សន្ធូមាយន្តិ ។ ឯវំ អនិច្ចា
ភិក្ខវេ សង្ខារា... អលំ វិមុច្ចិតុំ ។ ហោតិ សោ សោ ភិក្ខវេ
សមយោ យំ កទាចិ ករហចិ ទីឃស្ស អទ្ធុនោ
អច្ចយេន សត្តមោ សុរិយោ បាតុភវតិ ។ សត្តមស្ស
ភិក្ខវេ សុរិយស្ស បាតុភាវា អយញ្ច មហាបថវី សិនេរុ
ច បព្វតរាជា អាទិប្បន្តិ បជ្ជលន្តិ ឯកជាលា ភវន្តិ

១ ឧ. អាលិម្បិតោ បឋមំ ធូបេតិ ។ ម. អាលេបិតោ បឋមំ ធូមេតិ ។

ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនទៀងយ៉ាងនេះ ... គួរប្រស្រឡះ ។ ម្នាលភិក្ខុទាំងឡាយ មានសម័យដែលព្រះអាទិត្យ ជាគំរប់ ៦ កើតប្រាកដ ដោយកំណើះនៃកាលដ៏វែងមួន ៗ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះអាទិត្យជាគំរប់ ៦ កើតប្រាកដហើយ មហាប្រថពីនេះផង ស្តេចភ្នំឈ្មោះសិនេរុផង រមែងហុយផ្សែងឡើង ហុយផ្សែងឡើងព្រម ហុយផ្សែងឡើងសព្វ ។ ម្នាលភិក្ខុទាំងឡាយ ឡដុតឆ្នាំងដែលបុទ្ធឆ្នាំងបិទហើយ រមែងហុយផ្សែងឡើង ហុយផ្សែងឡើងព្រម ហុយផ្សែងឡើងសព្វ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ លុះព្រះអាទិត្យជាគំរប់ ៦ កើតប្រាកដហើយ មហាប្រថពីនេះផង ស្តេចភ្នំឈ្មោះសិនេរុផង ក៏ហុយផ្សែងឡើង ហុយផ្សែងឡើងព្រម យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនទៀងយ៉ាងនេះ ... គួរប្រស្រឡះ ។ ម្នាលភិក្ខុទាំងឡាយ មានសម័យដែលព្រះអាទិត្យជាគំរប់ ៧ កើតប្រាកដ ដោយកំណើះនៃកាលដ៏វែងមួន ៗ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះអាទិត្យ ជាគំរប់ ៧ កើតប្រាកដហើយ មហាប្រថពីនេះផង ស្តេចភ្នំឈ្មោះសិនេរុផង រមែងឆេះសព្វ រុងរឿង មានអណ្តាតតែមួយ

ឥមិស្សា ច ភិក្ខវេ មហាបថវិយា សិនេរុស្ស ច បព្វតរាជស្ស ឈាយមានានំ ឌយ្ហមានានំ អច្ចិ វាតេន ខិត្តា យាវ ព្រហ្មលោកាបិ គច្ឆតិ សិនេរុស្ស ភិក្ខវេ បព្វតរាជស្ស ឈាយមានស្ស ឌយ្ហមានស្ស វិនស្សមានស្ស មហតា តេជោខន្ធេន អភិភូតស្ស យោជនសតិកានិបិ កូដានិ បលុជ្ជន្តិ ទ្វិយោជនសតិកានិបិ តិយោជនសតិកានិបិ ចតុយោជនសតិកានិបិ បញ្ចយោជនសតិកានិបិ កូដានិ បលុជ្ជន្តិ ឥមិស្សា ច ភិក្ខវេ មហាបថវិយា សិនេរុស្ស ច បព្វតរាជស្ស ឈាយមានានំ ឌយ្ហមានានំ នេវ ឆារិកា បញ្ញាយតិ ន មសិ ។ សេយ្យថាបិ ភិក្ខវេ សប្បិស្ស វា តេលស្ស វា ឈាយមានស្ស ឌយ្ហមានស្ស នេវ ឆារិកា បញ្ញាយតិ ន មសិ ឯវមេវ ខោ ភិក្ខវេ ឥមិស្សា ច មហាបថវិយា សិនេរុស្ស ច បព្វតរាជស្ស ឈាយមានានំ ឌយ្ហមានានំ នេវ ឆារិកា បញ្ញាយតិ ន មសិ ។ ឯវំ អនិច្ចា ភិក្ខវេ សង្ខារា

ម្នាលភិក្ខុទាំងឡាយ កាលបើមហាប្រថពីនេះផង ស្តេចភ្នំឈ្មោះសិនេរុផង ដែលភ្លើងកំពុងឆេះក្តៅ អណ្តាតភ្លើងដែលត្រូវខ្យល់បក់ឡើងទៅ ដរាបដល់ព្រហ្មលោក ម្នាលភិក្ខុទាំងឡាយ កាលបើស្តេចភ្នំឈ្មោះសិនេរុ ដែលភ្លើងកំពុងឆេះក្តៅ កំពុងវិនាស ដែលគំនរភ្លើងធំ គ្របសង្កត់ហើយ កំពូលភ្នំទាំងឡាយ ១ រយយោជន៍ខ្លះ ក៏ដាច់រលំ កំពូលភ្នំទាំងឡាយ ២ រយយោជន៍ខ្លះ ៣ រយយោជន៍ខ្លះ ៤ រយយោជន៍ខ្លះ ៥ រយយោជន៍ខ្លះ ក៏ដាច់រលំ ម្នាលភិក្ខុទាំងឡាយ កាលបើមហាប្រថពីនេះផង ស្តេចភ្នំឈ្មោះសិនេរុផង ដែលភ្លើងកំពុងឆេះក្តៅ ផែះក៏មិនប្រាកដ កំញមក៏មិនប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាសប្បិក្តី ប្រេងក្តី កាលដែលភ្លើងកំពុងឆេះក្តៅ ផែះក៏មិនប្រាកដ កំញមក៏មិនប្រាកដ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ មហាប្រថពីនេះផង ស្តេចភ្នំឈ្មោះសិនេរុនេះផង កាលដែលភ្លើងកំពុងឆេះក្តៅ ផែះក៏មិនប្រាកដ កំញមក៏មិនប្រាកដ យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនទៀង យ៉ាងនេះ

ឯវំ អទ្ធុវា ភិក្ខវេ សង្ខារា ឯវំ អនស្សាសិកា ភិក្ខវេ សង្ខារា យាវញ្ចិទំ ភិក្ខវេ អលមេវ សព្វសង្ខារេសុ និព្វិន្ទិតុំ អលំ វិរជ្ជិតុំ អលំ វិមុច្ចិតុំ ។ តត្រ ភិក្ខវេ កោ មន្តា កោ សទ្ធាតា អយញ្ច បថវី សិនេរុ ច បព្វតរាជា ឌយ្ហិស្សន្តិ វិនស្សិស្សន្តិ ន ភវិស្សន្តិ អញ្ញត្រ ទិដ្ឋបទេហិ ។

ភូតបុព្វំ ភិក្ខវេ សុនេត្តោ នាម សត្ថា អហោសិ តិត្ថករោ កាមេសុ វីតរាគោ ។ សុនេត្តស្ស ខោ បន ភិក្ខវេ សត្ថុនោ អនេកានិ សាវកសតានិ អហេសុំ ។ សុនេត្តោ សត្ថា សាវកានំ ព្រហ្មលោកសហព្យតាយ ធម្មំ ទេសេតិ ។ យេ ខោ បន ភិក្ខវេ សុនេត្តស្ស សត្ថុនោ ព្រហ្មលោកសហព្យតាយ ធម្មំ ទេសេន្តស្ស សព្វេន សព្វំ សាសនំ អាជានិំសុ តេ កាយស្ស ភេទា បរម្មរណា សុគតិំ ព្រហ្មលោកំ ឧបបជ្ជិំសុ ។

ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនខ្ជាប់ខ្ជួនយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនឋិតថេរយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ បុគ្គលគួរនឿយណាយ គួរធុញទ្រាន់ គួររួចស្រឡះចាក សង្ខារទាំងពួង ។ ម្នាលភិក្ខុទាំងឡាយ នរណាដឹង នរណាជឿក្នុង សង្ខារនោះថា ផែនដីនេះក្តី ស្តេចភ្នំឈ្មោះសិនេរុក្តី គង់នឹងឆេះរលាយ គង់នឹងវិនាស មិនមានប្រាកដយ៉ាងនេះ វៀរលែងតែអរិយសាវកទាំងឡាយ អ្នកមានបទគឺធម៌ឃើញហើយ ។

ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយ មានគ្រូឈ្មោះសុនេត្តៈ ជាអ្នកធ្វើនូវលទ្ធិជាកំពង់ ជាអ្នកប្រាសចាក(១)រាគៈ ក្នុងកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ គ្រូឈ្មោះសុនេត្តៈ មានរយនៃសាវកដ៏ច្រើន ។ គ្រូឈ្មោះសុនេត្តៈ សំដែងធម៌ដល់ពួកសាវក ដើម្បីឲ្យបានទៅកើតក្នុងព្រហ្មលោក ។ ម្នាលភិក្ខុទាំងឡាយ កាលគ្រូឈ្មោះសុនេត្តៈ កំពុងសំដែងធម៌ ដើម្បីឲ្យបានទៅកើត ក្នុងព្រហ្មលោក ពួកសាវកណាដឹងច្បាស់នូវពាក្យប្រៀនប្រដៅទាំងអស់ ដោយសព្វគ្រប់ ពួកសាវកទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតឯសុគតិ ព្រហ្មលោក ។

---

១ គ្រាន់តែស្ងប់រាគៈដោយអំណាចឈាន មិនបានលះដាច់ទេ ។

យេ ច សព្វេន សត្ថុ សាសនំ អាជានិំសុ តេ កាយស្ស ភេទា បរម្មរណា អបរេកច្ចេ បរនិម្មិត-វសវត្តីនំ ទេវានំ សហព្យតំ ឧបបជ្ជឹសុ អបរេកច្ចេ និម្មានរតីនំ ទេវានំ សហព្យតំ ឧបបជ្ជឹសុ អបរេកច្ចេ តុសិតានំ ទេវានំ សហព្យតំ ឧបបជ្ជឹសុ អបរេកច្ចេ យាមានំ ទេវានំ សហព្យតំ ឧបបជ្ជឹសុ អបរេកច្ចេ តាវត្តឹសានំ ទេវានំ សហព្យតំ ឧបបជ្ជឹសុ អបរេកច្ចេ ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបជ្ជឹសុ អបរេកច្ចេ ខត្តិយមហាសាលានំ សហព្យតំ ឧបបជ្ជឹសុ អបរេកច្ចេ ព្រាហ្មណមហាសាលានំ សហព្យតំ ឧបបជ្ជឹសុ អបរេកច្ចេ គហបតិមហាសាលានំ សហព្យតំ ឧបបជ្ជឹសុ ។

អថខោ ភិក្ខវេ សុនេត្តស្ស សត្ថុនោ ឯតទហោសិ ន ខោ មេតំ បដិរូបំ យោហំ សាវកានំ សមសមគតិយោ អស្សំ អភិសម្បរាយំ យន្នូនាហំ ឧត្តរឹ មេត្តំ ភាវេយ្យន្តិ ។ អថខោ ភិក្ខវេ សុនេត្តោ សត្ថា សត្ត វស្សានិ មេត្តចិត្តំ ភាវេសិ

ពួកសាវ័កណា មិនដឹងច្បាស់នូវពាក្យប្រៀនប្រដៅ ដោយសព្វគ្រប់ទេ ពួកសាវ័កនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ពួកខ្លះ ទៅកើតជាមួយនឹងពួកទេវតា ជាន់បរនិម្មិតវសវត្តី ពួកខ្លះ ទៅកើតជាមួយនឹងពួកទេវតា ជាន់និម្មានរតី ពួកខ្លះ ទៅកើតជាមួយនឹងពួកទេវតាជាន់តុសិត ពួកខ្លះ ទៅកើតជាមួយនឹងពួកទេវតាជាន់យាមៈ ពួកខ្លះ ទៅកើតជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ពួកខ្លះ ទៅកើតជាមួយនឹងពួកទេវតាជាន់ចាតុម្មហារាជិក ពួកខ្លះ ទៅកើតជាមួយនឹងពួកខត្តិយ-មហាសាល ពួកខ្លះ ទៅកើតជាមួយនឹងពួកព្រាហ្មណមហាសាល ពួកខ្លះ ទៅកើតជាមួយនឹងពួកគហបតិមហាសាល ។

ម្នាលភិក្ខុទាំងឡាយ គ្រានោះ គ្រូឈ្មោះសុនេត្តៈ មានសេចក្តីត្រិះរិះដូច្នេះថា ហេតុនេះ មិនសមគួរសោះ ដែលអាត្មាអញ ជាអ្នកមានគតិស្មើ ៗ នឹងពួកសាវ័កក្នុងភពមុខ បើដូច្នោះ មានតែអាត្មាអញចំរើននូវមេត្តាឲ្យលើសលុប ជាងបឋមដ្ឋានទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ គ្រូឈ្មោះសុនេត្តៈ ចំរើននូវមេត្តាចិត្តអស់ ៧ ឆ្នាំ

សត្ត វស្សានិ មេត្តចិត្តំ ភាវេត្វា សត្ត សំវដ្ដវិវដ្ដកប្បេ ន យិមំ លោកំ បុនាគមាសិំ សំវដ្ដមានេ សុទំ ភិក្ខវេ លោកេ អាភស្សរូបគោ ហោមិ វិវដ្ដមានេ លោកេ សុញ្ញំ ព្រហ្មវិមានំ ឧបបជ្ជាមិ ។ តត្រ សុទំ ភិក្ខវេ ព្រហ្មា ហោមិ មហាព្រហ្មា អភិភូ អនភិភូតោ អញ្ញទត្ថុទសោ វសវត្តី ឆត្តឹសក្ខត្តុំ ខោ បន ភិក្ខវេ សក្កោ អហោសិំ ទេវានមិន្ទោ អនេកសតក្ខត្តុំ រាជា អហោសិំ ចក្កវត្តី ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី ជនបទត្ថាវរិយប្បត្តោ សត្តរតនសមន្នាគតោ បរោសហស្សំ ខោ បនស្ស បុត្តា អហេសុំ សូរា វីរង្គរូបា បរសេនប្បមទ្ទនា ។ សោ ឥមំ បថវឹ សាគរបរិយន្តំ អទណ្ឌេន អសត្ថេន ធម្មេន អភិវិជិយ អជ្ឈាវសិំ ។

លុះចំរើននូវមេត្តាចិត្តអស់ ៧ ឆ្នាំហើយ ក៏នៅមកកាន់លោកនេះទៀត អស់ ៧ សំវដ្តវិវដ្តកប្ប ម្នាលភិក្ខុទាំងឡាយ មានសេចក្តីដំណាលថា កាលលោកកំពុងវិនាស គ្រូឈ្មោះសុនេត្តៈ ក៏បានទៅកើត ក្នុងព្រហ្មលោកជាន់អាភស្សរៈ កាលលោកកំពុងចំរើន ក៏ចូលទៅកើតក្នុងសុញ្ញវិមាននៃព្រហ្ម ។ ម្នាលភិក្ខុទាំងឡាយ មានសេចក្តីដំណាលថា ក្នុងសុញ្ញវិមាននៃព្រហ្មនោះ មានព្រហ្មជាមហាព្រហ្ម គ្របសង្កត់នូវព្រហ្មឯទៀត ៗ បាន ព្រហ្មឯទៀត ៗ មិនអាចគ្របសង្កត់លើបាន ជាអ្នកឃើញហេតុដោយសព្វគ្រប់ ជាអ្នកធ្វើជនទាំងពួង ឲ្យលុះនៅក្នុងអំណាចខ្លួន ម្នាលភិក្ខុទាំងឡាយ គ្រូឈ្មោះសុនេត្តៈ បានជាសក្កៈ ជាធំជាងទេវតាទាំងឡាយ ៣៦ លើក បានជាស្តេចចក្រពត្តិ ប្រកបដោយធម៌ ជាធម្មរាជា (ជាឥស្សរៈលើផែនដី) មានមហាសមុទ្រទាំង ៤ ជាទីបំផុត ព្រះអង្គជាស្តេចឈ្នះសង្គ្រាម ទ្រង់មានជនបទ ដល់នូវសេចក្តីមាំមួន ប្រកបដោយកែវ ៧ ប្រការ ព្រះរាជបុត្ររបស់ព្រះអង្គច្រើនជាងពាន់ សុទ្ធតែជាអ្នកក្លៀវក្លា មានសភាពជាអ្នកមានសេចក្តីព្យាយាម សង្កត់សង្កិននូវសេនារបស់ស្តេចដទៃ បានច្រើនរយលើក ។ ព្រះអង្គទ្រង់ក្រោមក្រាប គ្រប់គ្រងផែនដីដែលមានសាគរ ជាទីបំផុតដោយធម៌ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រាវុធឡើយ ។

សោ ហិ នាម ភិក្ខវេ សុនេត្តោ សត្ថា ឯវំ ទីឃាយុកោ សមានោ ឯវំ ចិរដ្ឋិតិកោ អបរិមុត្តោ អហោសិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អបរិមុត្តោ ទុក្ខស្មាតិ វទាមិ ។ តំ កិស្ស ហេតុ ។ ចតុន្នំ ធម្មានំ អននុពោធា អប្បដិវេធា ។ កតមេសំ ចតុន្នំ ។ អរិយស្ស សីលស្ស អននុពោធា អប្បដិវេធា អរិយស្ស សមាធិស្ស អននុពោធា អប្បដិវេធា អរិយាយ បញ្ញាយ អននុពោធា អប្បដិវេធា អរិយាយ វិមុត្តិយា អននុពោធា អប្បដិវេធា ។ តយិទំ ភិក្ខវេ អរិយំ សីលំ អនុពុទ្ធំ បដិវិទ្ធំ អរិយោ សមាធិ អនុពុទ្ធោ បដិវិទ្ធោ អរិយា បញ្ញា អនុពុទ្ធា បដិវិទ្ធា អរិយា វិមុត្តិ អនុពុទ្ធា បដិវិទ្ធា ។ ឧច្ឆិន្នា ភវតណ្ហា ខីណា ភវនេត្តិ នត្ថិទានិ បុនព្ភវោតិ ។ ឥទមវោច ភគវា

ម្នាលភិក្ខុទាំងឡាយ អម្បាលដូចជាគ្រូឈ្មោះសុនេត្តៈនោះ មានអាយុវែងយ៉ាងនេះ ឋិតនៅយូរយ៉ាងនេះ ក៏នៅតែជាអ្នកមិនផុតអំពី ជាតិ ជរា មរណៈ សោកៈ ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ចិត្ត តថាគតហៅថា មិនរួចអំពីទុក្ខដូច្នេះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះ បំពោះនូវធម៌ទាំង ៤ ។ ធម៌ទាំង ៤ តើដូចម្តេច ។ គឺមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវសីលដ៏ប្រសើរ ១ មិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវសមាធិដ៏ប្រសើរ ១ មិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវបញ្ញាដ៏ប្រសើរ ១ មិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវវិមុត្តិដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ សីលដ៏ប្រសើរនោះឯង ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ សមាធិដ៏ប្រសើរ ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ បញ្ញាដ៏ប្រសើរ ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ វិមុត្តិដ៏ប្រសើរ ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ ។ ភវតណ្ហា គឺសេចក្តីប្រាថ្នាក្នុងភព ក៏ស្ងប់ទៅ ខ្សែ គឺតណ្ហាដែលអាចនាំសត្វអំពីភពមួយ ទៅភពមួយ ក៏អស់ទៅ ភពថ្មីទៀត ក៏មិនមានក្នុងកាលឥឡូវនេះឡើយ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដែងដូច្នេះហើយ

ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

សីលំ សមាធិ បញ្ញា ច វិមុត្តិ ច អនុត្តរា
អនុពុទ្ធា ឥមេ ធម្មា គោតមេន យសស្សិនា
ឥតិ ពុទ្ធោ អភិញ្ញាយ ធម្មមក្ខាសិ ភិក្ខុនំ
ទុក្ខស្សន្តករោ សត្ថា ចក្ខុមា បរិនិព្វុតោតិ ។

[៦៨] យតោ ខោ ភិក្ខវេ រញ្ញោ បច្ចន្តិមំ នគរំ សត្តហិ នគរបរិក្ខារេហិ សុបរិក្ខតំ(១) ហោតិ ចតុន្នញ្ច អាហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ឥទំ វុច្ចតិ ភិក្ខវេ រញ្ញោ បច្ចន្តិមំ នគរំ អករណីយំ ពាហិរេហិ បច្ចត្ថិកេហិ បច្ចាមិត្តេហិ ។ កតមេហិ សត្តហិ នគរបរិក្ខារេហិ សុបរិក្ខតំ ហោតិ ។ ឥធ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ ឯសិកា ហោតិ គម្ភីរនេមា សុនិខាតា អចលា អសម្បវេធិ ។ ឥមិនា បឋមេន នគរបរិក្ខារេន សុបរិក្ខតំ ហោតិ រញ្ញោ បច្ចន្តិមំ នគរំ អព្ភន្តរានំ គុត្តិយា

---

១ ឱ. ម. សុបរិក្ខិត្តំ ។

ព្រះសុគតជាសាស្តា លុះទ្រង់មានព្រះពុទ្ធដីកាដូច្នេះហើយ ក៏ទ្រង់ត្រាស់ដូច្នេះ តទៅទៀតថា

ធម៌ទាំងនេះ គឺសីល សមាធិ បញ្ញា និងវិមុត្តិ ដ៏ប្រសើរ
ព្រះគោតមដ៏មានយស បានត្រាស់ដឹងហើយ ព្រះពុទ្ធទ្រង់
ត្រាស់ដឹងយ៉ាងនេះហើយ ទើបសំដែងធម៌ប្រាប់ ដល់ភិក្ខុ
ទាំងឡាយ ព្រះសាស្តាមានចក្ខុ ទ្រង់ធ្វើនូវព្រះនិព្វាន
ជាទីបំផុតនៃកងទុក្ខ ទ្រង់បរិនិព្វានហើយ ។

(៦៤) ម្នាលភិក្ខុទាំងឡាយ កាលណា នគរនៃស្តេច ជាទីបំផុតនៃដែន ដែលរៀបចំល្អហើយ ដោយនគរបរិក្ខារ[១] ៧ យ៉ាង ទាំងស្តេចក៏រមែងបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវអាហារ ៤ យ៉ាង ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា នគរនៃស្តេចជាទីបំផុតនៃដែន ដែលពួកបច្ចាមិត្ត ជាសត្រូវខាងក្រៅ មិនគប្បីធ្វើបាន ។ នគរដែលរៀបចំល្អហើយ ដោយនគរបរិក្ខារ ៧ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេច ជាទីបំផុតនៃដែន ក្នុងលោកនេះ មានសសរគោល មានរណ្តៅដ៏ជ្រៅ ដែលគេដាំល្អហើយ មិនកម្រើក មិនរញ្ជួយ ។ នគរនៃស្តេច ជាទីបំផុតនៃដែន ដែលរៀបចំល្អហើយ ដោយនគរបរិក្ខារទី ១ នេះ ដើម្បីគ្រប់គ្រងនូវពួកជនខាងក្នុង

---

១ គ្រឿងរក្សាទីក្រុង ។

ពាហិរានំ បដិឃាតាយ ។ បុន ចបរំ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ បរិខា ហោតិ គម្ភីរា ចេវ វិត្ថតា ច ។ ឥមិនា ទុតិយេន នគរបរិក្ខារេន សុបរិក្ខិតំ ហោតិ រញ្ញោ បច្ចន្តិមំ នគរំ អព្ភន្តរានំ គុត្តិយា ពាហិរានំ បដិឃាតាយ ។ បុន ចបរំ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ អនុបរិយាយបថោ ហោតិ ឧច្ចោ ចេវ វិត្ថតោ ច ។ ឥមិនា តតិយេន នគរបរិក្ខារេន សុបរិក្ខិតំ ហោតិ រញ្ញោ បច្ចន្តិមំ នគរំ អព្ភន្តរានំ គុត្តិយា ពាហិរានំ បដិឃាតាយ ។ បុន ចបរំ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ ពហុំ អាវុធំ សន្និចិតំ ហោតិ សលាកញ្ចេវ ជេវនិកញ្ច(១) ។ ឥមិនា ចតុត្ថេន នគរបរិក្ខារេន សុបរិក្ខិតំ ហោតិ រញ្ញោ បច្ចន្តិមំ នគរំ អព្ភន្តរានំ គុត្តិយា ពាហិរានំ បដិឃាតាយ ។ បុន ចបរំ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ ពហុ ពលកាយោ បដិវសតិ សេយ្យថីទំ ហត្ថារោហា អស្សារោហា រថិកា ធនុគ្គហា ចេលកា ចលកា បិណ្ឌទាយកា

---

១ ឱ. ជេវនីយញ្ច ។

ដើម្បីការពារទ្វារពួកសត្រូវខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត នគរនៃស្តេច ជាទីបំផុតនៃដែន មានស្នាមភ្លោះដ៏ជ្រៅផង ធំទូលាយផង ។ នគរនៃស្តេច ជាទីបំផុតនៃដែន ដែលរៀបចំល្អហើយ ដោយនគរបរិក្ខារទី ២ នេះ ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត នគរនៃស្តេច ជាទីបំផុតនៃដែន មានផ្លូវយាមល្បាតដ៏ខ្ពស់ផង ទូលាយផង ។ នគរនៃស្តេច ជាទីបំផុតនៃដែន ដែលរៀបចំល្អហើយ ដោយនគរបរិក្ខារទី ៣ នេះ ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត នគរនៃស្តេច ជាទីបំផុតនៃដែន មានអាវុធដ៏ច្រើន គឺ ព្រួញ និងលំពែងផង និងអាវុធមានមុខម្ខាងផង ដែលគេសន្សំទុកហើយ ។ នគរនៃស្តេច ជាទីបំផុតនៃដែន ដែលគេរៀបចំល្អហើយ ដោយនគរបរិក្ខារ ទី ៤ នេះ ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត នគរនៃស្តេច ជាទីបំផុតនៃដែន មានពួកពលដ៏ច្រើន តែងនៅអាស្រ័យ គឺ ទ័ពដំរី ទ័ពសេះ ទ័ពរថ ខាន់ធ្នូ អ្នកកាន់ទង់ជ័យ ( ដើរមុខ ) អ្នកចាត់កងទ័ព ជាអ្នកឲ្យនូវស្បៀង (ពួកអ្នកចែកស្បៀងដល់ពួកទាហានក្នុងសង្គ្រាម)

ឧគ្គា រាជបុត្តា បក្ខន្ទិនោ មហានាគា សូរា ចណ្ឌាលិកា(១) ចម្មយោធិនោ ទាសកបុត្តា ។ ឥមិនា បញ្ចមេន នគរបរិក្ខារេន សុបរិក្ខតំ ហោតិ រញ្ញោ បច្ចន្តិមំ នគរំ អព្ភន្តរានំ គុត្តិយា ពាហិរានំ បដិឃាតាយ ។ បុន ចបរំ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ ទោវារិកោ ហោតិ បណ្ឌិតោ ព្យត្តោ មេធាវី អញ្ញាតានំ និវារេតា ញាតានំ បវេសេតា ។ ឥមិនា ឆដ្ឋេន នគរបរិក្ខារេន សុបរិក្ខតំ ហោតិ រញ្ញោ បច្ចន្តិមំ នគរំ អព្ភន្តរានំ គុត្តិយា ពាហិរានំ បដិឃាតាយ ។ បុន ចបរំ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ បាការោ ហោតិ ឧច្ចោ ចេវ វិត្ថតោ ច វាសនលេបនសម្បន្នោ ច ។ ឥមិនា សត្តមេន នគរបរិក្ខារេន សុបរិក្ខតំ ហោតិ រញ្ញោ បច្ចន្តិមំ នគរំ អព្ភន្តរានំ គុត្តិយា ពាហិរានំ បដិឃាតាយ ។ ឥមេហិ សត្តហិ នគរបរិក្ខារេហិ សុបរិក្ខតំ ហោតិ ។

១ អយំ បាឋោ ឱ.ម. បោត្ថកេសុ នត្ថិ ។ អដ្ឋកថាយម្បិ ន ទិស្សតិ ។

ពួករាជបុត្រ អ្នកពុះពារ (ចូលទៅក្នុងសង្គ្រាម) ពួកទាហាន អ្នកលុកចូល ពួកទាហាន អ្នកអង់អាច ពួកទាហាន អ្នកក្លៀវក្លា ដូចជាដំរីដ៏ប្រសើរ ពួកទាហាន អ្នកទ្រទ្រង់ទូលផែនក្តារ (សម្រាប់ការពារសរ) គឺខែល ពួកទាហាន អ្នកពាក់អាវក្រោះ ពួកទាហាន ជាកូននៃជនជាទាសៈ ។ នគរនៃស្តេច ជាទីបំផុតនៃដែន ដែលគេរៀបចំល្អហើយ ដោយនគរបរិក្ខារទី ៥ នេះ ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត នគរនៃស្តេច ជាទីបំផុតនៃដែន មានឆ្មាំទ្វារ ជាបណ្ឌិត អ្នកឈ្លាសវៃ មានបញ្ញា ឃាត់ពួកជនដែលមិនស្គាល់ បើកឲ្យពួកជនដែលស្គាល់ចូលទៅ ។ នគរនៃស្តេច ជាទីបំផុតនៃដែន ដែលគេរៀបចំល្អហើយ ដោយនគរបរិក្ខារ ទី ៦ នេះ ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត នគរនៃស្តេច ជាទីបំផុតនៃដែន មានកំពែងខ្ពស់ផង ក្រាស់ផង បរិបូណ៌ដោយគ្រឿងអប់និងគ្រឿងលាបផង ។ នគរនៃស្តេច ជាទីបំផុតនៃដែន ដែលគេរៀបចំល្អហើយ ដោយនគរបរិក្ខារទី ៧ នេះ ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ ។ នគរដែលគេរៀបចំល្អហើយ ដោយនគរបរិក្ខារ ៧ យ៉ាងនេះ ។

កតមេសំ ចតុន្នំ អាហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ។ ឥធ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ ពហុំ តិណកដ្ឋោទកំ សន្និចិតំ ហោតិ អព្ភន្តរានំ រតិយា អបរិតស្សាយ ផាសុវិហារាយ ពាហិរានំ បដិឃាតាយ ។ បុន ចបរំ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ ពហុំ សាលិយវកំ សន្និចិតំ ហោតិ អព្ភន្តរានំ រតិយា អបរិតស្សាយ ផាសុវិហារាយ ពាហិរានំ បដិឃាតាយ ។ បុន ចបរំ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ ពហុំ តិលមុគ្គមាសាបរណ្ណំ សន្និចិតំ ហោតិ អព្ភន្តរានំ រតិយា អបរិតស្សាយ ផាសុវិហារាយ ពាហិរានំ បដិឃាតាយ ។ បុន ចបរំ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ ពហុំ ភេសជ្ជំ សន្និចិតំ ហោតិ សេយ្យថីទំ សប្បិ នវនីតំ តេលំ មធុ ផាណិតំ លោណំ អព្ភន្តរានំ រតិយា អបរិតស្សាយ

ចុះស្តេចដែលបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវអាហារទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ នគរនៃស្តេច ជាទីបំផុតនៃដែន មានស្មៅនិងអុសនិងទឹកដ៏ច្រើន ដែលគេសន្សំទុកហើយ ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយដល់ពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត នគរនៃស្តេច ជាទីបំផុតនៃដែន មានស្រូវខ្សាយ និងស្រូវដំណើបដ៏ច្រើន ដែលគេសន្សំទុក ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដល់ពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត នគរនៃស្តេច ជាទីបំផុតនៃដែន មានល្ង និងសណ្តែក និងអបរណ្ណជាតិដ៏ច្រើន ដែលគេសន្សំទុក ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដល់ពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត នគរនៃស្តេច ជាទីបំផុតនៃដែន មានភេសជ្ជៈច្រើន គឺទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ និងអំបិល ដែលគេសន្សំទុក ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត

ផាសុវិហារាយ ពាហិរានំ បដិឃាតាយ ។ ឥមេសំ ចតុន្នំ អាហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ។ យតោ ខោ ភិក្ខវេ រញ្ញោ បច្ចន្តិមំ នគរំ សត្តហិ នគរបរិក្ខារេហិ សុបរិក្ខតំ ហោតិ ចតុន្នញ្ច អាហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អយំ វុច្ចតិ ភិក្ខវេ រញ្ញោ បច្ចន្តិមំ នគរំ អករណីយំ ពាហិរេហិ បច្ចត្ថិកេហិ បច្ចាមិត្តេហិ ឯវមេវ ខោ ភិក្ខវេ យតោ អរិយសាវកោ សត្តហិ សទ្ធម្មេហិ សមន្នាគតោ ហោតិ ចតុន្នញ្ច ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អយំ វុច្ចតិ ភិក្ខវេ អរិយសាវកោ អករណីយោ មារស្ស អករណីយោ បាបិមតោ ។ កតមេហិ សត្តហិ សទ្ធម្មេហិ សមន្នាគតោ ហោតិ ។ សេយ្យថាបិ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ ឯសិកា ហោតិ គម្ភីរនេមា សុនិខាតា អចលា អសម្បវេធិ អព្ភន្តរានំ គុត្តិយា ពាហិរានំ បដិឃាតាយ ។

ដើម្បីនៅសប្បាយ ដល់ពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ ។ ស្តេចរមែងបានតាមប្រាថ្នា បានមិនលំបាក បានដោយងាយនូវអាហារទាំង ៤ នេះ ។ ម្នាលភិក្ខុទាំងឡាយ កាលណា នគរនៃស្តេច ជាទីបំផុតនៃដែន ដែលរៀបចំល្អហើយ ដោយនគរ-បរិក្ខារទាំង ៧ យ៉ាង ទាំងស្តេចក៏រមែងបានតាមប្រាថ្នា បានមិនលំបាក បានដោយងាយនូវអាហារទាំង ៤ យ៉ាង ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា នគរនៃស្តេច ជាទីបំផុតនៃដែន ដែលពួកបច្ចាមិត្តជាសត្រូវខាងក្រៅ មិនគប្បីធ្វើបាន (យ៉ាងណាមិញ) ម្នាលភិក្ខុទាំងឡាយ កាលណា អរិយសាវក ជាអ្នកប្រកបដោយព្រះសទ្ធម្ម ៧ យ៉ាង បានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវឈានទាំង ៤ ដែលប្រព្រឹត្តទៅក្នុងចិត្តដ៏ប្រសើរ មានការនៅជាសុខក្នុងបច្ចុប្បន្ន ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា អរិយសាវក ដែលមារមិនគប្បីធ្វើបាន ដែលមារមានចិត្តបាប មិនគប្បីធ្វើបាន យ៉ាងនោះដែរ ។ អរិយសាវក ជាអ្នកប្រកបដោយព្រះសទ្ធម្ម ៧ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេច ជាទីបំផុតនៃដែន មានសសរគោល មានរណ្តៅដ៏ជ្រៅដែលគេដាំដោយល្អ មិនកម្រើក មិនរញ្ជួយ ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ យ៉ាងណាមិញ ។

ឯវមេវ ខោ ភិក្ខវេ អរិយសាវកោ សទ្ធោ ហោតិ សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា ។បេ។ ពុទ្ធោ ភគវាតិ ។ សទ្ធាសិកោ(១) ភិក្ខវេ អរិយសាវកោ អកុសលំ បជហតិ កុសលំ ភាវេតិ សាវជ្ជំ បជហតិ អនវជ្ជំ ភាវេតិ សុទ្ធំ អត្តានំ បរិហរតិ ។ ឥមិនា បឋមេន សទ្ធម្មេន សមន្នាគតោ ហោតិ ។ សេយ្យថាបិ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ បរិខា ហោតិ គម្ភីរា ចេវ វិត្ថតា ច អត្តគុត្តិយា ពាហិរានំ បដិឃាតាយ ឯវមេវ ខោ ភិក្ខវេ អរិយសាវកោ ហិរិមា ហោតិ ហិរីយតិ កាយទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេន ហិរីយតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ។ ហិរិបរិខោ ភិក្ខវេ អរិយសាវកោ អកុសលំ បជហតិ កុសលំ ភាវេតិ សាវជ្ជំ បជហតិ អនវជ្ជំ ភាវេតិ សុទ្ធំ អត្តានំ បរិហរតិ ។ ឥមិនា ទុតិយេន សទ្ធម្មេន សមន្នាគតោ ហោតិ ។

---

១ ម. សទ្ធេ ប ហេ ។

ម្នាលភិក្ខុទាំងឡាយ អរិយសាវក ជាអ្នកមានសទ្ធា រមែងជឿចំពោះ ពោធិញ្ញាណ របស់តថាគតដូច្នេះថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ទ្រង់លែងត្រឡប់មកកាន់គភ៌ទៀត ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ទុកដូចជាសសរគោល រមែងលះបង់នូវអកុសល ចំរើននូវកុសល លះបង់នូវអំពើ ដែលមានទោស ចំរើននូវអំពើ ដែលមិនមានទោស រក្សាខ្លួនឲ្យបរិសុទ្ធ ក៏យ៉ាងនោះដែរ ។ អរិយសាវក ជាអ្នកប្រកបដោយព្រះសទ្ធម្មទី ១ នេះ ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេចជាទីបំផុតនៃដែន មានស្នាមភ្លោះដ៏ជ្រៅផង ធំទូលាយផង ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ជាអ្នកខ្មាសបាប រមែងខ្មាសកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត រមែងខ្មាសការចូលប្រសព្វនូវអកុសលធម៌ ដ៏លាមកទាំងឡាយ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក មានហិរិទុកជាស្នាមភ្លោះ រមែងលះបង់នូវអកុសល ចំរើននូវកុសល លះបង់នូវអំពើ ដែលមានទោស ចំរើននូវអំពើ ដែលមិនមានទោស រក្សាខ្លួនឲ្យបរិសុទ្ធ ។ អរិយសាវក ជាអ្នកប្រកប ដោយព្រះសទ្ធម្មទី ២ នេះ ។

សេយ្យថាបិ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ អនុបរិយាយបថោ ហោតិ ឧច្ចោ ចេវ វិត្ថតោ ច អព្ភន្តរានំ គុត្តិយា ពាហិរានំ បដិឃាតាយ ឯវមេវ ខោ ភិក្ខវេ អរិយសាវកោ ឱត្តប្បី ហោតិ ឱត្តប្បតិ កាយទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេន ឱត្តប្បតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ។ ឱត្តប្បបរិយាយបថោ ភិក្ខវេ អរិយសាវកោ អកុសលំ បជហតិ កុសលំ ភាវេតិ សាវជ្ជំ បជហតិ អនវជ្ជំ ភាវេតិ សុទ្ធំ អត្តានំ បរិហរតិ ។ ឥមិនា តតិយេន សទ្ធម្មេន សមន្នាគតោ ហោតិ ។ សេយ្យថាបិ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ ពហុំ អាវុធំ សន្និចិតំ ហោតិ សលាកញ្ចេវ ជេវនិកញ្ច អព្ភន្តរានំ គុត្តិយា ពាហិរានំ បដិឃាតាយ ឯវមេវ ខោ ភិក្ខវេ អរិយសាវកោ ពហុស្សុតោ ហោតិ ។ បេ ។ ទិដ្ឋិយា សុប្បដិវិទ្ធា ។ សុតាវុធោ ភិក្ខវេ អរិយសាវកោ

ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេច ជាទីបំផុតនៃដែន មានផ្លូវដាំ យាមល្បាតដ៏ខ្ពស់ផង ធំទូលាយផង ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ជាអ្នកមានសេចក្តីតក់ស្លុត ចំពោះបាប រមែងតក់ស្លុត ចំពោះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត រមែងតក់ស្លុត ចំពោះការចូលប្រសព្វ នូវអកុសលធម៌ទាំងឡាយ ដ៏លាមក ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក មានឱត្តប្បៈទុកជាផ្លូវយាមល្បាត រមែងលះបង់នូវអកុសល ចំរើននូវកុសល លះបង់នូវអំពើមានទោស ចំរើននូវអំពើមិនមានទោស រក្សាខ្លួនឲ្យបរិសុទ្ធ ។ អរិយសាវក ជាអ្នកប្រកបដោយព្រះសទ្ធម្មទី ៣ នេះ ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេច ជាទីបំផុតនៃដែន មានគ្រឿងអាវុធដ៏ច្រើន គឺព្រួញនិងលំពែងផង និងអាវុធមានមុខម្ខាងផង ដែលគេសន្សំទុក ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ជាពហុស្សុត ។ បេ ។ ចាក់ធ្លុះចំពោះដោយទិដ្ឋិ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក មានការចេះដឹង ទុកជាអាវុធ រមែងលះបង់នូវអកុសល ចំរើននូវកុសល លះបង់នូវអំពើមានទោស

អកុសលំ បជហតិ កុសលំ ភាវេតិ សាវជ្ជំ បជហតិ អនវជ្ជំ ភាវេតិ សុទ្ធំ អត្តានំ បរិហរតិ ។ ឥមិនា ចតុត្ថេន សទ្ធម្មេន សមន្នាគតោ ហោតិ ។ សេយ្យថាបិ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ ពហុ ពលកាយោ បដិវសតិ សេយ្យថីទំ ហត្ថារោហា អស្សារោហា រថិកា ធនុគ្គហា ចេលកា ចលកា បិណ្ឌទាយកា ឧគ្គា រាជបុត្តា បក្ខន្ទិនោ មហានាគា សូរា បក្ខាវិកា(១) ចម្មយោធិនោ ទាសកបុត្តា អព្ភន្តរានំ គុត្តិយា ពាហិរានំ បដិឃាតាយ ឯវមេវ ខោ ភិក្ខវេ អរិយសាវកោ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។ វីរិយពលកាយោ ភិក្ខវេ អរិយសាវកោ អកុសលំ បជហតិ កុសលំ ភាវេតិ សាវជ្ជំ បជហតិ អនវជ្ជំ ភាវេតិ សុទ្ធំ អត្តានំ បរិហរតិ ។

---

១ អយំ បាឋោ ឱ. ម. ពោត្ថកេសុ នត្ថិ ។

បំពេញនូវអំពើមិនមានទោស រមែងរក្សាខ្លួនឲ្យបរិសុទ្ធ ។ អរិយសាវក ជាអ្នកប្រកបដោយព្រះសទ្ធម្មទី ៤ នេះ ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេច ជាទីបំផុតនៃដែន មានពួកពលដ៏ច្រើន តែងនៅអាស្រ័យ គឺ ទ័ពដំរី ទ័ពសេះ ទ័ពរថ ខ្មាន់ធ្នូ អ្នកកាន់ទង់ជ័យ (ដើរមុខ) អ្នកចាត់កងទ័ព អ្នកឲ្យនូវស្បៀង (ដល់ពួកទាហានក្នុងសង្គ្រាម) ពួករាជបុត្រ អ្នកពុះពារ (ចូលទៅក្នុងសង្គ្រាម) ពួកទាហាន អ្នកលុកចូលកាន់សង្គ្រាម ពួកទាហាន អ្នកអង់អាច ពួកទាហាន អ្នកក្លៀវក្លាដូចជាដំរីដ៏ប្រសើរ ពួកទាហាន អ្នកទ្រង់នូវផែនក្តារ ( សម្រាប់ការពារសរ ) គឺខែល ពួកទាហាន ជាកូននៃជនជាទាសៈ ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អរិយសាវក អ្នកប្រារព្ធសេចក្តីព្យាយាម ដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយ ដើម្បីបំពេញនូវកុសលធម៌ទាំងឡាយ ជាអ្នកមានកំឡាំង មានសេចក្តីប្រឹងប្រែងដ៏មាំមួន មិនដាក់ធុរៈចោលក្នុងកុសលធម៌ទាំងឡាយ ក៏យ៉ាងនោះដែរ ។ អរិយសាវក មានសេចក្តីព្យាយាមទុកជាពួកពល រមែងលះបង់នូវអកុសលធម៌ បំពេញនូវកុសលធម៌ លះបង់នូវអំពើមានទោស បំពេញនូវអំពើមិនមានទោស រមែងរក្សាខ្លួនឲ្យបរិសុទ្ធ ។

ឥមិនា បញ្ចមេន សទ្ធម្មេន សមន្នាគតោ ហោតិ ។ សេយ្យថាបិ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ ទោវារិកោ ហោតិ បណ្ឌិតោ ព្យត្តោ មេធាវី អញ្ញាតានំ និវារេតា ញាតានំ បវេសេតា អព្ភន្តរានំ គុត្តិយា ពាហិរានំ បដិឃាតាយ ឯវមេវ ខោ ភិក្ខវេ អរិយ-សាវកោ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតម្បិ ចិរភាសិតម្បិ សរិតា អនុស្សរិតា ។ សតិទោវារិកោ ភិក្ខវេ អរិយសាវកោ អកុសលំ បជហតិ កុសលំ ភាវេតិ សាវជ្ជំ បជហតិ អនវជ្ជំ ភាវេតិ សុទ្ធំ អត្តានំ បរិហរតិ ។ ឥមិនា ឆដ្ឋេន សទ្ធម្មេន សមន្នាគតោ ហោតិ ។ សេយ្យថាបិ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ បាការោ ហោតិ ឧច្ចោ ចេវ វិត្ថតោ ច វាសនលេបនសម្បន្នោ ច អព្ភន្តរានំ គុត្តិយា ពាហិរានំ បដិឃាតាយ ឯវមេវ ខោ ភិក្ខវេ អរិយសាវកោ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ។

អរិយសាវក ជាអ្នកប្រកបដោយព្រះសទ្ធម្មទី ៤ នេះ ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេច ជាទីបំផុតនៃដែន មានឆ្មាំទ្វារ ជាបណ្ឌិតឈ្លាសវៃមានប្រាជ្ញា ឃាត់នូវពួកជនដែលមិនស្គាល់ បើកឲ្យពួកជនដែលស្គាល់ឲ្យចូល ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ជាអ្នកមានសតិ ប្រកបដោយសតិ នឹងភាពជាបុគ្គលមានប្រាជ្ញាចាស់ក្លាដ៏ក្រៃលែង ជាអ្នករលឹកបានរឿយ ៗ នូវការងារដែលបានធ្វើយូរហើយក្តី និយាយយូរហើយក្តី ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកមានសតិ ទុកជាឆ្មាំទ្វារ រមែងលះបង់នូវអកុសល ចំរើននូវកុសល លះបង់នូវអំពើមានទោស ចំរើននូវអំពើមិនមានទោស រមែងរក្សាខ្លួនឲ្យបរិសុទ្ធ ។ អរិយសាវក ជាអ្នកប្រកបដោយព្រះសទ្ធម្មទី ៥ នេះ ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេច ជាទីបំផុតនៃដែន មានកំពែងដ៏ខ្ពស់ផង ក្រាស់ផង បរិបូណ៌ដោយគ្រឿងអប់នឹងគ្រឿងលាបផង ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញាជាគ្រឿងចាក់ធ្លុះ យល់នូវសេចក្តីចំរើននឹងសេចក្តីវិនាស ជាប្រាជ្ញាជាគ្រឿងចាក់ធ្លុះដ៏ប្រសើរ ដល់នូវសេចក្តីអស់ទៅនៃទុក្ខដោយប្រពៃ ក៏យ៉ាងនោះដែរ ។

បញ្ញាវុធេន សម្បន្នោ ភិក្ខវេ អរិយសាវកោ អកុសលំ បជហតិ កុសលំ ភាវេតិ សាវជ្ជំ បជហតិ អនវជ្ជំ ភាវេតិ សុទ្ធំ អត្តានំ បរិហរតិ ។ ឥមិនា សត្តមេន សទ្ធម្មេន សមន្នាគតោ ហោតិ ។ ឥមេហិ សត្តហិ សទ្ធម្មេហិ សមន្នាគតោ ហោតិ ។ កតមេសំ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ។ សេយ្យថាបិ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ ពហុំ តិណកដ្ឋោទកំ សន្និចិតំ ហោតិ អព្ភន្តរានំ រតិយា អបរិតស្សាយ ផាសុវិហារាយ ពាហិរានំ បដិឃាតាយ ឯវមេវ ខោ ភិក្ខវេ អរិយសាវកោ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ អត្តនោ រតិយា អបរិតស្សាយ ផាសុវិហារាយ ឱក្កមនាយ និព្ពានស្ស ។

ម្នាលភិក្ខុទាំងឡាយ អរិយសាវក បរិបូណ៌ដោយប្រាជ្ញា ទុកជាគ្រឿងអប់ទឹងគ្រឿងលាប រមែងលះបង់នូវអកុសល ចំរើននូវកុសល លះបង់នូវអំពើដែលមានទោស ចំរើននូវអំពើដែលមិនមានទោស រក្សាខ្លួនឲ្យបរិសុទ្ធ ។ អរិយសាវក ជាអ្នកប្រកបដោយព្រះសទ្ធម្មទី ៧ នេះ ។ អរិយសាវក ជាអ្នកប្រកបដោយព្រះសទ្ធម្មទាំង ៧ យ៉ាងនេះឯង ។ ( អរិយសាវក ) ជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវឈានទាំង ៤ ដែលប្រព្រឹត្តទៅ ក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅសប្បាយ ក្នុងបច្ចុប្បន្ន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេច ជាទីបំផុតនៃដែន មានស្មៅទឹងឧស ទឹងទឹកដ៏ច្រើន ដែលសន្សំទុក ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយដល់ពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីឈមចុះកាន់ព្រះនិព្វាន ចំពោះខ្លួន យ៉ាងនោះដែរ ។

សេយ្យថាបិ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ ពហុំ
សាលិយវកំ សន្និចិតំ ហោតិ អព្ភន្តរានំ រតិយា
អបរិតស្សាយ ផាសុវិហារាយ ពាហិរានំ បដិឃាតាយ
ឯវមេវ ខោ ភិក្ខវេ អរិយសាវកោ វិតក្កវិចារានំ
វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ
វិហរតិ អត្តនោ រតិយា អបរិតស្សាយ ផាសុវិហារាយ
ឱក្កមនាយ និព្វានស្ស ។ សេយ្យថាបិ ភិក្ខវេ
រញ្ញោ បច្ចន្តិមេ នគរេ ពហុំ តិលមុគ្គមាសាបរណ្ណំ
សន្និចិតំ ហោតិ អព្ភន្តរានំ រតិយា អបរិតស្សាយ
ផាសុវិហារាយ ពាហិរានំ បដិឃាតាយ ឯវមេវ ខោ
ភិក្ខវេ អរិយសាវកោ បីតិយា ច វិរាគា ។ បេ ។
តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ អត្តនោ រតិយា
អបរិតស្សាយ ផាសុវិហារាយ ឱក្កមនាយ និព្វានស្ស ។

ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេច ជាទីបំផុតនៃដែន មានស្រូវខ្សាយ ស្រូវដំណើបដ៏ច្រើន ដែលគេសន្សំទុក ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយដល់ពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីឈមចុះកាន់ព្រះនិព្វាន ចំពោះខ្លួន ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេច ជាទីបំផុតនៃដែន មានល្ង សណ្តែក និងអបរណ្ណជាតិដ៏ច្រើន ដែលគេសន្សំទុក ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដល់ពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ព្រោះនឿយណាយចាកបីតិផង ។ បេ ។ ចូលកាន់តតិយជ្ឈាន ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីឈមចុះកាន់ព្រះនិព្វាន ចំពោះខ្លួន ក៏យ៉ាងនោះដែរ ។

សេយ្យថាបិ ភិក្ខវេ រញ្ញោ បច្ចន្តិមេ នគរេ ពហុំ ភេសជ្ជំ សន្និចិតំ ហោតិ សេយ្យថីទំ សប្បិ នវនីតំ តេលំ មធុ ផាណិតំ លោណំ អព្ភន្តរានំ រតិយា អបរិតស្សាយ ផាសុវិហារាយ ពាហិរានំ បដិឃាតាយ ឯវមេវ ខោ ភិក្ខវេ អរិយសាវកោ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អត្តនោ រតិយា អបរិតស្សាយ ផាសុវិហារាយ ឱក្កមនាយ និព្ពានស្ស ។ ឥមេសំ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ។ យតោ ខោ ភិក្ខវេ អរិយសាវកោ ឥមេហិ សត្តហិ សទ្ធម្មេហិ សមន្នាគតោ ហោតិ ឥមេសញ្ច ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អយំ វុច្ចតិ ភិក្ខវេ អរិយសាវកោ អករណីយោ មារស្ស អករណីយោ បាបិមតោតិ ។

# បណ្ណាសកាសង្គហិត មហាវគ្គ

ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេច ជាទីបំផុតនៃដែន មានភេសជ្ជៈដ៏ច្រើន ដែលគេសន្សំទុក គឺទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ អំបិល ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដល់ពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ព្រោះលះបង់នូវសុខផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីឈមចុះកាន់ព្រះនិព្វាន ចំពោះខ្លួន ក៏យ៉ាងនោះដែរ ។ អរិយសាវក ជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវឈានទាំង ៤ នេះ ដែលប្រព្រឹត្តទៅ ក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅសប្បាយក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ កាលណា អរិយសាវក ជាអ្នកប្រកបដោយព្រះសទ្ធម្មទាំង ៧ យ៉ាងនេះ ទាំងបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវឈានទាំង ៤ នេះ ដែលប្រព្រឹត្តទៅ ក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅសប្បាយ ក្នុងបច្ចុប្បន្ន ម្នាលភិក្ខុទាំងឡាយ នេះ តថាគតហៅថា អរិយសាវក ដែលមារមិនគប្បីធ្វើបាន មារមានចិត្តបាប មិនគប្បីធ្វើបានឡើយ ។

(៦៨) សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ
ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ
បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ សត្តហិ ។
ឥធ ភិក្ខវេ ភិក្ខុ ធម្មញ្ញូ ច ហោតិ អត្ថញ្ញូ ច
អត្តញ្ញូ ច មត្តញ្ញូ ច កាលញ្ញូ ច បរិសញ្ញូ ច
បុគ្គលបរោបរញ្ញូ ច ។ កថញ្ច ភិក្ខវេ ភិក្ខុ
ធម្មញ្ញូ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ធម្មំ ជានាតិ
សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ
ជាតកំ អព្ភុតធម្មំ វេទល្លំ ។ នោ ចេ ភិក្ខវេ
ភិក្ខុ ធម្មំ ជានេយ្យ សុត្តំ . . . វេទល្លំ នយិទំ
ធម្មញ្ញូតិ វុច្ចេយ្យ យស្មា ច ខោ ភិក្ខវេ ភិក្ខុ
ធម្មំ ជានាតិ សុត្តំ . . . វេទល្លំ តស្មា ធម្មញ្ញូតិ វុច្ចតិ
ឥតិ ធម្មញ្ញូ ។ អត្ថញ្ញូ ច កថំ ហោតិ ។
ឥធ ភិក្ខវេ ភិក្ខុ តស្ស តស្សេវ ភាសិតស្ស
អត្ថំ ជានាតិ អយំ ឥមស្ស ភាសិតស្ស អត្ថោ
អយំ ឥមស្ស ភាសិតស្ស អត្ថោតិ ។ នោ ចេ
ភិក្ខវេ ភិក្ខុ តស្ស តស្សេវ ភាសិតស្ស អត្ថំ ជានេយ្យ

(៦៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា ។ បេ ។ ជាបុញ្ញក្ខេត្ត ដ៏ប្រសើររបស់សត្វលោក ។ ប្រកបដោយធម៌ ៧ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកដឹងនូវធម៌ ១ ដឹងនូវអត្ថ (របស់ធម៌) ១ ដឹងខ្លួន ១ ដឹងនូវប្រមាណក្នុង (ភោជន) ១ ដឹងកាលគួរ ១ ដឹងបរិស័ទ ១ ដឹងបុគ្គលដែលគួរគប់រក ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកដឹងនូវធម៌ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងនូវធម៌ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុ មិនគប្បីដឹងនូវធម៌គឺ សុត្តៈ ... វេទល្លៈទេ តថាគត មិនគប្បីហៅថា ជាអ្នកដឹងនូវធម៌ ក្នុងបទនេះឡើយ ម្នាលភិក្ខុទាំងឡាយ ចំណែកឯភិក្ខុ ដឹងនូវធម៌គឺ សុត្តៈ ... វេទល្លៈ ព្រោះហេតុនោះ ទើបតថាគតហៅថា អ្នកដឹងនូវធម៌ ភិក្ខុជាអ្នកដឹងនូវធម៌ យ៉ាងនេះឯង ។ ចុះភិក្ខុអ្នកដឹងនូវអត្ថ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងនូវអត្ថនៃភាសិតនោះ ៗ ថា នេះជាអត្ថ របស់ភាសិតនេះ នេះជាអត្ថ របស់ភាសិតនេះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុ មិនដឹងនូវអត្ថ នៃភាសិតនោះ ៗ ថា

អយំ ឥមស្ស ភាសិតស្ស អត្ថោ អយំ ឥមស្ស ភាសិតស្ស អត្ថោតិ ន យិន អត្ថញ្ញូតិ វុច្ចេយ្យ យស្មា ច ខោ ភិក្ខវេ ភិក្ខុ តស្ស តស្សេវ ភាសិតស្ស អត្ថំ ជានាតិ អយំ ឥមស្ស ភាសិតស្ស អត្ថោ អយំ ឥមស្ស ភាសិតស្ស អត្ថោតិ តស្មា អត្ថញ្ញូតិ វុច្ចតិ ឥតិ ធម្មញ្ញូ អត្ថញ្ញូ ។ អត្តញ្ញូ ច កថំ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ អត្តានំ ជានាតិ ឯត្តកោម្ហិ សទ្ធាយ សីលេន សុតេន ចាគេន បញ្ញាយ បដិភាណេនាតិ ។ នោ ចេ ភិក្ខវេ ភិក្ខុ អត្តានំ ជានេយ្យ ឯត្តកោម្ហិ សទ្ធាយ សីលេន សុតេន ចាគេន បញ្ញាយ បដិភាណេនាតិ ន យិន អត្តញ្ញូតិ វុច្ចេយ្យ យស្មា ច ខោ ភិក្ខវេ ភិក្ខុ អត្តានំ ជានាតិ ឯត្តកោម្ហិ សទ្ធាយ សីលេន សុតេន ចាគេន បញ្ញាយ បដិភាណេនាតិ តស្មា អត្តញ្ញូតិ វុច្ចតិ ឥតិ ធម្មញ្ញូ អត្ថញ្ញូ អត្តញ្ញូ ។ មត្តញ្ញូ ច កថំ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ មត្តំ ជានាតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ បដិគ្គហណាយ

នេះជាអត្ថ របស់ភាសិតនេះ នេះជាអត្ថ របស់ភាសិតនេះទេ តថាគត មិនហៅថា អ្នកដឹងនូវអត្ថ ក្នុងបទនេះឡើយ ម្នាលភិក្ខុទាំងឡាយ ចំណែកឯភិក្ខុ ដឹងនូវអត្ថរបស់ភាសិតនុ៎ះៗ ថា នេះជាអត្ថរបស់ភាសិតនេះ នេះជាអត្ថរបស់ភាសិតនេះ ព្រោះហេតុនោះ ទើបតថាគតហៅថា អ្នកដឹងនូវអត្ថ អ្នកដឹងនូវធម៌ ដឹងនូវអត្ថ យ៉ាងនេះឯង ។ ចុះភិក្ខុអ្នកដឹងខ្លួន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងខ្លួនថា អាត្មាអញជាអ្នកប្រកបដោយសទ្ធា មានសីលៈ សុតៈ ចាគៈ បញ្ញា បដិភាណៈ ត្រឹមប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុ មិនដឹងខ្លួនថា អាត្មាអញជាអ្នកប្រកបដោយសទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា បដិភាណៈ ត្រឹមប៉ុណ្ណោះទេ តថាគត មិនហៅថា អ្នកដឹងខ្លួន ក្នុងបទនេះឡើយ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងភិក្ខុ អ្នកដឹងខ្លួនថា អាត្មាអញ ជាអ្នកប្រកបដោយសទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា បដិភាណៈ ត្រឹមប៉ុណ្ណោះ ព្រោះហេតុនោះ ទើបតថាគតហៅថា អ្នកដឹងខ្លួន ភិក្ខុអ្នកដឹងធម៌ ដឹងអត្ថ ដឹងខ្លួន យ៉ាងនេះឯង ។ ចុះភិក្ខុ អ្នកដឹងប្រមាណ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងប្រមាណក្នុងការទទួលនូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ ។

នោ ចេ ភិក្ខវេ ភិក្ខុ មត្តំ ជានេយ្យ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ បដិគ្គហណាយ ន យិទំ មត្តញ្ញូតិ វទេយ្យុំ យស្មា ច ខោ ភិក្ខវេ ភិក្ខុ មត្តំ ជានាតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ បដិគ្គហណាយ តស្មា មត្តញ្ញូតិ វុច្ចតិ ឥតិ ធម្មញ្ញូ អត្ថញ្ញូ អត្តញ្ញូ មត្តញ្ញូ ។ កាលញ្ញូ ច កថំ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ កាលំ ជានាតិ អយំ កាលោ ឧទ្ទេសស្ស អយំ កាលោ បរិបុច្ឆាយ អយំ កាលោ យោគស្ស អយំ កាលោ បដិសល្លានាយាតិ ។ នោ ចេ ភិក្ខវេ ភិក្ខុ កាលំ ជានេយ្យ អយំ កាលោ ឧទ្ទេសស្ស អយំ កាលោ បរិបុច្ឆាយ អយំ កាលោ យោគស្ស អយំ កាលោ បដិសល្លានាយាតិ ន យិទំ កាលញ្ញូតិ វទេយ្យុំ យស្មា ច ខោ ភិក្ខវេ ភិក្ខុ កាលំ ជានាតិ អយំ កាលោ ឧទ្ទេសស្ស អយំ កាលោ បរិបុច្ឆាយ អយំ កាលោ យោគស្ស អយំ កាលោ បដិសល្លានាយាតិ តស្មា កាលញ្ញូតិ វុច្ចតិ

ម្នាលភិក្ខុទាំងឡាយ បើភិក្ខុ មិនដឹងប្រមាណ ក្នុងការទទួលចីវរបិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារទេ តថាគត មិនហៅថា អ្នកដឹងប្រមាណ ក្នុងបទនេះឡើយ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងភិក្ខុ ដឹងប្រមាណ ក្នុងការទទួល ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ ព្រោះហេតុនោះ ទើបតថាគតហៅថា អ្នកដឹងប្រមាណ ភិក្ខុអ្នកដឹងធម៌ ដឹងអត្ថ ដឹងខ្លួន ដឹងប្រមាណ យ៉ាងនេះឯង ។ ចុះភិក្ខុអ្នកដឹងនូវកាល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងនូវកាលថា នេះជាកាលគួររៀនបាលី នេះជាកាលគួរសាកសួរ នេះជាកាលគួរប្រកប នេះជាកាលគួរពួនសម្ងំ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុ មិនដឹងនូវកាលថា នេះជាកាលគួររៀនបាលី នេះជាកាលគួរសាកសួរ នេះជាកាលគួរប្រកប នេះជាកាលគួរពួនសម្ងំទេ តថាគតមិនហៅថា អ្នកដឹងកាល ក្នុងបទនេះឡើយ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងភិក្ខុអ្នកដឹងនូវកាលថា នេះជាកាលគួររៀនបាលី នេះជាកាលគួរសាកសួរ នេះជាកាលគួរប្រកប នេះជាកាលគួរពួនសម្ងំ ព្រោះហេតុនោះ ទើបតថាគតហៅថា

ឥតិ ធម្មញ្ញូ អត្ថញ្ញូ អត្តញ្ញូ មត្តញ្ញូ កាលញ្ញូ ។ បរិសញ្ញូ ច កថំ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ បរិសំ ជានាតិ អយំ ខត្តិយបរិសា អយំ ព្រាហ្មណបរិសា អយំ គហបតិបរិសា អយំ សមណបរិសា តត្ថ ឯវំ ឧបសង្កមិតព្វំ ឯវំ ឋាតព្វំ ឯវំ កាតព្វំ ឯវំ និសីទិតព្វំ ឯវំ ភាសិតព្វំ ឯវំ តុណ្ហីភវិតព្វន្តិ ។ នោ ចេ ភិក្ខវេ ភិក្ខុ បរិសំ ជានេយ្យ អយំ ខត្តិយបរិសា ... ឯវំ តុណ្ហីភវិតព្វន្តិ ន យិទំ បរិសញ្ញូតិ វុច្ចេយ្យ យស្មា ច ខោ ភិក្ខវេ ភិក្ខុ បរិសំ ជានាតិ អយំ ខត្តិយបរិសា ... ឯវំ តុណ្ហីភវិតព្វន្តិ តស្មា បរិសញ្ញូតិ វុច្ចតិ ឥតិ ធម្មញ្ញូ អត្ថញ្ញូ អត្តញ្ញូ មត្តញ្ញូ កាលញ្ញូ បរិសញ្ញូ ។ បុគ្គលបរោបរញ្ញូ ច កថំ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ ទ្វយេន បុគ្គលា វិទិតា ហោន្តិ ទ្វេ បុគ្គលា ឯកោ អរិយានំ ទស្សនកាមោ ឯកោ អរិយានំ ន ទស្សនកាមោ ។ យ្វាយំ បុគ្គលោ អរិយានំ ន ទស្សនកាមោ ឯវំ សោ តេន តេន[1] គារយ្ហោ ។

១ ឱ. ម. តេនង្គេន ។

បណ្ណាសកាសង្គហិត មហាវគ្គ

អ្នកដឹងនូវកាល ភិក្ខុអ្នកដឹងធម៌ ដឹងអត្ថ ដឹងខ្លួន ដឹងប្រមាណ ដឹងកាលយ៉ាងនេះឯង ៗ ចុះភិក្ខុអ្នកដឹងបរិសទ្យ តើដូចម្តេច ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងបរិសទ្យថា នេះជាខត្តិយ-បរិសទ្យ នេះជាព្រាហ្មណបរិសទ្យ នេះជាគហបតិបរិសទ្យ នេះជាសមណបរិសទ្យ អាត្មាអញ គួរចូលទៅរកយ៉ាងនេះ គួរឈរយ៉ាងនេះ គួរធ្វើយ៉ាងនេះ គួរអង្គុយយ៉ាងនេះ គួរនិយាយយ៉ាងនេះ គួរស្ងៀមយ៉ាងនេះ ចំពោះបរិសទ្យទាំងនុ៎ះ ៗ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនដឹងបរិសទ្យថា នេះជាខត្តិយបរិសទ្យ . . . គួរស្ងៀមយ៉ាងនេះ តថាគតមិនហៅថា អ្នកដឹងបរិសទ្យ ក្នុងបទនេះឡើយ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងភិក្ខុ ដឹងបរិសទ្យថា នេះជាខត្តិយបរិសទ្យ . . . គួរស្ងៀមយ៉ាងនេះ ព្រោះហេតុនោះ ទើបតថាគតហៅថា អ្នកដឹងបរិ-សទ្យ ភិក្ខុអ្នកដឹងធម៌ ដឹងអត្ថ ដឹងខ្លួន ដឹងប្រមាណ ដឹងកាល ដឹងបរិសទ្យ យ៉ាងនេះឯង ៗ ចុះភិក្ខុ ដឹងបុគ្គលដែលគួរគប់រក តើដូចម្តេច ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងដឹងច្បាស់នូវបុគ្គលពីរពួក ឯបុគ្គលពីរពួកគឺ មួយពួក ជាអ្នកចង់ចួបប្រទះពួកព្រះអរិយៈ មួយពួក មិនចង់ចួបប្រទះពួកព្រះអរិយៈ ។ បុគ្គលណា មិនចង់ចួបប្រទះពួកព្រះអរិយៈ បុគ្គលនោះ គេគប្បីតិះដៀល ដោយហេតុនោះ ៗ យ៉ាងនេះៗ

យ្វាយំ បុគ្គលោ អរិយានំ ទស្សនកាមោ ឯវំ សោ តេន តេន បាសំសោ ។ ទ្វេ បុគ្គលា អរិយានំ ទស្សនកាមា ឯកោ សទ្ធម្មំ សោតុកាមោ ឯកោ សទ្ធម្មំ ន សោតុកាមោ ។ យ្វាយំ បុគ្គលោ សទ្ធម្មំ ន សោតុកាមោ ឯវំ សោ តេន តេន គារយ្ហោ ។ យ្វាយំ បុគ្គលោ សទ្ធម្មំ សោតុកាមោ ឯវំ សោ តេន តេន បាសំសោ ។ ទ្វេ បុគ្គលា សទ្ធម្មំ សោតុកាមា ឯកោ ឱហិតសោតោ ធម្មំ សុណាតិ ឯកោ អនោហិតសោតោ ធម្មំ សុណាតិ ។ យ្វាយំ បុគ្គលោ អនោហិតសោតោ ធម្មំ សុណាតិ ឯវំ សោ តេន តេន គារយ្ហោ ។ យ្វាយំ បុគ្គលោ ឱហិតសោតោ ធម្មំ សុណាតិ ឯវំ សោ តេន តេន បាសំសោ ។ ទ្វេ បុគ្គលា ឱហិតសោតា ធម្មំ សុណន្តិ ឯកោ សុត្វា ធម្មំ ធារេតិ ឯកោ សុត្វា ធម្មំ ន ធារេតិ ។ យ្វាយំ បុគ្គលោ សុត្វា ធម្មំ ន ធារេតិ ឯវំ សោ តេន តេន គារយ្ហោ ។ យ្វាយំ បុគ្គលោ សុត្វា ធម្មំ ធារេតិ ឯវំ សោ តេន តេន បាសំសោ ។

បុគ្គលណា ចង់ជួបប្រទះពួកព្រះអរិយៈ បុគ្គលនោះ គេគប្បីសរសើរ ដោយហេតុនោះ ។ យ៉ាងនេះ ។ បុគ្គលពីរពួក ចង់ជួបប្រទះពួកព្រះអរិយៈគឺ មួយពួក ចង់ស្តាប់ព្រះសទ្ធម្ម មួយពួក មិនចង់ស្តាប់ព្រះសទ្ធម្ម ។ បុគ្គលណា មិនចង់ស្តាប់ព្រះសទ្ធម្ម បុគ្គលនោះ គេគប្បីតិះដៀល ដោយហេតុនោះ ។ យ៉ាងនេះ ។ បុគ្គលណា ចង់ស្តាប់ព្រះសទ្ធម្ម បុគ្គលនោះ គេគប្បីសរសើរ ដោយហេតុនោះ ។ យ៉ាងនេះ ។ បុគ្គលពីរពួក ចង់ស្តាប់នូវព្រះសទ្ធម្ម គឺបុគ្គលមួយពួក មានត្រចៀក ផ្ទៀងស្តាប់នូវធម៌ បុគ្គលមួយពួក មានត្រចៀក មិនផ្ទៀងស្តាប់នូវធម៌ ។ បុគ្គលណា មានត្រចៀក មិនផ្ទៀងស្តាប់នូវធម៌ បុគ្គលនោះ គេគប្បីតិះដៀល ដោយហេតុនោះ ។ យ៉ាងនេះ ។ បុគ្គលណា មានត្រចៀក ផ្ទៀងស្តាប់នូវធម៌ បុគ្គលនោះ គេគប្បីសរសើរ ដោយហេតុនោះ ។ យ៉ាងនេះ ។ បុគ្គលពីរពួក មានត្រចៀក ផ្ទៀងស្តាប់នូវធម៌ គឺមួយពួក ស្តាប់ហើយចាំទុកនូវធម៌ មួយពួក ស្តាប់ហើយមិនចាំទុកនូវធម៌ ។ បុគ្គលណា ស្តាប់ហើយ មិនចាំទុកនូវធម៌ បុគ្គលនោះ គេគប្បីតិះដៀល ដោយហេតុនោះ ។ យ៉ាងនេះ ។ បុគ្គលណា ស្តាប់ហើយចាំទុកនូវធម៌ បុគ្គលនោះ គេគប្បីសរសើរ ដោយហេតុនោះ ។ យ៉ាងនេះ ។

ទ្វេ បុគ្គលា សុត្វា ធម្មំ ធារេន្តិ ឯកោ ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខតិ ឯកោ ធតានំ ធម្មានំ អត្ថំ ន ឧបបរិក្ខតិ ។ យោយំ បុគ្គលោ ធតានំ ធម្មានំ អត្ថំ ន ឧបបរិក្ខតិ ឯវំ សោ តេន តេន គារយ្ហោ ។ យោយំ បុគ្គលោ ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខតិ ឯវំ សោ តេន តេន បាសំសោ ។ ទេ បុគ្គលា ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខន្តិ ឯកោ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ឯកោ ន អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ។ យោយំ បុគ្គលោ ន អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ឯវំ សោ តេន តេន គារយ្ហោ ។ យោយំ បុគ្គលោ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ឯវំ សោ តេន តេន បាសំសោ ។ ទ្វេ បុគ្គលា អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នា ឯកោ អត្តហិតាយ បដិបន្នោ នោ បរហិតាយ

បុគ្គលពីរពួក ស្តាប់ហើយចាំទុកនូវធម៌គឺ មួយពួក ពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនចាំទុកហើយ មួយពួក មិនពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនចាំទុកហើយទេ ។ បុគ្គលណា មិនពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនចាំទុកហើយ បុគ្គលនោះ គេគប្បីតិះដៀល ដោយហេតុនោះៗ យ៉ាងនេះ ។ បុគ្គលណា ពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនចាំទុកហើយ បុគ្គលនោះ គេគប្បីសរសើរ ដោយហេតុនោះៗ យ៉ាងនេះ ។ បុគ្គលពីរពួក ពិចារណា នូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនចាំទុកហើយ គឺមួយពួក ដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយប្រតិបត្តិធម៌ ដ៏សមគួរដល់ធម៌ មួយពួក ដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយមិនប្រតិបត្តិធម៌ ដ៏សមគួរដល់ធម៌ ។ បុគ្គលណា ដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយមិនប្រតិបត្តិធម៌ ដ៏សមគួរដល់ធម៌ បុគ្គលនោះ គេគប្បីតិះដៀល ដោយហេតុនោះៗ យ៉ាងនេះ ។ បុគ្គលណា ដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយប្រតិបត្តិធម៌ ដ៏សមគួរដល់ធម៌ បុគ្គលនោះ គេគប្បីសរសើរ ដោយហេតុនោះៗ យ៉ាងនេះ ។ បុគ្គលពីរពួក ដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយប្រតិបត្តិធម៌ ដ៏សមគួរដល់ធម៌ គឺមួយពួក ប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន មិនប្រតិបត្តិ ដើម្បីប្រយោជន៍បុគ្គលដទៃ

ឯកោ អត្តហិតាយ ច បដិបន្នោ បរហិតាយ ច ។ យ្វាយំ បុគ្គលោ អត្តហិតាយ បដិបន្នោ នោ បរហិតាយ ឯវំ សោ តេន តេន គារយ្ហោ ។ យ្វាយំ បុគ្គលោ អត្តហិតាយ ច បដិបន្នោ បរហិតាយ ច ឯវំ សោ តេន តេន បាសំសោ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុនោ ទ្វយេន បុគ្គលា វិទិតា ហោន្តិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ បុគ្គលបរោបរញ្ញូ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

(៦៦) យស្មឹ ភិក្ខវេ សមយេ ទេវានំ តាវត្តឹសានំ បារិច្ឆត្តកោ កោវិឡារោ បណ្ឌុបលាសោ ហោតិ អត្តមនា ភិក្ខវេ ទេវា តាវត្តឹសា តស្មឹ សមយេ ហោន្តិ បណ្ឌុបលាសោ ទានិ បារិច្ឆត្តកោ កោវិឡារោ ន ចិរស្សេវទានិ សន្នបលាសោ(១) ភវិស្សតីតិ ។ យស្មឹ ភិក្ខវេ សមយេ ទេវានំ តាវត្តឹសានំ បារិច្ឆត្តកោ កោវិឡារោ សន្នបលាសោ ហោតិ

១. ម. បន្នបលាសោ ។ អយំ បាឋោ យុត្តតរោ ។

មួយពួក ប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍បុគ្គលដទៃផង ។ បុគ្គលណា ប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន មិនប្រតិបត្តិ ដើម្បីប្រយោជន៍បុគ្គលដទៃ បុគ្គលនោះ គេគប្បីតិះដៀល ដោយហេតុនោះ ៗ យ៉ាងនេះ ។ បុគ្គលណា ប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍បុគ្គលដទៃផង បុគ្គលនោះ គេគប្បីសរសើរ ដោយហេតុនោះ ៗ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដឹងច្បាស់បុគ្គលពីរពួក យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដឹងនូវបុគ្គលដែលគួរគប់រក យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាងនេះ ជាអ្នកគួរទទួលបច្ច័យ ដែលគេនាំមកបូជា ។ បេ ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។

( ៦៦ ) ម្នាលភិក្ខុទាំងឡាយ សម័យណា ដើមរលួសផ្អុង ជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស មានស្លឹកទុំជ្រុះហើយ ម្នាលភិក្ខុទាំងឡាយ សម័យនោះ ពួកទេវតាជាន់តាវត្តិង្ស ក៏មានចិត្តត្រេកអរថា ឥឡូវនេះ ដើមរលួសផ្អុង ជាបារិច្ឆត្តកព្រឹក្ស មានស្លឹកទុំជ្រុះហើយ មិនយូរប៉ុន្មាន មុខជានឹងមានស្លឹក ៧ ក្នុងកាលឥឡូវនេះ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា ដើមរលួសផ្អុង ជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស មានស្លឹក ៧

អត្តមនា ភិក្ខវេ ទេវា តាវត្តឹសា តស្មឹ សមយេ ហោន្តិ
បន្នបលាសោទានិ បារិច្ឆត្តកោ កោវិឡារោ ន
ចិរស្សេវទានិ ជាលកជាតោ ភវិស្សតីតិ ។ យស្មឹ
ភិក្ខវេ សមយេ ទេវានំ តាវត្តឹសានំ បារិច្ឆត្តកោ
កោវិឡារោ ជាលកជាតោ ហោតិ អត្តមនា
ភិក្ខវេ ទេវា តាវត្តឹសា តស្មឹ សមយេ ហោន្តិ
ជាលកជាតោទានិ បារិច្ឆត្តកោ កោវិឡារោ ន
ចិរស្សេវទានិ ខារកជាតោ ភវិស្សតីតិ ។ យស្មឹ
ភិក្ខវេ សមយេ ទេវានំ តាវត្តឹសានំ បារិច្ឆត្តកោ
កោវិឡារោ ខារកជាតោ ហោតិ អត្តមនា ភិក្ខវេ
ទេវា តាវត្តឹសា តស្មឹ សមយេ ហោន្តិ ខារកជាតោ-
ទានិ បារិច្ឆត្តកោ កោវិឡារោ ន ចិរស្សេវទានិ
កុឌុមលកជាតោ ភវិស្សតីតិ ។ យស្មឹ ភិក្ខវេ
សមយេ ទេវានំ តាវត្តឹសានំ បារិច្ឆត្តកោ កោវិឡារោ

ម្នាលភិក្ខុទាំងឡាយ សម័យនោះ ពួកទេវតាជាន់តាវត្តិង្ស ក៏មានចិត្តត្រេកអរថា ឥឡូវនេះ ដើមរលួសផ្អុង ជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស មានស្លឹក ៧ ហើយ មិនយូរប៉ុន្មាន មុខជានឹងមានកញ្ចុំនៃស្លឹកនឹងផ្កា ក្នុងកាលឥឡូវនេះ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា ដើមរលួសផ្អុង ជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស ជាឈើមានកញ្ចុំនៃស្លឹកនឹងផ្កា ម្នាលភិក្ខុទាំងឡាយ សម័យនោះ ពួកទេវតាជាន់តាវត្តិង្ស ក៏មានចិត្តត្រេកអរថា ឥឡូវនេះ ដើមរលួសផ្អុង ជាបារិច្ឆត្តកព្រឹក្ស មានកញ្ចុំនៃស្លឹកនឹងផ្កាកើតហើយ មិនយូរប៉ុន្មាន មុខជានឹងមានកញ្ចុំនៃស្លឹកនឹងផ្កា តាំងឡើងផ្សេងៗគ្នា ក្នុងកាលឥឡូវនេះ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា ដើមរលួសផ្អុង ជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស ជាឈើមានកញ្ចុំនៃស្លឹកនឹងផ្កា តាំងឡើងផ្សេងៗគ្នា ម្នាលភិក្ខុទាំងឡាយ សម័យនោះ ពួកទេវតាជាន់តាវត្តិង្ស មានចិត្តត្រេកអរថា ឥឡូវនេះ ដើមរលួសផ្អុង ជាបារិច្ឆត្តកព្រឹក្ស មានកញ្ចុំនៃស្លឹកនឹងផ្កា តាំងឡើងផ្សេងៗគ្នា កើតហើយ មិនយូរប៉ុន្មាន មុខជានឹងមានផ្កាក្រពុំកើតឡើង ក្នុងកាលឥឡូវនេះ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា ដើមរលួសផ្អុង ជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស

កុដុមលកជាតោ ហោតិ អត្តមនា ភិក្ខវេ ទេវា តាវត្តឹសា តស្មឹ សមយេ ហោន្តិ កុដុមលកជាតោទានិ បារិច្ឆត្តកោ កោវិឡារោ ន ចិរស្សេវទានិ កោកាសក-ជាតោ ភវិស្សតីតិ ។ យស្មឹ ភិក្ខវេ សមយេ ទេវានំ តាវត្តឹសានំ បារិច្ឆត្តកោ កោវិឡារោ កោកាសក-ជាតោ ហោតិ អត្តមនា ភិក្ខវេ ទេវា តាវត្តឹសា តស្មឹ សមយេ ហោន្តិ កោកាសកជាតោទានិ បារិច្ឆត្តកោ កោវិឡារោ ន ចិរស្សេវទានិ សព្វផាលិផុល្លោ ភវិស្សតីតិ ។ យស្មឹ ភិក្ខវេ សមយេ ទេវានំ តាវត្តឹសានំ បារិច្ឆត្តកោ កោវិឡារោ សព្វផាលិផុល្លោ ហោតិ អត្តមនា ភិក្ខវេ ទេវា តាវត្តឹសា បារិច្ឆត្តកស្ស កោវិឡារស្ស មូលេ ទិព្វេ ចត្តារោ មាសេ បញ្ចហិ កាមគុណេហិ សមប្បិតា សមង្គីភូតា បរិចារេន្តិ ។ សព្វផាលិផុល្លស្ស ខោ បន ភិក្ខវេ បារិច្ឆត្តកស្ស កោវិឡារស្ស សមន្តា បញ្ញាសយោជនានិ អាភាយ ផុដំ ហោតិ

ជាឈើមានផ្កាក្រពុំ កើតឡើង ម្នាលភិក្ខុទាំងឡាយ សម័យនោះ ពួកទេវតាជាន់តាវត្តិង្ស ក៏មានចិត្តត្រេកអរថា ឥឡូវនេះ ដើមរលួសផ្អុន ជាបារិច្ឆត្តកព្រឹក្ស មានផ្កាក្រពុំ កើតឡើងហើយ មិនយូរប៉ុន្មាន មុខជានឹងមានផ្កាបែកជាមាត់បាប ក្នុងកាលឥឡូវនេះ ៗ ម្នាលភិក្ខុទាំងឡាយ សម័យណា ដើមរលួសផ្អុន ជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស ជាឈើមានផ្កាបែកជាមាត់បាប កើតឡើង ម្នាលភិក្ខុទាំងឡាយ សម័យនោះ ពួកទេវតាជាន់តាវត្តិង្ស ក៏មានចិត្តត្រេកអរថា ឥឡូវនេះ ដើមរលួសផ្អុន ជាបារិច្ឆត្តកព្រឹក្ស មានផ្កាបែកជាមាត់បាប កើតហើយ មិនយូរប៉ុន្មាន មុខជានឹងមានផ្ការីកស្គុសស្គាយ ដោយអាការទាំងពួង ក្នុងកាលឥឡូវនេះ ៗ ម្នាលភិក្ខុទាំងឡាយ សម័យណា ដើមរលួសផ្អុន ជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស ជាឈើមានផ្ការីកស្គុសស្គាយ ដោយអាការទាំងពួង ម្នាលភិក្ខុទាំងឡាយ សម័យនោះ ពួកទេវតាជាន់តាវត្តិង្ស ក៏មានចិត្តត្រេកអរ ឆ្អែតស្កប់ស្កល់ បរិបូណ៌ ឲ្យគេបម្រើដោយកាមគុណទាំង ៥ ជាទិព្វ អស់ ៤ ខែ ទៀបគល់រលួសផ្អុន ជាបារិច្ឆត្តកព្រឹក្ស ៗ ម្នាលភិក្ខុទាំងឡាយ ដើមរលួសផ្អុន ជាបារិច្ឆត្តកព្រឹក្ស មានផ្ការីកស្គុសស្គាយ ដោយអាការទាំងពួង មានពន្លឺផ្សាយចេញទៅ ៥០ យោជន៍ ដោយជុំវិញ

អនុវាតំ យោជនសតំ គន្ធោ គច្ឆតិ អយមានុភាវោ បារិច្ឆត្តកស្ស កោវិឡារស្ស ។ ឯវមេវ ខោ ភិក្ខវេ យស្មឹ សមយេ អរិយសាវកោ អគារស្មា អនគារិយំ បព្វជ្ជាយ ចេតេតិ បណ្ឌុបលាសោ ភិក្ខវេ អរិយសាវកោ តស្មឹ សមយេ ហោតិ ទេវានំ តាវតឹសានំ បារិច្ឆត្តកោ កោវិឡារោ ។ យស្មឹ ភិក្ខវេ សមយេ អរិយសាវកោ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតោ ហោតិ សន្នបលាសោ ភិក្ខវេ អរិយសាវកោ តស្មឹ សមយេ ហោតិ ទេវានំ តាវតឹសានំ បារិច្ឆត្តកោ កោវិឡារោ ។ យស្មឹ ភិក្ខវេ សមយេ អរិយសាវកោ វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ជាលកជាតោ ភិក្ខវេ អរិយសាវកោ តស្មឹ សមយេ ហោតិ ទេវានំ តាវតឹសានំ បារិច្ឆត្តកោ កោវិឡារោ ។ យស្មឹ ភិក្ខវេ សមយេ អរិយសាវកោ វិតក្កវិចារានំ វូបសមា ។បេ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ខារកជាតោ ភិក្ខវេ អរិយសាវកោ តស្មឹ សមយេ ហោតិ ទេវានំ តាវតឹសានំ បារិច្ឆត្តកោ កោវិឡារោ ។

ក្លិនផ្សាយទៅ បណ្តោយខ្យល់ ១០០ យោជន៍ នេះជាអានុភាពនៃដើមរលួសផ្អុង ជាបារិច្ឆត្តកព្រឹក្ស ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវកគិត ដើម្បីចេញចាកផ្ទះ បួសទៅកាន់ផ្នួស ម្នាលភិក្ខុទាំងឡាយ សម័យនោះ អរិយសាវក ដូចជាដើមរលួសផ្អុង ជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស ដែលមានស្លឹកទុំហើយ យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយ-សាវក កោរសក់និងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ ហើយចេញចាកផ្ទះ បួសទៅកាន់ផ្នួស ម្នាលភិក្ខុទាំងឡាយ សម័យនោះ អរិយសាវក ដូចជាដើមរលួសផ្អុង ជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស ដែលមានស្លឹក៧ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវក ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ម្នាលភិក្ខុទាំងឡាយ សម័យនោះ អរិយសាវក ដូចជាដើមរលួសផ្អុង ជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស ដែលមានកញ្ចុំនៃស្លឹកនិងផ្កា ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវក ព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ម្នាលភិក្ខុទាំងឡាយ សម័យនោះ អរិយសាវក ដូចជាដើមរលួសផ្អុង ជាបារិច្ឆត្តកព្រឹក្សរបស់ពួកទេវតាជាន់តាវត្តិង្ស ដែលមានស្លឹកនិងផ្កា តាំងឡើងផ្សេង ៗ គ្នា ។

យស្មឹ ភិក្ខវេ សមយេ អរិយសាវកោ បីតិយា ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ កុឌុមលកជាតោ ភិក្ខវេ អរិយសាវកោ តស្មឹ សមយេ ហោតិ ទេវានំ តាវត្តឹសានំ បារិច្ឆត្តកោ កោវិឡារោ ។ យស្មឹ ភិក្ខវេ សមយេ អរិយសាវកោ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ កោរកជាតោ ភិក្ខវេ អរិយសាវកោ តស្មឹ សមយេ ហោតិ ទេវានំ តាវត្តឹសានំ បារិច្ឆត្តកោ កោវិឡារោ ។ យស្មឹ ភិក្ខវេ សមយេ អរិយសាវកោ អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ សព្ពផាលិផុល្លោ ភិក្ខវេ អរិយសាវកោ តស្មឹ សមយេ ហោតិ ទេវានំ តាវត្តឹសានំ បារិច្ឆត្តកោ កោវិឡារោ ។ តស្មឹ ភិក្ខវេ សមយេ ភុម្មា ទេវា សទ្ទមនុស្សាវេន្តិ ឯសោ ឥត្ថន្នាមោ អាយស្មា ឥត្ថន្នាមស្ស អាយស្មតោ សទ្ធិវិហារិកោ[1] អមុកម្ហា គាមា វា និគមា វា អគារស្មា អនគារិយំ បព្ពជិតោ

---

១ ឱ. ម. សទ្ធិវិហារី ។

ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវក ព្រោះនឿយណាយ ចាកបីតិផង ។បេ។ ចូលកាន់តតិយជ្ឈាន ម្នាលភិក្ខុទាំងឡាយ សម័យនោះ អរិយសាវក ដូចជាដើមរលួសផ្អុំ ជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស ដែលមានផ្កាក្រពុំកើតហើយ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវក ព្រោះលះបង់នូវសុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ម្នាលភិក្ខុទាំងឡាយ សម័យនោះ អរិយសាវក ដូចជាដើមរលួសផ្អុំ ជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស ដែលមានផ្កាបែកជាមាត់ចាប កើតហើយ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវក ធ្វើឲ្យជាក់ច្បាស់ ។បេ។ ព្រោះអស់អាសវៈទាំងឡាយ ម្នាលភិក្ខុទាំងឡាយ សម័យនោះ អរិយសាវក ដូចជាដើមរលួសផ្អុំ ជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស ដែលមានផ្ការីកស្គុសស្គាយ ដោយអាការទាំងពួង ។ ម្នាលភិក្ខុទាំងឡាយ សម័យនោះ ភុម្មទេវតាទាំងឡាយ ក៏ញុំាងសំឡេងឲ្យលាន់ឮឡើងថា អរិយសាវក ដ៏មានអាយុ ឈ្មោះនេះ ជាសទ្ធិវិហារិករបស់លោក ដ៏មានអាយុ ឈ្មោះនេះ ចេញចាកផ្ទះដែលតាំងនៅក្នុងស្រុក ឬ និគមឯណោះ ហើយចូលមកកាន់ផ្នួស

អាសវានំ ខយា ។បេ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។ ភុម្មានំ ទេវានំ សទ្ទំ សុត្វា ចាតុម្មហា-រាជិកា ទេវា... តាវតិំសា ទេវា... យាមា ទេវា... តុសិតា ទេវា... និម្មានរតី ទេវា... បរនិម្មិតវសវត្តី ទេវា... ព្រហ្មកាយិកា ទេវា សទ្ទមនុស្សាវេសុំ ឯសោ ឥត្ថន្នាមោ អាយស្មា ឥត្ថន្នាមស្ស អាយស្មតោ សទ្ធិវិហារិកោ អមុកម្ហា គាមា វា និគមា វា អគារស្មា អនគារិយំ បព្វជិតោ អាសវានំ ខយា ។បេ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។ ឥតិហ តេន ខណេន តេន មុហុត្តេន យាវ ព្រហ្មលោកា សទ្ទោ អព្ភុគ្គច្ឆិ អយមានុភាវោ ខីណាសវស្ស ភិក្ខុនោតិ ។

(៦៧) អថខោ អាយស្មតោ សារីបុត្តស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ កិន្នុ ខោ ភិក្ខុ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរន្តោ អកុសលំ បជហេយ្យ កុសលំ ភាវេយ្យាតិ ។ អថខោ អាយស្មតោ សារីបុត្តស្ស ឯតទហោសិ សត្ថារំ ខោ ភិក្ខុ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរន្តោ

បានធ្វើឲ្យជាក់ច្បាស់ ។ បេ ។ ព្រោះអស់អាសវៈទាំងឡាយ ។ ពួកទេវតាជាន់ចាតុម្មហារាជិកៈ ឮនូវសំឡេងនៃភុម្មទេវតាទាំងឡាយ ... ពួកទេវតាជាន់តាវត្តិង្ស ... ពួកទេវតាជាន់យាមៈ ... ពួកទេវតាជាន់តុសិត ... ពួកទេវតាជាន់និម្មានរតី ... ពួកទេវតាជាន់បរនិម្មិត-វសវត្តី ... ពួកទេវតាជាន់ព្រហ្មកាយិកៈ ញុំាងសំឡេងឲ្យលាន់ឮឡើងថា អរិយសាវក ដ៏មានអាយុ ឈ្មោះនេះ ជាសទ្ធិវិហារិករបស់លោកដ៏មានអាយុ ឈ្មោះនេះ ចេញចាកផ្ទះ ដែលតាំងនៅក្នុងស្រុក ឬនិគមឯណោះ ហើយបួសមកកាន់ផ្នួស បានធ្វើឲ្យជាក់ច្បាស់ ។ បេ ។ ព្រោះអស់អាសវៈទាំងឡាយ ។ ព្រោះហេតុនោះ សំឡេងក៏ឮផ្សាយឡើងទៅ ដរាបដល់ព្រហ្មលោក ក្នុងខណៈនោះ មួយរំពេចនោះថា នេះជាអានុភាពរបស់ភិក្ខុ ជាព្រះខីណាស្រព ។

( ៦៧ ) គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ នៅក្នុងទីស្ងាត់ ពួនសម្ងំ ក៏មានចិត្តត្រិះរិះ កើតឡើងយ៉ាងនេះថា ភិក្ខុកាលធ្វើសក្ការៈ គោរព អាស្រ័យអ្វីហ្ន៎ ទើបលះបង់នូវអកុសល ចំរើននូវកុសលបាន ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុកាលធ្វើសក្ការៈ គោរព អាស្រ័យព្រះសាស្តា

អកុសលំ បជហេយ្យ កុសលំ ភាវេយ្យ ធម្មំ ខោ... សង្ឃំ ខោ... សិក្ខំ ខោ... សមាធឹ ខោ... អប្បមាទំ ខោ... បដិសន្ថារំ ខោ ភិក្ខុ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរន្តោ អកុសលំ បជហេយ្យ កុសលំ ភាវេយ្យាតិ ។ អថខោ អាយស្មតោ សារីបុត្តស្ស ឯតទហោសិ ឥមេ ខោ មេ ធម្មា បរិសុទ្ធា បរិយោទាតា យន្នូនាហំ ឥមេ ធម្មេ គន្ត្វា(១) ភគវតោ អារោចេយ្យំ ឯវំ មេ ឥមេ ធម្មា បរិសុទ្ធា ចេវ ភវិស្សន្តិ បរិបូរា ច ។ សេយ្យថាបិ នាម បុរិសោ សុវណ្ណនិក្ខំ អធិគច្ឆេយ្យ បរិសុទ្ធំ បរិយោទាតំ តស្ស ឯវមស្ស អយំ ខោ មេ សុវណ្ណនិក្ខោ បរិសុទ្ធោ បរិយោទាតោ យន្នូនាហំ ឥមំ សុវណ្ណនិក្ខំ គន្ត្វា(២) កម្មារានំ ទស្សេយ្យំ ឯវំ មេ អយំ សុវណ្ណនិក្ខោ សកម្មារគតោ បរិសុទ្ធោ ចេវ ភវិស្សតិ បរិបូរោ ច ។ ឯវមេវ មេ ឥមេ ធម្មា បរិសុទ្ធា បរិយោទាតា យន្នូនាហំ ឥមេ ធម្មេ គន្ត្វា ភគវតោ អារោចេយ្យំ

---

១-២ ម. គហេត្វា ។

ទើបលះបង់នូវអកុសល ចំរើននូវកុសលបាន ភិក្ខុកាលធ្វើសក្ការៈ គោរព អាស្រ័យព្រះធម៌ ... ព្រះសង្ឃ ..., សិក្ខា ... សមាធិ ... អប្បមាទៈ ... បដិសន្ថារៈ ទើបលះបង់នូវអកុសល ចំរើននូវកុសលបាន ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ធម៌ទាំងឡាយ របស់អាត្មាអញនេះ ដ៏បរិសុទ្ធ ផូរផង់ បើដូច្នេះ មានតែអាត្មាអញ យកធម៌ទាំងនេះ ទៅក្រាបបង្គំទូល ចំពោះព្រះដ៏មានព្រះភាគ កាលបើយ៉ាងនេះ ធម៌ទាំងឡាយ របស់អញនេះ នឹងជាធម៌ ដ៏បរិសុទ្ធផង ជាធម៌ដែលបុំយគាត់តែង ដ៏បរិសុទ្ធក្រៃពេក យ៉ាងនេះផង ។ ដូចជាបុរស បានមាសត្រាដ៏បរិសុទ្ធ ផូរផង់ បុរសនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា មាសត្រារបស់អាត្មាអញនេះ ដ៏បរិសុទ្ធ ផូរផង់ បើដូច្នោះ មានតែអាត្មាអញ យកមាសត្រានេះ ទៅបង្ហាញ ដល់ពួកជាងមាស កាលបើយ៉ាងនេះ មាសត្រារបស់អញនេះ តាំងនៅក្នុងច្រានៃជាងមាស នឹងជាមាសដ៏បរិសុទ្ធផង ជាមាសដែលជាងគាត់តែង ដ៏បរិសុទ្ធក្រៃពេកផង យ៉ាងណាមិញ ។ ធម៌ទាំងឡាយ របស់អាត្មាអញនេះ បរិសុទ្ធ ផូរផង់ បើដូច្នោះ មានតែអាត្មាអញ យកធម៌ទាំងនេះ ទៅក្រាបបង្គំទូលចំពោះព្រះដ៏មានព្រះភាគ

## បណ្ណាសកាសង្គហិតោ មហាវគ្គោ

ឯវំ មេ ឥមេ ធម្មា បរិសុទ្ធា ចេវ ភវិស្សន្តិ បរិសុទ្ធសង្ខាតកា ចាតិ ។ អថខោ អាយស្មា សារីបុត្តោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច ឥធ មយ្ហំ ភន្តេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ កិន្នុ ខោ ភិក្ខុ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរន្តោ អកុសលំ បជហេយ្យ កុសលំ ភាវេយ្យាតិ ។ តស្ស មយ្ហំ ភន្តេ ឯតទហោសិ សត្ថារំ ខោ ភិក្ខុ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរន្តោ អកុសលំ បជហេយ្យ កុសលំ ភាវេយ្យ ធម្មំ ខោ... សង្ឃំ ខោ... សិក្ខំ ខោ... សមាធឹ ខោ... អប្បមាទំ ខោ... បដិសន្ថារំ ខោ ភិក្ខុ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរន្តោ អកុសលំ បជហេយ្យ កុសលំ ភាវេយ្យាតិ ។ តស្ស មយ្ហំ ភន្តេ ឯតទហោសិ ឥមេ ខោ មេ ធម្មា បរិសុទ្ធា បរិយោទាតា

កាលបើយ៉ាងនេះ ធម៌របស់អញនេះឯង ទើបជាធម៌ដ៏បរិសុទ្ធផង ជាធម៌ដែលបច្ច័យតាក់តែង ដ៏បរិសុទ្ធក្រៃពេកផង ក៏យ៉ាងនោះដែរ ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ ចេញចាកការពួនសម្ងំ ក្នុងសាយណ្ហ-សម័យ ហើយក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គនៅក្នុងទីស្ងាត់ ហើយពួនសម្ងំ ក៏មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា ភិក្ខុកាលធ្វើសក្ការៈ គោរព អាស្រ័យអ្វីហ្ន៎ ទើបលះបង់នូវអកុសល ចំរើននូវកុសលបាន ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុកាលធ្វើសក្ការៈ គោរព អាស្រ័យព្រះសាស្តា ទើបលះបង់នូវអកុសល ចំរើននូវកុសលបាន ភិក្ខុកាលធ្វើសក្ការៈ គោរពអាស្រ័យព្រះធម៌ ... ព្រះសង្ឃ ... សិក្ខា ... សមាធិ ... អប្បមាទៈ ... បដិសន្ថារៈ ទើបលះបង់នូវអកុសល ចំរើននូវកុសលបាន ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះ មានសេចក្តីត្រិះរិះដូច្នេះថា ធម៌ទាំងឡាយ របស់អញនេះ ដ៏បរិសុទ្ធ ផូរផង់

យន្នូនាហំ ឥមេ ធម្មេ តត្ថ កុសលោ អាករេយ្យំ ឯវំ មេ ឥមេ ធម្មា បរិសុទ្ធា ចេវ ភវិស្សន្តិ បរិសុទ្ធសង្ខាត-តរា ច ។ សេយ្យថាបិ នាម បុរិសោ សុវណ្ណនិក្ខំ អធិគច្ឆេយ្យ បរិសុទ្ធំ បរិយោទាតំ តស្ស ឯវមស្ស អយំ ខោ មេ សុវណ្ណនិក្ខោ បរិសុទ្ធោ បរិយោទាតោ យន្នូនាហំ ឥមំ សុវណ្ណនិក្ខំ តត្ថ កម្មារានំ ទស្សេយ្យំ ឯវំ មេ អយំ សុវណ្ណនិក្ខោ សកម្មារគតោ បរិសុទ្ធោ ចេវ ភវិស្សតិ បរិសុទ្ធសង្ខាតតរោ ចាតិ ។ ឯវមេវ មេ ឥមេ ធម្មា បរិសុទ្ធា បរិយោទាតា យន្នូនាហំ ឥមេ ធម្មេ តត្ថ កុសលោ អាករេយ្យំ ឯវំ មេ ឥមេ ធម្មា បរិសុទ្ធា ចេវ ភវិស្សន្តិ បរិសុទ្ធសង្ខាតតរា ចាតិ ។ សាធុ សាធុ សារីបុត្ត សត្ថារំ ខោ សារីបុត្ត ភិក្ខុ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរន្តោ អកុសលំ បជហេយ្យ កុសលំ ភាវេយ្យ ធម្មំ ខោ… សង្ឃំ ខោ… សិក្ខំ ខោ… សមាធឹ ខោ… អប្បមាទំ ខោ… បដិសន្ថារំ ខោ សារីបុត្ត ភិក្ខុ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរន្តោ

បើដូច្នោះ មានតែអញយកធម៌ទាំងនោះទៅក្រាបទូល ចំពោះព្រះមានព្រះភាគ កាលបើយ៉ាងនេះ ធម៌ទាំងឡាយ របស់អញនេះ នឹងជាធម៌ដ៏បរិសុទ្ធផង ជាធម៌ដែលមានបច្ច័យតាក់តែង ដ៏បរិសុទ្ធក្រៃពេកផង ។ ដូចបុរសបានមាសត្ដោរ ដ៏បរិសុទ្ធ ផូរផង់ បុរសនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា មាសត្ដោររបស់អាត្មាអញនេះ ដ៏បរិសុទ្ធ ផូរផង់ បើដូច្នោះ មានតែអាត្មាអញ យកមាសត្ដោរនេះទៅបង្ហាញ ដល់ពួកជាងមាស កាលបើយ៉ាងនេះ មាសត្ដោររបស់អញនេះ តាំងនៅក្នុងចង្ក្រាននៃជាងមាស នឹងជាមាសដ៏បរិសុទ្ធផង ជាមាសដែលជាងតាក់តែង ដ៏បរិសុទ្ធក្រៃពេកផង យ៉ាងណាមិញ ។ ធម៌ទាំងឡាយ របស់អាត្មាអញនេះ ដ៏បរិសុទ្ធ ផូរផង់ បើដូច្នោះ មានតែអាត្មាអញ យកធម៌ទាំងនេះទៅក្រាបទូល ចំពោះព្រះមានព្រះភាគ កាលបើយ៉ាងនេះ ធម៌ទាំងឡាយ របស់អញនេះ នឹងជាធម៌បរិសុទ្ធផង ជាធម៌ដែលបច្ច័យតាក់តែង ដ៏បរិសុទ្ធក្រៃពេកផង យ៉ាងនោះដែរ ។ ម្នាលសារីបុត្ត ត្រូវហើយ ។ ម្នាលសារីបុត្ត ភិក្ខុកាលធ្វើសក្ការៈគោរព អាស្រ័យនូវព្រះសាស្ដា ទើបលះបង់នូវអកុសល ចំរើននូវកុសលបាន ម្នាលសារីបុត្ត ភិក្ខុកាលធ្វើសក្ការៈ គោរព អាស្រ័យនូវព្រះធម៌ ... ព្រះសង្ឃ ... សិក្ខា ... សមាធិ ... អប្បមាទៈ ... បដិសន្ថារៈ

អកុសលំ បជហេយ្យ កុសលំ ភាវេយ្យាតិ ។ ឯវំ វុត្តេ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច ឥមស្ស ខោ អហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមិ ។ សោ វត ភន្តេ ភិក្ខុ សត្ថរិ អគារវោ ធម្មេ សគារវោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ យោ សោ ភន្តេ ភិក្ខុ សត្ថរិ អគារវោ ធម្មេបិ សោ អគារវោ ។ សោ វត ភន្តេ ភិក្ខុ សត្ថរិ អគារវោ ធម្មេ អគារវោ សង្ឃេ សគារវោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ យោ សោ ភន្តេ ភិក្ខុ សត្ថរិ អគារវោ ធម្មេ អគារវោ សង្ឃេបិ សោ អគារវោ ។ សោ វត ភន្តេ ភិក្ខុ សត្ថរិ អគារវោ ធម្មេ អគារវោ សង្ឃេ អគារវោ សិក្ខាយ សគារវោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ យោ សោ ភន្តេ ភិក្ខុ សត្ថរិ អគារវោ ធម្មេ អគារវោ សង្ឃេ អគារវោ សិក្ខាយបិ សោ អគារវោ ។ សោ វត ភន្តេ ភិក្ខុ សត្ថរិ អគារវោ ធម្មេ អគារវោ សង្ឃេ អគារវោ សិក្ខាយ អគារវោ សមាធិស្មឹ សគារវោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ យោ សោ ភន្តេ ភិក្ខុ

ទើបលះបង់នូវអកុសល ចំរើននូវកុសលបាន ។ កាលបើព្រះសាស្តា ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះសារីបុត្តដ៏មានអាយុ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងដោយសង្ខេបនេះ ខ្ញុំព្រះអង្គយល់សេចក្តី ដោយពិស្តារបានយ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យថា ភិក្ខុនោះ មិនគោរពព្រះសាស្តា ជាអ្នកគោរពក្នុងព្រះធម៌ដូច្នេះ ហេតុនុ៎ះ មិនមានឡើយ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុណា មិនគោរពព្រះសាស្តា ភិក្ខុនោះ ឈ្មោះថា មិនគោរពក្នុងព្រះធម៌ដែរ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យថា ភិក្ខុនោះ មិនគោរពព្រះសាស្តា មិនគោរពព្រះធម៌ ជាអ្នកគោរពក្នុងព្រះសង្ឃដូច្នេះ ហេតុនុ៎ះ មិនមានឡើយ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុណា មិនគោរពព្រះសាស្តា មិនគោរពព្រះធម៌ ភិក្ខុនោះ ឈ្មោះថា មិនគោរពក្នុងព្រះសង្ឃដែរ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យថា ភិក្ខុនោះ មិនគោរពព្រះសាស្តា មិនគោរពព្រះធម៌ មិនគោរពព្រះសង្ឃ ជាអ្នកគោរពសិក្ខាដូច្នេះ ហេតុនុ៎ះ មិនមានឡើយ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុណា មិនគោរពព្រះសាស្តា មិនគោរពព្រះធម៌ មិនគោរពព្រះសង្ឃ ភិក្ខុនោះ ឈ្មោះថា មិនគោរពក្នុងសិក្ខាដែរ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យថា ភិក្ខុនោះ មិនគោរពព្រះសាស្តា មិនគោរពព្រះធម៌ មិនគោរពព្រះសង្ឃ មិនគោរពសិក្ខា ជាអ្នកគោរពក្នុងសមាធិដូច្នេះ ហេតុនុ៎ះ មិនមានឡើយ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុណា

សត្ថរិ អគារវោ ធម្មេ អគារវោ សង្ឃេ អគារវោ សិក្ខាយ អគារវោ សមាធិស្មឹបិ សោ អគារវោ ។ សោ វត ភន្តេ ភិក្ខុ សត្ថរិ អគារវោ ធម្មេ អគារវោ សង្ឃេ អគារវោ សិក្ខាយ អគារវោ សមាធិស្មឹ អគារវោ អប្បមាទេ សគារវោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ យោ សោ ភន្តេ ភិក្ខុ សត្ថរិ អគារវោ ធម្មេ អគារវោ សង្ឃេ អគារវោ សិក្ខាយ អគារវោ សមាធិស្មឹ អគារវោ អប្បមាទេបិ សោ អគារវោ ។ សោ វត ភន្តេ ភិក្ខុ សត្ថរិ អគារវោ ធម្មេ អគារវោ សង្ឃេ អគារវោ សិក្ខាយ អគារវោ សមាធិស្មឹ អគារវោ អប្បមាទេ អគារវោ បដិសន្ថារេ សគារវោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ យោ សោ ភន្តេ ភិក្ខុ សត្ថរិ អគារវោ ធម្មេ អគារវោ សង្ឃេ អគារវោ សិក្ខាយ អគារវោ សមាធិស្មឹ អគារវោ អប្បមាទេ អគារវោ បដិសន្ថារេបិ សោ អគារវោ ។ សោ វត ភន្តេ ភិក្ខុ សត្ថរិ សគារវោ ធម្មេ អគារវោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ យោ សោ ភន្តេ ភិក្ខុ សត្ថរិ សគារវោ ធម្មេបិ សោ សគារវោ ។

មិនគោរពព្រះសាស្តា មិនគោរពព្រះធម៌ មិនគោរពព្រះសង្ឃ មិនគោរពសិក្ខា ភិក្ខុនោះ ឈ្មោះថា មិនគោរព ក្នុងសមាធិដែរ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យថា ភិក្ខុនោះ មិនគោរពព្រះសាស្តា មិនគោរពព្រះធម៌ មិនគោរពព្រះសង្ឃ មិនគោរពសិក្ខា មិនគោរពសមាធិ ជាអ្នកគោរព ក្នុងអប្បមាទៈដូច្នេះ ហេតុនុ៎ះ មិនមានឡើយ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុណា មិនគោរពព្រះសាស្តា មិនគោរពព្រះធម៌ មិនគោរពព្រះសង្ឃ មិនគោរពសិក្ខា មិនគោរពសមាធិ ភិក្ខុនោះ ឈ្មោះថា មិនគោរព ក្នុងអប្បមាទៈដែរ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យថា ភិក្ខុនោះ មិនគោរពព្រះសាស្តា មិនគោរពព្រះធម៌ មិនគោរពព្រះសង្ឃ មិនគោរពសិក្ខា មិនគោរពសមាធិ មិនគោរពអប្បមាទៈ ជាអ្នកគោរព ក្នុងបដិសន្ថារៈដូច្នេះ ហេតុនុ៎ះ មិនមានឡើយ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុណា មិនគោរពព្រះសាស្តា មិនគោរពព្រះធម៌ មិនគោរពព្រះសង្ឃ មិនគោរពសិក្ខា មិនគោរពសមាធិ មិនគោរពអប្បមាទៈ ភិក្ខុនោះ ឈ្មោះថា មិនគោរព ក្នុងបដិសន្ថារៈដែរ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យថា ភិក្ខុនោះ គោរពក្នុងព្រះសាស្តា ជាអ្នកមិនគោរពព្រះធម៌ដូច្នេះ ហេតុនុ៎ះ មិនមានឡើយ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុណា គោរពព្រះសាស្តា ភិក្ខុនោះ ឈ្មោះថា គោរព ក្នុងព្រះធម៌ដែរ ។

សោ វត ភិក្ខវេ ភិក្ខុ សត្ថរិ សគារវោ ធម្មេ សគារវោ សង្ឃេ អគារវោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ យោ សោ ភិក្ខវេ ភិក្ខុ សត្ថរិ សគារវោ ធម្មេ សគារវោ សង្ឃេបិ សោ សគារវោ ។ សោ វត ភិក្ខវេ ភិក្ខុ សត្ថរិ សគារវោ ធម្មេ សគារវោ សង្ឃេ សគារវោ សិក្ខាយ អគារវោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ យោ សោ ភិក្ខវេ ភិក្ខុ សត្ថរិ សគារវោ ធម្មេ សគារវោ សង្ឃេ សគារវោ សិក្ខាយបិ សោ សគារវោ ។ សោ វត ភិក្ខវេ ភិក្ខុ សត្ថរិ សគារវោ ធម្មេ សគារវោ សង្ឃេ សគារវោ សិក្ខាយ សគារវោ សមាធិស្មឹ អគារវោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ យោ សោ ភិក្ខវេ ភិក្ខុ សត្ថរិ សគារវោ ធម្មេ សគារវោ សង្ឃេ សគារវោ សិក្ខាយ សគារវោ សមាធិស្មឹបិ សោ សគារវោ ។ សោ វត ភិក្ខវេ ភិក្ខុ សត្ថរិ សគារវោ ធម្មេ សគារវោ សង្ឃេ សគារវោ សិក្ខាយ សគារវោ សមាធិស្មឹ សគារវោ អប្បមាទេ អគារវោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ

បពិត្រព្រះអង្គដ៏ចំរើន ពាក្យថា ភិក្ខុនោះ គោរពព្រះសាស្តា គោរពព្រះធម៌ ជាអ្នកមិនគោរពក្នុងព្រះសង្ឃ ដូច្នេះ ហេតុនុ៎ះ មិនមានឡើយ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុណា គោរពព្រះសាស្តា គោរពព្រះធម៌ ភិក្ខុនោះ ឈ្មោះថា គោរពក្នុងព្រះសង្ឃដែរ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យថា ភិក្ខុនោះ គោរពព្រះសាស្តា គោរពព្រះធម៌ គោរពព្រះសង្ឃ ជាអ្នកមិនគោរពក្នុងសិក្ខាដូច្នេះ ហេតុនុ៎ះ មិនមានឡើយ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុណា គោរពព្រះសាស្តា គោរពព្រះធម៌ គោរពព្រះសង្ឃ ភិក្ខុនោះ ឈ្មោះថា គោរពក្នុងសិក្ខាដែរ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យថា ភិក្ខុនោះ គោរពព្រះសាស្តា គោរពព្រះធម៌ គោរពព្រះសង្ឃ គោរពសិក្ខា ជាអ្នកមិនគោរព ក្នុងសមាធិដូច្នេះ ហេតុនុ៎ះ មិនមានឡើយ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុណា គោរពព្រះសាស្តា គោរពព្រះធម៌ គោរពព្រះសង្ឃ គោរពសិក្ខា ភិក្ខុនោះ ឈ្មោះថា គោរពក្នុងសមាធិដែរ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យថា ភិក្ខុនោះ គោរពព្រះសាស្តា គោរពព្រះធម៌ គោរពព្រះសង្ឃ គោរពសិក្ខា គោរពសមាធិ ជាអ្នកមិនគោរព ក្នុងអប្បមាទៈដូច្នេះ ហេតុនុ៎ះ មិនមានឡើយ

យោ សោ ភន្តេ ភិក្ខុ សត្ថរិ សគារវោ ធម្មេ សគារវោ សង្ឃេ សគារវោ សិក្ខាយ សគារវោ សមាធិស្មឹ សគារវោ អប្បមាទេបិ សោ សគារវោ ។ សោ វត ភន្តេ ភិក្ខុ សត្ថរិ សគារវោ ធម្មេ សគារវោ សង្ឃេ សគារវោ សិក្ខាយ សគារវោ សមាធិស្មឹ សគារវោ អប្បមាទេ សគារវោ បដិសន្ថារេ អគារវោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ យោ សោ ភន្តេ ភិក្ខុ សត្ថរិ សគារវោ ធម្មេ សគារវោ សង្ឃេ សគារវោ សិក្ខាយ សគារវោ សមាធិស្មឹ សគារវោ អប្បមាទេ សគារវោ បដិសន្ថារេបិ សោ សគារវោ ។ ឥមស្ស ខោ អហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមីតិ ។ សាធុ សាធុ សារីបុត្ត សាធុ ខោ ត្វំ សារីបុត្ត ឥមស្ស មយា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាសិ ។ សោ វត សារីបុត្ត ភិក្ខុ សត្ថរិ អគារវោ ធម្មេ សគារវោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ យោ សោ សារីបុត្ត ភិក្ខុ សត្ថរិ អគារវោ ធម្មេបិ សោ អគារវោ ។ បេ ។

បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុណា គោរពព្រះសាស្ដា គោរពព្រះធម៌ គោរពព្រះសង្ឃ គោរពសិក្ខា គោរពសមាធិ ភិក្ខុនោះ ឈ្មោះថា គោរពក្នុងអប្បមាទៈដែរ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យថា ភិក្ខុនោះ គោរពព្រះសាស្ដា គោរពព្រះធម៌ គោរពព្រះសង្ឃ គោរពសិក្ខា គោរពសមាធិ គោរពអប្បមាទៈ ជាអ្នកមិនគោរពក្នុងបដិសន្ថារៈដូច្នេះ ហេតុនុះ មិនមានឡើយ បពិត្រព្រះអង្គដ៏ចំរើន ពាក្យថា ភិក្ខុនោះ គោរពព្រះសាស្ដា គោរពព្រះធម៌ គោរពព្រះសង្ឃ គោរពសិក្ខា គោរពសមាធិ គោរពអប្បមាទៈ ភិក្ខុនោះ ឈ្មោះថា គោរពក្នុងបដិសន្ថារៈដែរ ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងដោយសង្ខេបនេះ ខ្ញុំព្រះអង្គយល់សេចក្ដី ដោយពិស្ដារយ៉ាងនេះ ។ ម្នាលសារីបុត្ត ត្រូវហើយ ៗ ម្នាលសារីបុត្ត ធម៌ដែលតថាគត សំដែងដោយសង្ខេបនេះ អ្នកយល់សេចក្ដី ដោយពិស្ដារយ៉ាងនេះ ល្អហើយ ។ ម្នាលសារីបុត្ត ពាក្យថា ភិក្ខុនោះ មិនគោរពព្រះសាស្ដា ជាអ្នកគោរពក្នុងព្រះធម៌ដូច្នេះ ហេតុនុះ មិនមានឡើយ ម្នាលសារីបុត្ត ភិក្ខុណា មិនគោរពព្រះសាស្ដា ភិក្ខុនោះ ឈ្មោះថា មិនគោរពក្នុងព្រះធម៌ដែរ ។បេ។

សោ វត សារីបុត្ត ភិក្ខុ សត្ថរិ អគារវោ ធម្មេ អគារវោ សង្ឃេ អគារវោ សិក្ខាយ អគារវោ សមាធិស្មឹ អគារវោ អប្បមាទេ អគារវោ បដិសន្ថារេ សគារវោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ យោ សោ សារីបុត្ត ភិក្ខុ សត្ថរិ អគារវោ ធម្មេ អគារវោ សង្ឃេ អគារវោ សិក្ខាយ អគារវោ សមាធិស្មឹ អគារវោ អប្បមាទេ អគារវោ បដិសន្ថារេបិ សោ អគារវោ ។ សោ វត សារីបុត្ត ភិក្ខុ សត្ថរិ សគារវោ ធម្មេ អគារវោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ យោ សោ សារីបុត្ត ភិក្ខុ សត្ថរិ សគារវោ ធម្មេបិ សោ សគារវោ ។ បេ ។ សោ វត សារីបុត្ត ភិក្ខុ សត្ថរិ សគារវោ ធម្មេ សគារវោ សង្ឃេ សគារវោ សិក្ខាយ សគារវោ សមាធិស្មឹ សគារវោ អប្បមាទេ សគារវោ បដិសន្ថារេ អគារវោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ យោ សោ សារីបុត្ត ភិក្ខុ សត្ថរិ សគារវោ ធម្មេ សគារវោ សង្ឃេ សគារវោ សិក្ខាយ សគារវោ សមាធិស្មឹ សគារវោ អប្បមាទេ សគារវោ បដិសន្ថារេបិ សោ សគារវោ ។

ម្នាលសារីបុត្ត ពាក្យថា ភិក្ខុនោះ មិនគោរពព្រះសាស្តា មិនគោរពព្រះធម៌ មិនគោរពព្រះសង្ឃ មិនគោរពសិក្ខា មិនគោរពសមាធិ មិនគោរពអប្បមាទៈ ជាអ្នកគោរពក្នុងបដិសន្ថារៈ ដូច្នេះ ហេតុនុ៎ះ មិនមានឡើយ ម្នាលសារីបុត្ត ភិក្ខុណា មិនគោរពព្រះសាស្តា មិនគោរពព្រះធម៌ មិនគោរពព្រះសង្ឃ មិនគោរពសិក្ខា មិនគោរពសមាធិ មិនគោរពអប្បមាទៈ ភិក្ខុនោះ ឈ្មោះថា មិនគោរពក្នុងបដិសន្ថារៈដែរ ។ ម្នាលសារីបុត្ត ពាក្យថា ភិក្ខុនោះ គោរពព្រះសាស្តា ជាអ្នកមិនគោរពក្នុងព្រះធម៌ដូច្នេះ ហេតុនុ៎ះ មិនមានឡើយ ម្នាលសារីបុត្ត ភិក្ខុណា គោរពព្រះសាស្តា ភិក្ខុនោះ ឈ្មោះថា គោរពក្នុងព្រះធម៌ដែរ ។បេ។ ម្នាលសារីបុត្ត ពាក្យថា ភិក្ខុនោះ គោរពព្រះសាស្តា គោរពព្រះធម៌ គោរពព្រះសង្ឃ គោរពសិក្ខា គោរពសមាធិ គោរពអប្បមាទៈ ជាអ្នកមិនគោរពក្នុងបដិសន្ថារៈ ដូច្នេះ ហេតុនុ៎ះ មិនមែនជាឋានៈឡើយ ម្នាលសារីបុត្ត ភិក្ខុណា គោរពព្រះសាស្តា គោរពព្រះធម៌ គោរពព្រះសង្ឃ គោរពសិក្ខា គោរពសមាធិ គោរពអប្បមាទៈ ភិក្ខុនោះ ឈ្មោះថា គោរពក្នុងបដិសន្ថារៈដែរ ។

ឥមស្ស ខោ សារីបុត្ត មយា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។

(៦៨) ភាវនំ អននុយុត្តស្ស ភិក្ខវេ ភិក្ខុនោ វិហរតោ កិញ្ចាបិ ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មេ អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចេយ្យាតិ អថខ្វស្ស នេវ អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចតិ ។ តំ កិស្ស ហេតុ ។ អភាវិតត្តាតិស្ស វចនីយំ ។ កិស្ស អភាវិតត្តា ។ ចតុន្នំ សតិបដ្ឋានានំ ចតុន្នំ សម្មប្បធានានំ ចតុន្នំ ឥទ្ធិបាទានំ បញ្ចន្នំ ឥន្ទ្រិយានំ បញ្ចន្នំ ពលានំ សត្តន្នំ ពោជ្ឈង្គានំ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស ។ សេយ្យថាបិ ភិក្ខវេ កុក្កុដិយា អណ្ឌានិ អដ្ឋ វា ទស វា ទ្វាទស វា តានស្សុ កុក្កុដិយា ន សម្មាអធិសយិតានិ ន សម្មាបរិសេទិតានិ ន សម្មាបរិភាវិតានិ កិញ្ចាបិ តស្សា កុក្កុដិយា ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មេ កុក្កុដបោតកា បាទនខសិខាយ វា មុខតុណ្ឌកេន វា អណ្ឌកោសំ បទាលេត្វា

ម្នាលសារីបុត្ត ធម៌ដែលតថាគត សំដែងដោយសង្ខេបនេះ អ្នកយល់សេចក្តី ដោយពិស្តារយ៉ាងនេះ ។

(៦៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមិនប្រកបរឿយ ៗ នូវភាវនា បើទុកជាមានសេចក្តីប្រាថ្នា យ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ចិត្តរបស់អាត្មាអញ គប្បីផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ដូច្នេះក៏ដោយ ក៏គង់តែចិត្តរបស់ភិក្ខុនោះ មិនរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះតែមិនប្រកាន់មាំដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ត្រូវនិយាយថា ព្រោះតែភិក្ខុមិនបានចំរើន ។ ព្រោះមិនបានចំរើនអ្វី ។ ព្រោះតែមិនបានចំរើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ។ ម្នាលភិក្ខុទាំងឡាយ ដូចពងមាន់ទាំងឡាយ ៨ ក្តី ១០ ក្តី ១២ ក្តី ពងមាន់ទាំងឡាយនោះ ដែលមេមាន់មិនក្រាបដោយប្រពៃ មិនបានធ្វើឲ្យកក់ក្តៅដោយប្រពៃ មិនបានឲ្យជាប់ក្លិនរាជាមេដោយប្រពៃ បើទុកជាមេមាន់នោះ មានសេចក្តីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ កូនទាំងឡាយរបស់អញ គប្បីទំលាយសម្បកពង ដោយចុងក្រចកជើង ឬ ដោយចុងចំពុះ

សោត្ថិនា អភិនិព្ភិជ្ជេយ្យុន្តិ អថខោ អភព្វាវ តេ កុក្កុដបោតកា បាទនខសិខាយ វា មុខតុណ្ឌកេន វា អណ្ឌកោសំ បទាលេត្វា សោត្ថិនា អភិនិព្ភិជ្ជិតុំ ។ តំ កិស្ស ហេតុ ។ តថាហម្ពិ(១) ភិក្ខវេ កុក្កុដិយា អណ្ឌានិ ន សម្មា អធិសយិតានិ ន សម្មា បរិសេទិតានិ ន សម្មា បរិភាវិតានិ ឯវមេវ ខោ ភិក្ខវេ ភាវនំ អននុយុត្តស្ស ភិក្ខុនោ វិហរតោ កិញ្ចាបិ ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មេ អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចេយ្យាតិ អថខ្វស្ស នេវ អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចតិ ។ តំ កិស្ស ហេតុ ។ អភាវិតត្តាតិស្ស វចនីយំ ។ កិស្ស អភាវិតត្តា ។ ចតុន្នំ សតិបដ្ឋានានំ ចតុន្នំ សម្មប្បធានានំ ចតុន្នំ ឥទ្ធិបាទានំ បញ្ចន្នំ ឥន្ទ្រិយានំ បញ្ចន្នំ ពលានំ សត្តន្នំ ពោជ្ឈង្គានំ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស ។ ភាវនំ អនុយុត្តស្ស ភិក្ខវេ ភិក្ខុនោ វិហរតោ កិញ្ចាបិ ន ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ

១ ម. តថាហិ ។

ហើយញាស់ចេញមក ដោយស្រួល ដូច្នេះក៏ដោយ ក៏គង់តែកូនមាន់ទាំងនោះ មិនអាចនឹងទំលាយនូវសម្បកពង ដោយចុងក្រចកជើង ឬ ដោយចុងចំពុះ ហើយញាស់ចេញមក ដោយស្រួលបានដែរ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះពងទាំងនោះ ដែលមេមាន់មិនបានក្រាបដោយប្រពៃ មិនបានធ្វើឲ្យកក់ក្ដៅដោយប្រពៃ មិនបានឲ្យជាប់ក្លិនជាមេដោយប្រពៃ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមិនបានប្រកបរឿយ ៗ នូវភាវនា បើទុកជាមានសេចក្ដីប្រាថ្នា យ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ ចិត្តរបស់អាត្មាអញ គប្បីផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ដូច្នេះក៏ដោយ ក៏គង់តែចិត្តរបស់ភិក្ខុនោះ មិនផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះតែមិនប្រកាន់មាំបានដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ត្រូវនិយាយថា ព្រោះតែមិនបានចំរើន ។ ព្រោះមិនបានចំរើនអ្វី ។ ព្រោះមិនបានចំរើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបានប្រកបរឿយ ៗ នូវភាវនា បើទុកជាមិនមានសេចក្ដីប្រាថ្នា យ៉ាងនេះថា

អហោ វត មេ អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចេយ្យាតិ អថខ្វស្ស អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចតិ ។ តំ កិស្ស ហេតុ ។ ភាវិតត្តាតិស្ស វចនីយំ ។ កិស្ស ភាវិតត្តា ។ ចតុន្នំ សតិបដ្ឋានានំ ចតុន្នំ សម្មប្បធានានំ ចតុន្នំ ឥទ្ធិបាទានំ បញ្ចន្នំ ឥន្ទ្រិយានំ បញ្ចន្នំ ពលានំ សត្តន្នំ ពោជ្ឈង្គានំ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស ។ សេយ្យថាបិ ភិក្ខវេ កុក្កុដិយា អណ្ឌានិ អដ្ឋ វា ទស វា ទ្វាទស វា តានស្សុ កុក្កុដិយា សម្មា អធិសយិតានិ សម្មា បរិសេទិតានិ សម្មា បរិភាវិតានិ កិញ្ចាបិ តស្សា កុក្កុដិយា ន ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មេ កុក្កុដបោតកា បាទនខសិខាយ វា មុខតុណ្ឌកេន វា អណ្ឌកោសំ បទាលេត្វា សោត្ថិនា អភិនិព្ភិជ្ជេយ្យុន្តិ អថខោ ភព្វាវ តេ កុក្កុដបោតកា បាទនខសិខាយ វា មុខតុណ្ឌកេន វា អណ្ឌកោសំ បទាលេត្វា សោត្ថិនា អភិនិព្ភិជ្ជិតុំ ។ តំ កិស្ស ហេតុ ។ តថាហប្វិ(១) ភិក្ខវេ កុក្កុដិយា អណ្ឌានិ សម្មា អធិសយិតានិ

---

១ ម. តថាហិ ។

ធ្វើដូចម្ដេចហ្ន៎ ចិត្តរបស់អាត្មាអញ គប្បីផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ដូច្នេះក៏ដោយ ក៏គង់តែចិត្តរបស់ភិក្ខុនោះ ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំបានដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ត្រូវនិយាយថា ព្រោះតែភិក្ខុបានចំរើន ។ ព្រោះបានចំរើនអ្វី ។ ព្រោះបានចំរើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាពងមាន់ទាំងឡាយ ៨ ក្ដី ១០ ក្ដី ១២ ក្ដី ពងមាន់ទាំងនោះ ដែលមេមាន់ក្រាបដោយប្រពៃហើយ ធ្វើឲ្យកក់ក្ដៅដោយប្រពៃហើយ ធ្វើឲ្យជាប់ក្លិនជាមេដោយប្រពៃហើយ មេមាន់នោះ បើទុកជាមិនមានសេចក្ដីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ កូនទាំងឡាយរបស់អញ គប្បីទំលាយសម្បកពង ដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមក ដោយស្រួល ដូច្នេះក៏ដោយ ក៏គង់តែកូនមាន់ទាំងនោះ អាចទំលាយសម្បកពង ដោយចុងក្រចកជើង ឬ ដោយចុងចំពុះ ហើយញាស់ចេញមក ដោយស្រួលបាន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះតែពងទាំងនោះ ដែលមេមាន់ក្រាបដោយប្រពៃហើយ ធ្វើឲ្យកក់ក្ដៅ ដោយប្រពៃហើយ

សម្មាបរិសេទិតានិ សម្មាបរិភាវិតានិ ឯវមេវ ខោ ភិក្ខវេ ភាវនំ អនុយុត្តស្ស ភិក្ខុនោ វិហរតោ កិញ្ចាបិ ន ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មេ អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចេយ្យាតិ អថខ្វស្ស អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចតិ ។ តំ កិស្ស ហេតុ ។ ភាវិតត្តាតិស្ស វចនីយំ ។ កិស្ស ភាវិតត្តា ។ ចតុន្នំ សតិបដ្ឋានានំ ។ បេ ។ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស ។ សេយ្យថាបិ ភិក្ខវេ ពលវគណ្ឌស្ស វា ពលវគណ្ឌន្តេវាសិកស្ស[១] វា ទិស្សន្តេវ វាសិជដេ អង្គុលិបទានិ ទិស្សតិ អង្គុដ្ឋបទំ នោ ច ខ្វស្ស ឯវំ ញាណំ ហោតិ ឯត្តកំ វា មេ អជ្ជ តស្ស វាសិជដស្ស ខីណំ ឯត្តកំ វា ហីយោ ឯត្តកំ វា បរេតិ អថខ្វស្ស ខីណេ ខីណន្តេ្វវ ញាណំ ហោតិ

---

១ ឱ. បលគណ្ឌស្ស វា បលគណ្ឌន្តេវាសិកស្ស វា ។ ម. ផលគណ្ឌស្ស វា ផលគណ្ឌន្តេវាសិកស្ស វា ។

ឲ្យជាប់ក្លិនក់ជាមេដោយប្រពៃហើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបានប្រកបរឿយ ៗ នូវភាវនា បើទុកជា មិនមានសេចក្ដីប្រាថ្នា យ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ ចិត្តរបស់អាត្មាអញ គប្បីផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះតែមិនប្រកាន់មាំ ដូច្នេះក៏ដោយ ក៏គង់តែចិត្តរបស់ភិក្ខុនោះ ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះតែមិនប្រកាន់មាំបានដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ត្រូវនិយាយថា ព្រោះតែភិក្ខុបានចំរើន ។ ព្រោះបានចំរើនអ្វី ។ ព្រោះបានចំរើនសតិប្បដ្ឋាន ៤ ។ បេ ។ អរិយមគ្គប្រកបដោយអង្គ ៨ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាងឈើ ឬ កូនសិស្សរបស់ជាងឈើ យកម្រាមដៃនឹងមេដៃ ទៅចាប់កាន់ត្រង់មៀនកាំបិត ប៉ុន្តែជាងឈើ ឬ កូនសិស្សរបស់ជាងឈើនោះ មិនដឹងយ៉ាងនេះថា មៀនកាំបិតរបស់អញនោះ ថ្ងៃនេះ សឹកអស់ប៉ុណ្ណោះ ឬ ថ្ងៃម្សិល សឹកអស់ប៉ុណ្ណោះ ឬ កំម្សិលម្ង៉ៃ សឹកអស់ប៉ុណ្ណោះ ដូច្នេះទេ លុះដល់មៀនកាំបិតនោះ សឹកអស់ហើយ ទើបបានដឹងថា អស់ហើយ យ៉ាងណាមិញ

ឯវមេវ ខោ ភិក្ខវេ ភាវនំ អនុយុត្តស្ស ភិក្ខុនោ វិហរតោ កិញ្ចាបិ ន ឯវំ ញាណំ ហោតិ ឯត្តកំ វា មេ អជ្ជ អាសវានំ ខីណំ ឯត្តកំ វា ហីយោ ឯត្តកំ វា បរេតិ អថ ខ្វស្ស ខីណេ ខីណេត្វេវ ញាណំ ហោតិ ។ សេយ្យថាបិ ភិក្ខវេ សាមុទ្ទិកាយ នាវាយ វេត្តពន្ធនពទ្ធាយ ឆម្មាសានិ ឧទកេ បរិយាទាយ ហេមន្តិកេន ថលេ ឧក្ខិត្តាយ វាតាតបបរេតានិ ពន្ធនានិ តានិ បាវុស្សកេន មេឃេន អភិប្បវុដ្ឋានិ អប្បកសិរេនេវ បដិប្បស្សម្ភន្តិ[1] បូតិកានិ ភវន្តិ ឯវមេវ ខោ ភិក្ខវេ ភាវនំ អនុយុត្តស្ស ភិក្ខុនោ វិហរតោ អប្បកសិរេនេវ សញ្ញោជនានិ បដិប្បស្សម្ភីតិ[2] ។

(៦៩) ឯកំ សមយំ ភគវា កោសលេសុ ចារិកំ ចរតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ ។ អទ្ទសា ខោ ភគវា អទ្ធានមគ្គប្បដិបន្នោ អញ្ញតរស្មឹ បទេសេ មហន្តំ អគ្គិក្ខន្ធំ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ ទិស្វា មគ្គា ឱក្កម្ម អញ្ញតរស្មឹ រុក្ខមូលេ បញ្ញត្តេ អាសនេ និសីទិ ។

---

១ ម. បរិហាយន្តិ ។ ២ ឱ. ម. បដិប្បស្សម្ភន្តិ បូតិកានិ ភវន្តីតិ ។

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុប្រកបរឿយ ៗ នូវការនោះ បើទុកជាមិនបានដឹងយ៉ាងនេះថា ថ្ងៃនេះ អាសវៈទាំងឡាយ របស់អញ អស់ទៅប៉ុណ្ណោះ ឬ ថ្ងៃម្សិល អស់ទៅប៉ុណ្ណោះ ឬក៏ ម្សិលម្ង៉ៃ អស់ទៅប៉ុណ្ណោះ ដូច្នេះទេ លុះអាសវៈនោះអស់ទៅ ទើបដឹងថា អស់ហើយក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាសំពៅសមុទ្រដែលគេចងនឹងផ្តៅ ត្រាំនៅក្នុងទឹក អស់ ៦ ខែ ដល់ហេមន្តរដូវ គេលើកឡើងដាក់លើគោក ចំណងទាំងឡាយ ត្រូវខ្យល់នឹងកំដៅថ្ងៃ ចំណងទាំងនោះ ត្រូវភ្លៀង បង្អុរស្រោច ក៏ខូចពុកផុយបានដោយងាយយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុ បានប្រកបរឿយ ៗ នូវការនោះ សំយោជនៈទាំងឡាយ ក៏ស្ងប់រម្ងាប់បានដោយងាយ ក៏យ៉ាងនោះដែរ ។

(៦៨) សម័យមួយ ព្រះដ៏មានព្រះភាគ ត្រាច់ទៅកាន់ចារិក ក្នុងដែនគោសល ជាមួយនឹងភិក្ខុសង្ឃច្រើនរូប ។ ព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់ផ្លូវឆ្ងាយ ទ្រង់បានឃើញគំនរភ្លើងធំ ក្នុងប្រទេសមួយកន្លែងកំពុងឆេះភ្លឺច្រាលច្រោល សន្ធោសន្ធៅ លុះទតឃើញហើយ ក៏យាងចេញអំពីផ្លូវទៅគង់លើអាសនៈ ដែលគេក្រាលថ្វាយ ប្របគល់ឈើមួយដើម ។

និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ បស្សថ នោ តុម្ហេ ភិក្ខវេ អមុំ មហន្តំ អគ្គិក្ខន្ធំ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតន្តិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ វរំ យំ អមុំ មហន្តំ អគ្គិក្ខន្ធំ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ អាលិង្គិត្វា ឧបនិសីទេយ្យ វា ឧបនិបជ្ជេយ្យ វា យំ វា ខត្តិយកញ្ញំ វា ព្រាហ្មណកញ្ញំ វា គហបតិកញ្ញំ វា មុទុតលុនហត្ថបាទំ អាលិង្គិត្វា ឧបនិសីទេយ្យ វា ឧបនិបជ្ជេយ្យ វាតិ ។ ឯតទេវ ភន្តេ វរំ យំ ខត្តិយកញ្ញំ វា ព្រាហ្មណកញ្ញំ វា គហបតិកញ្ញំ វា មុទុតលុនហត្ថបាទំ អាលិង្គិត្វា ឧបនិសីទេយ្យ វា ឧបនិបជ្ជេយ្យ វា ។ ទុក្ខញ្ហេតំ ភន្តេ យំ អមុំ មហន្តំ អគ្គិក្ខន្ធំ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ អាលិង្គិត្វា ឧបនិសីទេយ្យ វា ឧបនិបជ្ជេយ្យ វាតិ ។ អារោចយាមិ វោ ភិក្ខវេ បដិវេទយាមិ វោ ភិក្ខវេ

លុះព្រះដ៏មានព្រះភាគ គង់រួចហើយ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ បានឃើញគំនរភ្លើងធំ ឯណោះ កំពុងឆេះភ្លឺប្រាលរន្ទាល សន្ធោសន្ធៅដែរឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់ហេតុនោះ ថាដូចម្តេច ភិក្ខុអង្គុយ ឬ ដេកឱបគំនរភ្លើងធំឯណោះ កំពុងឆេះភ្លឺប្រាលរន្ទាលសន្ធោសន្ធៅ ហើយនឹងភិក្ខុអង្គុយ ឬ ដេកឱបខត្តិយកញ្ញាក្តី ព្រាហ្មណកញ្ញាក្តី គហបតិកញ្ញាក្តី ដែលមានដៃនិងជើងដ៏ទន់ល្មោសល្មន់ តើរបស់ណាប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអង្គុយ ឬ ដេកឱបខត្តិយកញ្ញាក្តី ព្រាហ្មណកញ្ញាក្តី គហបតិកញ្ញាក្តី ដែលមានដៃនិងជើងដ៏ទន់ល្មោសល្មន់នុ៎ះឯង ប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចំរើន ឯភិក្ខុអង្គុយ ឬ ដេកឱបគំនរភ្លើងធំឯណោះ កំពុងឆេះភ្លឺប្រាលរន្ទាលសន្ធោសន្ធៅ នុ៎ះជាសេចក្តីទុក្ខវិញទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតពន្យល់អ្នកទាំងឡាយ

យថា ឯតទេវ តស្ស ហិ ទុស្សីលស្ស បាបធម្មស្ស អសុចិសង្កស្សរសមាចារស្ស បដិច្ឆន្នកម្មន្តស្ស អស្សមណស្ស សមណបដិញ្ញស្ស អព្រហ្មចារិស្ស ព្រហ្មចារិបដិញ្ញស្ស អន្តោបូតិស្ស អវស្សុតស្ស កសម្ពុជាតស្ស យំ អមុំ មហន្តំ អគ្គិក្ខន្ធំ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ អាលិង្គិត្វា ឧបនិសីទេយ្យ វា ឧបនិបជ្ជេយ្យ វា ។ តំ កិស្ស ហេតុ ។ តតោនិទានញ្ហិ សោ ភិក្ខវេ មរណំ វា និគច្ឆេយ្យ មរណមត្តំ វា ទុក្ខំ ន ត្វេវ តប្បច្ចយា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតិំ វិនិបាតំ និរយំ ឧបបជ្ជេយ្យ ។ យោ ច ខោ សោ ភិក្ខវេ ទុស្សីលោ បាបធម្មោ អសុចិសង្កស្សរសមាចារោ បដិច្ឆន្នកម្មន្តោ អស្សមណោ សមណបដិញ្ញោ អព្រហ្មចារី ព្រហ្មចារិបដិញ្ញោ អន្តោបូតិ អវស្សុតោ កសម្ពុជាតោ ខត្តិយកញ្ញំ វា ព្រាហ្មណកញ្ញំ វា គហបតិកញ្ញំ វា មុទុតលុនហត្ថបាទំ អាលិង្គិត្វា ឧបនិសីទតិ វា ឧបនិបជ្ជតិ វា

ភិក្ខុអង្គុយ ឬ ដេកឱបគំនរភ្លើងធំឯណោះ កំពុងឆេះរឿងប្រាលរន្ទាលសន្ធោសន្ធៅ អំពើនុ៎ះឯង ប្រសើរជាងភិក្ខុទ្រុស្តសីល មានធម៌អាក្រក់ មានមារយាទមិនស្អាត ដែលគួររលឹកដោយសេចក្តីរង្កៀស បិទបាំងអំពើអាក្រក់ មិនមែនសមណៈ តែប្តេជ្ញាខ្លួនថាជាសមណៈ មិនមែនព្រហ្មចារី តែប្តេជ្ញាខ្លួន ថាជាព្រហ្មចារី ស្អុយខាងក្នុង មានចិត្តទទឹកដោយរាគៈ ជាបុគ្គលមានចិត្តជ្រោកជ្រាក ៗ ដំណើរនោះ ព្រោះហេតុអ្វី ៗ ម្នាលភិក្ខុទាំងឡាយ ព្រោះភិក្ខុនោះ ដល់នូវសេចក្តីស្លាប់ សេចក្តីទុក្ខស្មើនឹងស្លាប់ ព្រោះតែអង្គុយ ឬ ដេកឱបគំនរភ្លើងនោះប៉ុណ្ណោះ ដល់បែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ ក៏មិនទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះតែអង្គុយ ឬ ដេកឱបគំនរភ្លើងនោះឡើយ ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទ្រុស្តសីល មានធម៌អាក្រក់ មានមារយាទមិនស្អាត ដែលគួររលឹកដោយសេចក្តីរង្កៀស បិទបាំងអំពើអាក្រក់ មិនមែនជាសមណៈ តែប្តេជ្ញាថាជាសមណៈ មិនមែនជាព្រហ្មចារី តែប្តេជ្ញាថាជា ព្រហ្មចារី ស្អុយខាងក្នុង មានចិត្តទទឹកដោយរាគៈ មានចិត្តជ្រោកជ្រាក អង្គុយ ឬ ដេកឱបខត្តិយកញ្ញាក្តី ព្រាហ្មណកញ្ញាក្តី គហបតិកញ្ញាក្តី ដែលមានដៃនិងជើងទន់ល្មាសល្មន់

បណ្ណាសកាសង្គហិតោ មហាវគ្គោ

តញ្ហិ តស្ស ភិក្ខវេ ហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ វរំ យំ ពលវា បុរិសោ ទឡ្ហាយ វាលរជ្ជុយា ឧភោ ជង្ឃា វេឋេត្វា ឃំសេយ្យ សា ឆវឹ ឆិន្ទេយ្យ ឆវឹ ឆេត្វា ចម្មំ ឆិន្ទេយ្យ ចម្មំ ឆេត្វា មំសំ ឆិន្ទេយ្យ មំសំ ឆេត្វា ន្ហារុំ ឆិន្ទេយ្យ ន្ហារុំ ឆេត្វា អដ្ឋឹ ឆិន្ទេយ្យ អដ្ឋឹ ឆេត្វា អដ្ឋិមិញ្ជំ អាហច្ច តិដ្ឋេយ្យ យំ វា ខត្តិយមហាសាលានំ វា ព្រាហ្មណមហាសាលានំ វា គហបតិមហាសាលានំ វា អភិវាទនំ សាទិយេយ្យាតិ ។ ឯតទេវ ភន្តេ វរំ យំ ខត្តិយមហាសាលានំ វា ព្រាហ្មណមហាសាលានំ វា គហបតិមហាសាលានំ វា អភិវាទនំ សាទិយេយ្យ ។ ទុក្ខញ្ហេតំ ភន្តេ យំ ពលវា បុរិសោ ទឡ្ហាយ វាលរជ្ជុយា ឧភោ ជង្ឃា វេឋេត្វា ឃំសេយ្យ សា ឆវឹ ឆិន្ទេយ្យ ។ បេ ។ អដ្ឋិមិញ្ជំ អាហច្ច តិដ្ឋេយ្យាតិ ។

ម្នាលភិក្ខុទាំងឡាយ ហេតុនោះឯង នាំឲ្យភិក្ខុនោះ បានសេចក្តីវិនាស នឹងសេចក្តីទុក្ខអស់កាលយូរ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់សេចក្តីនោះ ដូចម្តេច បុរសមានកំឡាំង រុំរួតស្មងទាំងពីរ ដោយខ្សែកន្ទុយសត្វយ៉ាងជាប់ ខ្សែនោះក៏មុតស្បែកសម្បុរថ្ងៃ លុះមុតស្បែកសម្បុរថ្ងៃហើយ ក៏មុតស្បែកខាងក្នុង លុះមុតស្បែកខាងក្នុងហើយ ក៏មុតសាច់ លុះមុតសាច់ហើយ ក៏មុតសរសៃ លុះមុតសរសៃហើយ ក៏មុតឆ្អឹង លុះមុតឆ្អឹងហើយ ក៏បុចជាប់ទៅនឹងខួរក្នុងឆ្អឹង ភិក្ខុត្រេកអរនឹងការថ្វាយបង្គំរបស់ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬគហបតិមហាសាលទាំងឡាយ (ទាំងពីរនេះ) ឯណាប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុត្រេកអរនឹងការថ្វាយបង្គំរបស់ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬគហបតិមហាសាលទាំងឡាយ ការត្រេកអរនឹងគេថ្វាយបង្គំ +នុះប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចំរើន បុរសមានកំឡាំង រុំរួតស្មងទាំងពីរ ដោយខ្សែកន្ទុយសត្វយ៉ាងជាប់ ខ្សែនោះ ក៏មុតស្បែកសម្បុរថ្ងៃ ។បេ។ ក៏បុចជាប់ទៅនឹងខួរក្នុងឆ្អឹង ការមុត+នុះជាទុក្ខ លំបាកវិញទេ ។

អារោចយាមិ វោ ភិក្ខវេ បដិវេទយាមិ វោ ភិក្ខវេ យថា ឯតទេវ តស្ស វរំ ទុស្សីលស្ស ។ បេ ។ កសម្ពុជាតស្ស យំ ពលវា បុរិសោ ទឡ្ហាយ វាលរជ្ជុយា ឧភោ ជង្ឃា វេឋេត្វា ឃំសេយ្យ សា ឆវឹ ឆិន្ទេយ្យ ។ បេ ។ អដ្ឋិមិញ្ជំ អាហច្ច តិដ្ឋេយ្យ ។ តំ កិស្ស ហេតុ ។ តតោនិទានញ្ហិ សោ ភិក្ខវេ មរណំ វា និគច្ឆេយ្យ មរណមត្តំ វា ទុក្ខំ ន ត្វេវ តប្បច្ចយា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ ។ យញ្ច ខោ សោ ភិក្ខវេ ទុស្សីលោ ។ បេ ។ កសម្ពុជាតោ ខត្តិយមហាសាលានំ វា ព្រាហ្មណមហាសាលានំ វា គហបតិមហាសាលានំ វា អភិវាទនំ សាទិយតិ តញ្ហិ តស្ស ភិក្ខវេ ហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។

ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតពន្យល់អ្នកទាំងឡាយ បុរសមានកំឡាំង ហើយក្ដួតស្នួនទាំងពីរ ដោយខ្សែកន្ទុយសត្វយ៉ាងជាប់ ខ្សែនោះ ក៏មុតស្បែកសម្បុរថ្ងៃ ៗ ។បេ។ ក៏បុបដាច់ទៅទល់ខួរក្នុងឆ្អឹង ការមុតនុះ ប្រសើរជាងបុគ្គលទ្រុស្តសីល ។បេ។ មានចិត្តជ្រោកជ្រាកនោះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុរសនោះ ដល់នូវសេចក្ដីស្លាប់ ឬដល់នូវសេចក្ដីទុក្ខស្មើនឹងស្លាប់ ព្រោះហេតុតែរុំហើយក្ដួតនូវស្នួនទាំងពីរ ដោយខ្សែកន្ទុយសត្វយ៉ាងជាប់ ( ប៉ុណ្ណោះ ) ដល់បែកធ្លាយរាងកាយស្លាប់ទៅ ក៏មិនទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះតែរុំហើយក្ដួតនូវស្នួនទាំងពីរ ដោយខ្សែកន្ទុយសត្វនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទ្រុស្តសីលនោះ ។បេ។ មានចិត្តជ្រោកជ្រាក ត្រេកអរចំពោះការថ្វាយបង្គំ របស់ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬក៏ គហបតិមហាសាលទាំងឡាយ ដោយហេតុណា ម្នាលភិក្ខុទាំងឡាយ ហេតុនោះ នាំឲ្យភិក្ខុនោះ បានសេចក្ដីវិនាស សេចក្ដីទុក្ខ អស់កាលដ៏វែង លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ទៀត ។

តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ វរំ យំ ពលវា បុរិសោ តិណ្ហាយ សត្តិយា តេលធោតាយ បច្ចោរស្មឹ បហរេយ្យ យំ វា ខត្តិយមហាសាលានំ វា ព្រាហ្មណមហាសាលានំ វា គហបតិមហាសាលានំ វា អញ្ជលិកម្មំ សាទិយេយ្យាតិ ។ ឯតទេវ ភន្តេ វរំ យំ ខត្តិយមហាសាលានំ វា ព្រាហ្មណមហាសាលានំ វា គហបតិមហាសាលានំ វា អញ្ជលិកម្មំ សាទិយេយ្យ ។ ទុក្ខញ្ហេតំ ភន្តេ យំ ពលវា បុរិសោ តិណ្ហាយ សត្តិយា តេលធោតាយ បច្ចោរស្មឹ បហរេយ្យាតិ ។ អារោចយាមិ វោ ភិក្ខវេ បដិវេទយាមិ វោ ភិក្ខវេ យថា ឯតទេវ តស្ស វរំ ទុស្សីលស្ស ។ បេ ។ កសម្ពុជាតស្ស យំ ពលវា បុរិសោ តិណ្ហាយ សត្តិយា តេលធោតាយ បច្ចោរស្មឹ បហរេយ្យ ។ តំ កិស្ស ហេតុ ។ តតោនិទានញ្ហិ សោ ភិក្ខវេ មរណំ វា និគច្ឆេយ្យ មរណមត្តំ វា ទុក្ខំ

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់សេចក្ដីនោះថាដូចម្ដេច បើបុរសមានកំឡាំង ពួយនឹងលំពែងដ៏មុត ដែលគេលាបដោយប្រេង បំដើមទ្រូង ភិក្ខុត្រេកអរនឹងអញ្ជលិកម្ម របស់ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬគហបតិមហាសាលទាំងឡាយ ឯណាប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុត្រេកអរនឹងអញ្ជលិ-កម្ម របស់ខត្តិយមហាសាលទាំងឡាយ ឬ ព្រាហ្មណមហាសាលទាំងឡាយ ឬគហបតិមហាសាលទាំងឡាយ ការត្រេកអរនឹងអញ្ជលិកម្មនុះប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចំរើន បុរសមានកំឡាំង ពួយនឹងលំពែងដ៏មុត ដែលគេលាបដោយប្រេង បំដើមទ្រូង ការពួយបំដើមទ្រូងនោះ ជាទុក្ខលំបាកវិញ ។ ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគត ពន្យល់អ្នកទាំងឡាយ បុរសមានកំឡាំង ពួយនឹងលំពែងដ៏មុត ដែលគេលាបដោយប្រេង បំដើមទ្រូង ដោយហេតុណា ហេតុនោះ ប្រសើរជាងភិក្ខុទ្រុស្ដសីល ។ បេ ។ មានចិត្តជ្រោកជ្រាកនោះ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុរសនោះដល់នូវសេចក្ដីស្លាប់ ឬ ដល់នូវសេចក្ដីទុក្ខស្មើរតែនឹងស្លាប់ ព្រោះហេតុតែពួយនឹងលំពែងដ៏មុត ដែលលាបដោយប្រេង បំដើមទ្រូងប៉ុណ្ណោះ

ន ត្វេវ តប្បច្ចយា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ ។ យញ្ច ខោ សោ ភិក្ខវេ ទុស្សីលោ ។ បេ ។ កសម្ពុជាតោ ខត្តិយមហា-សាលានំ. វា ព្រាហ្មណមហាសាលានំ វា គហបតិមហា-សាលានំ វា អញ្ជលិកម្មំ សាទិយតិ តញ្ហិ តស្ស ភិក្ខវេ ហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ វរំ យំ ពលវា បុរិសោ ទឡ្ហេន អយោបដ្ដេន អាទិត្តេន សម្បជ្ជលិតេន សញ្ជោតិភូតេន កាយំ សម្បលិវេឋេយ្យ យំ វា ខត្តិយមហាសាលានំ វា ព្រាហ្មណមហាសា-លានំ វា គហបតិមហាសាលានំ វា សទ្ធាទេយ្យំ ចីវរំ បរិភុញ្ជេយ្យាតិ ។ ឯតទេវ ភន្តេ វរំ យំ ខត្តិយមហា-សាលានំ វា ព្រាហ្មណមហាសាលានំ វា គហបតិម-ហាសាលានំ វា សទ្ធាទេយ្យំ ចីវរំ បរិភុញ្ជេយ្យ ។

លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏មិនទៅកើតក្នុង អបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែគេពួយនឹងលំពែងដ៏មុត ដែលលាបដោយប្រេង បំពើមទ្រូងនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទ្រុស្តសីលនោះ ។ បេ ។ មានចិត្តជ្រោកជ្រាក ត្រេកអរនឹងអញ្ជលិកម្ម របស់ខត្តិយមហាសាលទាំងឡាយ ឬ ព្រាហ្មណមហាសាលទាំងឡាយ ឬក៏ គហបតិមហាសាលទាំងឡាយ ដោយហេតុណា ម្នាលភិក្ខុទាំងឡាយ ហេតុនោះ នាំឲ្យភិក្ខុនោះ បានសេចក្តីវិនាស សេចក្តីទុក្ខ អស់កាលដ៏វែង លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់សេចក្តីនោះដូចម្តេច បុរសមានកំឡាំង ស្រោបកាយដោយបន្ទះដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះភ្លឺប្រាលផ្លោល សន្ធោសន្ធៅ ភិក្ខុប្រើប្រាស់ចីវរ របស់ខត្តិយមហាសាលទាំងឡាយ ឬ ព្រាហ្មណមហាសាលទាំងឡាយ ឬក៏ គហបតិមហាសាលទាំងឡាយ ដែលគេឲ្យដោយសទ្ធា ណាប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រើប្រាស់ចីវរ របស់ខត្តិយមហាសាលទាំងឡាយ ឬ ព្រាហ្មណមហាសាលទាំងឡាយ ឬក៏ គហបតិមហាលទាំងឡាយ ដែលគេឲ្យដោយសទ្ធា ការប្រើប្រាស់ចីវរនោះ ប្រសើរជាង ។

ទុក្ខញ្ហេតំ ភន្តេ យំ ពលវា បុរិសោ តត្តេន អយោបដ្ដេន អាទិត្តេន សម្បជ្ជលិតេន សញ្ជោតិភូតេន កាយំ សម្បលិវេឋេយ្យាតិ ។ អាវេទយាមិ វោ ភិក្ខវេ បដិវេទយាមិ វោ ភិក្ខវេ យថា ឯតទេវ តស្ស វរំ ទុស្សីលស្ស ។ បេ ។ កសម្ពុជាតស្ស យំ ពលវា បុរិសោ តត្តេន អយោបដ្ដេន អាទិត្តេន សម្បជ្ជលិតេន សញ្ជោតិភូតេន កាយំ សម្បលិវេឋេយ្យ ។ តំ កិស្ស ហេតុ ។ តតោនិទានញ្ហិ សោ ភិក្ខវេ មរណំ វា និគច្ឆេយ្យ មរណមត្តំ វា ទុក្ខំ ន ត្វេវ តប្បច្ចយា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ ។ យញ្ច ខោ សោ ភិក្ខវេ ទុស្សីលោ ។ បេ ។ កសម្ពុជាតោ ខត្តិយមហាសាលានំ វា ព្រាហ្មណមហាសាលានំ វា គហបតិមហាសាលានំ សទ្ធាទេយ្យំ ចីវរំ បរិភុញ្ជតិ តញ្ហិ តស្ស ភិក្ខវេ ហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយ កាយស្ស ភេទា បរម្មរណា

បពិត្រព្រះអង្គដ៏ចំរើន បុរសមានកំឡាំង ស្រោបកាយដោយបន្ទះដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះភ្លឺច្រាលរន្ទាលសន្ធោសន្ធៅ ការស្រោបកាយដោយដែកដ៏ក្តៅនុ៎ះ ជាទុក្ខលំបាកវិញ ។ ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតពន្យល់អ្នកទាំងឡាយ បុរសមានកំឡាំង ស្រោបកាយដោយបន្ទះដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះភ្លឺច្រាលរន្ទាលសន្ធោសន្ធៅ ដោយហេតុណា ហេតុនុ៎ះ ប្រសើរជាង ។ ភិក្ខុទ្រុស្តសីល ។ បេ ។ មានចិត្តជ្រោកជ្រាកនោះ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុរសនោះ ដល់នូវសេចក្តីស្លាប់ ឬដល់នូវសេចក្តីទុក្ខ ស្មើនឹងស្លាប់ ព្រោះហេតុតែស្រោបកាយដោយបន្ទះដែកដ៏ក្តៅនោះប៉ុណ្ណោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏មិនទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែស្រោបកាយ ដោយបន្ទះដែកដ៏ក្តៅនោះទៀតទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទ្រុស្តសីលនោះ ។ បេ ។ មានចិត្តជ្រោកជ្រាក ប្រើប្រាស់ចីវររបស់ខត្តិយមហាសាលទាំងឡាយ ឬ ព្រាហ្មណមហាសាលទាំងឡាយ ឬក៏គហបតិមហាសាលទាំងឡាយ ដែលគេឲ្យដោយសទ្ធា ដោយហេតុណា ម្នាលភិក្ខុទាំងឡាយ ហេតុនោះ នាំឲ្យភិក្ខុនោះ បានសេចក្តីវិនាស សេចក្តីទុក្ខអស់កាលដ៏វែង លុះបែកធ្លាយរាងកាយស្លាប់ទៅ

អបាយំ ទុគ្គតិំ វិនិបាតំ និរយំ ឧបបជ្ជតិ ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ វរំ យំ ពលវា បុរិសោ តត្តេន អយោសង្កុនា អាទិត្តេន សម្បជ្ជលិតេន សជោតិភូតេន មុខំ វិវរិត្វា តត្តំ លោហគុឡំ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ មុខេ បក្ខិបេយ្យ តំ តស្ស ឱដ្ឋម្បិ ឌហេយ្យ មុខម្បិ ឌហេយ្យ ជិវ្ហម្បិ ឌហេយ្យ កណ្ឋម្បិ ឌហេយ្យ ឧរម្បិ ឌហេយ្យ អន្តម្បិ អន្តគុណម្បិ អាទាយ អធោភាគា និក្ខមេយ្យ យំ វា ខត្តិយមហាសាលានំ វា ព្រាហ្មណមហាសាលានំ វា គហបតិមហាសាលានំ វា សទ្ធាទេយ្យំ បិណ្ឌបាតំ បរិភុញ្ជេយ្យាតិ ។ ឯតទេវ ភន្តេ វរំ យំ ខត្តិយមហាសាលានំ វា ព្រាហ្មណមហាសាលានំ វា គហបតិមហាសាលានំ វា សទ្ធាទេយ្យំ បិណ្ឌបាតំ បរិភុញ្ជេយ្យ ។

ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់សេចក្តីនោះដូចម្តេច បុរសមានកម្លាំង បើកមាត់ដោយសណ្តាសដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះភ្លឺប្រាលន្រ្ទាលសន្ធោសន្ធៅ ហើយដាក់ដុំទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះភ្លឺប្រាលន្រ្ទាលសន្ធោសន្ធៅទៅក្នុងមាត់ ដុំទង់ដែងនោះរលាកបបូរមាត់បុរសនោះផង រលាកមាត់ផង រលាកអណ្តាតផង រលាកកផង រលាកទ្រូងផង រលួយទាំងពោះវៀនធំ ពោះវៀនតូច ធ្លាក់ហូតទៅខាងក្រោមផង ភិក្ខុឆាន់ចង្ហាន់បិណ្ឌបាត របស់ខត្តិយមហាសាលទាំងឡាយ ឬ ព្រាហ្មណមហាសាលទាំងឡាយ ឬក៏ គហបតិមហា-សាលទាំងឡាយ ដែលគេឲ្យដោយសទ្ធា ណាប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុឆាន់ចង្ហាន់របស់ខត្តិយមហាសាលទាំងឡាយ ឬ ព្រាហ្មណមហាសាលទាំងឡាយ ឬក៏គហបតិមហាសាលទាំងឡាយ ដែលគេឲ្យដោយសទ្ធា ការឆាន់ចង្ហាន់បិណ្ឌបាតនុ៎ះ ប្រសើរជាង ។

## បណ្ណាសកាតវគ្គហិតោ មហាវគ្គោ

ទុក្ខញ្ចេតំ ករ្តេ យំ ពលវា បុរិសោ តត្តេន អយោសង្កុនា អាទិត្តេន សម្បជ្ជលិតេន សជោតិភូតេន មុខំ វិវរិត្វា តត្តំ លោហគុលំ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ មុខេ បក្ខិបេយ្យ តំ តស្ស ឱដ្ឋម្បិ ឌហេយ្យ មុខម្បិ ឌហេយ្យ ជិវ្ហម្បិ ឌហេយ្យ កណ្ឋម្បិ ឌហេយ្យ ឧរម្បិ ឌហេយ្យ អន្តម្បិ អន្តគុណម្បិ អាទាយ អធោភាគា និក្ខមេយ្យាតិ ។ អារោចយាមិ វោ ភិក្ខវេ បដិវេទយាមិ វោ ភិក្ខវេ យថា ឯតទេវ តស្ស វរំ ទុស្សីលស្ស ។បេ។ កសម្ពុជាតស្ស យំ ពលវា បុរិសោ តត្តេន អយោសង្កុនា អាទិត្តេន សម្បជ្ជលិតេន សជោតិភូតេន មុខំ វិវរិត្វា តត្តំ លោហគុលំ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ មុខេ បក្ខិបេយ្យ តំ តស្ស ឱដ្ឋម្បិ ឌហេយ្យ មុខម្បិ ឌហេយ្យ ជិវ្ហម្បិ ឌហេយ្យ កណ្ឋម្បិ ឌហេយ្យ ឧរម្បិ ឌហេយ្យ អន្តម្បិ អន្តគុណម្បិ អាទាយ អធោភាគា និក្ខមេយ្យ ។ តំ កិស្ស ហេតុ ។

បពិត្រព្រះអង្គដ៏ចំរើន ឯបុរសមានកំឡាំង បើកមាត់ដោយសណ្ដាសដែកដ៏ក្ដៅ ដែលភ្លើងកំពុងឆេះ ភ្លឺច្រាលរន្ទាលសន្ធោសន្ធៅ ហើយដាក់ដុំទង់ដែងដ៏ក្ដៅ ដែលភ្លើងកំពុងឆេះភ្លឺច្រាលរន្ទាលសន្ធោសន្ធៅទៅក្នុងមាត់ ដុំទង់ដែងនោះ រលាកបបូរមាត់បុរសនោះផង រលាកមាត់ផង រលាកអណ្ដាតផង រលាកកផង រលាកទ្រូងផង រលាករលួយទាំងពោះវៀនធំ ពោះវៀនតូច ធ្លាក់ទៅខាងក្រោមផង ដោយហេតុណា ហេតុនុ៎ះ ជាទុក្ខលំបាកវិញ ។ ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតពន្យល់អ្នកទាំងឡាយ បុរសមានកំឡាំង បើកមាត់ដោយសណ្ដាសដែកដ៏ក្ដៅ ដែលភ្លើងកំពុងឆេះ ភ្លឺច្រាលរន្ទាលសន្ធោសន្ធៅ ហើយដាក់ដុំទង់ដែងដ៏ក្ដៅ ដែលភ្លើងកំពុងឆេះភ្លឺច្រាលរន្ទាលសន្ធោសន្ធៅទៅក្នុងមាត់ ដុំទង់ដែងនោះ រលាកបបូរមាត់បុរសនោះផង រលាកមាត់ផង រលាកអណ្ដាតផង រលាកកផង រលាកទ្រូងផង រលាករលួយទាំងពោះវៀនធំ ពោះវៀនតូច ធ្លាក់ហូតទៅខាងក្រោមផង ដោយហេតុណា ហេតុនុ៎ះ ប្រសើរជាងភិក្ខុទ្រុស្តសីល ។បេ។ មានចិត្តជ្រោកជ្រាកនោះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។

តតោនិទានញ្ហិ សោ ភិក្ខវេ មរណំ វា និគច្ឆេយ្យ មរណមត្តំ វា ទុក្ខំ ន ត្វេវ តប្បច្ចយា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ ។ យញ្ច ខោ សោ ភិក្ខវេ ទុស្សីលោ ។ បេ ។ កសម្ពុជាតោ ខត្តិយមហាសាលានំ វា ព្រាហ្មណមហាសាលានំ វា គហបតិមហាសាលានំ វា សទ្ធាទេយ្យំ បិណ្ឌបាតំ បរិភុញ្ជតិ តញ្ហិ តស្ស ភិក្ខវេ ហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ វរំ យំ ពលវា បុរិសោ សីសេ វា គហេត្វា ខន្ធេ វា គហេត្វា តត្តំ អយោមញ្ចំ វា អយោបីឋំ វា អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ អភិនិសីទាបេយ្យ វា អភិនិបជ្ជាបេយ្យ វា យំ វា ខត្តិយមហាសាលានំ វា ព្រាហ្មណមហាសាលានំ វា គហបតិមហាសាលានំ វា សទ្ធាទេយ្យំ មញ្ចបីឋំ បរិភុញ្ជេយ្យាតិ ។

ម្នាលភិក្ខុទាំងឡាយ ព្រោះបុរសនោះ ដល់នូវសេចក្តីស្លាប់ ឬ ដល់នូវសេចក្តីទុក្ខ ស្មើតែនឹងស្លាប់ ព្រោះហេតុតែដាក់ដុំទង់ដែងដ៏ក្តៅទៅក្នុងមាត់នោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏មិនទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ទៀត ព្រោះតែដាក់ដុំទង់ដែងដ៏ក្តៅទៅក្នុងមាត់នោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទ្រុស្តសីលនោះ ។ បេ ។ មានចិត្តជ្រោកជ្រាក ឆាន់បិណ្ឌបាត របស់ខត្តិយមហាសាលទាំងឡាយ ឬ ព្រាហ្មណមហាសាលទាំងឡាយ ឬក៏ គហបតិមហា-សាលទាំងឡាយ ដែលឲ្យដោយសទ្ធា ម្នាលភិក្ខុទាំងឡាយ ការឆាន់បិណ្ឌបាតនោះ នាំឲ្យភិក្ខុនោះ បាននូវសេចក្តីវិនាស សេចក្តីទុក្ខអស់កាលដ៏វែង លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់សេចក្តីនោះដូចម្តេច បុរសមានកំឡាំង ចាប់បុរសឯទៀត ត្រង់ក្បាល ឬ ត្រង់ក ហើយទង្គិចឲ្យអង្គុយ ឬ ឲ្យដេកលើគ្រែដែក ឬក៏ តាំងដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះ ភ្លឺច្រាលរន្ទាលសន្ធោសន្ធៅ ភិក្ខុប្រើប្រាស់គ្រែនិងតាំង របស់ខត្តិយមហាសាលទាំងឡាយ ឬ ព្រាហ្មណមហាសាលទាំងឡាយ ឬក៏ គហបតិមហា-សាលទាំងឡាយ ដែលឲ្យដោយសទ្ធា ណាប្រសើរជាង ។

ឯតទេវ ភន្តេ វរំ យំ ខត្តិយមហាសាលានំ វា ព្រាហ្មណមហាសាលានំ វា គហបតិមហាសាលានំ វា សទ្ធាទេយ្យំ មញ្ចបីឋំ បរិភុញ្ជេយ្យ ។ ទុក្ខញ្ហេតំ ភន្តេ យំ ពលវា បុរិសោ សីសេ វា គហេត្វា ខន្ធេ វា គហេត្វា តត្តំ អយោមញ្ចំ វា អយោបីឋំ វា អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ អភិនិសីទាបេយ្យ វា អភិនិបជ្ជាបេយ្យ វាតិ ។ អារោចយាមិ វោ ភិក្ខវេ បដិវេទយាមិ វោ ភិក្ខវេ យថា ឯតទេវ តស្ស វរំ ទុស្សីលស្ស ។ បេ ។ កសម្ពុជាតស្ស យំ ពលវា បុរិសោ សីសេ វា គហេត្វា ខន្ធេ វា គហេត្វា តត្តំ អយោមញ្ចំ វា អយោបីឋំ វា អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ អភិនិសីទាបេយ្យ វា អភិនិបជ្ជាបេយ្យ វា ។ តំ កិស្ស ហេតុ ។ តតោនិទានញ្ហិ សោ ភិក្ខវេ មរណំ វា និគច្ឆេយ្យ មរណមត្តំ វា ទុក្ខំ ន ត្វេវ តប្បច្ចយា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ ។

បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រើប្រាស់គ្រឿងតាំងរបស់ខត្តិយមហាសាលទាំងឡាយ ឬ ព្រាហ្មណមហាសាលទាំងឡាយ ឬក៏ គហបតិមហាសាលទាំងឡាយ ដែលឲ្យដោយសទ្ធា ការប្រើប្រាស់គ្រឿងតាំងនុ៎ះប្រសើរជាង ៗ បពិត្រព្រះអង្គដ៏ចំរើន បុរសមានកំឡាំង ចាប់ (បុរសឯទៀត) ត្រង់ក្បាល ឬ ត្រង់ក ហើយទង្គិចឲ្យអង្គុយ ឬ ដេកលើគ្រែដែក ឬ តាំងដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះ ក្ដីប្រហាលខ្លោលសន្ធោសន្ធៅ នុ៎ះជាទុក្ខលំបាកវិញទេ ៗ ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតពន្យល់អ្នកទាំងឡាយ បុរសដ៏មានកំឡាំង ចាប់ (បុរសឯទៀត) ត្រង់ក្បាល ឬត្រង់ក ហើយទង្គិចឲ្យអង្គុយ ឬ ដេកលើគ្រែដែក ឬ តាំងដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះ ក្ដីប្រហាលខ្លោលសន្ធោសន្ធៅ ការដេកនោះ ប្រសើរជាងភិក្ខុទ្រុស្តសីល ៗ បេ ៗ មានចិត្តជ្រោកជ្រាកនោះ ៗ ដំណើរនោះព្រោះហេតុអ្វី ៗ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុរសនោះ គ្រាន់តែដល់នូវសេចក្តីស្លាប់ ឬ ដល់នូវសេចក្តីទុក្ខ ស្មើរតែនឹងស្លាប់ ព្រោះហេតុតែអង្គុយ ឬ ដេកលើគ្រែ ឬ តាំងដ៏ក្តៅនោះ (ប៉ុណ្ណោះ) លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏មិនទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាតនរក ព្រោះតែអង្គុយ ឬ ដេកលើគ្រែ ឬ តាំងដ៏ក្តៅនោះ ទៀតទេ ៗ

យញ្ច ខោ សោ ភិក្ខវេ ទុស្សីលោ ។ បេ ។ កសម្ពុជាតោ ខត្តិយមហាសាលានំ វា ព្រាហ្មណមហាសាលានំ វា គហបតិមហាសាលានំ វា សទ្ធាទេយ្យំ មញ្ចបីឋំ បរិភុញ្ជតិ តញ្ហិ តស្ស ភិក្ខវេ ហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតិំ វិនិបាតំ និរយំ ឧបបជ្ជតិ ។ តំ កិំ មញ្ញថ ភិក្ខវេ កតមំ នុ ខោ វរំ យំ ពលវា បុរិសោ ឧទ្ធំបាទំ អវំសិរំ គហេត្វា តត្តាយ លោហកុម្ភិយា បក្ខិបេយ្យ អាទិត្តាយ សម្បជ្ជលិតាយ សជោតិភូតាយ សោ តត្ថ ផេណុទ្ទេហកំ បច្ចមានោ សកិម្បិ ឧទ្ធំ គច្ឆេយ្យ សកិម្បិ អធោ គច្ឆេយ្យ សកិម្បិ តិរិយំ គច្ឆេយ្យ យំ វា ខត្តិយមហាសាលានំ វា ព្រាហ្មណមហាសាលានំ វា គហបតិមហាសាលានំ វា សទ្ធាទេយ្យំ វិហារំ បរិភុញ្ជេយ្យាតិ ។ ឯតទេវ ភន្តេ វរំ យំ ខត្តិយមហាសាលានំ វា ព្រាហ្មណមហាសាលានំ វា គហបតិមហាសាលានំ វា សទ្ធាទេយ្យំ វិហារំ បរិភុញ្ជេយ្យ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុទ្រុស្តសីលនោះ ។ បេ ។ មានចិត្ត
ជ្រោកជ្រាក ប្រើប្រាស់គ្រែនឹងតាំង របស់ខត្តិយមហាសាលទាំង
ឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬក៏ គហបតិមហាសាលទាំង
ឡាយ ដែលឲ្យដោយសទ្ធា ម្នាលភិក្ខុទាំងឡាយ ការប្រើប្រាស់
នោះនាំឲ្យភិក្ខុនោះ បានសេចក្តីវិនាស សេចក្តីទុក្ខអស់កាលដ៏វែង
លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត
នរក (ថែមទៀត) ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ
សំគាល់សេចក្តីនោះ ដូចម្តេច បុរសមានកំឡាំង ចាប់ (បុរសឯទៀត)
យួរជើង (ទាំងពីរ) ឡើងលើ ឲ្យក្បាលសំយុងចុះក្រោម ហើយបោះទៅ
ក្នុងខ្ទះទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះ ភ្លឺប្រាលរន្ទាលសន្ធោសន្ធៅ
កាលបុរសនោះ កំពុងឆេះពុះផុលក្នុងខ្ទះនោះ អណ្តែតឡើងលើម្តង
លិចចុះក្រោមម្តង ទៅទទឹងម្តង ភិក្ខុប្រើប្រាស់វិហារ របស់ខត្តិយ-
មហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬក៏ គហ-
បតិមហាសាលទាំងឡាយ ដែលឲ្យដោយសទ្ធា ណាប្រសើរជាង ។
បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រើប្រាស់វិហារ របស់ខត្តិយមហាសាល
ទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬក៏គហបតិមហាសាល
ទាំងឡាយ ដែលឲ្យដោយសទ្ធា ការប្រើប្រាស់នុ៎ះប្រសើរជាង ។

ទុក្ខញ្ហេតំ កដ្តេ យំ ពលវា បុរិសោ ឧទ្ធំបាទំ អធោសិរំ គហេត្វា តត្តាយ លោហកុម្ភិយា បក្ខិបេយ្យ អាទិត្តាយ សម្បជ្ជលិតាយ សជោតិភូតាយ សោ តត្ថ ផេណុទ្ទេហកំ បច្ចមានោ សកិម្បិ ឧទ្ធំ គច្ឆេយ្យ សកិម្បិ អធោ គច្ឆេយ្យ សកិម្បិ តិរិយំ គច្ឆេយ្យាតិ ។ អារោចយាមិ វោ ភិក្ខវេ បដិវេទយាមិ វោ ភិក្ខវេ យថា ឯតទេវ តស្ស វរំ ទុស្សីលស្ស ។ បេ ។ កសម្ពុជាតស្ស យំ ពលវា បុរិសោ ឧទ្ធំបាទំ អធោសិរំ គហេត្វា តត្តាយ លោហកុម្ភិយា បក្ខិបេយ្យ អាទិត្តាយ សម្បជ្ជលិតាយ សជោតិភូតាយ សោ តត្ថ ផេណុទ្ទេហកំ បច្ចមានោ សកិម្បិ ឧទ្ធំ គច្ឆេយ្យ សកិម្បិ អធោ គច្ឆេយ្យ សកិម្បិ តិរិយំ គច្ឆេយ្យ ។ តំ កិស្ស ហេតុ ។ តតោនិទានញ្ហិ សោ ភិក្ខវេ មរណំ វា និគច្ឆេយ្យ មរណមត្តំ វា ទុក្ខំ ន ត្វេវ តប្បច្ចយា. កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតិំ វិនិបាតំ និរយំ ឧបបជ្ជតិ(១) ។

១ ឱ. ម. ឧបបជ្ជេយ្យ ។

បពិត្រព្រះអង្គដ៏ចំរើន បុរសមានកំឡាំង ចាប់ ( បុរសឯទៀត ) យួរជើង ( ទាំងពីរ ) ឡើងលើ ឲ្យក្បាលសំយុងចុះក្រោម ហើយបោះទៅក្នុងខ្ទះទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះ ភ្លឺប្រាលរន្ទាលសន្ធោសន្ធៅ កាលបុរសនោះ កំពុងឆេះពុះពុល ក្នុងខ្ទះទង់ដែងនោះ ក៏អណ្តែតឡើងលើម្តង លិចចុះក្រោមម្តង ទៅទទឹងម្តង ការនុះ ជាទុក្ខលំបាកវិញ ។ ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតពន្យល់អ្នកទាំងឡាយ បុរសមានកំឡាំង ចាប់ ( បុរសឯទៀត ) យួរជើង ( ទាំងពីរ ) ឡើងលើ ឲ្យក្បាលសំយុងចុះក្រោម ហើយបោះទៅ ក្នុងខ្ទះទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះ ភ្លឺប្រាល រន្ទាលសន្ធោសន្ធៅ កាលបុរសនោះ កំពុងឆេះពុះពុល ក្នុងខ្ទះទង់ដែងនោះ អណ្តែតឡើងលើម្តង លិចចុះក្រោមម្តង ទៅទទឹងម្តង ការនុះ ប្រសើរជាងភិក្ខុទ្រុស្តសីល ។ បេ ។ មានចិត្តជ្រោកជ្រាកនោះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះបុរសនោះ ដល់នូវសេចក្តីស្លាប់ ឬ ដល់នូវសេចក្តីទុក្ខ ស្មើនឹងស្លាប់ ព្រោះហេតុតែគេបោះទៅក្នុងខ្ទះទង់ដែងដ៏ក្តៅនោះ លុះដល់បែកធ្លាយរាងកាយស្លាប់ទៅ ក៏មិនទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែគេបោះទៅក្នុងខ្ទះទង់ដែង ដ៏ក្តៅនោះទៀតឡើយ ។

យញ្ច ខោ សោ ភិក្ខវេ ទុស្សីលោ ។ បេ ។ កសម្ពុជាតោ ខត្តិយមហាសាលានំ វា ព្រាហ្មណមហាសាលានំ វា គហបតិមហាសាលានំ វា សទ្ធាទេយ្យំ វិហារំ បរិភុញ្ជតិ តញ្ហិ តស្ស ភិក្ខវេ ហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ យេសញ្ច មយំ បរិភុញ្ជាម ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ តេសំ តេ ការា មហប្ផលា ភវិស្សន្តិ មហានិសំសា អម្ហាកញ្ចេវាយំ បព្វជ្ជា អវញ្ឈា ភវិស្សតិ សផលា សឧទ្រយាតិ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។ អត្តត្ថំ វា ភិក្ខវេ សម្បស្សមានេន អលមេវ អប្បមាទេន សម្បាទេតុំ បរត្ថំ វា ភិក្ខវេ សម្បស្សមានេន អលមេវ អប្បមាទេន សម្បាទេតុំ ឧភយត្ថំ វា ភិក្ខវេ សម្បស្សមានេន អលមេវ អប្បមាទេន សម្បាទេតុន្តិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុទ្រុស្តសីលនោះ ។បេ។ មានចិត្តជ្រោកជ្រាក ប្រើប្រាស់វិហារ របស់ខត្តិយមហាសាលទាំងឡាយ ឬ ព្រាហ្មណមហាសាលទាំងឡាយ ឬក៏ គហបតិមហាសាលទាំងឡាយ ដែលឲ្យដោយសទ្ធា ម្នាលភិក្ខុទាំងឡាយ ការប្រើប្រាស់នោះ នាំឲ្យភិក្ខុនោះ បានសេចក្តីវិនាស សេចក្តីទុក្ខ អស់កាលដ៏វែង លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក (ថែមទៀត) ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ពួកភិក្ខុក្នុងសាសនានេះ ត្រូវសិក្សាយ៉ាងនេះថា យើងបរិភោគប្រើប្រាស់ ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ របស់ពួកបុគ្គលណា បច្ចយទានទាំងនោះ នឹងមានផលច្រើន មានអានិសង្សច្រើន ដល់ពួកបុគ្គលទាំងនោះ ឯបព្វជ្ជារបស់យើងនេះ មានផល មានប្រយោជន៍ (មិនមែនឥតអំពើទេ) ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសិក្សាយ៉ាងនេះ ។

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុ ឃើញប្រយោជន៍របស់ខ្លួនច្បាស់ហើយ គួរដើម្បីញុំាងកិច្ចឲ្យសម្រេចដោយសេចក្តីមិនប្រមាទផង

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុ ឃើញប្រយោជន៍របស់អ្នកដទៃច្បាស់ហើយ គួរដើម្បីញុំាងកិច្ចឲ្យសម្រេចដោយសេចក្តីមិនប្រមាទផង

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុ ឃើញប្រយោជន៍ទាំងពីរច្បាស់ហើយ គួរដើម្បីញុំាងកិច្ចឲ្យសម្រេចដោយសេចក្តីមិនប្រមាទផង ។

ឥទមវោច ភគវា ឥមស្មិញ្ច បន វេយ្យាករណស្មិំ ភញ្ញមានេ សដ្ឋិមត្តានំ ភិក្ខូនំ ឧណ្ហំ លោហិតំ មុខតោ ឧគ្គញ្ឆិ សដ្ឋិមត្តា ភិក្ខូ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តឹសុ ទុក្ករំ ភគវា សុទុក្ករំ ភគវាតិ សដ្ឋិមត្តានំ ភិក្ខូនំ អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចឹសូតិ ។

(៧០) ភូតបុព្វំ ភិក្ខវេ សុនេត្តោ នាម សត្ថា អហោសិ តិត្ថករោ កាមេសុ វីតរាគោ ។ សុនេត្តស្ស ខោ បន ភិក្ខវេ សត្ថុនោ អនេកានិ សាវកសតានិ អហេសុំ ។ សុនេត្តោ សត្ថា សាវកានំ ព្រហ្មលោកសហព្យតាយ ធម្មំ ទេសេតិ ។ យេ ខោ បន ភិក្ខវេ សុនេត្តស្ស សត្ថុនោ ព្រហ្មលោកសហព្យតាយ ធម្មំ ទេសេន្តស្ស ចិត្តានិ នប្បសាទេសុំ តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជឹសុ ។ យេ ខោ បន ភិក្ខវេ សុនេត្តស្ស សត្ថុនោ ព្រហ្មលោកសហព្យតាយ ធម្មំ ទេសេន្តស្ស ចិត្តានិ បសាទេសុំ

ព្រះដ៏មានព្រះភាគ បានទ្រង់ត្រាស់ភាសិតនេះហើយ កាលព្រះដ៏មានព្រះភាគ សំដែងវេយ្យាករណ៍នេះចប់ហើយ ពួកភិក្ខុទាំង ៦០ រូប ក្អួតសុទ្ធតែឈាមក្តៅ ៗ តាមមាត់ ពួកភិក្ខុ ៦០ រូបទៀត លះបង់សិក្ខា ត្រឡប់ទៅកាន់ភេទថោកទាប ព្រោះមានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគ សំដែងនូវអំពើដែលគេធ្វើបានដោយក្រ ព្រះដ៏មានព្រះភាគ សំដែងនូវអំពើដែលគេមិនងាយធ្វើកើត ពួកភិក្ខុ ៦០ រូបទៀត មានចិត្តរួចស្រឡះ ចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ៗ

(៧០) ម្នាលភិក្ខុទាំងឡាយ កាលពីដើម មានគ្រូឈ្មោះសុនេត្តៈ ជាអ្នកធ្វើនូវកំពង់ ជាទីទៅកាន់សុគតិភព ជាអ្នកប្រាសចាកតម្រេក ក្នុងកាមទាំងឡាយ ៗ ម្នាលភិក្ខុទាំងឡាយ ឯគ្រូឈ្មោះសុនេត្តៈ មានសាវកច្រើនរយ ៗ ក៏គ្រូឈ្មោះសុនេត្តៈ តែងសំដែងធម៌ ដើម្បីដឹកនាំសាវកទាំងឡាយ ឲ្យទៅកើតក្នុងព្រហ្មលោក ៗ ម្នាលភិក្ខុទាំងឡាយ ពួកសាវកណា មិនបានញុំាងចិត្តឲ្យជ្រះថ្លា ចំពោះគ្រូឈ្មោះសុនេត្តៈ ដែលសំដែងធម៌ ដើម្បីដឹកនាំឲ្យទៅកើតក្នុងព្រហ្មលោក ពួកសាវកនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ៗ ម្នាលភិក្ខុទាំងឡាយ ពួកសាវកណា បានញុំាងចិត្តឲ្យជ្រះថ្លា ចំពោះគ្រូឈ្មោះសុនេត្តៈដែលសំដែងធម៌ ដើម្បីដឹកនាំឲ្យទៅកើត ក្នុងព្រហ្មលោកហើយ

តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជឹសុ ។ ភូតបុព្វំ ភិក្ខវេ មូគបក្ខា នាម សត្ថា អហោសិ ។ បេ ។ អរនេមិ នាម សត្ថា អហោសិ ។ បេ ។ កុទ្ទាលោ នាម សត្ថា អហោសិ ។ បេ ។ ហត្ថិបាលោ នាម សត្ថា អហោសិ ។ បេ ។ ជោតិបាលោ នាម សត្ថា អហោសិ ។ បេ ។ អរកោ នាម សត្ថា អហោសិ តិត្ថករោ កាមេសុ វីតរាគោ ។ អរកស្ស ខោ បន ភិក្ខវេ សត្ថុនោ អនេកានិ សាវកសតានិ អហេសុំ ។ អរកោ នាម សត្ថា សាវកានំ ព្រហ្មលោកសហព្យតាយ ធម្មំ ទេសេតិ ។ យេ ខោ បន ភិក្ខវេ អរកស្ស សត្ថុនោ ព្រហ្មលោក-សហព្យតាយ ធម្មំ ទេសេន្តស្ស ចិត្តានិ នប្បសាទេសុំ តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជឹសុ ។ យេ ខោ បន ភិក្ខវេ អរកស្ស សត្ថុនោ ព្រហ្មលោកសហព្យតាយ ធម្មំ ទេសេន្តស្ស ចិត្តានិ បសាទេសុំ តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជឹសុ ។

ពួកសាវកនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ កាលពីដើម មានគ្រូឈ្មោះមូគបក្ខៈ ។ បេ ។ មានគ្រូឈ្មោះអរនេមិ ។ បេ ។ មានគ្រូឈ្មោះកុទ្ទាលៈ ។ បេ ។ មានគ្រូឈ្មោះហត្ថិបាល ។ បេ ។ មានគ្រូឈ្មោះជោតិបាល ។ បេ ។ មានគ្រូឈ្មោះអរកៈ ជាអ្នកធ្វើនូវកំពង់ជាទីទៅកាន់សុគតិភព ជាអ្នកប្រាសចាកតម្រេក ក្នុងកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ឯគ្រូឈ្មោះអរកៈមានសាវកច្រើនរយ ។ គ្រូឈ្មោះអរកៈតែងសំដែងធម៌ ដើម្បីដឹកនាំសាវកទាំងឡាយ ឲ្យទៅកើតក្នុងព្រហ្មលោក ។ ម្នាលភិក្ខុទាំងឡាយ ពួកសាវកណា មិនបានញុំាងចិត្តឲ្យជ្រះថ្លា ចំពោះគ្រូឈ្មោះអរកៈ ដែលសំដែងធម៌ ដើម្បីដឹកនាំឲ្យទៅកើតក្នុងព្រហ្មលោកទេ ពួកសាវកទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុទាំងឡាយ បើពួកសាវកណា បានញុំាងចិត្តឲ្យជ្រះថ្លា ចំពោះគ្រូឈ្មោះអរកៈ ដែលសំដែងធម៌ ដើម្បីដឹកនាំឲ្យទៅកើតក្នុងព្រហ្មលោកហើយ ពួកសាវកនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។

តំ កឹ មញ្ញថ ភិក្ខវេ យោ ឥមេ សត្ត សត្ថារេ តិត្ថ-ករេ កាមេសុ វីតរាគេ អនេកសតបរិវារេ សសាវក-សង្ឃេ បទុដ្ឋចិត្តោ អក្កោសេយ្យ បរិភាសេយ្យ ពហុំ សោ អបុញ្ញំ បសវេយ្យាតិ ។ ឯវំ ភន្តេ ។ យោ ភិក្ខវេ ឥមេ សត្ត សត្ថារេ តិត្ថករេ កាមេសុ វីតរាគេ អនេកសតបរិវារេ សសាវកសង្ឃេ បទុដ្ឋចិត្តោ អក្កោសេយ្យ បរិភាសេយ្យ ពហុំ សោ អបុញ្ញំ បសវេយ្យ យោ ឯកំ ទិដ្ឋិសម្បន្នំ បុគ្គលំ បទុដ្ឋចិត្តោ អក្កោសតិ បរិភាសតិ អយំ តតោ ពហុតរំ អបុញ្ញំ បសវតិ ។ តំ កិស្ស ហេតុ ។ នាហំ ភិក្ខវេ ឥតោ ពហិទ្ធា ឯវរូបឹ ខន្តឹ វទាមិ យថា មំ សព្រហ្ម-ចារីសុ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ ន នោ អម្ហំ(១) សព្រហ្មចារីសុ ចិត្តានិ បទុដ្ឋានិ ភវិស្សន្តីតិ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

---

១ ឱ. ម. ន នោ សព្រហ្មចារីសុ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់ហេតុនោះ ដូចម្តេច អ្នកណា មានចិត្តប្រទូស្ត ជេរប្រទេច ផ្ដាសានូវគ្រូទាំង ៧ នេះ ជាអ្នកធ្វើនូវកំពង់ ជាទីទៅកាន់សុគតិភព ជាអ្នកប្រាសចាកតម្រេក ក្នុងកាមទាំងឡាយ មានបរិវារច្រើនរយ ប្រកបដោយពួកសាវក អ្នកនោះឈ្មោះថា សន្សំនូវបាបច្រើនដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន យ៉ាងនោះមែន ។ ម្នាលភិក្ខុទាំងឡាយ អ្នកណា មានចិត្តប្រទូស្ត ជេរប្រទេច ផ្ដាសាគ្រូទាំង ៧ នេះ ជាអ្នកធ្វើនូវកំពង់ ជាទីទៅកាន់សុគតិភព ជាអ្នកប្រាសចាកតម្រេក ក្នុងកាមទាំងឡាយ មានបរិវារច្រើនរយ ប្រកបដោយពួកសាវក អ្នកនោះ ឈ្មោះថា សន្សំបាបដ៏ច្រើន អ្នកណាមានចិត្តប្រទូស្ត ជេរប្រទេច ផ្ដាសាបុគ្គលម្នាក់ ដែលបរិបូណ៌ដោយទិដ្ឋិ (សោតាបន្នបុគ្គល) អ្នកនេះ ឈ្មោះថា សន្សំនូវបាបដ៏ច្រើនជាងនោះទៅទៀត ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះតថាគត មិនហៅការជេរប្រទេច ពួកសព្រហ្មចារីបុគ្គលនេះ ថាជាខន្តិ មានសភាពយ៉ាងនេះ ខាងក្រៅអំពីខន្តិនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ ត្រូវសិក្សាយ៉ាងនេះថា ចិត្តទាំងឡាយរបស់យើង នឹងមិនបានប្រទូស្ត ពួកសព្រហ្មចារីបុគ្គល ដូច្នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសិក្សាយ៉ាងនេះ ។

(៧១) ភូតបុព្វំ ភិក្ខវេ អរកោ នាម សត្ថា អហោសិ តិត្ថករោ កាមេសុ វីតរាគោ ។ អរកស្ស ខោ បន ភិក្ខវេ សត្ថុនោ អនេកានិ សាវកសតានិ អហេសុំ ។ អរកោ សត្ថា សាវកានំ ឯវំ ធម្មំ ទេសេតិ អប្បកំ ព្រាហ្មណា ជីវិតំ មនុស្សានំ បរិត្តំ លហុកំ ពហុទុក្ខំ ពហុបាយាសំ មន្តាយ ពោទ្ធព្វំ កត្តព្វំ កុសលំ ចរិតព្វំ ព្រហ្មចរិយំ នត្ថិ ជាតស្ស អមរណំ ។ សេយ្យថាបិ ព្រាហ្មណា តិណគ្គេ ឧស្សាវពិន្ទុ សុរិយេ ឧគ្គច្ឆន្តេ ខិប្បំយេវ បដិវិគច្ឆតិ ន ចិរដ្ឋិតិកំ ហោតិ ឯវមេវ ខោ ព្រាហ្មណា ឧស្សាវពិន្ទូបមំ ជីវិតំ មនុស្សានំ បរិត្តំ លហុកំ ពហុទុក្ខំ ពហុបាយាសំ ។ មន្តាយ ពោទ្ធព្វំ កត្តព្វំ កុសលំ ចរិតព្វំ ព្រហ្មចរិយំ នត្ថិ ជាតស្ស អមរណំ ។ សេយ្យថាបិ ព្រាហ្មណា ថុល្លផុសិតកេ ទេវេ វស្សន្តេ ឧទកពុព្វុឡំ(១) ខិប្បំយេវ បដិវិគច្ឆតិ ន ចិរដ្ឋិតិកំ ហោតិ

---

១ ឱ. ឧទកេ ឧទកពុព្វុឡំ ។ ម. ឧទកេ ឧទកបុប្ផុឡំ ។

(៧១) ម្នាលភិក្ខុទាំងឡាយ កាលពីដើម មានគ្រូឈ្មោះអរកៈ ជាអ្នកធ្វើនូវកំពង់ ជាទីទៅកាន់សុគតិភព ជាអ្នកប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ឯគ្រូឈ្មោះអរកៈ មានសាវកច្រើនរយ ។ គ្រូឈ្មោះអរកៈ រមែងសំដែងធម៌ដល់សាវកទាំងឡាយ យ៉ាងនេះថា ម្នាលព្រាហ្មណ៍ ជីវិតពួកមនុស្ស ជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ។ អ្នកទាំងឡាយ ត្រូវដឹង ត្រូវធ្វើនូវកុសល ត្រូវប្រព្រឹត្តនូវព្រហ្មចរិយធម៌ ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយ សុទ្ធតែស្លាប់ ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ប្រៀបដូចដំណក់ទឹកសន្សើម លើចុងស្មៅ ដល់ព្រះអាទិត្យ រះឡើង ក៏ត្រឡប់បាត់វិញឆាប់រហ័ស ជារបស់មិនឋិតថេរ នៅយូរយារបាន យ៉ាងណា ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្ស ជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ប្រៀបដូចដំណក់ទឹកសន្សើម យ៉ាងនោះដែរ ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើនូវកុសល ត្រូវប្រព្រឹត្តនូវព្រហ្មចរិយធម៌ ដោយប្រាជ្ញា សត្វដែលកើតហើយ សុទ្ធតែស្លាប់ ។ ម្នាលព្រាហ្មណ៍ ប្រៀបដូចភ្លៀង មានដំណក់ដ៏ថ្លោសធ្លាក់ចុះមក ក្រពេញទឹក ក៏ត្រឡប់បាត់ទៅវិញឆាប់ មិនឋិតថេរយូរយារបាន យ៉ាងណាមិញ

ឯវមេវ ខោ ព្រាហ្មណ ឧទកពុព្ពុឡុបមំ ជីវិតំ មនុស្សានំ បរិត្តំ លហុកំ ពហុទុក្ខំ ពហុបាយាសំ ។ មន្តាយ ពោទ្ធព្វំ កត្តព្វំ កុសលំ ចរិតព្វំ ព្រហ្មចរិយំ នត្ថិ ជាតស្ស អមរណំ ។ សេយ្យថាបិ ព្រាហ្មណ ឧទកេ ទណ្ឌរាជិ ខិប្បំយេវ បដិវិគច្ឆតិ ន ចិរដ្ឋិតិកា ហោតិ ឯវមេវ ខោ ព្រាហ្មណ ឧទកេ ទណ្ឌរាជុបមំ ជីវិតំ មនុស្សានំ បរិត្តំ លហុកំ ... នត្ថិ ជាតស្ស អមរណំ ។ សេយ្យថាបិ ព្រាហ្មណ នទី បព្វតេយ្យា ទូរង្គមា សីឃសោតា ហារហារិនី នត្ថិ សោ ខណោ វា លយោ វា មុហុត្តោ វា យំ សា ចរតិ(១) អថខោ សា គច្ឆតេ ច វត្តតេ ច សន្ទតេ(២) ច ឯវមេវ ខោ ព្រាហ្មណ នទីបព្វតេយ្យុបមំ ជីវិតំ មនុស្សានំ បរិត្តំ លហុកំ ... នត្ថិ ជាតស្ស អមរណំ ។ សេយ្យថាបិ ព្រាហ្មណ ពលវា បុរិសោ ជិវ្ហគ្គេ ខេឡបិណ្ឌំ សញ្ញូហិត្វា អកសិរេនេវ វមេយ្យ

---

១ ឱ. យំ សា អារមតិ ។ ម. យាយ អាវត្តតិ ។ ២ ឱ. ម. គច្ឆតេវ វត្តតេវ សន្ទតេវ ។

ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្ស ជារបស់តិច ខ្លី មានសេចក្តីទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ប្រៀបដូចជាក្រពេញទឹក យ៉ាងនោះដែរ ។ អ្នកទាំងឡាយ ត្រូវដឹង ត្រូវធ្វើនូវកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយ សុទ្ធតែស្លាប់ ៗ ម្នាលព្រាហ្មណ៍ ប្រៀបដូចស្នាមគំនូសដម្បងលើទឹក តែងត្រឡប់បាត់ទៅវិញឆាប់ មិនឋិតនៅយូរយារបាន យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្ស ជារបស់តិច ខ្លី.. ប្រៀបដូចជាស្នាមគំនូសដម្បងលើទឹក យ៉ាងនោះដែរ ព្រោះសត្វដែលកើតហើយ សុទ្ធតែស្លាប់ទៅវិញ ៗ ម្នាលព្រាហ្មណ៍ ប្រៀបដូចស្ទឹងហូរពីភ្នំ ហូរទៅកាន់ទីឆ្ងាយ មានខ្សែទឹករហ័ស កាចនាំ វត្ថុរបស់ដែលគួរនាំទៅបាន គ្មានកំណត់កាល កំណត់វេលា កំណត់យាមឡើយ ព្រោះស្ទឹងនោះចេះតែទៅ ចេះតែប្រព្រឹត្តទៅ ចេះតែហូរទៅបាន យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្ស ជារបស់តិច ខ្លី ប្រៀបដូចជាស្ទឹងហូរពីភ្នំ ... យ៉ាងនោះដែរ ព្រោះសត្វដែលកើតហើយ សុទ្ធតែស្លាប់ទៅវិញ ៗ ម្នាលព្រាហ្មណ៍ ប្រៀបដូចបុរសដែលមានកម្លាំង គ្រលៀវដុំទឹកមាត់ដាក់លើចុងអណ្តាត ហើយស្តោះចោលទៅ ដោយងាយបាន យ៉ាងណាមិញ

ឯវមេវ ខោ ព្រាហ្មណ ខេឡបិណ្ឌូបមំ ជីវិតំ មនុស្សានំ បរិត្តំ លហុកំ ... នត្ថិ ជាតស្ស អមរណំ ។ សេយ្យថាបិ ព្រាហ្មណ ទិវសសន្តត្តេ អយោកដាហេ មំសបេសិ បក្ខិត្តា ខិប្បំយេវ បដិវិគច្ឆតិ ន ចិរដ្ឋិតិកា ហោតិ ឯវមេវ ខោ ព្រាហ្មណ មំសបេសូបមំ ជីវិតំ មនុស្សានំ បរិត្តំ លហុកំ ... នត្ថិ ជាតស្ស អមរណំ ។ សេយ្យថាបិ ព្រាហ្មណ គាវី វជ្ឈា អាឃាតនំ នីយមានា យញ្ញទេវ បាទំ ឧទ្ធរតិ សន្តិកេ វធស្ស សន្តិកេ មរណស្ស(១) ឯវមេវ ខោ ព្រាហ្មណ គាវីវជ្ឈូបមំ(២) ជីវិតំ មនុស្សានំ បរិត្តំ លហុកំ ពហុទុក្ខំ ពហុបាយាសំ ។ មន្តាយ ពោទ្ធព្វំ កត្តព្វំ កុសលំ ចរិតព្វំ ព្រហ្មចរិយំ នត្ថិ ជាតស្ស អមរណន្តិ ។ តេន ខោ បន ភិក្ខវេ សមយេន មនុស្សានំ សដ្ឋិវស្សសហស្សានិ អាយុប្បមាណំ អហោសិ ។ បញ្ចវស្សសតិកា កុមារិកា អលំបតេយ្យា អហោសិ ។

---

១ ឱ. ម. សន្តិកេវ ហោតិ វធស្ស សន្តិកេវ មរណស្ស ។ ២ ឱ. ម. គាវីវជ្ឈូបមំ ។

ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្ស ជារបស់តិច ខ្លី ប្រៀប
ដូចដុំទឹកមាត់ ... យ៉ាងនោះដែរ ព្រោះសត្វដែលកើតហើយ
សុទ្ធតែស្លាប់វិញ ។ ម្នាលព្រាហ្មណ៍ ដូចជាដុំសាច់ដែល
គេយកទៅដាក់ ក្នុងខ្ទះដែកដ៏ក្តៅ អស់មួយថ្ងៃ រមែងខ្ទាចបជ្រុះ
ឆាប់ មិនឋិតថេរយូរយារបាន យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ ជីវិត
របស់ពួកមនុស្ស ជារបស់តិច ខ្លី ប្រៀបដូចដុំសាច់ ... យ៉ាងនោះ
ដែរ ព្រោះសត្វដែលកើតហើយ សុទ្ធតែស្លាប់ ។ ម្នាលព្រាហ្មណ៍
ដូចមេគោដែលត្រូវសម្លាប់ ដែលគេនាំទៅកាន់កន្លែងសម្លាប់ ឈានជំ-
ហានណាទៅ ឈ្មោះថា ខិតទៅជិតកន្លែងសម្លាប់ ជិតសេចក្តីស្លាប់ យ៉ាង
ណាមិញ ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្ស ជារបស់តិច ខ្លី មាន
ទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ប្រៀបដូចជាមេគោ ដែល
ត្រូវសម្លាប់ យ៉ាងនោះដែរ ។ អ្នកទាំងឡាយ ត្រូវដឹង ត្រូវធ្វើនូវកុសល
ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយ សុទ្ធ
តែស្លាប់ ។ ម្នាលភិក្ខុទាំងឡាយ សម័យនោះឯង ពួកមនុស្ស មានអាយុ
ប្រាំមួយហ្មឺនឆ្នាំ ។ កុមារិកាមានអាយុត្រឹមប្រាំរយឆ្នាំ ទើបល្មមមានប្តី ។

តេន ខោ បន ភិក្ខវេ សមយេន មនុស្សានំ ឆឡេវាពាធា អហេសុំ សីតំ ឧណ្ហំ ជិឃច្ឆា បិបាសា ឧច្ចារោ បស្សាវោ ។ សោ ហិ នាម ភិក្ខវេ អរកោ សត្ថា ឯវំ ទីឃាយុកេសុ មនុស្សេសុ ឯវំ ចិរដ្ឋិតិកេសុ ឯវំ អប្បាពាធេសុ សាវកានំ ឯវំ ធម្មំ ទេសេស្សតិ អប្បកំ ព្រាហ្មណា ជីវិតំ មនុស្សានំ បរិត្តំ លហុកំ ពហុទុក្ខំ ពហុបាយាសំ ។ មន្តាយ ផោដ្ឋព្វំ កត្តព្វំ កុសលំ ចរិតព្វំ ព្រហ្មចរិយំ នត្ថិ ជាតស្ស អមរណន្តិ ។ ឯតរហិ[១] ភិក្ខវេ សម្មា វទមានោ វទេយ្យ អប្បកំ ជីវិតំ មនុស្សានំ បរិត្តំ លហុកំ ពហុទុក្ខំ ពហុបាយាសំ ។ មន្តាយ ផោដ្ឋព្វំ កត្តព្វំ កុសលំ ចរិតព្វំ ព្រហ្មចរិយំ នត្ថិ ជាតស្ស អមរណន្តិ ។ ឯតរហិ ភិក្ខវេ យោ ចិរំ ជីវតិ សោ វស្សសតំ អប្បំ វា ភិយ្យោ វា ។ វស្សសតំ ខោ បន ភិក្ខវេ ជីវន្តោ តីណិយេវ ឧតុសតានិ ជីវតិ ឧតុសតំ ហេមន្តានំ ឧតុសតំ គិម្ហានំ

---

១ ឱ. ឯតរហិ ខោ តំ ។

ម្នាលភិក្ខុទាំងឡាយ សម័យនោះឯង ពួកមនុស្សមានតែអាពាធ ៦ យ៉ាងគឺ រងា ១ ស្អុះ ១ ឃ្លាន ១ ស្រេក ១ ឈឺឧច្ចារៈ ១ ឈឺបស្សាវៈ ១ ៗ ម្នាលភិក្ខុទាំងឡាយ គ្រូឈ្មោះអរកៈនោះ អម្បាលពួកមនុស្សមានអាយុវែងយ៉ាងនេះ ឋិតនៅយូរយ៉ាងនេះ មានអាពាធតិចយ៉ាងនេះ ស្តេចគង់សំដែងធម៌ដល់ពួកសាវកយ៉ាងនេះថា ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្ស ជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ៗ អ្នកទាំងឡាយ ត្រូវដឹង ត្រូវធ្វើនូវកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយ សុទ្ធតែស្លាប់ ៗ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ បើបុគ្គលនិយាយឲ្យត្រូវ ត្រូវនិយាយថា ជីវិតរបស់ពួកមនុស្ស ជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ៗ បុគ្គលត្រូវដឹង ត្រូវធ្វើនូវកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយ សុទ្ធតែស្លាប់ ៗ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ បុគ្គល រស់នៅយ៉ាងយូរ ត្រឹមមួយរយឆ្នាំ ឬ តិចជាង ឬក៏ លើសពីមួយរយឆ្នាំបន្តិចបន្តួច ៗ ម្នាលភិក្ខុទាំងឡាយ ក៏បុគ្គលដែលរស់នៅបានមួយរយឆ្នាំ ឈ្មោះថា រស់នៅអស់បីរយរដូវ គឺហេមន្តរដូវ មួយរយ គិម្ហរដូវ មួយរយ

ឧតុសតំ វស្សានំ ។ តីណិ ខោ បន ភិក្ខវេ ឧតុ-
សតានិ ជីវន្តោ ទ្វាទសយេវ មាសសតានិ ជីវតិ
ចត្តារិ មាសសតានិ ហេមន្តានំ ចត្តារិ មាសសតានិ
គិម្ហានំ ចត្តារិ មាសសតានិ វស្សានំ ។ ទ្វាទស ខោ
បន ភិក្ខវេ មាសសតានិ ជីវន្តោ ចតុវីសតិយេវ អឌ្ឍ-
មាសសតានិ ជីវតិ អដ្ឋឌ្ឍមាសសតានិ ហេមន្តានំ អដ្ឋ-
ឌ្ឍមាសសតានិ គិម្ហានំ អដ្ឋឌ្ឍមាសសតានិ វស្សានំ ។
ចតុវីសតិ ខោ បន ភិក្ខវេ អឌ្ឍមាសសតានិ ជីវន្តោ
ឆត្តឹសំយេវ រត្តិសហស្សានិ ជីវតិ ទ្វាទស រត្តិសហស្សានិ
ហេមន្តានំ ទ្វាទស រត្តិសហស្សានិ គិម្ហានំ ទ្វាទស
រត្តិសហស្សានិ វស្សានំ ។ ឆត្តឹសំ ខោ បន ភិក្ខវេ
រត្តិសហស្សានិ ជីវន្តោ ទ្វេសត្តតិញ្ញេវ ភត្តសហស្សានិ
ភុញ្ជតិ ចតុវីសតិ ភត្តសហស្សានិ ហេមន្តានំ ចតុ-
វីសតិ ភត្តសហស្សានិ គិម្ហានំ ចតុវីសតិ ភត្ត-
សហស្សានិ វស្សានំ សទ្ធឹ មាតុថញ្ញាយ សទ្ធឹ
ភត្តន្តរាយេន ។ តត្រិមេ ភត្តន្តរាយា កុបិតោបិ ភត្តំ
ន ភុញ្ជតិ ទុក្ខិតោបិ ភត្តំ ន ភុញ្ជតិ ព្យាធិតោបិ
ភត្តំ ន ភុញ្ជតិ ឧបោសថិកោបិ ភត្តំ ន ភុញ្ជតិ

វស្សានរដូវ មួយរយ ។ ម្នាលភិក្ខុទាំងឡាយ ក៏បុគ្គលដែលរស់នៅអស់បីរយរដូវ ឈ្មោះថា រស់នៅមួយពាន់ពីររយខែ គឺហេមន្តរដូវ បួនរយខែ គិម្ហរដូវ បួនរយខែ វស្សានរដូវ បួនរយខែ ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គល រស់នៅអស់មួយពាន់ពីររយខែហើយ បើកប់ជាកន្លះ ៗ ខែ ឈ្មោះថា រស់នៅអស់ពីរពាន់បួនរយកន្លះ ៗ ខែគឺ ហេមន្តរដូវ ប្រាំបីរយកន្លះខែ គិម្ហរដូវ ប្រាំបីរយកន្លះខែ វស្សានរដូវ ប្រាំបីរយកន្លះខែ ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គល រស់នៅអស់ពីរពាន់បួនរយកន្លះ ៗ ខែហើយ ឈ្មោះថា រស់នៅអស់បីហ្មឺនប្រាំមួយពាន់រាត្រី គឺហេមន្តរដូវ មួយហ្មឺនពីរពាន់រាត្រី គិម្ហរដូវ មួយហ្មឺនពីរពាន់រាត្រី វស្សានរដូវ មួយហ្មឺនពីរពាន់រាត្រី ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គល រស់នៅអស់បីហ្មឺនប្រាំមួយពាន់រាត្រីហើយ រមែងបរិភោគបាយ ប្រាំពីរហ្មឺនពីរពាន់ដង គឺហេមន្តរដូវ ពីរហ្មឺនបួនពាន់ដង គិម្ហរដូវ ពីរហ្មឺនបួនពាន់ដង វស្សានរដូវ ពីរហ្មឺនបួនពាន់ដង រាប់ទាំងបៅទឹកដោះម្តាយ រាប់ទាំងខានបរិភោគបាយ ។ ក្នុងហេតុទាំងនោះ ការអត់បាយនេះគឺ បុគ្គលខឹង មិនបរិភោគបាយ បុគ្គលព្រួយ មិនបរិភោគបាយ បុគ្គលឈឺចាប់ មិនបរិភោគបាយ បុគ្គលរក្សាឧបោសថ មិនបរិភោគបាយ

អលភកតោចបិ ភត្តំ ន កុញ្ជតិ ។ ឥតិ ខោ ភិក្ខវេ មយា វស្សសតាយុកស្ស មនុស្សស្ស អាយុបិ សង្ខាតោ អាយុប្បមាណម្បិ សង្ខាតំ ឧតូបិ សង្ខាតា សំវច្ឆរាបិ សង្ខាតា មាសាបិ សង្ខាតា អឌ្ឍមាសាបិ សង្ខាតា រត្តិបិ សង្ខាតា ទិវាបិ សង្ខាតា ភត្តាបិ សង្ខាតា ភត្តន្តរាយាបិ សង្ខាតា ។ យំ ភិក្ខវេ សត្ថារា ករណីយំ សាវកានំ ហិតេសិនា អនុកម្បកេន អនុកម្បំ ឧបាទាយ កតំ វោ តំ មយា ។ ឯតានិ ភិក្ខវេ រុក្ខមូលានិ ឯតានិ សុញ្ញាគារានិ ឈាយថ ភិក្ខវេ មា បមាទត្ថ មា បច្ឆា វិប្បដិសារិនោ អហុវត្ថ ។ អយំ វោ អម្ហាកំ អនុសាសនីតិ ។

មហាវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

ហិរិសុរិយំ(១) នាគរំ(២) ឧបមា ធម្មញ្ញូ បារិច្ឆត្តកំ

---

១ ឱ. ម. ហិរិ សុរិយំ ។ អយំ បុគ្គលោ ។ ២ ម. នាគន្តិ ន ទិស្សតិ ។

បណ្ណាសកាសង្គហិត មហាវគ្គ

បុគ្គលមិនបរិភោគបាយ ព្រោះរកអ្វីមិនបាន ៗ ម្នាលភិក្ខុទាំងឡាយ អាយុរបស់មនុស្ស ដែលមានអាយុមួយរយឆ្នាំ តថាគតបានរាប់ហើយ ប្រមាណនៃអាយុ តថាគតបានរាប់ហើយ រដូវទាំងឡាយ តថាគតបានរាប់ហើយ ឆ្នាំទាំងឡាយ តថាគតបានរាប់ហើយ ខែទាំងឡាយ តថាគតបានរាប់ហើយ កន្លះខែទាំងឡាយ តថាគតបានរាប់ហើយ រាត្រីទាំងឡាយ តថាគតបានរាប់ហើយ ថ្ងៃទាំងឡាយ តថាគតបានរាប់ហើយ បាយទាំងឡាយ តថាគតបានរាប់ហើយ ការអត់បាយទាំងឡាយ តថាគតបានរាប់ហើយដូច្នេះឯង ៗ ម្នាលភិក្ខុទាំងឡាយ កិច្ចណា ដែលសាស្តា ជាអ្នកស្វែងរកប្រយោជន៍ ទំនុកបំរុង ជាអ្នកឈឺឆ្អាល អាស្រ័យនូវសេចក្តីឈឺឆ្អាល គួរធ្វើដល់ពួកសាវ័ក កិច្ចនោះ តថាគតបានធ្វើហើយដល់អ្នកទាំងឡាយ ៗ ម្នាលភិក្ខុទាំងឡាយ នុះជាគល់ឈើទាំងឡាយ នុះជាផ្ទះស្ងាត់ទាំងឡាយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរបំពេញឈាន កុំប្រមាទ កុំមានសេចក្តីក្តៅក្រហាយ ក្នុងកាលជាខាងក្រោយឡើយ ៗ នេះជាពាក្យប្រៀនប្រដៅរបស់តថាគត បំពោះអ្នកទាំងឡាយ ៗ

ចប់ មហាវគ្គទី ២ ។

## ឧទ្ទានក្នុងមហាវគ្គនោះគឺ

និយាយពីហិរិ (ឧត្តប្បៈ) ១ ព្រះអាទិត្យ ១ ប្រៀបដូច

ជានគរ ១អ្នកដឹងនូវធម៌ ១ ដើមបារិច្ឆត្តកព្រឹក្ស ១

សក្កច្ចំ(១) ការំ អត្ថិ សុនេត្តអរកានុសាសនីតិ(២) ។

---

១ ឱ. សក្កញា ។ ម. សក្កតំ ។ ២ ឱ. ម. សុនេត្តអរកេនបាតិ ។

ធ្វើសក្ការៈគោរព ១ ការទា ១ គំនរក្ងើង ១ ពាក្យ ប្រៀនប្រដៅរបស់គ្រូសុនេត្តៈ ១ របស់គ្រូអរកៈ ១ ។

# វិនយវគ្គោ

[៧២] សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ វិនយធរោ ហោតិ ។ កតមេហិ សត្តហិ ។ អាបត្តឹ ជានាតិ អនាបត្តឹ ជានាតិ លហុកំ អាបត្តឹ ជានាតិ គរុកំ អាបត្តឹ ជានាតិ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ ធម្មេហិ សមន្នាគតោ ភិក្ខុ វិនយធរោ ហោតីតិ ។

[៧៣] សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ វិនយធរោ ហោតិ ។ កតមេហិ សត្តហិ ។ អាបត្តឹ ជានាតិ អនាបត្តឹ ជានាតិ លហុកំ អាបត្តឹ ជានាតិ គរុកំ អាបត្តឹ ជានាតិ ឧភយានិ ខោ បនស្ស បាតិមោក្ខានិ វិត្ថារេន ស្វាគតានិ ហោន្តិ

# វិនយវគ្គ

[៧២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង ឈ្មោះជាវិនយធរ (អ្នកទ្រទ្រង់វិន័យ) ។ ប្រកបដោយធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយបន្តិចបន្តួច សមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ជាអ្នកបានតាមប្រាថ្នា បានដោយងាយ បានដោយស្រួល នូវឈានទាំង ៤ ដែលប្រព្រឹត្តទៅក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ១ ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៧ យ៉ាងនេះ ឈ្មោះជា វិនយធរ ។

[៧៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង ឈ្មោះជាវិនយធរ ។ ប្រកបដោយធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ បាតិមោក្ខទាំងពីរ ភិក្ខុនោះ ចេះចាំដោយត្រឹមត្រូវល្អ យ៉ាងពិស្តារ

សុវិភត្តានិ សុប្បវត្តីនិ សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ ធម្មេហិ សមន្នាគតោ ភិក្ខុ វិនយធរោ ហោតីតិ ។

[៧៤] សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ វិនយធរោ ហោតិ ។ កតមេហិ សត្តហិ ។ អាបត្តិំ ជានាតិ អនាបត្តិំ ជានាតិ លហុកំ អាបត្តិំ ជានាតិ គរុកំ អាបត្តិំ ជានាតិ វិនយេ ខោ បន ឋិតោ ហោតិ អសំហីរោ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ ធម្មេហិ សមន្នាគតោ ភិក្ខុ វិនយធរោ ហោតីតិ ។

បានចែករំលែកដោយល្អ បានឲ្យប្រព្រឹត្តទៅដោយប្រពៃ បានវិនិច្ឆ័យដោយត្រឹមត្រូវ តាមសុត្តៈ តាមរបៀបនៃព្យញ្ជនៈ ១ ជាអ្នកបានតាមប្រាថ្នា បានដោយងាយ បានដោយស្រួលនូវឈានទាំង ៤ ដែលកើតក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ១ ធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៧ យ៉ាងនេះ ឈ្មោះថា វិនយធរ ។

( ៧៤ ) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង ឈ្មោះថា វិនយធរ ។ ប្រកបដោយធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ ជាអ្នកខ្ជាប់ខ្ជួន មិនយេងយោង ក្នុងវិន័យ ១ ជាអ្នកបានតាមប្រាថ្នា បានដោយងាយ បានដោយស្រួលនូវឈានទាំង ៤ ដែលកើតក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ១ ធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាងនេះ ឈ្មោះថា វិនយធរ ។

(៧៥) សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ វិនយធរោ ហោតិ ។ កតមេហិ សត្តហិ ។ អាបត្តឹ ជានាតិ អនាបត្តឹ ជានាតិ លហុកំ អាបត្តឹ ជានាតិ គរុកំ អាបត្តឹ ជានាតិ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។ បេ ។ យថាកម្មូបគេ សត្តេ បជានាតិ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ ធម្មេហិ សមន្នាគតោ ភិក្ខុ វិនយធរោ ហោតីតិ ។

(៧៦) សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ វិនយធរោ សោភតិ ។ កតមេហិ សត្តហិ ។ អាបត្តឹ ជានាតិ អនាបត្តឹ ជានាតិ លហុកំ អាបត្តឹ ជានាតិ គរុកំ អាបត្តឹ ជានាតិ សីលវា ហោតិ ។ បេ ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ

(៧៥) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង ឈ្មោះថា វិនយធរ ។ ប្រកបដោយធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺ ស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុ-កាបត្តិ ១ រលឹកឃើញនូវបុព្វេនិវាសៈ ជាច្រើនប្រការគឺ ១ ជាតិ ២ ជាតិ ។ បេ ។ រលឹកឃើញនូវបុព្វេនិវាសៈ ជាច្រើនប្រការព្រមទាំងអាការៈ និងឧទ្ទេស ១ មានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងផុតចក្ខុ ជារបស់មនុស្សធម្មតា ។ បេ ។ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្ម ១ ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៧ យ៉ាងនេះ ឈ្មោះថា វិនយធរ ។

(៧៦) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាវិនយធរ ប្រកបដោយធម៌ ៧ យ៉ាង ទើបរុងរឿង ។ ប្រកបដោយធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ ជាអ្នកមានសីល ។ បេ ។ សមាទាន សិក្សា ក្នុងសិក្ខាបទទាំងឡាយ ១

ចតុន្នំ ឈានានំ ។ បេ ។ អកសិរលាភី អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ ធម្មេហិ សមន្នាគតោ ភិក្ខុ វិនយធរោ សោភតីតិ ។

(៧៧) សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ វិនយធរោ សោភតិ ។ កតមេហិ សត្តហិ ។ អាបត្តិំ ជានាតិ អនាបត្តិំ ជានាតិ លហុកំ អាបត្តិំ ជានាតិ គរុកំ អាបត្តិំ ជានាតិ ឧភយានិ ខោ បនស្ស បាតិមោក្ខានិ វិត្ថារេន ស្វាគតានិ ហោន្តិ សុវិភត្តានិ សុប្បវត្តីនិ សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ ចតុន្នំ ឈានានំ ។ បេ ។ អកសិរលាភី អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ ធម្មេហិ សមន្នាគតោ វិនយធរោ សោភតីតិ ។

(៧៨) សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ វិនយធរោ សោភតិ ។ កតមេហិ សត្តហិ ។ អាបត្តិំ ជានាតិ អនាបត្តិំ ជានាតិ លហុកំ អាបត្តិំ ជានាតិ

ជាអ្នកបានដោយស្រួលនូវឈានទាំង ៤ ។ បេ ។ ១ ធ្វើឲ្យជាក់ច្បាស់សម្រេច ។បេ។ ព្រោះអស់អាសវៈទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាវិនយធរ ប្រកបដោយធម៌ទាំង ៧ យ៉ាងនេះ ទើបរុងរឿង ។

(៧៧) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាវិនយធរ ប្រកបដោយធម៌ ៧ យ៉ាង ទើបរុងរឿង ។ ប្រកបដោយធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ ទាំងបាតិមោក្ខទាំងពីរ ភិក្ខុនោះ ចេះចាំដោយត្រឹមត្រូវល្អ យ៉ាងពិស្តារ បានចែករលែកដោយល្អ ឲ្យប្រព្រឹត្តទៅដោយប្រពៃ បានវិនិច្ឆ័យដោយត្រឹមត្រូវ តាមសូត្រ តាមរបៀបនៃព្យញ្ជនៈ ១ ជាអ្នកបានដោយស្រួលនូវឈានទាំង ៤ ។ បេ ។ ១ ធ្វើឲ្យជាក់ច្បាស់សម្រេច ។ បេ ។ ព្រោះអស់អាសវៈទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាវិនយធរ ប្រកបដោយធម៌ទាំង ៧ យ៉ាងនេះ ទើបរុងរឿងបាន ។

(៧៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាវិនយធរ ប្រកបដោយធម៌ ៧ យ៉ាង ទើបរុងរឿង ។ ប្រកបដោយធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺ ស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១

គរុកំ អាបត្តឹ ជានាតិ វិនយេ ខោ បន ឋិតោ ហោតិ អសំហីរោ ចតុន្នំ ឈានានំ ។ បេ ។ អកសិរលាភី អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ ធម្មេហិ សមន្នាគតោ វិនយធរោ សោភតីតិ ។

(៧៩) សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ វិនយធរោ សោភតិ ។ កតមេហិ សត្តហិ ។ អាបត្តឹ ជានាតិ អនាបត្តឹ ជានាតិ លហុកំ អាបត្តឹ ជានាតិ គរុកំ អាបត្តឹ ជានាតិ អនេកវិហិតំ បុព្វេ-និវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេក-វិហិតំ បុព្វេនិវាសំ អនុស្សរតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។ បេ ។ យថាកម្មូបគេ សត្តេ បជានាតិ អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ ធម្មេហិ សមន្នាគតោ វិនយធរោ សោភតីតិ ។

(៨០) អថ ខោ អាយស្មា ឧបាលិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា

ស្គាល់គរុកាបត្តិ ១ ជាអ្នកខ្ជាប់ខ្ជួន មិនឃ្លេងឃ្លោង ក្នុងវិន័យ ១ ជាអ្នកបានដោយស្រួលនូវឈានទាំង ៤ ។ បេ ។ ១ ធ្វើឲ្យជាក់ច្បាស់ សម្រេច ។ បេ ។ ព្រោះអស់អាសវៈទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាវិនយធរ ប្រកបដោយធម៌ទាំង ៧ យ៉ាងនេះ ទើបរុងរឿង ។

(៧៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាវិនយធរ ប្រកបដោយធម៌ ៧ យ៉ាង ទើបរុងរឿង ។ ប្រកបដោយធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ រលឹកឃើញនូវបុព្វេនិវាសៈ ជាច្រើនប្រការ គឺ ១ ជាតិ ២ ជាតិ ។បេ។ រលឹកឃើញនូវបុព្វេនិវាសៈ ជាច្រើនប្រការ ព្រមទាំងអាការៈទាំងឧទ្ទេស ១ មានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងផុតចក្ខុ ជារបស់មនុស្សធម្មតា ។ បេ ។ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្ម ១ ធ្វើឲ្យជាក់ច្បាស់ សម្រេច ។ បេ ។ ព្រោះអស់អាសវៈទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាវិនយធរ ប្រកបដោយធម៌ទាំង ៧ យ៉ាងនេះ ទើបរុងរឿង ។

(៨០) គ្រានោះឯង ព្រះឧបាលិដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ

ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ឧទាយិ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។ យេ ខោ ត្វំ ឧទាយិ ធម្មេ ជានេយ្យាសិ ឥមេ ធម្មា ន ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តីតិ ឯកំសេន ឧទាយិ ធារេយ្យាសិ នេសោ ធម្មោ នេសោ វិនយោ នេតំ សត្ថុសាសនន្តិ ។ យេ ច ខោ ត្វំ ឧទាយិ ធម្មេ ជានេយ្យាសិ ឥមេ ធម្មា ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តីតិ ឯកំសេន ឧទាយិ ធារេយ្យាសិ ឯសោ ធម្មោ ឯសោ វិនយោ ឯតំ សត្ថុសាសនន្តិ ។

រួបអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះឧបាលិដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ សំដែង ធម៌ដល់ខ្ញុំព្រះអង្គដោយសេចក្ដីសង្ខេបឲ្យបាន ខ្ញុំព្រះអង្គបានស្ដាប់ធម៌ របស់ព្រះដ៏មានព្រះភាគហើយ នៅតែម្នាក់ឯង ចៀសចេញចាកពួកគណៈ ជាអ្នកមិនប្រមាទ មានព្យាយាមដុតកំដៅកិលេស បញ្ជូនចិត្តទៅកាន់ព្រះនិព្វាន ។ ម្នាលឧបាលិ អ្នកគប្បីដឹងនូវពួកធម៌ណាថា ធម៌ទាំងនេះមិននាំឲ្យនឿយណាយដោយដាច់ខាត មិននាំឲ្យរសាយចិត្ត មិននាំឲ្យរលត់ មិននាំឲ្យស្ងប់ មិននាំឲ្យបានអភិញ្ញា មិននាំឲ្យបានត្រាស់ដឹង មិននាំឲ្យបានព្រះនិព្វាន ម្នាលឧបាលិ អ្នកគប្បីចាំទុក ដោយដាច់ខាតថា នេះមិនមែនជាធម៌ នេះមិនមែនជាវិន័យ នេះមិនមែនជាពាក្យប្រដៅរបស់ព្រះសាស្ដាឡើយ ។ ម្នាលឧបាលិ អ្នកគប្បីដឹងនូវពួកធម៌ណាថា ធម៌ទាំងឡាយនេះ នាំឲ្យនឿយណាយ ដោយដាច់ខាត នាំឲ្យរសាយចិត្ត នាំឲ្យរលត់ នាំឲ្យស្ងប់ នាំឲ្យបានអភិញ្ញា នាំឲ្យបានត្រាស់ដឹង នាំឲ្យបានព្រះនិព្វាន ម្នាលឧបាលិ អ្នកគប្បីចាំទុក ដោយដាច់ខាតថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅ របស់ព្រះសាស្ដា ។

(៨១) សត្តិមេ ភិក្ខវេ អធិករណសមថា ធម្មា ឧប្បន្នុប្បន្នានំ អធិករណានំ សមថាយ វូបសមាយ។ កតមេ សត្ត ។ សម្មុខាវិនយោ ទាតព្វោ សតិវិនយោ ទាតព្វោ អមូឡ្ហវិនយោ ទាតព្វោ បដិញ្ញាតករណំ យេភុយ្យសិកា តស្សបាបិយសិកា តិណវត្ថារកោ ។ ឥមេ ខោ ភិក្ខវេ សត្ត អធិករណសមថា ធម្មា ឧប្បន្នុប្បន្នានំ អធិករណានំ សមថាយ វូបសមាយាតិ ។

វិនយវគ្គោ តតិយោ(១) ។

## តស្សុទ្ទានំ

ចតុរោ វិនយធរា ចតុរោ វិនយធរសោភនា ហោន្តិ សាសនំ អដ្ឋមវគ្គេ ទស បាឡិ អធិករណសមថេនាតិ ។

---

១ អដ្ឋមោតិ អដ្ឋកថាយំ ទិស្សតិ ។

(៨១) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៧ នេះ ឈ្មោះថា អធិករណ-សមថៈ សម្រាប់រម្ងាប់ សម្រាប់ផ្សះផ្សានូវអធិករណៈទាំងឡាយ ដែលកើតឡើងហើយ កើតឡើងហើយ ៗ ធម៌ទាំង ៧ យ៉ាង តើដូចម្ដេចខ្លះ ។ គឺសង្ឃត្រូវឲ្យសម្មុខាវិន័យ ១ ត្រូវឲ្យសតិវិន័យ ១ ត្រូវឲ្យអមូឡ្ហវិន័យ ១ ត្រូវវិនិច្ឆ័យកាត់ទោស តាមពាក្យប្ដេជ្ញារបស់អ្នកឆ្លើយ ១ ត្រូវវិនិច្ឆ័យ តាមភាគច្រើនជាប្រមាណ ១ ត្រូវកាត់ទោស តាមកម្មរបស់ភិក្ខុ ដែលប្រព្រឹត្តលាមក ១ ត្រូវវិនិច្ឆ័យឲ្យពួកភិក្ខុ ដែលវិវាទទាស់ទែងគ្នា សម្រួបសម្រួម អត់ទុនគ្នាទៅវិញទៅមក ដូចគេគ្របមូត្រលាមកដោយស្មៅ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៧ យ៉ាងនេះ ឈ្មោះថាអធិករណសមថៈ សម្រាប់រម្ងាប់ សម្រាប់ផ្សះផ្សានូវអធិករណៈទាំងឡាយ ដែលកើតឡើងហើយ កើតឡើងហើយ ៗ

ចប់ វិនយវគ្គទី ៣ ។

## ឧទ្ទាននៃវិនយវគ្គនោះគឺ

បាលី ១០ លើក មានក្នុងអដ្ឋមវគ្គ គឺនិយាយអំពីភិក្ខុ ជាវិនយធរបួនពួក ១ ភិក្ខុជាវិនយធរ ដែលរុងរឿងបួនពួក ១ ពាក្យប្រដៅ ១ អធិករណសមថៈ ១ ៗ

(៨២) សត្តន្នំ ភិក្ខវេ ធម្មានំ ភិន្នត្តា ភិក្ខុ ហោតិ ។ កតមេសំ សត្តន្នំ ។ សក្កាយទិដ្ឋិ ភិន្នា ហោតិ វិចិកិច្ឆា ភិន្នា ហោតិ សីលព្វតបរាមាសោ ភិន្នោ ហោតិ រាគោ ភិន្នោ ហោតិ ទោសោ ភិន្នោ ហោតិ មោហោ ភិន្នោ ហោតិ មានោ ភិន្នោ ហោតិ ។ ឥមេសំ ខោ ភិក្ខវេ សត្តន្នំ ធម្មានំ ភិន្នត្តា ភិក្ខុ ហោតីតិ ។

(៨៣) សត្តន្នំ ភិក្ខវេ ធម្មានំ សមិតត្តា សមណោ ហោតិ ។ បេ ។ ពាហិតត្តា ព្រាហ្មណោ ហោតិ ។ បេ ។ និស្សុតត្តា សោត្តិយោ ហោតិ ។ បេ ។ ន្ហាតត្តា(១) ន្ហាតកោ ហោតិ ។ បេ ។ វិទិតត្តា វេទគូ ហោតិ ។ បេ ។ អារកត្តា អរហា ហោតិ(២) ។ កតមេសំ សត្តន្នំ ។ សក្កាយទិដ្ឋិ អារកា ហោតិ វិចិកិច្ឆា អារកា ហោតិ សីលព្វតបរាមាសោ អារកា ហោតិ រាគោ អារកា ហោតិ ទោសោ អារកា ហោតិ

---

១ ម. និយុត្តា សោត្តិយោ ហោតិ ។ ល ។ ន្ហាតត្តា ។ ឱ. ន្ហាតហោតត្តា ។ ២ ឱ.ម. អរីហតត្តា អរីយោ ហោតិ ។ បេ ។ អារកត្តា អរហោ ហោតិ ។

(៨២) ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលហៅថា ភិក្ខុ ព្រោះបានទម្លាយនូវធម៌ ៧ យ៉ាង ។ ធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកបានទម្លាយសក្កាយទិដ្ឋិ ១ ទម្លាយវិចិកិច្ឆា ១ ទម្លាយសីលព្វតបរាមាសៈ ១ ។ ទម្លាយរាគៈ ១ ទម្លាយទោសៈ ១ ទម្លាយមោហៈ ១ ទម្លាយមានះ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលហៅថា ភិក្ខុ ព្រោះបានទម្លាយនូវធម៌ទាំង ៧ យ៉ាងនេះ ។

(៨៣) ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលហៅថា សមណៈ ព្រោះបានរម្ងាប់ធម៌ ៧ យ៉ាង ។ បេ ។ បុគ្គលដែលហៅថា ព្រាហ្មណ៍ ព្រោះបានបន្សាត់ ។ បេ ។ បុគ្គលដែលហៅថា សោត្ថិកៈ ព្រោះជាអ្នកច្រាសចាក ។ បេ ។ បុគ្គលដែលហៅថា នហាតកៈ ព្រោះជាអ្នកលាងជំរះ ។ បេ ។ បុគ្គលដែលហៅថា វេទគូ ព្រោះជាអ្នកត្រាស់ដឹង ។ បេ ។ បុគ្គលដែលហៅថា អរហន្ត ព្រោះជាអ្នកឆ្ងាយ ។ ធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺឆ្ងាយចាកសក្កាយទិដ្ឋិ ១ ឆ្ងាយចាកវិចិកិច្ឆា ១ ឆ្ងាយចាកសីលព្វតបរាមាសៈ ១ ឆ្ងាយចាករាគៈ ១ ឆ្ងាយចាកទោសៈ ១

មោហោ អាហារោ ហោតិ មានោ អាហារោ ហោតិ ។ ឥមេសំ ខោ ភិក្ខវេ សត្តន្នំ ធម្មានំ អាហារត្តា អាហោ ហោតីតិ ។

(៨៤) សត្តិមេ ភិក្ខវេ អសទ្ធម្មា ។ កតមេ សត្ត ។ អស្សទ្ធោ ហោតិ អហិរិកោ ហោតិ អនោត្តប្បី ហោតិ អប្បស្សុតោ ហោតិ កុសីតោ ហោតិ មុដ្ឋស្សតិ ហោតិ ទុប្បញ្ញោ ហោតិ ។ ឥមេ ខោ ភិក្ខវេ សត្ត អសទ្ធម្មាតិ ។ សត្តិមេ ភិក្ខវេ សទ្ធម្មា ។ កតមេ សត្ត ។ សទ្ធោ ហោតិ ហិរិមា ហោតិ ឱត្តប្បី ហោតិ ពហុស្សុតោ ហោតិ អារទ្ធវីរិយោ ហោតិ សតិមា ហោតិ បញ្ញវា ហោតិ ។ ឥមេ ខោ ភិក្ខវេ សត្ត សទ្ធម្មាតិ[១] ។

(៨៥) សត្តិមេ ភិក្ខវេ បុគ្គលា អាហុនេយ្យា បាហុនេយ្យា ទក្ខិណេយ្យា អញ្ជលិករណីយា អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេ សត្ត ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ

---

១ ម. ឥតោ បរំ តស្សុទ្ទានំ ភិន្នា សមណព្រាហ្មណា ច សោតិយន្នាតកោ វេទគារិយោ អរហាសទ្ធម្មសទ្ធម្មេនោ ទេសិតា តេ តថាគតាតិ ។

ឆ្ងាយចាកមោហៈ ១ ឆ្ងាយចាកមានះ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលហៅថា អរហន្ត ព្រោះជាអ្នកឆ្ងាយចាកធម៌ទាំង ៧ យ៉ាងនេះឯង ។

( ៨៤ ) ម្នាលភិក្ខុទាំងឡាយ អសទ្ធម្មនេះ មាន ៧ យ៉ាង ។ អសទ្ធម្ម ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលមិនមានសទ្ធា ១ មិនមានហិរិ ១ មិនមានឱត្តប្បៈ ១ ជាអ្នកចេះដឹងតិច ១ ខ្ជិលច្រអូស ១ ភ្លេចភ្លាំងស្មារតី ១ ឥតប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ អសទ្ធម្មមាន ៧ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សទ្ធម្មនេះមាន ៧ យ៉ាង ។ សទ្ធម្ម ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលមានសទ្ធា ១ មានហិរិ ១ មានឱត្តប្បៈ ១ អ្នកចេះដឹងច្រើន ១ ជាអ្នកផ្គងព្យាយាម ១ មានស្មារតី ១ មានប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ សទ្ធម្មមាន ៧ យ៉ាងនេះឯង ។

( ៨៥ ) ម្នាលភិក្ខុទាំងឡាយ បុគ្គល ៧ ពួកនេះ ជាអ្នកគួរទទួលនូវវត្ថុ ដែលគេនាំមកបូជា គួរទទួលនូវវត្ថុ ដែលគេរៀបចំទទួលភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរគេប្រណម្យអញ្ជលី ជាស្រែបុណ្យដ៏ប្រសើរ របស់សត្វលោក ។ បុគ្គល ៧ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ

ចក្ខុស្មឹ អនិច្ចានុបស្សី វិហរតិ អនិច្ចសញ្ញី អនិច្ចប្បដិសំវេទី សតតំ សមិតំ អព្វោកិណ្ណំ ចេតសា អធិមុច្ចមានោ បញ្ញាយ បរិយោគាហមានោ ។ សោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អយំ ភិក្ខវេ បឋមោ បុគ្គលោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។

បុន ចបរំ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ ចក្ខុស្មឹ អនិច្ចានុបស្សី វិហរតិ អនិច្ចសញ្ញី អនិច្ចប្បដិសំវេទី សតតំ សមិតំ អព្វោកិណ្ណំ ចេតសា អធិមុច្ចមានោ បញ្ញាយ បរិយោគាហមានោ ។ តស្ស អបុព្វំ អចរិមំ អាសវបរិយាទានញ្ច ហោតិ ជីវិតបរិយាទានញ្ច ។ អយំ ភិក្ខវេ ទុតិយោ បុគ្គលោ អាហុនេយ្យោ... អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។

បុន ចបរំ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ ចក្ខុស្មឹ អនិច្ចានុបស្សី វិហរតិ អនិច្ចសញ្ញី អនិច្ចប្បដិសំវេទី សតតំ សមិតំ អព្វោកិណ្ណំ ចេតសា អធិមុច្ចមានោ បញ្ញាយ បរិយោគាហមានោ ។

ជាអ្នកឃើញរឿយៗថា មិនទៀង មានសេចក្ដីសំគាល់ថា មិនទៀង ដឹងច្បាស់ថា មិនទៀង មានចិត្តចុះស៊ប់ ស្កប់ ដោយប្រាជ្ញាជាប់រឿយ ៗ មិនប្រែឡូកប្រែឡំក្នុងចិត្ត ។ បុគ្គលនោះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ នេះជាបុគ្គលទី ១ ដែលគួរទទួលនូវវត្ថុ ដែលគេនាំមកបូជា គួរទទួលនូវវត្ថុ ដែលគេរៀបចំទទួលភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរគេប្រណម្យអញ្ជលី ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកឃើញរឿយៗថា មិនទៀង មានសេចក្ដីសំគាល់ថា មិនទៀង ដឹងច្បាស់ថា មិនទៀង មានចិត្តចុះស៊ប់ ស្កប់ ដោយប្រាជ្ញាជាប់រឿយ ៗ មិនប្រែឡូកប្រែឡំក្នុងចិត្ត ។ បុគ្គលនោះ អស់ទាំងអាសវៈ របស់ទាំងជីវិតដំណាល ៗ គ្នា ។ ម្នាលភិក្ខុទាំងឡាយ នេះជាបុគ្គលទី ២ ដែលគួរទទួលនូវវត្ថុ ដែលគេនាំមកបូជា... ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកឃើញរឿយៗថា មិនទៀង មានសេចក្ដីសំគាល់ថា មិនទៀង ដឹងច្បាស់ថា មិនទៀង មានចិត្តចុះស៊ប់ ស្កប់ ដោយប្រាជ្ញាជាប់រឿយ ៗ មិនប្រែឡូកប្រែឡំក្នុងចិត្ត ។

## វគ្គសង្គហិតា សុត្តា

សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អន្តរាបរិនិព្វាយី ហោតិ ។ បេ ។ ឧបហច្ចបរិនិព្វាយី ហោតិ ។ បេ ។ អសង្ខារបរិនិព្វាយី ហោតិ ។ បេ ។ សសង្ខារបរិនិព្វាយី ហោតិ ។ បេ ។ ឧទ្ធំសោតោ ហោតិ អកនិដ្ឋគាមី ។ អយំ ភិក្ខវេ សត្តមោ បុគ្គលោ អាហុនេយ្យោ ... អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ ឥមេ ខោ ភិក្ខវេ សត្ត បុគ្គលា អាហុនេយ្យា បាហុនេយ្យា ទក្ខិណេយ្យា អញ្ជលិករណីយា អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

(៨៦) សត្តិមេ ភិក្ខវេ បុគ្គលា អាហុនេយ្យា ... អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេ សត្ត ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ចក្ខុស្មឹ ទុក្ខានុបស្សី វិហរតិ... ចក្ខុស្មឹ អនត្តានុបស្សី វិហរតិ ចក្ខុស្មឹ ខយានុបស្សី វិហរតិ ចក្ខុស្មឹ វយានុបស្សី វិហរតិ ចក្ខុស្មឹ វិរាគានុបស្សី វិហរតិ ចក្ខុស្មឹ និរោធានុបស្សី វិហរតិ ចក្ខុស្មឹ បដិនិស្សគ្គានុបស្សី វិហរតិ

បុគ្គលនោះ បានឈ្មោះថា អន្តរាបរិនិព្វាយី ព្រោះអស់សំយោជនៈ ៥ ដែលជាចំណែកខាងក្រោមហើយ ។បេ។ បានឈ្មោះថា ឧបហច្ចបរិនិព្វាយី ។បេ។ បានឈ្មោះថា អសង្ខារបរិនិព្វាយី ។បេ។ បានឈ្មោះថា សសង្ខារ-បរិនិព្វាយី ។បេ។ បានឈ្មោះថា ឧទ្ធំសោតអកនិដ្ឋគាមី ។ ម្នាលភិក្ខុទាំងឡាយ នេះជាបុគ្គលទី ៧ ដែលគួរទទួលនូវវត្ថុ ដែលគេនាំមកបូជា... ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៧ ពួកនេះ ជាអ្នកគួរទទួលនូវវត្ថុ ដែលគេនាំមកបូជា គួរទទួលនូវវត្ថុ ដែលគេរៀបចំទទួលភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរគេប្រណម្យអញ្ជលី ជាស្រែបុណ្យដ៏ប្រសើរ របស់សត្វលោក ។

[៨៦] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៧ ពួកនេះ គួរទទួលនូវវត្ថុ ដែលគេនាំមកបូជា . . . ជាស្រែបុណ្យដ៏ប្រសើរ របស់សត្វលោក ។ បុគ្គល ៧ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកឃើញរឿយ ៗ ក្នុងចក្ខុថាជាទុក្ខ . . . ១ ឃើញរឿយ ៗ ក្នុងចក្ខុថា មិនមែនជារបស់ខ្លួន ១ ឃើញរឿយ ៗ ក្នុងចក្ខុថា អស់ទៅ ១ ឃើញរឿយៗ ក្នុងចក្ខុថា សាបសូន្យទៅ ១ ឃើញរឿយៗ ក្នុងចក្ខុថា គួររសាយចិត្ត ១ ឃើញរឿយ ៗ ក្នុងចក្ខុថាជារបស់រលត់ ១ ឃើញរឿយៗ ក្នុងចក្ខុ ថាជារបស់គួរលះបង់ចេញ ១

សោតស្មឹ ឃានស្មឹ ជិវ្ហាយ កាយស្មឹ មនស្មឹ
រូបេសុ សទ្ទេសុ គន្ធេសុ រសេសុ ផោដ្ឋព្វេសុ ធម្មេសុ
ចក្ខុវិញ្ញាណេ សោតវិញ្ញាណេ ឃានវិញ្ញាណេ
ជិវ្ហាវិញ្ញាណេ កាយវិញ្ញាណេ មនោវិញ្ញាណេ
ចក្ខុសម្ផស្សេ សោតសម្ផស្សេ ឃានសម្ផស្សេ
ជិវ្ហាសម្ផស្សេ កាយសម្ផស្សេ មនោសម្ផស្សេ
ចក្ខុសម្ផស្សជាយ វេទនាយ សោតសម្ផស្សជាយ
វេទនាយ ឃានសម្ផស្សជាយ វេទនាយ ជិវ្ហាសម្ផស្ស-
ជាយ វេទនាយ កាយសម្ផស្សជាយ វេទនាយ មនោ-
សម្ផស្សជាយ វេទនាយ រូបសញ្ញាយ សទ្ទសញ្ញាយ
គន្ធសញ្ញាយ រសសញ្ញាយ ផោដ្ឋព្វសញ្ញាយ ធម្ម-
សញ្ញាយ រូបសញ្ចេតនាយ សទ្ទសញ្ចេតនាយ គន្ធ-
សញ្ចេតនាយ រសសញ្ចេតនាយ ផោដ្ឋព្វសញ្ចេតនាយ
ធម្មសញ្ចេតនាយ រូបតណ្ហាយ សទ្ទតណ្ហាយ គន្ធ-
តណ្ហាយ រសតណ្ហាយ ផោដ្ឋព្វតណ្ហាយ ធម្មតណ្ហាយ
រូបវិតក្កេ សទ្ទវិតក្កេ គន្ធវិតក្កេ រសវិតក្កេ ផោដ្ឋព្វវិតក្កេ
ធម្មវិតក្កេ រូបវិចារេ សទ្ទវិចារេ គន្ធវិចារេ រសវិចារេ
ផោដ្ឋព្វវិចារេ ធម្មវិចារេ រូបក្ខន្ធេ វេទនាក្ខន្ធេ

ក្នុងសោតៈ ឃានៈ ជិវ្ហា កាយ មនៈ ក្នុងរូបទាំងឡាយ សម្លេងទាំងឡាយ ក្លិនទាំងឡាយ រសទាំងឡាយ ផោដ្ឋព្វៈទាំងឡាយ ធម្មារម្មណ៍ទាំងឡាយ ក្នុងចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ ក្នុងចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស ក្នុងវេទនាដែលកើតអំពីចក្ខុសម្ផស្ស វេទនាដែលកើតអំពីសោតសម្ផស្ស វេទនាដែលកើតអំពីឃានសម្ផស្ស វេទនាដែលកើតអំពីជិវ្ហាសម្ផស្ស វេទនាដែលកើតអំពីកាយសម្ផស្ស វេទនាដែលកើតអំពីមនោសម្ផស្ស ក្នុងរូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ធម្មសញ្ញា ក្នុងរូបសញ្ចេតនា សទ្ទសញ្ចេតនា គន្ធសញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា ធម្មសញ្ចេតនា ក្នុងរូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ក្នុងរូបវិតក្កៈ សទ្ទវិតក្កៈ គន្ធវិតក្កៈ រសវិតក្កៈ ផោដ្ឋព្វវិតក្កៈ ធម្មវិតក្កៈ ក្នុងរូបវិចារៈ សទ្ទវិចារៈ គន្ធវិចារៈ រសវិចារៈ ផោដ្ឋព្វវិចារៈ ធម្មវិចារៈ ក្នុងរូបក្ខន្ធ វេទនាខន្ធ

សញ្ញាខន្ធេ សង្ខារក្ខន្ធេ វិញ្ញាណក្ខន្ធេ អនិច្ចានុបស្សី វិហរតិ ទុក្ខានុបស្សី វិហរតិ អនត្តានុបស្សី វិហរតិ ខយានុបស្សី វិហរតិ វយានុបស្សី វិហរតិ វិរាគានុបស្សី វិហរតិ និរោធានុបស្សី វិហរតិ បដិនិស្សគ្គានុបស្សី វិហរតិ ។

[៨៧] រាគស្ស ភិក្ខវេ អភិញ្ញាយ សត្ត ធម្មា ភាវេតព្វា ។ កតមេ សត្ត ។ សតិសម្ពោជ្ឈង្គោ ។ បេ។ ឧបេក្ខាសម្ពោជ្ឈង្គោ ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ សត្ត ធម្មា ភាវេតព្វាតិ ។

[៨៨] រាគស្ស ភិក្ខវេ អភិញ្ញាយ សត្ត ធម្មា ភាវេតព្វា ។ កតមេ សត្ត ។ អនិច្ចសញ្ញា អនត្តសញ្ញា អសុភសញ្ញា អាទីនវសញ្ញា បហានសញ្ញា វិរាគសញ្ញា និរោធសញ្ញា ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ សត្ត ធម្មា ភាវេតព្វាតិ ។

[៨៩] រាគស្ស ភិក្ខវេ អភិញ្ញាយ សត្ត ធម្មា ភាវេតព្វា ។ កតមេ សត្ត ។ អសុភសញ្ញា មរណសញ្ញា អាហារេ បដិក្កូលសញ្ញា

សញ្ញាខន្ធ សង្ខារក្ខន្ធ ជាអ្នកឃើញរឿយ ៗ ក្នុងវិញ្ញាណក្ខន្ធថាជារបស់មិនទៀង ឃើញរឿយ ៗ ថាជាទុក្ខ ឃើញរឿយៗ ថា មិនមែនរបស់ខ្លួន ឃើញរឿយ ៗថា អស់ទៅ ឃើញរឿយៗថា សាបសូន្យទៅ ឃើញរឿយៗថា គួរសោយចិត្ត ឃើញរឿយៗថា រលត់ ឃើញរឿយ ៗ ថាជារបស់គួរលះបង់ចេញ ។

(៨៧) ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាង ដែលបុគ្គលត្រូវចំរើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺ សតិ-សម្ពោជ្ឈង្គ ១ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៧ យ៉ាងនេះ ដែលបុគ្គលត្រូវចំរើន ដើម្បីដឹងច្បាស់នូវរាគៈ ។

(៨៨) ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាង ដែលបុគ្គលត្រូវចំរើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺ អនិច្ចសញ្ញា ១ អនត្តសញ្ញា ១ អសុភសញ្ញា ១ អាទីនវសញ្ញា ១ បហានសញ្ញា ១ វិរាគសញ្ញា ១ និរោធសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះ ដែលបុគ្គលត្រូវចំរើន ដើម្បីដឹងច្បាស់នូវរាគៈ ។

(៨៩) ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាង ដែលបុគ្គលត្រូវចំរើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺ អសុភសញ្ញា ១ មរណសញ្ញា ១ អាហារេ បដិកូលសញ្ញា ១

សព្វលោកេ អនភិរតសញ្ញា អនិច្ចសញ្ញា អនិច្ចេ ទុក្ខសញ្ញា ទុក្ខេ អនត្តសញ្ញា ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ សត្ត ធម្មា ភាវេតព្វាតិ ។

(៩០) រាគស្ស ភិក្ខវេ បរិញ្ញាយ ។ បេ ។ បរិក្ខយាយ បហានាយ ខយាយ វយាយ វិរាគាយ និរោធាយ ចាគាយ បដិនិស្សគ្គាយ ឥមេ សត្ត ធម្មា ភាវេតព្វា ។ ទោសស្ស មោហស្ស កោធស្ស ឧបនាហស្ស មក្ខស្ស បឡាសស្ស ឥស្សាយ មច្ឆរិយស្ស មាយាយ សាឋេយ្យស្ស ថម្ភស្ស សារម្ភស្ស មានស្ស អតិមានស្ស មទស្ស បមាទស្ស អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ខយាយ វយាយ វិរាគាយ និរោធាយ ចាគាយ បដិនិស្សគ្គាយ ឥមេ សត្ត ធម្មា ភាវេតព្វាតិ(១) ។

សត្តកនិបាតោ និដ្ឋិតោ ។

---

១ ឥតោ បរំ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ឥមេ បាឋា ទិស្សន្តិ ។

សព្វលោកេ អនភិរតសញ្ញា ១ អនិច្ចសញ្ញា ១ អនិច្ចេ ទុក្ខសញ្ញា ១ ទុក្ខេ អនត្តសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៧ យ៉ាងនេះ ដែលបុគ្គលត្រូវចំរើន ដើម្បីដឹងច្បាស់នូវរាគៈ ។

[៩០] ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាង ដែលបុគ្គលត្រូវចំរើន ដើម្បីកំណត់ដឹង ។ បេ ។ ដើម្បីឲ្យអស់រលីង ដើម្បីលះ ដើម្បីឲ្យក្ស័យ ដើម្បីឲ្យសាបសូន្យ ដើម្បីរសាយ ដើម្បីរលត់ ដើម្បីឲ្យដាច់ ដើម្បីបោះបង់នូវរាគៈ ។ ធម៌ ៧ យ៉ាងនេះ ដែលបុគ្គលត្រូវចំរើន ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីឲ្យអស់រលីង ដើម្បីលះ ដើម្បីឲ្យក្ស័យ ដើម្បីឲ្យសាបសូន្យទៅ ដើម្បីរសាយ ដើម្បីរលត់ ដើម្បីឲ្យដាច់ ដើម្បីបោះបង់នូវទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ ។

ចប់ សត្តកនិបាត ។

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | រជ្ជុលេខាយំ |
|---|---|---|---|
| បរិក្ខយា | បរិក្ខយា | ១៩ | ៨ |
| ផលត្តិ | ផលន្តិ | ៨៣ | ៧ |
| តិព្វាភយសញ្ញា | តិព្វា ភយសញ្ញា | ៩៧ | ៨ |
| " | " " | " | ១៤ |
| " | " " | ៩៨ | ៥ |
| តត្រាតិរេត្ដា | តត្រាតិរេតោ | ១០៧ | ៦ |
| ចាមេយ្យកា | ចាម្បេយ្យកា | ១១០ | ១៦ |
| អតិក្កេត្វា | អតិក្កមេត្វា | ១១១ | ៥ |
| អានន្ទ្វា | អានន្ទា | ១១៤ | ១៧ |
| បបាមិ | បចាមិ | ១១៥ | ៦ |
| វិសិត្វា | វិសិត្វា | ១១៧ | ១៦ |
| អយោកបាមោ | អយោកបាលេ | ១៣១ | ១៣ |
| ហញ្ញលានេ | ហញ្ញមានេ | " | " |
| អាសជ្ជិ | អាសជ្ជំ | ១៣៦ | ១០ |
| ឥទមា បនំ | ឥទមាសនំ | ១៣៩ | ៦ |
| មច្ចុ | មច្ចូ | ១៤៩ | ១៨ |

| ខុស | ត្រូវ | ទំព័រ | បន្ទាត់លេខ |
|---|---|---|---|
| បំ | មំ | ១៥៣ | ១៤ |
| យផាកបំ | យថាកបំ | ១៧៩ | ៩ |
| ត្តាស | សត្តា | ១៨០ | ២ |
| ...វំបន្ទស្ស | ..វិបន្ទស្ស | ១៨២ | ១០ |
| អផ្គុ... | អគ្គុ... | ១៨៧ | ១៧ |
| សុ ត្តបិ កេ | សុត្តន្តបិដកេ | ១៨៨ | ១ |
| ឯកជាលា | ឯកជ្ឈាលា | ១៨៨ | ១៦ |
| សង៊ារ | សង្គារ | ១៨៩ | ១៧ |
| អភិសព្យាកយំ | អភិសម្យាកយំ | ១៩១ | ១៦ |
| ភកព | ភគព | ១៩៣ | ១៦ |
| ហាតិ | ហោតិ | ១៩៥ | ១៤ |
| បច្ចនិមេ | បច្ចន្តិមេ | ២០៤ | ២ |
| យាយំ | ញ្ញាយំ | ២១០ | ៧ |
| លោ ុកា មា | សោតុកាមោ | ២១០ | ៧ |
| ធដ្ឋំ | ធម្មំ | ២១០ | ១៣ |
| អនោគាកា | អនោគាគា | ២៣៩ | ៨ |

# សន្លឹកប្រាប់ពាក្យខុស ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ឆទាទីតិ | ឆទាទីតិ ៗ | ៧ | ៣ |
| ព្រាហណ្ម៍ | ព្រាហ្មណ៍ | ៧៩ | ១១ |
| វេស្សនករ | វេស្សនរក | ៨១ | ៩ |
| បន្អូទ់ | បន្អូន់ | ៨៥ | ៦ |
| តើព្រោះ អាស្រ័យ | តើព្រោះអាស្រ័យ | ៩៨ | ១៧ |
| ទុក្ខអ គ្គសញ្ញា | ទុក្ខ អនត្តសញ្ញា | ៩៩ | ១៥ |
| ជាណុសោភណិ | ជាណុសោភណី | ១០០ | ១៤ |
| " | " | ១០១ | ៦ |
| ខទ្ម | ខ្ទម | ១០៥ | ៣ |
| កិរយា | កិរិយា | ១០៦ | ១៦ |
| ហតុ | ហេតុ | " | ១៣ |
| កៅ | ក្រៅ | ១០៩ | ១១ |
| ហីយ | ហើយ | ១១១ | ១៣ |

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| អាត្មាអញមិនគួរ | មានជាការល្អ ចំណែកខ្លះ ឲ្យមានដោយគិតថា អាត្មាអញមិនគួរ | ១១៣ | ៦ |
| តាំងមិនឲ្យ | តាំងមិនឲ្យមាន | ១១៣ | ៧ |
| ឈ្មា: | ឈ្មោះ | ១១៥ | ៩ |
| មោគល្លាន | មោគ្គល្លាន | ១១៦ | ១០ |
| អកុសល | អកុសលធម៌ | ១២២ | ៩ |
| គម្រេកខ្លះ | រែកពយខ្លះ | ១៣៥ | ១១ |
| មហាមោគ្គល្លាន | មោគ្គល្លាន | ១៣៩ | ៧ |
| អធិបតេយ្យ | អាធិបតេយ្យ | ១៤០ | ៨ |
| កាយសុទ្ធិ | កាយសុទ្ធី | ១៤២ | ៣ |
| នា: | នោះ | " | ១២ |
| តាំងនោះ | តាំងនុ៎ះ | ១៥០ | ១៣ |
| នោះ | តាំងនុ៎ះ | ១៥១ | ១៦ |
| នុ៎ះ | តាំងនុ៎ះ | ១៥២ | ៣ |
| គឺមិត្ត | គឺមានៈ | ១៦១ | ៥ |

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| " | " | " | ៧ |
| មេត្តា | មេត្ត | ១៦៤ | ១៤ |
| វូជា | បូជា | ១៦៨ | ៧ |
| ទុកជាលាបស្រឡាបល្អ | ទុកជាដូតស្អាត លាបស្រឡាបល្អ | ១៧៣ | ៥ |
| ដូចជា | ដូចជាត្រូវ | ១៧៥ | ៥ |
| ទមបញ្ញា | ទម:បញ្ញា | ១៨០ | ១៣ |
| ទាំងពួង | ទាំងពួង ៗ | ១៨៥ | ៨ |
| ឡើយ | ឡើយ ៗ | ១៨៧ | ១៦ |
| ក៏នៅមក | មិនបានមក | ១៩២ | ២ |
| ទុកដូចជា | មានសណ្ឋា ទុកជា | ១៩៩ | ៥ |
| អ ិយ | អរិយ | ២០២ | ២ |
| បិតិ | បីតិ | ២០៤ | ១៣ |
| + នុះ ៗ | នោះ ៗ | ២០៧ | ៤ |
| ព្រឹក | ព្រឹក្ស | ២១២ | ១៥ |

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ឈ្មាះថា | ឈ្មោះថា | ២២៣ | ១៣ |
| ដេល | ដែល | ២១៨ | ៩ |
| សន្ងំ | សម្ងំ | ២១៩ | ៩ |
| ឈ្មាះថា | ឈ្មោះថា | ២២៣ | ១៣ |
| [illegible] | [illegible] | ២៣០ | ១៧ |
| ឬ ដេក | ឬឱ្យដេក | ២៤១ | ១១ |
| ក្រាម | ក្រោម | ២៤២ | ១០ |
| ជ្រាកជ្រាក | ជ្រោកជ្រោក | ២៤៤ | ២ |
| សចក្ដី | សេចក្ដី | ,, | ១៥ |
| គួរ | គួរ | ,, | ១៧ |
| កាលបី | កាលបើ | ,, | ១៨ |
| ត ម្រក | តម្រេក | ២៤៥ | ១០ |
| ម្នាលព្រាហ្មណ៍ទាំងឡាយ | ម្នាលព្រាហ្មណ៍ | ២៤៨ | ៩ |
| សន្ទឹម | សន្ទើម | ,, | ១៣ |
| ថ្ងាស | ថ្ងោស | ,, | ១៦ |
| យាន | យ៉ាន | ២៦៧ | ៧ |

# សុត្តន្តបិដកេ

# អង្គុត្តរនិកាយស្ស សត្តកនិបាតោ

## អដ្ឋមោ ភាគោ

មាតិកា — អង្កេ

### បឋមបណ្ណាសកោ


បឋមបណ្ណាសកេ ធនវគ្គោ បឋមោ . . . . . . . . ១

អនុសយវគ្គោ ទុតិយោ . . . . . . ១៤

វជ្ជិវគ្គោ តតិយោ . . . . . . ២៧

ទេវតាវគ្គោ ចតុត្ថោ . . . . . . ៥២

មហាយញ្ញវគ្គោ បញ្ចមោ . . . . . . ៧៤


### បណ្ណាសកាសង្គហិតា វគ្គា


បណ្ណាសកាសង្គហិតវគ្គេសុ អព្យាកតវគ្គោ បឋមោ . . . . . . ១២៥

មហាវគ្គោ ទុតិយោ . . . . . ១៨២

វិនយវគ្គោ តតិយោ . . . . . ២៥៥

វគ្គសង្គហិតា សុត្តន្តា . . . . . . ២៦២

# សុត្តន្តបិដក
# អង្គុត្តរនិកាយ សត្តកនិបាត
## អដ្ឋមភាគ

**មាតិកា** **លេខទំព័រ**

## បឋមបណ្ណាសក


| | | | |
|---|---|---|---|
| បឋមបណ្ណាសក | ធនវគ្គ | ទី ១ | ១ |
| | អនុសយវគ្គ | ទី ២ | ១៤ |
| | វជ្ជិវគ្គ | ទី ៣ | ២៧ |
| | ទេវតាវគ្គ | ទី ៤ | ៥២ |
| | មហាយញ្ញវគ្គ | ទី ៥ | ៧៤ |


## បណ្ណាសកាសង្គហិតវគ្គ


| | | | |
|---|---|---|---|
| បណ្ណាសកាសង្គហិតវគ្គ | អព្យាកតវគ្គ | ទី ១ | ១២៥ |
| | មហាវគ្គ | ទី ២ | ១៨២ |
| | វិនយវគ្គ | ទី ៣ | ២៥៥ |
| | វគ្គាសង្គហិត សុត្តន្ត | | ២៦២ |

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE